ក្រសួងអប់រំ យុវជន និងកីឡា

អក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន



ឆ្នាំ២០២៦

អក្ខរកម្មឌីជីថល
ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន

នាយកដ្ឋានបរិវត្តកម្មឌីជីថល

ឆ្នាំ២០២៦

បុព្វកថា

នៅក្នុងបរិការណ៍នៃបដិវត្តឧស្សាហកម្ម ៤.០ ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ជាពិសេសការវិវត្តយ៉ាងហ៊ៃសនៃបញ្ញាសិប្បនិម្មិត បាននឹងកំពុងជះឥទ្ធិពលយ៉ាងខ្លាំងដល់ការរស់នៅ ការសិក្សា និងការធ្វើការងារ លើស្ទើរគ្រប់វិស័យ។ ទន្ទឹមនឹងកាលានុវត្តភាពដ៏សម្បូរបែបនេះ វាក៏នាំមកនូវការប្រឈម និងហានិភ័យស្មុគស្មាញជាច្រើនដូចជា កំណើននៃការរីកសាយភាយព័ត៌មានខុស ព័ត៌មានមិនពិត ការរំលោភលើឯកជនភាពផ្ទាល់ខ្លួន អសន្តិសុខសាយប័រ និងការរើសអើងតាមប្រព័ន្ធអនឡាញ ដែលអាចបង្កផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់សិស្សានុសិស្ស។ ផ្អែកលើហេតុផលទាំងនេះ ការបញ្ជ្រាបជំនាញផ្នែកអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ក្លាយជាតម្រូវការចាំបាច់បំផុតមួយ និងមិនអាចខ្វះបានក្នុងរបៀបវារៈនៃការកំណែទម្រង់ការអប់រំរបៀបឌីជីថលរបស់ក្រសួងអប់រំ យុវជន និងកីឡា។

បំណិនអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ជាបំណិនស្នូលក្នុងការកសាងយុវជន កម្ពុជាឱ្យក្លាយជាពលរដ្ឋឌីជីថលសាកល។ ពលរដ្ឋឌីជីថលសាកលមិនត្រឹមតែត្រូវចេះប្រើប្រាស់បច្ចេកវិទ្យាប៉ុណ្ណោះទេ ប៉ុន្តែត្រូវចេះវិភាគ វាយតម្លៃ និងប្រើប្រាស់ឧបករណ៍ឌីជីថលប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព ក្រមសីលធម៌ និងការទទួលខុសត្រូវ។ ជំនាញនេះដើរតួជាខែលការពារអ្នកសិក្សាពីហានិភ័យ ការកេងប្រវ័ញ្ចតាមអនឡាញ ព្រមទាំងផ្តល់អំណាចដល់ពលរដ្ឋក្នុងការចូលរួមយ៉ាងសកម្ម មានទំនុកចិត្តកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា។ នៅពេលដែលសាលារៀន គ្រួសារ និងសហគមន៍ រួមគ្នាបង្កើតបរិយាកាសឌីជីថលប្រកបដោយបរិយាបន្ន នោះសង្គមជាតិយើងនឹងកាន់តែមានសុវត្ថិភាព ភាពឆ្លាតវៃ និងមានភាពធន់សម្រាប់មនុស្សគ្រប់រូប។

សៀវភៅមគ្គុទ្ទេសក៍អក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាននេះ ត្រូវបានរៀបចំឡើងដើម្បីរួមចំណែកធ្វើទំនើបកម្មកម្មវិធីសិក្សា និងពង្រឹងសមត្ថភាពឌីជីថលតាំងពីកម្រិតមូលដ្ឋាន។ សម្រាប់លោកគ្រូ-អ្នកគ្រូ សៀវភៅនេះជាឧបករណ៍គរុកោសល្យដ៏មានឥទ្ធិពល ក្នុងការគាំទ្រដល់ការបង្រៀនគ្រប់មុខវិជ្ជា ការពង្រឹងការគិតត្រិះរិះ និងការគ្រប់គ្រងថ្នាក់រៀនឌីជីថលប្រកបដោយសុវត្ថិភាព។ សម្រាប់សិស្សានុសិស្ស នេះជាបំណិនពេញមួយជីវិត ជួយពួកគេចេះសម្រេចចិត្តបានត្រឹមត្រូវ ការពារឯកជនភាព ជៀសផុតពីការបោកបញ្ឆោត និងប្រាស្រ័យទាក់ទងគ្នាដោយក្តីគោរព និងទទួលខុសត្រូវក្នុងនាមជាអ្នកបង្កើតនវានុវត្តន៍ឌីជីថលជំនាន់ថ្មីរបស់ប្រទេសជាតិ។

ក្រសួងអប់រំ យុវជន និងកីឡា មានជំនឿយ៉ាងមុតមាំថាសៀវភៅនេះនឹងក្លាយជាគ្រឹះវិស័យមិនអាចខ្វះបានក្នុងការតម្រង់ទិស និងពង្រឹងសមត្ថភាពទាំងផ្នែកផ្នត់គំនិត និងបំណិនឌីជីថលជាក់ស្តែងដល់បុគ្គលិកអប់រំ លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សនៅគ្រប់កម្រិតសិក្សា ដើម្បីឈានទៅសម្រេចបានជោគជ័យ សុវត្ថិភាព និងភាពថ្លៃថ្នូរ ក្នុងយុគសម័យឌីជីថល និងបញ្ញាសិប្បនិម្មិត។

ថ្ងៃសុក្រ ១០ កើត ខែ ភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស ២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០២៦

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

គណៈកម្មការគ្រប់គ្រង

១. លោកជំទាវបណ្ឌិត គឹម សេដ្ឋានី

២. ឯកឧត្តម ទេព ភិយ្យោរិទ្ធ

៣. លោក សុក ថា

៤. លោកស្រី សេង ស៊ីណែត

៥. Ms. Deborah Urban

គណៈកម្មការនិពន្ធ

១. Ms. Sylvia Braesel

២. Mr. Kyle James

គណៈកម្មការពិនិត្យ និងកែលម្អ

១. លោកស្រី សរ វរលក្ខណ៍

២. លោក អ៊ុក សម្ផស្ស

៣. លោកស្រី អ៊ិត ចណ្ណា

៤. លោក ផូ សុវណ្ណ

៥. លោក ផាន់ ស៊ូមី

អ្នកជំនួយបច្ចេកទេស

១. លោក បែន ម៉ៅ

២. លោក សុខា វិសាលពេជ្រ

៣. លោក ធឿន សំបូរ

មាតិកា

សេចក្តីផ្តើម

ជំពូកទី១ – អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន

មេរៀនទី១៖ អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន

ក. អ្វីទៅជាអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន?.....៦
ខ. តើអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន មានសារៈសំខាន់យ៉ាងណា?.....៦
គ. ធាតុទាំង៥ នៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន..... ៧

មេរៀនទី២៖ ជំនាញប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានសតវត្សរ៍ទី២១

ក. ហេតុអ្វីបានជាជំនាញប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន មានសារៈសំខាន់?.....១៤
ខ. ទម្រង់នៃប្រព័ន្ធផ្សព្វផ្សាយ.....១៥
គ. ទម្រង់ និងលក្ខណៈសម្គាល់របស់ប្រព័ន្ធផ្សព្វផ្សាយ..... ១៧

មេរៀនទី៣៖ ដំណឹង និងព័ត៌មាន

ក. តើដំណឹងជាអ្វី?.....២៦
ខ. តើអ្វីជាព័ត៌មាន? តើអ្វីជាភាពខុសគ្នារវាងព័ត៌មាន និងដំណឹង?.....២៧
គ. តើសេចក្តីរាយការណ៍ដំណឹងគួរឆ្លើយសំណួរអ្វីខ្លះ? ២៨
ឃ. ហេតុអ្វីបានជាការទទួលបានព័ត៌មានដែលអាចទុកចិត្តបានមានសារៈសំខាន់? ២៩
ង. ព័ត៌មានខុស ព័ត៌មានមិនពិត និងព័ត៌មានបង្កព្យសនកម្ម ៣០

មេរៀនទី៤៖ ការសរសេរដំណឹង

ក. ការជ្រើសរើសប្រធានបទសម្រាប់សរសេរ ៣៨
ខ. ចំណុចសំខាន់ៗដែលត្រូវដឹងនៅពេលសរសេរដំណឹង.....៣៨
គ. ចំណុចសំខាន់ៗដែលត្រូវដឹងនៅពេលរៀបចំផែនការសម្ភាសន៍ ៣៩
ឃ. ការសរសេរដំណឹងដោយប្រើសំណួរមូលដ្ឋានទាំង៦ និងទម្រង់ពីរ៉ាមីដផ្ងារ.....៤០

ជំពូកទី២ – អក្ខរកម្មឌីជីថល និងទំនួលខុសត្រូវ

មេរៀនទី១៖ អក្ខរកម្មឌីជីថល

ក. តើអក្ខរកម្មឌីជីថលជាអ្វី?..... ៤៨
ខ. សារៈសំខាន់នៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានក្នុងសម័យឌីជីថល..... ៤៨
គ. តើអ៊ីនធឺណិត អ៊ីមែល និងបណ្តាញផ្សព្វផ្សាយសង្គមជាអ្វី?..... ៤៩
ឃ. សុវត្ថិភាព និងឯកជនភាពនៅលើអ៊ីនធឺណិត..... ៥១

មេរៀនទី២៖ អក្ខរកម្មទិន្នន័យ

ក. តើអក្ខរកម្មទិន្នន័យជាអ្វី?..... ៦០
ខ. តើទិន្នន័យនោះគួរឱ្យទុកចិត្តដែរឬទេ?..... ៦១
គ. ការអានតារាងទិន្នន័យ..... ៦២

មេរៀនទី៣៖ ក្រមសីលធម៌ និងទំនួលខុសត្រូវក្នុងប្រព័ន្ធផ្សព្វផ្សាយ

ក. សុក្រឹតភាព ការគិតបែបត្រិះរិះ និងសេរីភាពនៃការបញ្ចេញមតិ..... ៦៨
ខ. ចំណុចសំខាន់ៗដែលត្រូវពិចារណា នៅពេលបញ្ចេញមតិ និងចែករំលែកព័ត៌មាន ៧០

មេរៀនទី៤៖ សុខុមាលភាពឌីជីថល

ក. ទម្លាប់ឌីជីថលប្រកបដោយសុខុមាលភាព ៧៦
ខ. ផលប៉ះពាល់អវិជ្ជមាននៃការចំណាយពេលច្រើនហួសកម្រិតលើអនឡាញ..... ៧៦
គ. សញ្ញាព្រមាននៃការប្រើប្រាស់ឧបករណ៍ឌីជីថលច្រើនហួសកម្រិត..... ៧៧
ឃ. ការស្តារតុល្យភាពឡើងវិញរវាងជីវិតឌីជីថល និងជីវិតពិត ៧៨

ជំពូកទី៣ – បញ្ញាសិប្បនិម្មិត

មេរៀនទី១៖ បញ្ញាសិប្បនិម្មិត គោលគំនិត និងការអនុវត្ត

ក. និយមន័យ និងប្រភេទផ្សេងៗនៃបញ្ញាសិប្បនិម្មិត..... ៨៦
ខ. បញ្ញាសិប្បនិម្មិតក្នុងប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ ៨៧
គ. បញ្ញាសិប្បនិម្មិត និងសាលារៀន..... ៨៨
ឃ. បញ្ញាសិប្បនិម្មិតដែលយើងកំពុងប្រើប្រាស់..... ៨៩

មេរៀនទី២៖ ទំនួលខុសត្រូវក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិត

ក. ការប្រើប្រាស់បញ្ញាសិប្បនិម្មិតជាជំនួយការ..... ៩៤
ខ. ភាពស្មោះត្រង់ក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិត..... ៩៤

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

គ. ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មានពីបញ្ញាសិប្បនិម្មិត ៩៥
ឃ. ការការពារឯកជនភាពក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិត ៩៦

មេរៀនទី៣៖ ហានិភ័យ និងក្រមសីលធម៌បញ្ញាសិប្បនិម្មិត

ក. ភាពលម្អៀងនៃបញ្ញាសិប្បនិម្មិត..... ១០២
ខ. បញ្ហានានាដែលអាចបង្កឡើងដោយបញ្ញាសិប្បនិម្មិត ១០២
គ. ការប្រើប្រាស់បញ្ញាសិប្បនិម្មិតប្រកបដោយសីលធម៌.....១០៣

មេរៀនទី៤៖ ការប្រើប្រាស់បញ្ញាសិប្បនិម្មិតក្នុងការបង្កើតមាតិកា

ក. ការបង្កើតអត្ថបទដោយប្រើបញ្ញាសិប្បនិម្មិត.....១០៨
ខ. ការបង្កើតរូបភាពដោយប្រើបញ្ញាសិប្បនិម្មិត.....១០៩
គ. ការបង្កើតវីដេអូ និងសំឡេងដោយប្រើបញ្ញាសិប្បនិម្មិត.....១០៩
ឃ. គោលការណ៍ណែនាំសម្រាប់ការបង្កើតមាតិកាដោយប្រើបញ្ញាសិប្បនិម្មិត.....១១០

ជំពូកទី៤៖ ឯកជនភាព និងសន្តិសុខអនឡាញ

មេរៀនទី១៖ ដានជើងឌីជីថល និងឯកជនភាពលើអនឡាញ

ក. តើដានជើងឌីជីថលជាអ្វី?.....១១៨
ខ. ការគ្រប់គ្រងដានជើងឌីជីថលរបស់អ្នក.....១១៩
គ. ការពារឯកជនភាពឌីជីថលរបស់អ្នក..... ១២០

មេរៀនទី២៖ ការគំរាមកំហែងតាមអនឡាញ

ក. ការសម្គាល់ និងការចៀសវាងគ្រោះថ្នាក់ក្នុងប្រព័ន្ធឌីជីថល..... ១២៦
ខ. ប្រភេទនៃការគំរាមកំហែងតាមអ៊ីនធឺណិតដែលកើតមានញឹកញាប់..... ១២៦
គ. ការពារខ្លួនអ្នកនៅលើអនឡាញ ១២៩

មេរៀនទី៣៖ ការបង្កើនសុវត្ថិភាពគណនី

ក. យុទ្ធសាស្ត្រការពារសុវត្ថិភាពឌីជីថល.....១៣៦
ខ. របៀបសម្គាល់ការលួចចូលគណនី ១៣៧
គ. ការបណ្តុះទម្លាប់ការពារសុវត្ថិភាព.....១៣៨

មេរៀនទី៤៖ ការបង្កទុក្ខបុកម្នេញតាមអនឡាញ និងសម្តីស្អប់ខ្ពើម

ក. ការបង្កទុក្ខបុកម្នេញតាមអនឡាញ និងសម្តីស្អប់ខ្ពើម ១៤៤
ខ. ការបង្កទុក្ខបុកម្នេញតាមអនឡាញ និងសម្តីស្អប់ខ្ពើមប៉ះពាល់លើមនុស្ស.....១៤៤
គ. យុទ្ធសាស្ត្របង្ការ និងការពារ.....១៤៦
ឃ. ការស្វែងរកជំនួយ និងការគាំទ្រ..... ១៤៧

មេរៀនទី៥៖ ជនងាយរងគ្រោះ និងសុវត្ថិភាពលើអនឡាញ

ក. ក្រុមមនុស្សងាយរងគ្រោះ ១៥២
ខ. ប្រភេទនៃការបៀតបៀនតាមអនឡាញដែលដាក់គោលដៅលើក្រុមមនុស្សងាយរងគ្រោះ.១៥៣
គ. យុទ្ធសាស្ត្រការពារសម្រាប់ក្រុមមនុស្សងាយរងគ្រោះ.....១៥៤
ឃ. ការគាំទ្រដល់ក្រុមមនុស្សងាយរងគ្រោះតាមអនឡាញ ១៥៥

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

សេចក្តីផ្តើម

ក្នុងយុគសម័យដែលបច្ចេកវិទ្យាវិវត្តឥតឈប់ឈរ គ្រឹះស្ថានសិក្សាទាំងអស់មិនត្រឹមជាកន្លែងផ្តល់ចំណេះដឹងបែបប្រពៃណីនោះទេ ប៉ុន្តែត្រូវប្រែក្លាយជាមជ្ឈមណ្ឌលបណ្តុះបណ្តាលបំណិនឌីជីថលប្រកបដោយបរិយាបន្ន។ ឆ្លើយតបតម្រូវការនេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសៀវភៅមគ្គុទ្ទេសក៍ “អក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន” ក្នុងគោលបំណងផ្លាស់ប្តូរឥរិយាបថ និងទម្លាប់ការប្រើប្រាស់បច្ចេកវិទ្យារបស់អ្នកសិក្សាជាក់ស្តែង។

សៀវភៅមគ្គុទ្ទេសក៍នេះមាន៤ជំពូកសំខាន់ដែលផ្តល់ការអប់រំ និងគន្លឹះការពារខ្លួនក្នុងយុគសម័យឌីជីថល។ ជំពូកទី១ ផ្តោតលើបំណិនស្នូលទាំង៥ នៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន។ ជំពូកទី២ កសាងភាពជាពលរដ្ឋឌីជីថលសាកល រៀបប្រើប្រាស់អ៊ីនធឺណិត និងបណ្តាញសង្គមប្រកបដោយសុវត្ថិភាព អក្ខរកម្មទិន្នន័យ ក្រមសីលធម៌ និងសុខុមាលភាពឌីជីថល។ ជំពូកទី៣ បញ្ជាបការយល់ដឹងពីបញ្ហាសិប្បនិម្មិតការប្រើប្រាស់ប្រកបដោយសីលធម៌ និងការទទួលខុសត្រូវ។ ជំពូកទី៤ ការការពារសន្តិសុខអនឡាញ បំណិនគ្រប់គ្រងដានជើងឌីជីថល ការពារឯកជនភាពចៀសវាងការគំរាមកំហែងផ្តោតអាទិភាពលើការគាំទ្រជនងាយរងគ្រោះ។

ការបញ្ជាបបំណិនអក្ខរកម្មឌីជីថលប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន មិនត្រឹមតែបណ្តុះបំណិននិងឥរិយាបថសម្រាប់ការពារបុគ្គលក្នុងពិភពអនឡាញនោះទេ ប៉ុន្តែជាការបង្កើតសហគមន៍មួយដែលមានភាពធន់រួមគ្នាដើរតួជាកម្លាំងចលករជំរុញការកសាងសង្គម និងសេដ្ឋកិច្ចឌីជីថលប្រកបដោយបរិយាបន្ន និងចីរភាពពិតប្រាកដនៅកម្ពុជា។

ដើម្បីគាំទ្រការអនុវត្តកំណែទម្រង់ការអប់រំឌីជីថលប្រកបដោយប្រសិទ្ធភាព សៀវភៅមគ្គុទ្ទេសក៍នេះត្រូវបានផ្សារភ្ជាប់នឹងឧបករណ៍ឌីជីថលរួមមានកម្មវិធីទូរសព្ទដៃ SALA MIL App និងប្រព័ន្ធស្វ័យសិក្សាតាមតេឡេក្រាម MIL Chatbot។ នៅរាល់ចុងបញ្ចប់មេរៀនមានសន្ធានុក្រមពាក្យបច្ចេកទេសនិងលំហាត់អនុវត្តជាក់ស្តែង។

សូម ស្កេន QR Code ខាងក្រោមដើម្បីភ្ជាប់ និងទាញយកកម្មវិធី



ជំពូកទី១

អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន

មេរៀនទី១៖ អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន

មេរៀនទី២៖ ជំនាញប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានសតវត្សរ៍ទី២១

មេរៀនទី៣៖ ដំណឹង និងព័ត៌មាន

មេរៀនទី៤៖ ការសរសេរដំណឹង

មេរៀនទី ១ អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន



មេរៀនទី១.១ និង១.២



ជំពូកទី១

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

ក. អ្វីទៅជាអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន?

ខ. តើអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន មានសារៈសំខាន់យ៉ាងណា?

គ. ធាតុទាំង៥ នៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន

ហេតុអ្វីបានជាមេរៀននេះសំខាន់?

ការយល់ដឹងអំពីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ជួយឱ្យមនុស្សប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដោយសុវត្ថិភាព និងធ្វើការសម្រេចចិត្តដោយភាពឆ្លាតវៃ អំពីមាតិកាប្រព័ន្ធផ្សព្វផ្សាយ ដែលពួកគេឃើញទាំងនៅលើអ៊ីនធឺណិត និងក្រៅប្រព័ន្ធអ៊ីនធឺណិត។ វាក៏បង្រៀនពីជំនាញដែលចាំបាច់ដើម្បីចូលរួមប្រកបដោយការទទួលខុសត្រូវនៅក្នុងលំហឌីជីថលផងដែរ។

ក. អ្វីទៅជាអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន?

ពាក្យថា «អក្ខរកម្ម» សំដៅលើសមត្ថភាពក្នុងការអាន និងសរសេរ។ ចំណែក «អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន» សំដៅលើសមត្ថភាពក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ប្រកបដោយសុវត្ថិភាព ឈ្លាសវៃ និងការទទួលខុសត្រូវ។

និយមន័យ

អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន គឺជាបណ្តុំជំនាញដែលអនុញ្ញាតឱ្យបុគ្គលម្នាក់ៗ អាចប្រើប្រាស់ វិភាគ បង្កើតមាតិកាថ្មី ឆ្លុះបញ្ចាំង និងចូលរួមយ៉ាងសកម្មនៅក្នុងបរិស្ថានប្រព័ន្ធផ្សព្វផ្សាយ។

បុគ្គលដែលមានចំណេះដឹងអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ គឺជាអ្នកដែលមានសមត្ថភាពយល់ដឹងអំពីសារជ័ស្មុគស្មាញដែលត្រូវបានបង្ហាញនៅក្នុងទំព័រកាសែត ផ្ទាំងប៉ាណូ វីដេអូហ្គេម តន្ត្រី អ៊ីនធឺណិត បណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត ក៏ដូចជាមានសមត្ថភាពក្នុងការបង្កើតមាតិកាផ្សព្វផ្សាយដោយខ្លួនឯងផងដែរ។

តើអ្នកដឹងទេ?

នៅក្នុងប្រទេសជាច្រើនអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានបានក្លាយជាផ្នែកមួយនៃកម្មវិធីសិក្សាអប់រំរួចទៅហើយ។ គ្រូបង្រៀនទទួលស្គាល់ថា អក្ខរកម្មឌីជីថលប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន គឺមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះវាអនុញ្ញាតឱ្យសិស្សអនុវត្តជំនាញការគិតបែបស៊ីជម្រៅបានយ៉ាងទូលំទូលាយ។

ដោយសារបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ហើយមាតិកាប្រព័ន្ធផ្សព្វផ្សាយមានភាពស្មុគស្មាញ និងផ្លាស់ប្តូរឥតឈប់ឈរ អក្ខរកម្មឌីជីថលប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានបានក្លាយជាជំនាញដ៏ចាំបាច់មួយនៅទូទាំងពិភពលោក។

ខ. តើអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន មានសារៈសំខាន់យ៉ាងណា?

ការយល់ដឹងអំពីប្រព័ន្ធផ្សព្វផ្សាយ និងឥទ្ធិពលរបស់វាទៅលើសង្គម ឬបុគ្គល គឺជាជំនាញដ៏ចាំបាច់សម្រាប់មនុស្សគ្រប់រូប។ ការអនុវត្តជំនាញអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ជួយឱ្យយើងយល់កាន់តែច្បាស់អំពីរបៀបធម៌ គុណតម្លៃ និងការប្រាស្រ័យទាក់ទងគ្នា។ ទោះជានៅក្នុងសង្គម ឬបុគ្គលក្តី ប្រព័ន្ធផ្សព្វផ្សាយតែងតែមានភាពស្មុគស្មាញ និងពិបាកយល់ឱ្យបានពេញលេញ។ ប៉ុន្តែអ្នកដែលមានចំណេះដឹងអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន តែងតែមិនធ្វើការវិនិច្ឆ័យភ្លាមៗ ដោយគ្មានការពិចារណាឱ្យបានម៉ត់ចត់នោះទេ។

អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន មានគោលបំណងជួយយើងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាព និងលើកទឹកចិត្តដល់ការបង្កើតមាតិកានៅលើថ្នាលផ្សព្វផ្សាយ។ វិធីសាស្ត្រនេះអាចបង្កើនឱកាសសម្រាប់ការរកឃើញ និងទស្សនវិស័យថ្មីៗ រួមចំណែកដល់ការអភិវឌ្ឍសង្គមមួយដែលពលរដ្ឋរស់នៅប្រកបដោយគុណតម្លៃ និងសីលធម៌រឹងមាំ។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

បច្ចេកវិទ្យាទំនើបជួយឱ្យយើងបង្កើត និងវិភាគមាតិកាក្នុងទម្រង់ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដូចជា អត្ថបទ រូបភាព ឬវីដេអូ។ ទោះជាយ៉ាងណាក៏ដោយការបង្កើត និងការវិភាគមាតិកាប្រព័ន្ធផ្សព្វផ្សាយទាមទារ ឱ្យមានការរៀនសូត្រ និងការអនុវត្តជាប្រចាំ។ ជាក់ស្តែងការបន្តការសិក្សាអំពីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និង ព័ត៌មាន គឺជាការសិក្សាពេញមួយជីវិតព្រោះតែបច្ចេកវិទ្យាផ្លាស់ប្តូរគ្រប់ពេលវេលា។

អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ជួយឱ្យយើង៖

- បង្កើនជំនាញគិតបែបត្រិះរិះ
- ស្វែងយល់អំពីឥទ្ធិពលនៃប្រព័ន្ធផ្សព្វផ្សាយ មកលើការអភិវឌ្ឍសង្គម និងវប្បធម៌
- យល់ដឹងអំពីយុទ្ធសាស្ត្រទីផ្សារ
- ស្វែងយល់ពីចេតនារបស់អ្នកផលិតមាតិកា ក្នុងការបញ្ចុះបញ្ចូលឱ្យសាធារណជនជឿ ឬអនុវត្តតាម
- សម្គាល់បាននូវបច្ចេកទេសដែលគេប្រើសម្រាប់ការបញ្ចុះបញ្ចូល ឬការអូសទាញ
- ផ្តល់មតិដើម្បីកែលម្អប្រព័ន្ធផ្សព្វផ្សាយ
- រកឃើញព័ត៌មានលម្អៀង រឿងប្រឌិត ព័ត៌មានក្លែងក្លាយ និងមាតិកាមិនពិត
- ស្វែងយល់ពីទិដ្ឋភាពទានានៃរឿងរ៉ាវដែលត្រូវបានគេលាក់បាំង ឬរឹតត្បិត
- វិភាគខ្លឹមសារប្រព័ន្ធផ្សព្វផ្សាយ ដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួន ចំណេះដឹង ជំនាញ ជំនឿ និង គុណតម្លៃ
- បង្កើត និងចែករំលែកមាតិកាដោយឯករាជ្យ

គ. ធាតុទាំង៥ នៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន

១. សមត្ថភាពក្នុងការប្រើប្រាស់

សមត្ថភាពក្នុងការចូលប្រើប្រាស់គឺជាជំហានដំបូងបង្អស់នៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយនិង ព័ត៌មាន។ ជំហាននេះផ្តោតសំខាន់លើការស្វែងរក និងការយល់ដឹងពីមាតិកានៅលើថ្នាលផ្សព្វផ្សាយ ព្រមទាំងការចេះប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាផងដែរ។ នៅក្នុងផ្នែកនេះ អ្នកនឹងសិក្សាអំពីវិធីសាស្ត្រក្នុង ការស្វែងរក និងការចែករំលែកព័ត៌មានដែលត្រឹមត្រូវ និងឆ្លើយតបចំតម្រូវការរបស់អ្នក។

ឧទាហរណ៍៖ នៅពេលកុមាររៀនអានពួកគេចាប់ផ្តើមដោយការបើកសៀវភៅអានម្តងមួយទំព័រៗ។ តាមរយៈសកម្មភាពនេះ ពួកគេចាប់ផ្តើមចំណាំតួអក្សរដែលផ្សំចូលគ្នាជាពាក្យ និងស្វែងយល់ពី ទំនាក់ទំនងរវាងអត្ថបទ និងរូបភាព។ ដំណើរការនៃការបកស្រាយ និងការចាប់យកអត្ថន័យនៃសំណេរ នៅលើទំព័រសៀវភៅ គឺជាជំនាញមូលដ្ឋានដ៏មានសារៈសំខាន់បំផុត។

ឧទាហរណ៍៖ វិធីដែលប្រើសម្រាប់ស្វែងរកអត្ថបទ ឬសៀវភៅ អាចយកទៅអនុវត្តបានចំពោះប្រព័ន្ធ ផ្សព្វផ្សាយគ្រប់ប្រភេទ។ ការស្វែងរកព័ត៌មាននៅលើអ៊ីនធឺណិត ទាមទារឱ្យយើងមានជំនាញបច្ចេកទេស។ យើងត្រូវដឹងថា ពាក្យគន្លឹះណាខ្លះដែលសមស្របសម្រាប់ការរាយបញ្ជូលទៅក្នុងម៉ាស៊ីនស្វែងរក និងចេះ កំណត់សម្គាល់វេបសាយដែលអាចទុកចិត្តបាន និងគួរឱ្យចូលមើល។



រូបភាព ១.១ ការស្វែងរកព័ត៌មាននៅលើអ៊ីនធឺណិត

ការចូលរួមនៅក្នុងបណ្តាញសង្គម ទាមទារឱ្យយើងមានសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃដោយផ្ទាល់តាមប្រព័ន្ធអនឡាញ។ ចំណុចនេះជួយដល់ការសម្រេចចិត្តថាតើព័ត៌មានបែបណាដែលគួរឬមិនគួរចែករំលែក។

យើងទាំងអស់គ្នាមិនអាចចេះស្ទាត់ជំនាញរាល់ប្រភេទនៃប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាននោះទេព្រោះបច្ចេកវិទ្យាទាំងអស់តែងតែវិវត្តប្រែប្រួលឥតឈប់ឈរ។ គោលបំណងនៃការសិក្សាអំពីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ដើម្បីស្វែងយល់អំពីមូលដ្ឋានគ្រឹះនៃដំណើរការរបស់ប្រព័ន្ធផ្សព្វផ្សាយ និងដើម្បីប្រើប្រាស់ឧបករណ៍ឌីជីថលដែលយើងកំពុងមានសព្វថ្ងៃ ប្រកប ដោយសុវត្ថិភាព និងទំនួលខុសត្រូវ។

ប្រសិនបើបុគ្គលម្នាក់មានសមត្ថភាពក្នុងការយល់ដឹង និងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពនាពេលបច្ចុប្បន្ន នោះពួកគេនឹងយល់ឃើញថាវាកាន់តែងាយស្រួល ក្នុងការស្វែងយល់អំពីប្រព័ន្ធផ្សព្វផ្សាយប្រភេទ និងទម្រង់ថ្មីៗដែលនឹងលេចឡើងនាពេលអនាគត។

២. ការវិភាគ



រូបភាព ១.២ ការវិភាគមាតិកាផ្សព្វផ្សាយ

សមត្ថភាពក្នុងការវិភាគព័ត៌មាន គឺជាជំហានទីពីរនៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន។ បុគ្គលដែលមានជំនាញក្នុងការវិភាគសាររបស់ប្រព័ន្ធផ្សព្វផ្សាយ អាចបកស្រាយអត្ថន័យ និងវាយតម្លៃលើមាតិកាទាំងទម្រង់បោះពុម្ពផ្សាយ និងឌីជីថល រួមមាន៖ រូបភាព អត្ថបទ សារព័ត៌មាន វីដេអូ ភាពយន្ត វីដេអូហ្គេម អ៊ីនធឺណិត និងបណ្តាញសង្គម។

ក្នុងការវិភាគប្រព័ន្ធផ្សព្វផ្សាយ ការពិចារណាអំពីអ្នកនិពន្ធ ឬអ្នកបង្កើតមាតិកាផ្សព្វផ្សាយ (សៀវភៅ ភាពយន្ត ការបង្ហោះសារលើបណ្តាញសង្គម កម្មវិធីទូរទស្សន៍ ។ល។)។ ការស្វែងយល់ពីគោលបំណងនិងចេតនានៃខ្លឹមសារមាតិកាថ្នាលផ្សព្វផ្សាយ គឺជាកត្តាដ៏សំខាន់បំផុត។ យើងអាចសិក្សាស្វែងយល់ពីសារៈសំខាន់នៃការគិតដល់ជនគោលដៅសម្រាប់សារផ្សព្វផ្សាយនីមួយៗ ដោយពិចារណាលើគុណភាព ភាពស្របច្បាប់ ភាពជឿជាក់ និងផលប៉ះពាល់ដែលអាចកើតមាន បន្ទាប់ពីសារនោះត្រូវបានផ្សព្វផ្សាយ។

គោលដៅមួយទៀតគឺការយល់ឱ្យបានច្បាស់លាស់អំពីសារប្រព័ន្ធផ្សព្វផ្សាយ ដែលទាក់ទងនឹងបញ្ហាសង្គម នយោបាយ ប្រវត្តិសាស្ត្រ សេដ្ឋកិច្ច និងវប្បធម៌។ ឧទាហរណ៍៖ អត្ថប្រយោជន៍ក្នុងការចោទសួរអំពីស្ថាប័នដែលពាក់ព័ន្ធក្នុងការផលិតមាតិកាប្រព័ន្ធផ្សព្វផ្សាយ និងតួនាទីរបស់សាធារណជនក្នុងការបកស្រាយសារដែលត្រូវបានផ្សព្វផ្សាយទាំងនោះ។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

៣. ការបង្កើត

ការបង្កើតគឺជាជំហានទីបីនៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន។ កាលពីអតីតកាល មាតិកាប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានបង្កើតឡើងដោយប្រើក្រដាស និងទឹកខ្មៅ។ ប៉ុន្តែបច្ចុប្បន្ននេះ គេប្រើប្រាស់ឧបករណ៍ឌីជីថល ដូចជា កុំព្យូទ័រ ឬទូរសព្ទដៃ ដើម្បីបង្កើតអត្ថបទ សារជាសំឡេង តន្ត្រី រូបថត ក្រាបវីដេអូ ផតខាស់ វេបសាយ គំនូរជីវចលនិងវីដេអូហ្គេម។ មាតិកាផ្សព្វផ្សាយ ក៏ប្រើប្រាស់ទម្រង់ខុសៗគ្នាផងដែរ រួមមានៈ ទម្រង់ការនិទានរឿង ការបញ្ចុះបញ្ចូល និងបែបពន្យល់។

ការបង្កើតសារ និងមាតិកាឌីជីថល អនុញ្ញាតឱ្យយើងអាចបញ្ចេញគំនិត និងចែករំលែកទៅកាន់អ្នកដទៃតាមរយៈអ៊ីនធឺណិត។ ការចែករំលែកស្នាដៃផ្ទាល់ខ្លួននេះ នឹងជួយកសាងទំនុកចិត្តលើខ្លួនឯង ក្នុងការបញ្ចេញមតិយោបល់ និងបង្ហាញសមត្ថភាពរបស់អ្នក។



រូបភាព ១.៣ ការបង្កើតព័ត៌មានឌីជីថល

៤. ការឆ្លុះបញ្ចាំង

ការឆ្លុះបញ្ចាំងគឺជាជំហានទីបួននៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ដែលទាមទារឱ្យមានការពិចារណាយ៉ាងម៉ត់ចត់ទៅលើការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយប្រចាំថ្ងៃរបស់អ្នក ព្រមទាំងការស្វែងយល់ពីរបៀបដែលប្រព័ន្ធផ្សព្វផ្សាយដំណើរការ។ ជំហាននេះសំដៅទៅលើការគិតអំពីផលប៉ះពាល់នៃសារពីប្រព័ន្ធផ្សព្វផ្សាយ និងបច្ចេកវិទ្យា មកលើរូបអ្នកផ្ទាល់ អ្នកដទៃ និងសង្គមទាំងមូល។

ទម្លាប់នៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់បុគ្គលម្នាក់ៗ មានឥទ្ធិពលទៅលើអត្តសញ្ញាណ ការឱ្យតម្លៃលើខ្លួនឯង ទំនាក់ទំនង និងអនាគតរបស់អ្នកដទៃ។ នេះមានន័យថាការឆ្លុះបញ្ចាំងឡើងវិញ មានសារៈសំខាន់ណាស់ ក្នុងការកសាងទំនាក់ទំនងរវាងជំនាញអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន និងតរិយាបថផ្ទាល់ខ្លួន ជួយយើងឱ្យយល់ដឹងកាន់តែច្បាស់អំពីទំនួលខុសត្រូវក្នុងសង្គម និងក្រមសីលធម៌។

ឧទាហរណ៍ៈ ការរីកចម្រើនយ៉ាងរហ័សនៃប្រព័ន្ធផ្សព្វផ្សាយអាចជំរុញឱ្យយើងធ្វើសកម្មភាព ឬមានប្រតិកម្មភ្លាមៗ។ យើងអាចឆ្លុះបញ្ចាំងពីទម្លាប់ និងបទពិសោធន៍ផ្ទាល់ខ្លួនដោយត្រួតពិនិត្យមើលសាររបស់យើងនៅលើបណ្តាញសង្គមឡើងវិញ ព្រមទាំងសង្កេតមើលតរិយាបថ និងរបៀបប្រាស្រ័យទាក់ទងជាមួយមិត្តភក្តិ។



រូបភាព ១.៤ ការឆ្លុះបញ្ចាំងខ្លួនឯង

យើងអាចពិនិត្យមើលដោយយកចិត្តទុកដាក់នូវអន្តរកម្មតាមអនឡាញផ្សេងៗទៀតដូចជា ការចែករំលែកការបញ្ចេញមតិ ឬការបង្ហោះសារិះគន់ដើម្បីស្វែងយល់ពីឥទ្ធិពលដែលអាចកើតមានមកលើអត្តសញ្ញាណឌីជីថលរបស់យើងព្រមទាំងការប្រព្រឹត្តរបស់យើងចំពោះអ្នកដទៃ។

៥. ការចូលរួម

ការចូលរួមជាជំហានទីប្រាំ និងជាជំហានចុងក្រោយនៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ដោយ ផ្អែកលើជំនាញដែលបានរៀននៅក្នុងជំហានទាំងបួនខាងលើ។ គោលគំនិតនៃការចូលរួម ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សាអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ពីព្រោះវាមានសារៈសំខាន់សម្រាប់ការពង្រឹងសមត្ថភាពរបស់សិស្ស ឱ្យលើសពីការរៀននៅក្នុងថ្នាក់ ព្រមទាំងមានឥទ្ធិពលលើសង្គមផងដែរ។



រូបភាព ១.៥ ការចូលរួមផ្សព្វផ្សាយ

ការរៀនសូត្រនឹងទទួលបានលទ្ធផលល្អ នៅពេលដែលយើងអាចផ្សារភ្ជាប់ការអប់រំក្នុងថ្នាក់រៀនទៅនឹងស្ថានភាពជាក់ស្តែងក្នុងជីវិតពិត បញ្ហាសង្គមសកល ព្រឹត្តិការណ៍ក្នុងមូលដ្ឋាន និងសហគមន៍របស់យើង។

គោលដៅនៃការចូលរួមយ៉ាងសកម្មក្នុងប្រព័ន្ធផ្សព្វផ្សាយ គឺដើម្បីចែករំលែកចំណេះដឹង និងទាក់ទាញចំណាប់អារម្មណ៍ទៅលើបញ្ហាប្រឈមក្នុងសហគមន៍ ជាតិ និងអន្តរជាតិ។ ការអប់រំនិងទំនួលខុសត្រូវសង្គមមានទំនាក់ទំនងផ្សារភ្ជាប់គ្នា ដូច្នេះមនុស្សគ្រប់រូបចាំបាច់ត្រូវរៀនធ្វើសកម្មភាពប្រកបដោយសុចរិតភាព និងទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន។

មេរៀនសង្ខេប

នៅក្នុងមេរៀននេះ យើងបានសិក្សាចំណុចសំខាន់ៗដូចខាងក្រោម៖

- អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន គឺជាបណ្តុំនៃជំនាញដែលអនុញ្ញាតឱ្យបុគ្គលម្នាក់ប្រើប្រាស់ វិភាគ បង្កើតសារប្រព័ន្ធផ្សព្វផ្សាយថ្មី ឆ្លុះបញ្ចាំងឡើងវិញលើព័ត៌មានប្រព័ន្ធផ្សព្វផ្សាយដែលមានស្រាប់ និងចូលរួមយ៉ាងសកម្មនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។
- អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន អាចជួយឱ្យយើង៖
  - ពង្រឹងជំនាញគិតបែបត្រិះរិះ
  - ស្វែងយល់អំពីឥទ្ធិពលនៃប្រព័ន្ធផ្សព្វផ្សាយ មកលើការអភិវឌ្ឍសង្គម និងវប្បធម៌
  - ស្វែងយល់ពីចេតនារបស់អ្នកផលិតមាតិកា ក្នុងការបញ្ចុះបញ្ចូលឱ្យសាធារណជនជឿ ឬអនុវត្តតាម
  - កំណត់សម្គាល់បច្ចេកទេសនៃការបញ្ចុះបញ្ចូល ដែលត្រូវបានប្រើប្រាស់នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ
  - រកឃើញព័ត៌មានលម្អៀង រឿងប្រឌិត ព័ត៌មានមិនពិត និងការកុហក
  - ស្វែងរកផ្នែកខ្លះនៃរឿងរ៉ាវដែលត្រូវបានលាក់បាំង ឬរំលងចោល
  - វិភាគសាររបស់ប្រព័ន្ធផ្សព្វផ្សាយ ដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួន ចំណេះដឹង ជំនាញ ជំនឿ និងគុណតម្លៃ
  - បង្កើត និងចែករំលែកសារប្រព័ន្ធផ្សព្វផ្សាយដែលផលិតដោយខ្លួនឯង
- ធាតុផ្សំទាំង៥នៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានរួមមាន៖ សមត្ថភាពក្នុងការប្រើប្រាស់ការវិភាគ ការបង្កើត ការឆ្លុះបញ្ចាំង និងការចូលរួម។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

សទ្ទានុក្រម

- **ព័ត៌មាន៖** អង្គហេតុ/ហេតុការណ៍ ឬគំនិតដែលជួយពន្យល់អំពីអ្វីមួយ។
- **អក្ខរកម្ម៖** សមត្ថភាពក្នុងការយល់ និងប្រើប្រាស់អ្វីមួយប្រកបដោយប្រសិទ្ធភាព ដូចជាការអាន ឬការប្រើប្រាស់កុំព្យូទ័រ។
- **ប្រព័ន្ធផ្សព្វផ្សាយ៖** ពហុវចនៈនៃពាក្យ “មធ្យោបាយផ្សព្វផ្សាយ” ដែលសំដៅលើ ឧបករណ៍ ឬវេទិកាដែលចែករំលែកព័ត៌មាន ដូចជា ទូរទស្សន៍ វិទ្យុ អ៊ីនធឺណិត។
- **សារ៖** មាតិកាណាមួយដែលនរណាម្នាក់បង្កើតឡើងដើម្បីប្រាប់អំពីគំនិតអ្វីមួយ។

លំហាត់អនុវត្តន៍

១. ប្រវត្តិប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ៖ រំលឹកអំពីការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយកាលពីអ្នកនៅក្មេង

សូមរំលឹកទៅដល់ពេលវេលាដែលអ្នកនៅក្មេង។ តើមានសៀវភៅ កម្មវិធីវិទ្យុ ទូរទស្សន៍ ព័ត៌មានតន្ត្រី វីដេអូហ្គេម ឬប្រព័ន្ធផ្សព្វផ្សាយណាខ្លះដែលមានសារៈសំខាន់បំផុតសម្រាប់អ្នកកាលពីពេលនោះ? តើបទពិសោធន៍ ឬខ្លឹមសារនៃប្រព័ន្ធផ្សព្វផ្សាយទាំងនោះ បានបន្តជះឥទ្ធិពលអ្វីខ្លះមកលើខ្លួនអ្នករហូតមកដល់សព្វថ្ងៃនេះ?

សូមព្យាយាមចងចាំទាំងគ្រាដែលរីករាយ និងគ្រាដែលពិបាកហើយកត់សម្គាល់ថា តើអ្នកមានអាយុប៉ុន្មាន នៅពេលដែលព្រឹត្តិការណ៍ទាំងនោះកើតឡើង។



២.ទម្លាប់ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ៖ កត់សម្គាល់លើការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយប្រចាំថ្ងៃ

សូមសង្កេតមើលទម្លាប់នៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយផ្ទាល់ខ្លួនរបស់អ្នកនិងសមាជិកគ្រួសារ។ ឆ្លើយសំណួរខាងក្រោម ហើយកត់ត្រាចម្លើយទុក៖

- តើអ្នកនិងគ្រួសាររបស់អ្នក ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយអ្វីខ្លះជាប្រចាំថ្ងៃ ហើយប្រើប្រាស់ក្នុងគោលបំណងអ្វី?
- តើអ្នកនិងសមាជិកគ្រួសារ ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយនីមួយៗនោះ ក្នុងកម្រិតញឹកញាប់ប៉ុនណា?
- តើអ្នកឬសមាជិកគ្រួសារណាម្នាក់ ធ្លាប់បានផលិតខ្លឹមសារផ្សព្វផ្សាយដែរឬទេ? ប្រសិនបើធ្លាប់ តើខ្លឹមសារប្រភេទណាដែលអ្នកបានផលិត?

៣. អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន៖ មើលវីដេអូ

សូមប្រើប្រាស់កម្មវិធីទូរសព្ទ SALA MIL ហើយចូលទៅកាន់ជំពូកទី១ មេរៀនទី១.១៖ អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន រួចទស្សនាវីដេអូ និងឆ្លើយសំណួរខាងក្រោម៖

១. ចូរពន្យល់អំពីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន។

២. តើអ្នកទទួលបានចំណេះដឹងអ្វីខ្លះ ពីការចែករំលែកព័ត៌មានមិនពិត?

៣. តើអ្នកទទួលបានដំបូន្មានអ្វីខ្លះ អំពីការប្រើប្រាស់បណ្តាញសង្គមដោយសុវត្ថិភាព និងប្រកបដោយការទទួលខុសត្រូវ?

៤. អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន៖ បង្កើតបទបង្ហាញមួយ

សូមប្រើប្រាស់ MIL Chatbot ហើយចូលទៅកាន់ជំពូកទី១៖ អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន។ ស្វែងយល់ពីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន។ សូមរៀបចំបទបង្ហាញខ្លីមួយដែលមានរចនាសម្ព័ន្ធល្អត្រឹមត្រូវ ដើម្បីចែករំលែកការរកឃើញរបស់អ្នក។ សូមលើកយកឧទាហរណ៍ពីប្រព័ន្ធផ្សព្វផ្សាយ និងជីវិតប្រចាំថ្ងៃជាក់ស្តែង។ បទបង្ហាញរបស់អ្នកគួរតែមានបញ្ចូលចំណុចខាងក្រោម៖

- ផ្នែកទី១៖ តើអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានជាអ្វី?
- ផ្នែកទី២៖ ហេតុអ្វីបានជាអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន មានសារៈសំខាន់?
- ផ្នែកទី៣៖ តើចំណេះដឹងអំពីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន អាចជួយមនុស្សយ៉ាងដូចម្តេច?
- ផ្នែកទី៤៖ តើការគិតបែបស៊ីជម្រៅជាអ្វី?

សំណួរសំរាប់ពិភាក្សា

១. ចូរឱ្យនិយមន័យអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន។

២. ហេតុអ្វីបានជាប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មាន មានសារៈសំខាន់ចំពោះអ្នក?

៣. តើធាតុផ្សំទាំង៥ នៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន មានអ្វីខ្លះ? ចូររៀបរាប់សង្ខេបអំពីធាតុផ្សំទាំងនោះ។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

មេរៀនទី ២

ជំនាញប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានសតវត្សរ៍ទី២១



មេរៀនទី១.២



ជំពូកទី៤

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីៈ

ក. ហេតុអ្វីបានជាជំនាញប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន មានសារៈសំខាន់?

ខ. ទម្រង់នៃប្រព័ន្ធផ្សព្វផ្សាយ

គ. ទម្រង់ និងលក្ខណៈសម្គាល់របស់ប្រព័ន្ធផ្សព្វផ្សាយ

ហេតុអ្វីបានជាមេរៀននេះសំខាន់?

ក្នុងយុគសម័យនៃការរីកចម្រើនបច្ចេកវិទ្យា មនុស្សម្នាក់ៗកាន់តែពឹងផ្អែកលើឧបករណ៍ឌីជីថល។ អ្នកសិក្សាចាំបាច់ត្រូវមានជំនាញអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន សម្រាប់ការសិក្សា បំពេញការងារ និងជីវិតប្រចាំថ្ងៃ។ ជំនាញនេះជួយឱ្យអ្នកយល់ច្បាស់ពីទម្រង់ និងវិធីសាស្ត្រនៃការផ្សព្វផ្សាយព័ត៌មានផ្សេងៗ។

ក. ហេតុអ្វីបានជាជំនាញប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន មានសារៈសំខាន់?

បច្ចេកវិទ្យាកំពុងក្លាយជាផ្នែកមួយនៃសកម្មភាពប្រចាំថ្ងៃ សិស្សានុសិស្សប្រើប្រាស់ទូរសព្ទ និងកុំព្យូទ័រសម្រាប់ការសិក្សា។ ចំណែកអ្នកធ្វើការវិញ ត្រូវការជំនាញឌីជីថលច្បាស់លាស់ សម្រាប់ការងារ។ មនុស្សភាគច្រើន កំពុងប្រើប្រាស់កម្មវិធីធនាគារតាមទូរសព្ទដៃ ដើម្បីធ្វើប្រាក់ និងទូទាត់វិក្កយបត្រផ្សេងៗ។ បច្ចុប្បន្ននេះ សូម្បីតែកិច្ចការប្រចាំថ្ងៃសាមញ្ញៗ ដូចជា ការទិញទំនិញ ឬការទទួលសេវាសាធារណៈ ក៏ច្រើនតែធ្វើឡើងតាមប្រព័ន្ធអនឡាញដែរ។ នេះហើយជាមូលហេតុដែលជំនាញប្រព័ន្ធ ផ្សព្វផ្សាយ និងព័ត៌មាន មានសារៈសំខាន់ ជួយឱ្យអ្នកប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពទាំងការសិក្សា ការងារ និងការរស់នៅប្រចាំថ្ងៃ។

ភាពចាំបាច់នៃជំនាញឌីជីថលនៅក្នុងសាលារៀន



រូបភាព ២.១ ភាពចាំបាច់នៃជំនាញឌីជីថល

បច្ចុប្បន្នសាលារៀនភាគច្រើនតែងតែប្រើប្រាស់ឧបករណ៍ឌីជីថល ចាប់តាំងពីការស្រាវជ្រាវតាមអនឡាញ កម្មវិធីសាលា ឬវេបសាយ រហូតដល់ថ្នាក់រៀននិម្មិត។ ដូច្នេះ សិស្សានុសិស្សចាំបាច់ត្រូវមានជំនាញប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ដើម្បីសិក្សាឱ្យមានប្រសិទ្ធភាពនៅក្នុងបរិយាកាសឌីជីថលទាំងនេះ។ ជំនាញទាំងនោះរួមមាន ការស្រាវជ្រាវសម្រាប់កិច្ចការសាលា ការស្វែងរកព័ត៌មានពីប្រភពដែលអាចទុកចិត្តបាន ការគិតបែបត្រិះរិះ ការបែងចែករវាងការពិត និងមតិយោបល់ ព្រមទាំងការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយការទទួលខុសត្រូវ ដើម្បីទទួលបានអត្ថប្រយោជន៍ជាអតិបរមាពីការសិក្សា។

ជំនាញឌីជីថល និងទីផ្សារការងារ

ប្រទេសកម្ពុជាកំពុងបង្កើតការងារឌីជីថលថ្មីៗជាច្រើន ហើយសូម្បីតែការងារបែបប្រពៃណីក៏ត្រូវការជំនាញឌីជីថលនៅពេលបច្ចុប្បន្ននេះដែរ។ អ្នកធ្វើការដែលយល់ដឹងពីបច្ចេកវិទ្យា នឹងអាចធ្វើការជាមួយប្រព័ន្ធឌីជីថល មានឱកាសការងារល្អ និងទទួលបានប្រាក់បៀវត្សរ៍ខ្ពស់។ ការងារដែលទាមទារជំនាញឌីជីថលមានចាប់ពីអ្នកអភិវឌ្ឍន៍កម្មវិធីនិងអ្នកវិភាគទិន្នន័យ រហូតដល់អ្នកធ្វើទីផ្សារតាមបណ្តាញសង្គម និងអ្នកជំនាញផ្សព្វផ្សាយពាណិជ្ជកម្មតាមឌីជីថល។ សូម្បីតែកសិករក៏អាចទទួលបានអត្ថប្រយោជន៍ដោយការប្រើប្រាស់ថ្នាលឌីជីថល ដើម្បីលក់ផលិតផលរបស់ពួកគាត់ទៅកាន់ទីផ្សារបានច្រើន រួមទាំងប្រើកម្មវិធីព្យាករណ៍អាកាសធាតុ និងការជូនដំណឹងផ្សេងៗ។

សព្វថ្ងៃនេះនិយោជកចង់បានបុគ្គលិកដែលចេះប្រាស្រ័យទាក់ទងបានល្អតាមប្រព័ន្ធអនឡាញ និងចេះធ្វើការសម្រេចចិត្តដ៏ឆ្លាតវៃ។ ជាក់ស្តែងបុគ្គលិកគួរតែអាចសរសេរអ៊ីមែលបានត្រឹមត្រូវ បង្កើតបទបង្ហាញ និងចូលរួមការប្រជុំតាមសន្និសិទវីដេអូ។ ពួកគេត្រូវយល់ដឹងអំពីរបៀបការពារទិន្នន័យឯកជន និងមានឥរិយាបថ ប្រកបដោយវិជ្ជាជីវៈនៅលើប្រព័ន្ធអនឡាញ។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

បច្ចេកវិទ្យាឌីជីថលក្នុងជីវិតប្រចាំថ្ងៃ

បច្ចុប្បន្នប្រជាពលរដ្ឋកម្ពុជាជាច្រើនកំពុងងាកមកប្រើប្រាស់សេវាធនាគារតាមទូរសព្ទដៃ និងទូទាត់ចំណាយប្រចាំថ្ងៃតាមរយៈការស្កេន QR កូដ។ ជំនាញប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ជួយឱ្យអ្នកប្រើប្រាស់សេវាកម្មទាំងនេះដោយសុវត្ថិភាព និងធ្វើការសម្រេចចិត្តបានត្រឹមត្រូវមិនថាជាការប្រើប្រាស់កម្មវិធីធនាគារតាមទូរសព្ទ។ ការយល់ដឹងអំពីជម្រើសនៃការទូទាត់ និងកម្រៃសេវា ឬការបែងចែកឱ្យដាច់រវាងសារពិតរបស់ធនាគារ និងសារបោកបញ្ឆោតដែលព្យាយាមបោកយកប្រាក់របស់អ្នក។

ការប្រើប្រាស់ និងទំនួលខុសត្រូវ

បច្ចេកវិទ្យាឌីជីថលធ្វើឱ្យជីវិតកាន់តែងាយស្រួល ប៉ុន្តែយើងត្រូវតែមានការប្រុងប្រយ័ត្នដើម្បីចៀសវាងហានិភ័យផ្សេងៗ។ សព្វថ្ងៃនេះ អ្នកប្រើប្រាស់បច្ចេកវិទ្យាឌីជីថលត្រូវយល់ដឹងថា ព័ត៌មានអ្វីខ្លះអាចដាក់លើអនឡាញបាន ហើយព័ត៌មានអ្វីខ្លះគួររក្សាទុកជាឯកជន របៀបបែងចែករវាងព័ត៌មានដែលអាចទុកចិត្តបាននិងព័ត៌មានក្លែងក្លាយ ព្រមទាំងចេះរក្សាតុល្យភាពឱ្យបានល្អរវាងជីវិតលើអនឡាញ និងជីវិតខាងក្រៅ។

ខ. ទម្រង់នៃប្រព័ន្ធផ្សព្វផ្សាយ

ប្រព័ន្ធផ្សព្វផ្សាយសំដៅលើបណ្តុំនៃបណ្តាញទំនាក់ទំនងផ្សេងៗ រួមមាន កាសែត វិទ្យុ ទូរទស្សន៍ និងមធ្យោបាយផ្សព្វផ្សាយដទៃទៀត ដែលត្រូវបានប្រើប្រាស់សម្រាប់ចែករំលែកព័ត៌មាននិងការកម្សាន្តនៅក្នុងសង្គម។

ជាទូទៅប្រព័ន្ធផ្សព្វផ្សាយត្រូវបានប្រើដើម្បីបញ្ជូនសាររវាងមនុស្សពីរឬច្រើននាក់។ សារទាំងនេះ ត្រូវបានផ្លាស់ប្តូរពីមនុស្សម្នាក់ទៅម្នាក់ទៀត ដោយឆ្លងកាត់មធ្យោបាយទាក់ទងនានា ដូចជា សំបុត្រ កម្មវិធីវិទ្យុ អ៊ីមែល ឬផ្ទាំងប៉ាណូពាណិជ្ជកម្ម។ អ្នកបង្កើតមាតិកា ជាអ្នកបង្កើតសារទាំងនេះឡើង ដើម្បីបញ្ជូនទៅកាន់ភាគីម្ខាងទៀត ជាជនគោលដៅ ដែលសារប្រភេទនេះហៅថា សារប្រព័ន្ធផ្សព្វផ្សាយ។



រូបភាព ២.២ ទម្រង់នៃប្រព័ន្ធផ្សព្វផ្សាយ

ការយល់ដឹងអំពីប្រព័ន្ធផ្សព្វផ្សាយ និងឧទាហរណ៍ខ្លះៗ

ប្រព័ន្ធផ្សព្វផ្សាយបានលេចចេញរូបរាងដំបូងជាមួយនឹងការបង្កើតភាសាសរសេរ។ ដំបូងឡើយមនុស្សរៀនសរសេរ និងចម្លងសារពីកន្លែងមួយទៅកន្លែងមួយ។ បច្ចុប្បន្នប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពរួមមាន៖

- សេចក្តីប្រកាស និងសេចក្តីជូនដំណឹង
- កាសែត និងទស្សនាវដ្តី
- សំបុត្រ
- សៀវភៅ សៀវភៅរូបភាព សៀវភៅគំនូរ។

នៅសតវត្សរ៍ទី២០មនុស្សបានចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក។ បច្ចេកវិទ្យានេះបានរីកសាយភាយយ៉ាងឆាប់រហ័សរួមមាន៖

- វិទ្យុ
- ទូរទស្សន៍ និងភាពយន្ត
- កុំព្យូទ័រ និងអ៊ីនធឺណិត
- វីដេអូហ្គេម
- តន្ត្រីដែលបានថតទុក
- ទូរសព្ទដៃ
- ឧបករណ៍អានសៀវភៅអេឡិចត្រូនិក។

យើងអាចបែងចែកប្រព័ន្ធផ្សព្វផ្សាយទាំងនេះជា៤ ប្រភេទគឺ៖ **ការបោះពុម្ព រូបភាព សំឡេង និង ឌីជីថល៖**

- **ការបោះពុម្ព៖** សៀវភៅ កាសែត ទស្សនាវដ្តី
- **រូបភាព៖** ភាពយន្ត ទូរទស្សន៍ រូបថត គំនូរ
- **សំឡេង៖** វិទ្យុ តន្ត្រីថតទុក ស៊ីឌី ឯកសារសំឡេង
- **ឌីជីថល៖** អ៊ីនធឺណិត អ៊ីមែល វីដេអូហ្គេម បណ្តាញផ្សព្វផ្សាយសង្គម។

ការបែងចែកប្រភេទនេះ គឺគ្រាន់តែដើម្បីភាពងាយស្រួលប៉ុណ្ណោះ រីឯទម្រង់ប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត អាចត្រូវបានចាត់ថ្នាក់ខុសពីនេះផងដែរ។

ចំណុចសំខាន់ៗទាំង៥ សម្រាប់យល់ដឹងអំពីប្រព័ន្ធផ្សព្វផ្សាយ៖

១. ម្ចាស់ស្នាដៃនិពន្ធ៖ គ្រប់សារនៃប្រព័ន្ធផ្សព្វផ្សាយទាំងអស់ សុទ្ធតែត្រូវបានបង្កើតឡើងដោយនរណាម្នាក់។

២. ទម្រង់៖ សារប្រព័ន្ធផ្សព្វផ្សាយនីមួយៗ ត្រូវបានបង្កើតឡើងដោយប្រើភាសាប្រកបដោយភាពច្នៃប្រឌិត រួមផ្សំជាមួយវិធីសាស្ត្រផ្ទាល់ខ្លួន។

៣. ជនគោលដៅ៖ មនុស្សម្នាក់ៗអាចយល់ន័យ នៃសារតែមួយខុសៗគ្នា ដោយផ្អែកលើចំណេះដឹង និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ។

៤. ខ្លឹមសារ៖ ប្រព័ន្ធផ្សព្វផ្សាយតែងតែបង្កប់នូវគុណតម្លៃ និងការយល់ឃើញរបស់មនុស្ស។

៥. គោលបំណង៖ ប្រព័ន្ធផ្សព្វផ្សាយភាគច្រើន បង្កើតឡើងដើម្បីរកប្រាក់ចំណេញ ឬអត្ថប្រយោជន៍ណាមួយ។

យើងអាចវិភាគនិងស្វែងយល់ពីទិដ្ឋភាពសំខាន់ៗទាំង៥ នៃប្រព័ន្ធផ្សព្វផ្សាយណាមួយបាន ដោយឆ្លើយសំណួរទាំង៥ ខាងក្រោម៖

១. តើនរណាជាអ្នកបង្កើតសារប្រព័ន្ធផ្សព្វផ្សាយនេះ? (ម្ចាស់ស្នាដៃនិពន្ធ)

២. តើបច្ចេកទេសច្នៃប្រឌិតអ្វីខ្លះ ត្រូវបានប្រើដើម្បីទាក់ទាញចំណាប់អារម្មណ៍? (ទម្រង់)

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

៣. តើអ្នកដទៃផ្សេងទៀត អាចយល់ឃើញអំពីសារនេះយ៉ាងដូចម្តេច? (ជនគោលដៅ)

៤. តើរបៀបរស់នៅ គុណតម្លៃ និងទស្សនៈអ្វីខ្លះដែលត្រូវបាន ឬមិនត្រូវបានដាក់បញ្ចូលនៅក្នុងសារនេះ? (ខ្លឹមសារ)

៥. ហេតុអ្វីបានជាគេផ្សព្វផ្សាយសារនេះឡើង? (គោលបំណង)



រូបភាព ២.៣ មធ្យោបាយទទួលព័ត៌មាន

នៅពេលដែលយើងអាចឆ្លើយសំណួរទាំងនេះបានយើងនឹងយល់កាន់តែច្បាស់ និងស៊ីជម្រៅពីខ្លឹមសារនៃប្រព័ន្ធផ្សព្វផ្សាយនីមួយៗ។

គ. ទម្រង់ និងលក្ខណៈសម្គាល់របស់ប្រព័ន្ធផ្សព្វផ្សាយ

កាសែត និងទស្សនាវដ្តី



រូបភាព ២.៤ ការទទួលព័ត៌មានតាមកាសែត

ជាទូទៅកាសែត និងទស្សនាវដ្តី ជាការបោះពុម្ពផ្សាយលើក្រដាស ដែលមិនមែនជាប្រភេទប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិកឡើយ។ នាពេលបច្ចុប្បន្នកាសែត និងទស្សនាវដ្តីភាគច្រើន ក៏បានផ្សាយតាមប្រព័ន្ធអនឡាញផងដែរ។ ប្រភពថវិកាគាំទ្រអាចបានមកពីក្រុមហ៊ុន បុគ្គលឯកជន និងជួនកាលពីរដ្ឋាភិបាល។ ស្ថាប័នផ្តល់ថវិកាទាំងនោះ មិនមានសិទ្ធិគ្រប់គ្រងខ្លឹមសារព័ត៌មានដោយផ្ទាល់ឡើយ ដែលកត្តានេះអនុញ្ញាតឱ្យស្ថាប័នព័ត៌មាន រក្សាបាននូវឯករាជ្យភាពក្នុងការរាយការណ៍អំពីបញ្ហាជាក់លាក់នានាជូនសហគមន៍។

អ្នកផលិតមាតិកាផ្សព្វផ្សាយរួមមាន អ្នកសារព័ត៌មាន អ្នកថតរូប អ្នកកែសម្រួល និពន្ធនាយក អ្នករចនា អ្នកបោះពុម្ព និងអ្នកផ្សព្វផ្សាយខ្លឹមសារនៅលើអនឡាញ។ ក្រុមការងារទាំងនេះប្រើប្រាស់ចំណងជើង អត្ថបទ រូបគំនូរ និងរូបថតដើម្បីបង្ហាញសាររបស់ខ្លួន។ ជាទូទៅប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពមានការចេញផ្សាយតាមកាលវិភាគទៀងទាត់ ដូចជា ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ឬប្រចាំខែ។ ដំណើរការផលិតសម្រាប់ការចេញផ្សាយមួយលេខៗ អាចចំណាយពេលពីមួយថ្ងៃទៅមួយខែ។

ការចេញផ្សាយញឹកញាប់ជួយឱ្យស្ថាប័នព័ត៌មាន អាចផ្សព្វផ្សាយព្រឹត្តិការណ៍នានាបានជាបន្តបន្ទាប់។ ប្រាក់ចំណូលរបស់ស្ថាប័នទាំងនេះបានមកពីការលក់ការជាវជាប្រចាំ និងការផ្សាយពាណិជ្ជកម្ម។

សៀវភៅ

សៀវភៅភាគច្រើន បោះពុម្ពផ្សាយនៅលើក្រដាស ហើយទម្រង់នេះមិនត្រូវបានចាត់ទុកថា ជាការផ្សព្វផ្សាយអេឡិចត្រូនិកឡើយ។ ទោះជាយ៉ាងណា សៀវភៅមួយចំនួន ក៏មានទម្រង់ជាសៀវភៅអេឡិចត្រូនិក ដែលយើងអាចអាននៅលើកុំព្យូទ័រ ថាប្លេត ឬឧបករណ៍អានសៀវភៅអេឡិចត្រូនិកផងដែរ។

ស្ថាប័ន ឬក្រុមហ៊ុនបោះពុម្ពផ្សាយភាគច្រើនដើរតួជាអ្នកចែកចាយសៀវភៅ។ អ្នកនិពន្ធ អ្នកគូររូបភាព អ្នកបោះពុម្ពផ្សាយ និងរោងពុម្ព ឬអ្នកអភិវឌ្ឍន៍កម្មវិធីសម្រាប់សៀវភៅអេឡិចត្រូនិក ជាអ្នកទទួលខុសត្រូវក្នុងការផលិតសៀវភៅ។ សារផ្សព្វផ្សាយត្រូវបានបញ្ជូនទៅកាន់អ្នកអានតាមរយៈក្របសៀវភៅ និងអត្ថបទ ខ្លឹមសារជារូបភាពនៅខាងក្នុង។



រូបភាព ២.៥ ការទទួលព័ត៌មានតាមសៀវភៅ

គេអាចចាត់ថ្នាក់សៀវភៅ ទៅតាមខ្លឹមសាររបស់វា។ ឧទាហរណ៍៖ អក្សរសិល្ប៍ សៀវភៅមិនមែនប្រលោមលោក រឿងប្រលោមលោក សៀវភៅណែនាំ សៀវភៅជំនាញ ឬសៀវភៅសិក្សាផ្សេងៗ។ ការផលិតសៀវភៅមួយក្បាលៗ អាចចំណាយពេលពីច្រើនខែរហូតដល់ច្រើនឆ្នាំ។ ប្រាក់ចំណូលចម្បង គឺបានមកពីការលក់សៀវភៅ។ ដើម្បីជំរុញការលក់ អ្នកបោះពុម្ពផ្សាយតែងតែវិនិយោគលើការផ្សាយពាណិជ្ជកម្មតាមរយៈកាសែត វិទ្យុ ទូរទស្សន៍ ផ្ទាំងប៉ាណូ វេបសាយ ឬបណ្តាញសង្គមនានា។

វិទ្យុ និងផតខាស់

វិទ្យុគឺជាការផ្សព្វផ្សាយតាមអេឡិចត្រូនិក ហើយសព្វថ្ងៃនេះ ស្ថានីយវិទ្យុជាច្រើនក៏ធ្វើការផ្សាយតាមរយៈអ៊ីនធឺណិតផងដែរ។ ស្ថានីយវិទ្យុភាគច្រើន ដំណើរការដោយក្រុមហ៊ុនឯកជន ឬរដ្ឋាភិបាល។ អ្នកផលិតការផ្សព្វផ្សាយសម្រាប់វិទ្យុរួមមាន អ្នកយកព័ត៌មាន ពិធីករ អ្នកសម្របសម្រួលកម្មវិធី អ្នកសរសេរអត្ថបទ អ្នកកែសម្រួល និងអ្នកដឹកនាំផ្នែកតន្ត្រី។ កម្មវិធីវិទ្យុមួយអាចធ្វើការផ្សាយផ្ទាល់ដោយត្រូវការមនុស្សត្រឹមតែពីរ ឬបីនាក់ប៉ុណ្ណោះ។



រូបភាព ២.៦ ការទទួលព័ត៌មានតាមវិទ្យុ

កម្មវិធីវិទ្យុជាច្រើនត្រូវបានផលិតទុកជាមុន មុនពេលធ្វើការផ្សាយចេញហើយអ្នកសម្របសម្រួលកម្មវិធីទទួលបានព័ត៌មានពីអ្នកយកព័ត៌មានរបស់ពួកគេ។ ខ្លឹមសារនៃការផ្សព្វផ្សាយត្រូវបានបញ្ជូនតាមរយៈភាសានិយាយ តន្ត្រី កម្មវិធីព័ត៌មាន និងកម្មវិធីកម្សាន្ត។ ពេលវេលាដែលត្រូវការដើម្បីផលិតកម្មវិធីផ្សាយមួយអាចមានរយៈពេលចាប់ពីច្រើននាទីទៅច្រើនសប្តាហ៍ ឬយូរជាងនេះ អាស្រ័យលើប្រភេទកម្មវិធីនិងប្រធានបទ។ ប្រភពចំណូលចម្បងសម្រាប់ស្ថានីយវិទ្យុ បានមកពីការផ្សាយពាណិជ្ជកម្មអំឡុងពេលម៉ោងផ្សាយ។ ស្ថានីយវិទ្យុមួយចំនួនក៏រកចំណូលបានពីម្ចាស់ស្ថានីយ ឬថ្លៃសេវាជារំពីអ្នកស្តាប់ ហើយស្ថានីយវិទ្យុសហគមន៍មួយចំនួនទទួលបានថវិកាតាមរយៈការបរិច្ចាគពីសប្បុរសជនដែរ។ ស្ថានីយដែលគ្រប់គ្រងដោយរដ្ឋជាធម្មតាទទួលបានថវិកាពីរដ្ឋាភិបាល។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ផតខាស់គឺជាទម្រង់ឯកសារសំឡេងមួយប្រភេទទៀត ដែលបានលេចឡើងនៅដើមសតវត្សរ៍ទី២១ ទោះបីជាវាទើបតែទទួលបានការពេញនិយមយ៉ាងទូលំទូលាយចាប់ពីឆ្នាំ២០១៥ក៏ដោយ។ វាជាកម្មវិធីសំឡេងដែលគេអាចផលិត និងចែកចាយតាមរយៈអ៊ីនធឺណិត។ ការផលិតផតខាស់គឺសាមញ្ញ និងមានភាពងាយស្រួលណាស់ ដោយគ្រាន់តែត្រូវការទូរសព្ទដែលមានមុខងារថតសំឡេង និងភ្ជាប់អ៊ីនធឺណិតតែប៉ុណ្ណោះ។ អ្នកផលិតគ្រាន់តែថត កែសម្រួល និងបង្ហោះឯកសារសំឡេងទៅកាន់សេវាកម្មផតខាស់ បន្ទាប់មកភ្ជាក់ងារនោះនឹងចែកចាយវាបន្តទៅកាន់កម្មវិធីផតខាស់នានាដូចជា Spotify Apple Podcasts និង YouTube ជាដើម។ ស្របពេលដែលទម្រង់នេះកាន់តែទទួលបានការពេញនិយម ស្ថានីយវិទ្យុជាច្រើនក៏បានចាប់ផ្តើមចែកចាយការផ្សាយរបស់ខ្លួនជាទម្រង់ផតខាស់ផងដែរ។

ដោយសារភាពងាយស្រួលក្នុងការផលិត គេអាចស្វែងរកផតខាស់រាប់លាន ដែលគ្របដណ្តប់ស្ទើរតែគ្រប់ប្រធានបទ។ ផតខាស់ខ្លះជាកម្មវិធីសាមញ្ញៗដែលមិត្តភក្តិជជែកគ្នាលេង ខ្លះទៀតជាបទសម្ភាស ឬកិច្ចពិភាក្សាជាក្រុម ចំណែកខ្លះទៀតជាកម្មវិធីនិទានរឿងប្រលោមលោក ឬរឿងពិត ដែលគេផលិតឡើងយ៉ាងសម្រិតសម្រាំងតាមរយៈសំឡេង។ បច្ចុប្បន្ន មានក្រុមហ៊ុនផលិតផតខាស់អាជីពជាច្រើននៅទូទាំងពិភពលោក ប៉ុន្តែលក្ខណៈដ៏ទាក់ទាញបំផុតនៃប្រព័ន្ធផ្សព្វផ្សាយនេះ គឺភាពងាយស្រួលក្នុងការផលិតនេះឯង។ ផតខាស់ផ្តល់ឱកាសឱ្យអ្នកដែលគ្មានធនធាន ឬគ្មានការគាំទ្រពីស្ថាប័នផ្សព្វផ្សាយអាចផលិតកម្មវិធីផ្ទាល់ខ្លួនបាន។

ចំណែកឯវីដេអូផតខាស់គឺជាការវិវត្តចេញពីផតខាស់សំឡេង ដោយបន្ថែមរូបភាពជាធាតុផ្សំ។ វីដេអូផតខាស់ភាគច្រើន បង្ហាញសកម្មភាពអ្នកផលិត និងភ្ញៀវកិត្តិយសនិយាយទៅកាន់មីក្រូហ្វូន ហើយជួនកាលក៏មានបង្ហាញព័ត៌មានជារូបភាពផ្សេងៗទៀតផងដែរ។ ភាពពេញនិយមនៃវីដេអូផតខាស់ធ្វើឱ្យគេកាន់តែពិបាកបែងចែកឱ្យដាច់រវាងផតខាស់ និងវីដេអូ YouTube ឬ Vlog។

កុន ឬភាពយន្ត

ភាពយន្តគឺជាទម្រង់នៃប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក។ ដំបូងឡើយភាពយន្តត្រូវបានចាក់បញ្ចាំងនៅក្នុងរោងភាពយន្តសាធារណៈហើយក្រោយមកត្រូវបានបញ្ចេញជាទម្រង់ថាសដោយឡែកបច្ចុប្បន្នវាមាននៅលើប្រព័ន្ធឌីជីថល ដូចជា Netflix និងទីតាំងផ្សេងទៀតនៅលើអនឡាញជាដើម។

ការចំណាយលើការផលិតភាពយន្តមានទំហំខុសៗគ្នា និងមានភាពស្មុគស្មាញ។ មុនពេលចាប់ផ្តើមផលិត អ្នកនិពន្ធ និងអ្នកដឹកនាំរឿង ត្រូវស្វែងរកអ្នកផ្តល់ទុនសម្រាប់ការផលិត។ ទំហំទឹកប្រាក់ដែលត្រូវការ គឺអាស្រ័យលើសាច់រឿង ប៉ុន្តែជាទូទៅ ការចំណាយមានកម្រិតខ្ពស់ណាស់។ ភាគច្រើនការផលិតភាពយន្ត តែងមានការចូលរួមសហហិរញ្ញប្បទានពីស្ថានីយទូរទស្សន៍ ឬក្រុមហ៊ុនធំៗ ដែលចង់បញ្ចូលការផ្សព្វផ្សាយផលិតផលរបស់ខ្លួនទៅក្នុងខ្សែភាពយន្តនោះ។ ឧទាហរណ៍៖ ប្រសិនបើតួអង្គជិះរថយន្តម៉ាក Mercedes ឬ BMW នោះវាប្រៀបដូចជាការផ្សាយពាណិជ្ជកម្មដោយប្រយោល ឱ្យក្រុមហ៊ុនរថយន្តទាំងនោះយ៉ាងដូច្នោះដែរ។

ចំនួនអ្នកពាក់ព័ន្ធក្នុងការផលិតភាពយន្តមួយរឿងៗ អាចមានចាប់ពីរាប់រយដល់រាប់ពាន់នាក់។ សមាសភាពទាំងនោះរួមមាន អ្នកដឹកនាំរឿង សហអ្នកដឹកនាំរឿង អ្នកនិពន្ធ តួសម្តែង បច្ចេកទេសសំឡេង អ្នករចនាសំលៀកបំពាក់ អ្នកស្វែងរកទីតាំងថត តួជំនួសក្នុងឈុតគ្រោះថ្នាក់ អ្នកបញ្ជាកាមេរ៉ា និងអ្នកកែសម្រួលបច្ចេកទេសជាច្រើនរូបទៀត។



រូបភាព ២.៧ ការទទួលព័ត៌មានតាមភាពយន្ត

ការរចនាឆាក សំលៀកបំពាក់ តួអង្គ បច្ចេកទេសរូបភាព និងការកែច្នៃបន្ថែម (ពន្លឺ កម្រិតភ្លឺ ភាពងងឹត និងពណ៌) សំឡេង (សំឡេងនិយាយ ឬសំឡេងបរិយាកាស) ព្រមទាំងបច្ចេកទេសកាត់ត។ ការផលិតភាពយន្តមួយរឿងៗ អាចចំណាយពេលពីច្រើនខែរហូតដល់ច្រើនឆ្នាំ។

ប្រាក់ចំណូល បានមកពីក្រុមហ៊ុនដែលផ្តល់ទុនផលិត ការលក់សំបុត្រ ការលក់ថាស ទំនិញពាក់ព័ន្ធនឹងភាពយន្ត កម្រៃសិទ្ធិផ្សាយពីស្ថានីយទូរទស្សន៍ និងការទិញសិទ្ធិទស្សនាតាមអនឡាញ។ ដើម្បីបង្កើនការលក់សំបុត្រ និងទាក់ទាញអ្នកទស្សនាឱ្យកាន់តែច្រើន ជាទូទៅអ្នកផលិតភាពយន្តតែងតែវិនិយោគទុនយ៉ាងសន្ធឹកសន្ធាប់ លើការផ្សាយពាណិជ្ជកម្ម ដូចជាវីដេអូខ្លីៗតាមរោងកុន ខិត្តប័ណ្ណ និងពាណិជ្ជកម្មតាមទូរទស្សន៍។

ទូរទស្សន៍

ទូរទស្សន៍គឺជាប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក ដែលក្រោយពេលចាក់ផ្សាយរួច គេតែងតែបង្ហោះកម្មវិធីទូរទស្សន៍ជាច្រើនទៅលើអ៊ីនធឺណិតបន្តទៀត។ ស្ថានីយទូរទស្សន៍ អាចរកប្រាក់ចំណូលបានពីអ្នកទស្សនា ក្រុមហ៊ុនឬបុគ្គលឯកជន។ សមាសភាពពាក់ព័ន្ធក្នុងការផលិតកម្មវិធីទូរទស្សន៍រួមមាន៖ អ្នកដឹកនាំកម្មវិធី ពិធីករផ្សាយផ្ទាល់ អ្នកបញ្ជាកាមេរ៉ា បច្ចេកទេសសំឡេង អ្នកកាត់ត អ្នកបញ្ជាបច្ចេកទេសផ្សាយ អ្នករចនាឆាក តួសម្តែង តារាល្បីៗ អ្នកនយោបាយ និងតន្ត្រីករ ជាដើម។



រូបភាពទី ២.៨ ការទទួលព័ត៌មានតាមទូរទស្សន៍

ការផលិតកម្មវិធីទូរទស្សន៍មួយៗ អាចចំណាយពេលខុសៗគ្នាចាប់ពី២-៣ម៉ោង រហូតដល់រាប់ខែ អាស្រ័យលើកម្មវិធីព័ត៌មានឬកម្មវិធីកម្សាន្ត។

ប្រាក់ចំណូលភាគច្រើនបានមកពីការលក់ម៉ោងផ្សាយពាណិជ្ជកម្ម។ ប្រសិនបើក្រុមហ៊ុន ឬបុគ្គលណាម្នាក់វិនិយោគទុនគាំទ្រស្ថានីយទូរទស្សន៍ណាមួយ អ្នកវិនិយោគទាំងនោះតែងតែចង់ឱ្យមានការផ្សព្វផ្សាយប្រធានបទឬសារដែលស្របទៅតាមប្រធានបទ និងចក្ខុវិស័យរបស់ខ្លួន។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

វីដេអូហ្គេម



រូបភាព ២.៩ ការទទួលព័ត៌មានតាមលេងហ្គេម

វីដេអូហ្គេមគឺជាប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក ដែលអាចលេងកម្សាន្ត នៅលើម៉ាស៊ីនហ្គេម កុំព្យូទ័រ ឬទូរសព្ទដៃ។ សមាសភាពពាក់ព័ន្ធក្នុងការបង្កើតហ្គេមរួមមាន៖ អ្នកដឹកនាំផ្នែកសិល្បៈ អ្នករចនាក្រាហ្វិក អ្នកសរសេរកូដ អ្នករចនាកម្រិតហ្គេម អ្នកនិពន្ធសាច់រឿង អ្នកជំនាញសំឡេង និងអ្នកសរសេរស្គ្រីប។

ខ្លឹមសារវីដេអូហ្គេម ត្រូវបានបញ្ជូនទៅកាន់អ្នកលេងតាមរយៈប្រភេទហ្គេម កម្រិតហ្គេម សាច់រឿង តួអង្គ របៀបដែលអ្នកលេងធ្វើអន្តរកម្មជាមួយហ្គេម គោលបំណងនៃហ្គេម ភាសាដែលប្រើប្រាស់ ព្រមទាំងគុណភាពសំឡេង និងក្រាហ្វិក។ ការអភិវឌ្ឍហ្គេមមួយៗ អាចចំណាយពេលរាប់សប្តាហ៍ រហូតដល់រាប់ឆ្នាំ។ ចំណែកឯប្រាក់ចំណូល បានមកពីការលក់ហ្គេម ការផ្សាយពាណិជ្ជកម្មមុនពេល ឬអំឡុងពេលលេង និងការលក់ទំនិញពាក់ព័ន្ធនឹងហ្គេម។

អ៊ីនធឺណិត



រូបភាព ២.១០ ការទទួលព័ត៌មានតាមអ៊ីនធឺណិត

អ៊ីនធឺណិតគឺជាប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក ដែលអាចចូលប្រើប្រាស់រាបានតាមរយៈឧបករណ៍ ដូចជា ថាប្លេត កុំព្យូទ័រ ទូរសព្ទដៃ ម៉ាស៊ីនហ្គេម និងឧបករណ៍អានសៀវភៅអេឡិចត្រូនិក។ ទោះជាយ៉ាងណាក៏ដោយ ទាំងក្រុមហ៊ុន រដ្ឋាភិបាល និងបុគ្គលឯកជន តែងតែមានវត្តមាននៅលើអ៊ីនធឺណិត។ ម្យ៉ាងទៀតក្រុមហ៊ុនដ៏មានឥទ្ធិពលបំផុតមួយចំនួននៅលើពិភពលោក គឺជាក្រុមហ៊ុនផ្តល់សេវាថ្នាលនិងឧបករណ៍អ៊ីនធឺណិត ដូចជា YouTube Facebook និង Google ជាដើម។

សមាសភាពពាក់ព័ន្ធ ក្នុងការបង្កើតមាតិកាលើអ៊ីនធឺណិត រួមមាន៖ អ្នកសរសេរកូដ អ្នករចនាវេបសាយ អ្នកឯកទេសបច្ចេកវិទ្យាព័ត៌មាន អ្នកនិពន្ធ អ្នកសារព័ត៌មាន ប្រជាពលរដ្ឋទូទៅ និងអ្នកផលិតមាតិកាដទៃទៀត។

មាតិកានៅលើអ៊ីនធឺណិតត្រូវបានបញ្ជូនទៅកាន់អ្នកប្រើប្រាស់តាមរយៈ អត្ថបទ ចំណងជើង រូបភាព វីដេអូ សំឡេង គំនូរជីវចល ។ល។ ការបង្កើតមាតិកាលើអ៊ីនធឺណិតអាចចំណាយពេលខុសៗគ្នាអាស្រ័យលើប្រភេទមាតិកា ដែលអាចប្រើពេលត្រឹម២-៣នាទី រហូតដល់យូរជាងនេះ។ ប្រាក់ចំណូលបានមកតាមវិធីផ្សេងៗ តែភាគច្រើនតាមរយៈការផ្សាយពាណិជ្ជកម្ម។ មាតិកាជាច្រើននៅលើវេបសាយទាំងនេះ មិនបានបង្កើតប្រាក់ចំណូលដោយផ្ទាល់ឡើយ ប៉ុន្តែវាមានគោលបំណងផ្តល់ព័ត៌មាន ចែករំលែកគំនិត បង្ហាញមតិ និងអារម្មណ៍ផ្ទាល់ខ្លួនព្រមទាំងដើម្បីទាក់ទាញមហាជនថ្មីៗ។

បណ្តាញផ្សព្វផ្សាយសង្គម



រូបភាព ២.១១ បណ្តាញផ្សព្វផ្សាយសង្គម

បណ្តាញផ្សព្វផ្សាយសង្គម ជាប្រភេទប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិកនៅលើអ៊ីនធឺណិត ដែលអាចចូលប្រើបានតាមរយៈកុំព្យូទ័រ ថាប្លេត និងទូរសព្ទដៃ។ វេទិកាបណ្តាញផ្សព្វផ្សាយសង្គមធំៗមួយចំនួនមានដូចជា Facebook TikTok Instagram ជាដើម។ Facebook ជាសេវាកម្មបណ្តាញសង្គមមួយក្នុងចំណោមសេវាកម្មជាច្រើនត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៤ ដោយលោក Mark Zuckerberg ដែលកាលនោះមានអាយុត្រឹមតែ២០ឆ្នាំប៉ុណ្ណោះ ដោយមានការចូលរួមចំណែកពីបុគ្គលផ្សេងទៀត។ សព្វថ្ងៃនេះ Facebook ត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនMeta។ មនុស្សដែលពាក់ព័ន្ធក្នុងការបង្កើតប្រព័ន្ធផ្សព្វផ្សាយប្រភេទនេះរួមមាន អ្នកសរសេរកូដ អ្នករចនាវេបសាយ អ្នកឯកទេស IT និងអ្នកប្រើប្រាស់រាប់លាននាក់ ធម្មតាជាបុគ្គល ក្រុមហ៊ុន ឬក្រុមដែលបង្កើត និងចែករំលែកមាតិកា។ សារនៅលើបណ្តាញផ្សព្វផ្សាយសង្គមត្រូវបានចែករំលែកតាមរយៈ អត្ថបទ រូបភាព ក្រាហ្វិក និងវីដេអូ។ ការបង្កើតមាតិកាអាចចំណាយពេល ចាប់ពី២-៣និទាទី រហូតដល់ច្រើនម៉ោង។

ប្រាក់ចំណូលសម្រាប់ការសរសេរកូដ និងការគ្រប់គ្រងវេទិកាបណ្តាញផ្សព្វផ្សាយសង្គមអាចបានមកពីការផ្សាយពាណិជ្ជកម្មតាមអនឡាញ ការលក់ទិន្នន័យអ្នកប្រើប្រាស់ទៅឱ្យក្រុមហ៊ុន អង្គការ ឬរដ្ឋាភិបាលដែលចង់ទិញព័ត៌មាននេះ។ អ្នកប្រើប្រាស់ភាគច្រើន មិនទទួលបានប្រាក់ចំណូលពីការបង្កើតមាតិការបស់ពួកគេទេ លើកលែងតែអ្នកសរសេរ Blog ឬអ្នកបង្កើតវីដេអូ Vlog ដែលអាចបង្កើតប្រាក់ចំណូលតាមរយៈការផ្សាយពាណិជ្ជកម្ម ឬពីក្រុមហ៊ុនដែលបង់ប្រាក់ ដើម្បីផ្សព្វផ្សាយផលិតផលរបស់ពួកគេ នៅក្នុងវីដេអូរបស់អ្នកបង្កើតមាតិកាទាំងនោះ។

មេរៀនសង្ខេប

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីចំណុចសំខាន់ៗដូចខាងក្រោម៖

- ប្រព័ន្ធផ្សព្វផ្សាយ សំដៅលើបណ្តុំនៃបណ្តាញប្រាស្រ័យទាក់ទងផ្សេងៗគ្នា រួមមានកាសែត វិទ្យុ ទូរទស្សន៍ និងវេទិកាប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត ដែលត្រូវបានប្រើសម្រាប់ចែករំលែកព័ត៌មាន និងការកម្សាន្ត។
- ការបញ្ជូនសារ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ មានភាគីម្ខាងដែលផ្ញើសារ (ហៅថាអ្នកបង្កើត ឬអ្នកផលិតមាតិកា) និងភាគីម្ខាងទៀតដែលទទួលសារ (ហៅថាមហាជន ឬសាធារណជន)។ សារទាំងនេះត្រូវបានហៅថាជា សារប្រព័ន្ធផ្សព្វផ្សាយ។
- ប្រព័ន្ធផ្សព្វផ្សាយ អាចបែងចែកជា៤ ប្រភេទធំៗ គឺ៖ ការបោះពុម្ព រូបភាព សំឡេង និងឌីជីថល។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

- ដើម្បីទទួលបានការយល់ដឹងស៊ីជម្រៅអំពីប្រព័ន្ធផ្សព្វផ្សាយ យើងគួរពិចារណាលើចំណុចសំខាន់ៗចំនួន៥៖
  - តើនរណាជាអ្នកបង្កើតសារ?
  - តើពួកគេបានប្រើបច្ចេកទេសអ្វីខ្លះដើម្បីបង្កើតសារនេះ?
  - តើមហាជនជនផ្សេងគ្នាអាចយល់ឃើញសារនេះខុសគ្នាដោយរបៀបណា?
  - តើអ្វីខ្លះជាគុណតម្លៃ និងទស្សនៈរបស់សារមួយ?
  - តើអ្វីជាគោលបំណងរបស់សារនោះ?

សទ្ធានុក្រម

- **ប្រព័ន្ធផ្សព្វផ្សាយឌីជីថល៖** ថ្នាលអនឡាញដូចជា បណ្តាញផ្សព្វផ្សាយសង្គម កម្មវិធី (Apps) និងវេបសាយ។
- **ជំនាញឌីជីថល៖** សមត្ថភាពក្នុងការប្រើប្រាស់កុំព្យូទ័រ និងឧបករណ៍ថ្នាលឌីជីថល។
- **សារប្រព័ន្ធផ្សព្វផ្សាយ៖** សំដៅលើគំនិតដែលត្រូវបានធ្វើការប្រាស្រ័យទាក់ទងតាមរយៈមធ្យោបាយណាមួយ។ វាអាចជាអត្ថបទ រូបភាព វីដេអូ ការបង្ហោះលើបណ្តាញសង្គម ។ល។
- **ក្រុមជនគោលដៅ៖** សំដៅក្រុមមនុស្សដែលអ្នកបង្កើតសារប្រព័ន្ធផ្សព្វផ្សាយ ចង់ឱ្យសាររបស់ខ្លួននោះបានទៅដល់ និងមានភាពពាក់ព័ន្ធជាមួយពួកគេ។
- **ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី៖** សំដៅលើសារព័ត៌មានទម្រង់ចាស់ៗ ដូចជា កាសែត វិទ្យុ និងទូរទស្សន៍។

លំហាត់អនុវត្តន៍

១. ប្រព័ន្ធផ្សព្វផ្សាយនាពេលបច្ចុប្បន្ន៖ ការសង្កេតមើលការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ យើងបែងចែកប្រព័ន្ធផ្សព្វផ្សាយជា៤ប្រភេទ។ សូមពិនិត្យមើលប្រភេទនីមួយៗខាងក្រោម ហើយបន្ថែមឧទាហរណ៍នៃប្រព័ន្ធផ្សព្វផ្សាយដែលត្រូវបានប្រើប្រាស់នៅក្នុងសហគមន៍របស់អ្នក៖

- ការបោះពុម្ពផ្សាយ៖ សៀវភៅ កាសែត ទស្សនាវដ្តី
- ប្រព័ន្ធផ្សព្វផ្សាយទស្សនីយភាព៖ ភាពយន្ត ទូរទស្សន៍ រូបថត រូបភាព
- ប្រព័ន្ធផ្សព្វផ្សាយជាសំឡេង៖ វិទ្យុ តន្ត្រី ឯកសារសម្លេង ផតខាស់
- ប្រព័ន្ធផ្សព្វផ្សាយឌីជីថល៖ អ៊ីនធឺណិត អ៊ីមែល ហ្គេមវីដេអូ បណ្តាញសង្គម បញ្ញាសិប្បនិម្មិត

សូមកត់ចំណាំថា តើប្រភេទណាខ្លះដែលត្រូវបានប្រើប្រាស់ច្រើនជាងគេ និងប្រភេទណាខ្លះដែលត្រូវបានប្រើប្រាស់តិចជាងគេ។ រួចពន្យល់មូលហេតុដែលអ្នកគិតថាវាមានសភាពបែបនេះ។

២. ប្រព័ន្ធផ្សព្វផ្សាយដ៏ពេញនិយម៖

សូមកំណត់ប្រព័ន្ធផ្សព្វផ្សាយដែលកំពុងមានប្រជាប្រិយភាពនៅក្នុងភូមិ ឬស្រុករបស់អ្នក។ សូមសិក្សាស្រាវជ្រាវអំពីវេទិកាទាំងនោះ រួចឆ្លើយនឹងសំណួរខាងក្រោម៖

- តើអ្នកណាជាអ្នកបង្កើតប្រព័ន្ធផ្សព្វផ្សាយនេះ? តើវាបានដំណើរការតាំងពីពេលណាមក?
- តើអ្នកណាជាក្រុមមហាជនគោលដៅនៃវេទិកាប្រព័ន្ធផ្សព្វផ្សាយនេះ?
- តើមានមនុស្សប៉ុន្មាននាក់កំពុងប្រើប្រាស់ថ្នាលផ្សព្វផ្សាយនេះ? ហេតុអ្វីបានជាវាពេញនិយម?
- តើប្រព័ន្ធផ្សព្វផ្សាយនេះផលិតមាតិកាទូទៅ ឬខ្លឹមសារគោលប្រភេទអ្វី?
- តើថ្នាលផ្សព្វផ្សាយនេះបានប្រាក់ចំណូលពីប្រភពណា?
- តើអ្នកទុកចិត្តដែរឬទេ? ហេតុអ្វី?

លំហាត់អនុវត្តន៍ជាមួយឧបករណ៍ | **កម្មវិធី SALA MIL | ជំពូកទី១៖ អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន**

៣. ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន៖ ស្វែងយល់ពីទំនាក់ទំនងរវាងគ្នា

សូមប្រើប្រាស់កម្មវិធីទូរសព្ទ SALA MIL ហើយចូលទៅកាន់ជំពូកទី១ មេរៀនទី១.២៖ អ្វីជាព័ត៌មានប្រព័ន្ធផ្សព្វផ្សាយ? សូមអានដើម្បីស្វែងយល់ឱ្យបានច្បាស់អំពីភាពខុសគ្នារវាងប្រព័ន្ធផ្សព្វផ្សាយ និងដំណឹង។

- ចូររាប់ឈ្មោះព័ត៌មាននានា ដែលអ្នកបានឃើញកាលពីម្សិលមិញ។
- នៅក្បែរចំណុចនីមួយៗ សូមកត់សម្គាល់ថាតើនរណាជាអ្នកបញ្ជូនដំណឹងនោះ។ សូមបែងចែកឱ្យដាច់រវាងបុគ្គល និងប្រព័ន្ធផ្សព្វផ្សាយ។

៤. ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ឬឌីជីថល?

សាកល្បងការយល់ដឹងរបស់អ្នកអំពីភាពខុសគ្នារវាងប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយឌីជីថល៖

- ដោះស្រាយលំហាត់ ដោយប្រើប្រាស់មុខងារអូស និងទម្លាក់ ដើម្បីភ្ជាប់ចំណុចដែលត្រូវគ្នា។
- តើអ្នកទទួលបានពិន្ទុប៉ុន្មាន?
- ហេតុអ្វីបានជាប្រព័ន្ធផ្សព្វផ្សាយឌីជីថលក្លាយជាទីពេញនិយមជាងប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី?
- សូមសរសេររៀបរាប់ពីគុណសម្បត្តិ៣យ៉ាង និងគុណវិបត្តិ៣យ៉ាងនៃសន្ទុះរីកចម្រើននេះ។

សំណួរឬសឹកមេរៀន

១. តើអ្វីទៅជាប្រព័ន្ធផ្សព្វផ្សាយ?

២. តើយើងអាចបែងចែកប្រព័ន្ធផ្សព្វផ្សាយជាប៉ុន្មានប្រភេទ? សូមរៀបរាប់ឈ្មោះ និងផ្តល់ឧទាហរណ៍ជាក់លាក់។

៣. តើចំណុចសំខាន់ៗទាំង៥ សម្រាប់យល់ដឹងស៊ីជម្រៅអំពីប្រព័ន្ធផ្សព្វផ្សាយមានអ្វីខ្លះ? សូមរៀបរាប់អំពីចំណុចទាំងនោះ។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

មេរៀនទី ៣

ដំណឹង និងព័ត៌មាន



មេរៀនទី១.៥ ១.៧ ១.៨



ជំពូកទី២ ទី៤

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

ក. តើដំណឹងជាអ្វី?

ខ. តើអ្វីជាព័ត៌មាន? តើអ្វីជាភាពខុសគ្នារវាងព័ត៌មាន និងដំណឹង?

គ. តើសេចក្តីរាយការណ៍ដំណឹងគួរឆ្លើយសំណួរអ្វីខ្លះ?

ឃ. ហេតុអ្វីបានជាការទទួលបានព័ត៌មានដែលអាចទុកចិត្តបានមានសារៈសំខាន់?

ង. ព័ត៌មានខុស ព័ត៌មានមិនពិត និងព័ត៌មានបង្កឲ្យសនកម្ម

ហេតុអ្វីបានជាមេរៀននេះសំខាន់?

ការយល់ដឹងពីភាពខុសគ្នារវាងដំណឹង និងព័ត៌មាន ជួយយើងឱ្យចេះថ្លឹងថ្លែងនូវអ្វីដែលគួរឱ្យទុកចិត្ត និងអ្វីដែលជាការភូតកុហក។ ទន្ទឹមនឹងនេះ ការយល់ដឹងអំពីក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន នឹងជួយឱ្យយើងមើលឃើញពីសារៈសំខាន់នៃភាពត្រឹមត្រូវនៅក្នុងសង្គម។

ក. តើដំណឹងជាអ្វី?

ដំណឹងគឺជាការបង្ហាញអង្គហេតុអំពីព្រឹត្តិការណ៍ ឬហេតុការណ៍ដែលបានកើតឡើងថ្មីៗ ដែលមានសារៈសំខាន់ និងមានតម្លៃជាដំណឹង។ ឧទាហរណ៍៖ រាជារឿងប្លែកពីគេ ឬពាក់ព័ន្ធបុគ្គលល្បីឈ្មោះ ឬបានកើតឡើងជាលើកដំបូង។ «ស៊ីណេតដុសធ្មេញនៅព្រឹកនេះ» គឺជាហេតុការណ៍ថ្មីៗមែនប៉ុន្តែវាមិនមានតម្លៃជាដំណឹងទេដូច្នេះវាមិនមែនជាដំណឹងឡើយ។ ប៉ុន្តែបើ «ស៊ីណេតឈ្នះការប្រកួតកម្មវិធី Cambodian Idol» នោះគឺជាដំណឹង។

ឧទាហរណ៍៖

- អាកាសធាតុក្តៅខ្លាំងត្រូវបានគេបន្ទោសថាជាមូលហេតុនាំឱ្យមានការផ្ទុះគ្រាប់រំសេវ បណ្តាលឱ្យមានមនុស្សស្លាប់ នៅខេត្តកំពង់ស្ពឺ។
- សារមន្ទីរនៅទីក្រុងញូវយ៉កប្រគល់វត្ថុបុរាណខ្មែរចំនួន១៦ មកកម្ពុជាវិញ។
- កម្ពុជាបើកដំណើរការអាកាសយានដ្ឋានអន្តរជាតិថ្មីនៅសៀមរាប។

អ្នកសារព័ត៌មាន គឺជាអ្នកដែលផលិតសេចក្តីរាយការណ៍ដំណឹងដោយប្រមូលដំណឹង ហើយផ្សៀងផ្គាត់មុននឹងបញ្ជូនទៅកាន់អ្នកអាន អ្នកទស្សនា ឬអ្នកស្តាប់តាមរយៈការបោះពុម្ព ឬមធ្យោបាយផ្សព្វផ្សាយរបស់ពួកគេ។

ដំណឹងដែលមានគុណភាព គឺជាដំណឹងដែលមិនលម្អៀង។ ពោលគឺវាមិនកាន់ជើងខាងណាមួយនៅក្នុងការជជែកដេញដោល ឬទាក់ទងនឹងបញ្ហាណាមួយឡើយ ប៉ុន្តែវាគ្រាន់តែរាយការណ៍អំពីអ្វីដែល បានកើតឡើង និងអត្ថន័យនៃហេតុការណ៍នោះតែប៉ុណ្ណោះ។ អ្នកអាន អ្នកស្តាប់ និងអ្នកទស្សនាគួរពិចារណាឱ្យបានហ្មត់ចត់ថា តើដំណឹងរបស់ពួកគេបានមកពីណា ហេតុអ្វីបានជាគេចែករំលែក និងតើប្រភពនៅពីក្រោយដំណឹងនោះមានភាពជឿជាក់ និងសក្ខានុម័តកម្រិតណា។ ភាពត្រឹមត្រូវមានសារៈសំខាន់ណាស់ សម្រាប់អ្នកសារព័ត៌មានល្អ ហើយពួកគេតែងតែអនុវត្តតាម «វិធានប្រភពពីរ» ដើម្បីផ្សៀងផ្គាត់ភាពត្រឹមរបស់ព័ត៌មាន មុននឹងបោះពុម្ពផ្សាយ។



រូបភាព ៣.១ ប្រភពផ្តល់ដំណឹង

ពួកគេផ្សៀងផ្គាត់ភាពត្រឹមត្រូវរបស់ព័ត៌មាន មួយជាមួយប្រភពពីរផ្សេងគ្នា ដើម្បីមើលថាតើអង្គហេតុស៊ីចង្វាក់គ្នាដែរឬទេ។ ប្រសិនបើមិនស៊ីចង្វាក់គ្នាទេ គេចាំបាច់ត្រូវធ្វើការស្រាវជ្រាវថែមទៀត។

ដើម្បីដឹងថាស្ថាប័នផ្សព្វផ្សាយណាមួយលម្អៀងឬទេ យើងអាចស្រាវជ្រាវមើលថា តើស្ថាប័នទោះស្ថិតក្រោមការគ្រប់គ្រងរបស់សហគ្រិន រដ្ឋាភិបាល ក្រុមហ៊ុនឯកជន ឬជាស្ថាប័នឯករាជ្យ។ ម្ចាស់ស្ថាប័នផ្សព្វផ្សាយឯកជន ច្រើនតែមានរបៀបវារៈផ្ទាល់ខ្លួន ដូចជាការលើកកម្ពស់មតិគាំទ្រស្ថាប័ន ឬក្រុមណាមួយ ដែលខ្លួនចង់ផ្សព្វផ្សាយ។ ចំណែកស្ថាប័នឯករាជ្យ ក៏អាចមានរបៀបវារៈរបស់ខ្លួនដែរ ដូចជាការលាតត្រដាងចំណុចអវិជ្ជមានរបស់ស្ថាប័ន ឬក្រុមណាមួយ ដើម្បីជំរុញឱ្យមានការកែលម្អ។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ទន្ទឹមនឹងនេះយើងគួរពិចារណាថាតើមានកត្តាអ្វីខ្លះដែលជះឥទ្ធិពលលើប្រភពដំណឹងនោះ។ តើគោលដៅចម្បងរបស់ស្ថាប័ននោះ គឺដើម្បីរកប្រាក់ចំណេញ ឬដើម្បីផ្តល់ព័ត៌មានត្រឹមត្រូវដល់សាធារណជន?

ភាពពេញនិយមនៃបណ្តាញសង្គមបានធ្វើឱ្យទិដ្ឋភាពព័ត៌មានកាន់តែស្មុគស្មាញ។ បណ្តាញសង្គមអាចជាប្រភពព័ត៌មានដ៏ល្អ ប៉ុន្តែផ្ទុកនូវព័ត៌មានមិនពិតជាច្រើនផងដែរ ដូចជាពាក្យចចាមអារ៉ាមគ្មានប្រភពច្បាស់លាស់ និងការឃោសនា ជាដើម។

អ្នកប្រើប្រាស់បណ្តាញផ្សព្វផ្សាយសង្គមប្រឈមមុខនឹងលំហូរចូលនៃល្បាយព័ត៌មាន ដែលមានគុណភាព និងមិនមានគុណភាព ហើយពួកគេត្រូវសម្រេចចិត្តដោយខ្លួនឯងថា តើព័ត៌មានទាំងនោះអាចទុកចិត្តបានឬអត់។ ដើម្បីអាចកំណត់ត្រង់នេះបានពួកគេចាំបាច់ត្រូវយល់ដឹងជាមូលដ្ឋាន អំពីរបៀបដែលបណ្តាញផ្សព្វផ្សាយសង្គមដំណើរការ និងរបៀបវិនិច្ឆ័យថាតើការបង្ហោះមាតិកាណាមួយ នៅលើបណ្តាញផ្សព្វផ្សាយសង្គម ទំនងជាពិតឬក្លែងក្លាយ។

ខ. តើអ្វីជាព័ត៌មាន? តើអ្វីជាភាពខុសគ្នារវាងព័ត៌មាន និងដំណឹង?

ព័ត៌មានជាពាក្យទូលំទូលាយជាងដំណឹងដែលរួមបញ្ចូលទិន្នន័យ អង្គហេតុ ចំណេះដឹង និងសេចក្តីលម្អិតអំពីប្រធានបទផ្សេងៗគ្នា។ ព័ត៌មានមិនមែនមានលក្ខណៈបន្ទាន់ គ្រប់ពេលឬសុទ្ធតែទាក់ទងនឹងព្រឹត្តិការណ៍ថ្មីៗនោះទេ។ សរុបមកវិញរាល់ដំណឹងកើតចេញពីព័ត៌មានតាមទម្រង់ផ្សេងៗ ប៉ុន្តែមិនមែនរាល់ព័ត៌មានសុទ្ធតែជាដំណឹងនោះទេ។

ឧទាហរណ៍៖

- ប្រជាជនកម្ពុជាមានចំនួន ១៧លាននាក់។
- ប្រាសាទអង្គរវត្តស្ថិតនៅក្នុងខេត្តសៀមរាប។
- កម្ពុជាមានព្រំប្រទល់ជាប់នឹងប្រទេសថៃ ឡាវ និងវៀតណាម។
- ផ្សារកណ្តាលស្ថិតនៅក្នុងរាជធានីភ្នំពេញ។



រូបភាព ៣.២ ភាពខុសគ្នារវាងព័ត៌មាន និងដំណឹង

ព័ត៌មាននៅលើបណ្តាញសង្គម បានមកពីប្រភពផ្សេងៗគ្នា ដូចជាស្ថាប័នរដ្ឋាភិបាល ស្ថាប័នឯកជន ស្ថាប័នផ្សព្វផ្សាយអាជីព ឬបុគ្គលឯកជន។ ប្រភពនីមួយៗ តែងមានទស្សនៈខុសៗគ្នា អំពីអ្វីដែលចាត់ទុកថា «មានតម្លៃជាដំណឹង»។

ក្នុងវិជ្ជាជីវៈសារព័ត៌មានការចាត់ទុកហេតុការណ៍ណាមួយជាដំណឹងអាស្រ័យលើកត្តាផ្សេងៗ ដូចជាពេលវេលា ទីកន្លែងកើតហេតុ ទស្សនិកជនគោលដៅព្រមទាំងការវិនិច្ឆ័យរបស់និពន្ធនាយក ឬអ្នកសារព័ត៌មានផ្ទាល់។ ឧទាហរណ៍៖ អំពើចោរកម្មប្លន់ហាងនៅភូមិតូចមួយ គឺជាដំណឹងដ៏សំខាន់សម្រាប់កាសែតក្នុងស្រុក ព្រោះវាជារឿងពាក់ព័ន្ធនឹងសហគមន៍នោះ។ ប៉ុន្តែស្ថាប័នព័ត៌មានថ្នាក់ជាតិឬអ្នកសារព័ត៌មាននៅប្រទេសផ្សេង អាចនឹងមិនចាត់ទុករឿងដដែលនេះជាដំណឹងសំខាន់ឡើយ។

គ. តើសេចក្តីរាយការណ៍ដំណឹងគួរឆ្លើយសំណួរអ្វីខ្លះ?

សេចក្តីរាយការណ៍ព័ត៌មានត្រូវផ្តល់ព័ត៌មានដល់ទស្សនិកជនអ្នកអាន និងអ្នកទស្សនា ឱ្យបានដឹងច្បាស់ថា តើមានរឿងអ្វីកើតឡើង នៅទីណា ពេលណា និងមានអ្នកណាខ្លះពាក់ព័ន្ធក្នុងហេតុការណ៍នោះ។ បន្ថែមពីនេះសេចក្តីរាយការណ៍ព័ត៌មានដែលល្អ ក៏ត្រូវព្យាយាមពន្យល់ផងដែរថា តើហេតុការណ៍នោះកើតឡើងដោយរបៀបណា និងហេតុអ្វី។ ឧទាហរណ៍៖ អ្នកសារព័ត៌មានផ្សេងគ្នាអាចមានទស្សនៈខុសៗគ្នាអំពីមូលហេតុនៃហេតុការណ៍ណាមួយ អាស្រ័យលើនិន្នាការ ការអប់រំ និងឥទ្ធិពលពីមិត្តរួមអាជីព។

អ្នកសារព័ត៌មានអាចផ្តល់ចម្លើយខុសៗគ្នាចំពោះសំណួរសំខាន់ៗ អាស្រ័យលើបុគ្គលដែលខ្លួនបានសម្ភាស ឬអាស្រ័យលើភាពស៊ីជម្រៅ និងទូលំទូលាយនៃការស្រាវជ្រាវ។ អ្នកសារព័ត៌មានដែលល្អតែងតែព្យាយាមផ្តល់ព័ត៌មានប្រកបដោយភាពអព្យាក្រឹត និងបង្ហាញប្រភពចម្រុះពីព្រោះប្រភពព័ត៌មានខុសៗគ្នា អាចធ្វើឱ្យទស្សនិកជនទាញបានសេចក្តីសន្និដ្ឋានខុសៗគ្នា។ ជារួមសារធ្យូធ្យាយគឺតែងតែឆ្លុះបញ្ចាំងពីគុណតម្លៃ និងទស្សនៈរបស់អ្នកផលិតផ្ទាល់។

ស្តង់ដាក្រមសីលធម៌របស់អ្នកសារព័ត៌មាន

អ្នកសារព័ត៌មានមានការទទួលខុសត្រូវលើភាពត្រឹមត្រូវ និងភាពច្បាស់លាស់នៃស្នាដៃរបស់ខ្លួន។ ពួកគាត់ត្រូវស្រាវជ្រាវ និងសម្ភាសប្រភពចម្រុះដើម្បីផ្ទៀងផ្ទាត់ព័ត៌មាន។ លើសពីនេះអ្នកសារព័ត៌មានត្រូវរាយការណ៍តែព័ត៌មានពិត ដោយដើរតួជាអន្តរការីប្រកបដោយភាពអព្យាក្រឹត។ ការបញ្ជាក់ប្រភពព័ត៌មានឱ្យទស្សនិកជនបានដឹង គឺជារឿងដ៏មានសារៈសំខាន់ ព្រោះការអនុវត្តបែបនេះ ធ្វើឱ្យការងាររបស់ខ្លួនកាន់តែមានតម្លាភាព និងគួរឱ្យជឿទុកចិត្ត។

អ្នកសារព័ត៌មានត្រូវរាយការណ៍ព័ត៌មានឱ្យច្បាស់លាស់ និងងាយយល់សម្រាប់សាធារណជន។ ខាងក្រោមនេះ គឺជាគោលការណ៍សីលធម៌ជាមូលដ្ឋានដែលអ្នកសារព័ត៌មានគួរប្រកាន់ខ្ជាប់៖

១. ភាពពិត និងភាពត្រឹមត្រូវ

អ្នកសារព័ត៌មានមិនអាចធានាបាននូវ “ការពិត” ទាំងស្រុងនោះទេ ប៉ុន្តែការស្វែងរកអង្គហេតុឱ្យបានត្រឹមត្រូវគឺជាគោលការណ៍ចម្បងនៃវិជ្ជាជីវៈសារព័ត៌មាន។ ពួកគាត់ត្រូវខិតខំស្វែងរកភាពត្រឹមត្រូវ ផ្តល់អង្គហេតុពាក់ព័ន្ធទាំងអស់ និងផ្ទៀងផ្ទាត់ព័ត៌មានទាំងនោះឱ្យបានច្បាស់លាស់។ ក្នុងករណីដែលព័ត៌មានណាមួយមិនអាចផ្ទៀងផ្ទាត់បានពួកគេត្រូវបញ្ជាក់ប្រាប់តាមត្រង់ថា ព័ត៌មាននោះមិនទាន់អាចបញ្ជាក់បានឡើយ។

២. ឯករាជ្យភាព

អ្នកសារព័ត៌មានត្រូវតែជាសំឡេងឯករាជ្យ ពួកគាត់មិនត្រូវធ្វើសកម្មភាពបម្រើផលប្រយោជន៍ណាមួយឡើយ។ លើសពីនេះពួកគេត្រូវជម្រាបជូននិពន្ធនាយកឬទស្សនិកជនឱ្យបានដឹងអំពីទំនាក់ទំនងសាធារណៈ កិច្ចព្រមព្រៀងហិរញ្ញវត្ថុ ឬព័ត៌មានផ្ទាល់ខ្លួនផ្សេងៗដែលអាចបង្កឱ្យមានទំនាស់ផលប្រយោជន៍។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

៣. ភាពយុត្តិធម៌ និងភាពមិនលម្អៀង

រឿងរ៉ាវភាគច្រើនតែងតែមានយ៉ាងហោចណាស់ពីរជ្រុង។ អ្នកសារព័ត៌មានមិនតម្រូវឱ្យបង្ហាញគ្រប់ជ្រុងជ្រោយនៅក្នុងរាល់អត្ថបទព័ត៌មាននោះទេ ប៉ុន្តែការសរសេរត្រូវមានតុល្យភាព និងមានបរិបទច្បាស់លាស់ ដើម្បីជួយឱ្យបញ្ហាកាន់តែងាយយល់។ អ្នកសារព័ត៌មានមិនអាចចៀសផុតពីភាពលម្អៀងបានទាំងស្រុងនោះឡើយហើយជួនកាលភាពលម្អៀងនេះអាចជារឿងចាំបាច់ផងដែរ (ជាពិសេសនៅចំពោះមុខអំពើឃោរឃៅឬអំពើអមនុស្សធម៌)។ ប៉ុន្តែទោះជាយ៉ាងណាការរាយការណ៍ប្រកបដោយភាពអព្យាក្រឹតទើបអាចកសាងបាននូវទំនុកចិត្ត និងភាពគួរឱ្យជឿទុកចិត្ត។

៤. មនុស្សធម៌

អ្នកសារព័ត៌មានត្រូវចៀសវាងការបង្កផលប៉ះពាល់ឬការឈឺចាប់នានា។ រាល់ការចុះផ្សាយឬការចាក់ផ្សាយអាចបង្កការឈឺចាប់ដល់បុគ្គលណាមួយ ដូច្នេះពួកគេត្រូវយល់ដឹងឱ្យបានច្បាស់ពីឥទ្ធិពលនៃពាក្យពេចន៍ និងរូបភាពទៅលើជីវិតរបស់អ្នកដទៃ។ ពួកគេត្រូវចៀសវាងការប្រើប្រាស់សម្តីស្អប់ខ្ពើមព្រមទាំងមិនត្រូវប្រើប្រាស់រូបភាពអាសអាភាស និងរូបភាពហិង្សាឡើយ។

៥. គណនេយ្យភាព

សញ្ញាណដ៏ច្បាស់លាស់មួយនៃវិជ្ជាជីវៈសារព័ត៌មានប្រកបដោយការទទួលខុសត្រូវ គឺការប្រកាន់ខ្ជាប់នូវគណនេយ្យភាព។ នៅពេលមានកំហុសឆ្គងពួកគេត្រូវតែកែតម្រូវឡើងវិញ ព្រមទាំងយកចិត្តទុកដាក់ស្តាប់កង្វល់របស់សាធារណជន។ លើសពីនេះពួកគេគួរស្វែងរកដំណោះស្រាយ ក្នុងករណីដែលស្នាដៃរបស់ខ្លួនបានបង្កឱ្យមានភាពអយុត្តិធម៌ណាមួយកើតឡើង។

ឃ. ហេតុអ្វីបានជាការទទួលបានព័ត៌មានដែលអាចទុកចិត្តបានមានសារៈសំខាន់?

ការទទួលបានព័ត៌មានអំពីព្រឹត្តិការណ៍នានាដែលកំពុងកើតឡើង គឺជារឿងសំខាន់ក្នុងការស្វែងយល់ពីសង្គម។ វាក៏ជាមធ្យោបាយជួយយើងឱ្យដឹងពីស្ថានការណ៍ជុំវិញពិភពលោក ព្រមទាំងផលប៉ះពាល់ដែលអាចកើតមានមកលើខ្លួនយើង និងសហគមន៍ផងដែរ។ ឧទាហរណ៍៖ ប្រសិនបើទិន្នផលកសិកម្មនៅប្រទេសណាមួយធ្លាក់ចុះអាចធ្វើឱ្យតម្លៃផលិតផលកសិកម្មនៅក្នុងប្រទេសរបស់យើងកើនឡើងដោយសារមានតម្រូវការខ្ពស់លើការផ្គត់ផ្គង់ដែលមានស្រាប់។ ជារួមប្រសិនបើសាធារណជនទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ពួកគេនឹងអាចកំណត់ពីបញ្ហាក្នុងសង្គម និងអាចស្វែងរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។

តើអ្នកអាចទទួលបានព័ត៌មានល្អៗ និងគ្រប់គ្រាន់ដោយរបៀបណា?

មានវិធីសាស្ត្រជាច្រើនក្នុងការតាមដានព័ត៌មាន ដូចជាការអានកាសែត និងព័ត៌មានអនឡាញ ព្រមទាំងការស្តាប់សេចក្តីរាយការណ៍តាមវិទ្យុឬទូរទស្សន៍។ ស្ថាប័នផ្សព្វផ្សាយផ្សេងៗគ្នាតែងតែរាយការណ៍រឿងរ៉ាវក្នុងជ្រុងខុសៗគ្នាលើបញ្ហាណាមួយ ឬអាចចុះផ្សាយព័ត៌មានដែលស្ថាប័នផ្សេងមិនបានលើកយកមកបង្ហាញ។ លើសពីនេះយើងក៏អាចតាមដានព័ត៌មានតាមរយៈការជជែកជាមួយអ្នកដទៃឬការអានការបង្ហោះនៅលើបណ្តាញសង្គមដូចជា Facebook ផងដែរ។ ការធ្វើបែបនេះ ជួយឱ្យ

ពីទស្សនៈរបស់អ្នកដទៃទៅលើព័ត៌មានដែលបានចុះផ្សាយ។ ទោះជាយ៉ាងណាក្តីរាល់ពេលអានព័ត៌មាន យើងត្រូវពិចារណាលើប្រភពនៃដំណឹងនោះជានិច្ច។ សូមប្រើប្រាស់ជំនាញវិភាគអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានរបស់យើង ដោយចោទសួរថាតើអ្វីដែលយើងកំពុងអាន គឺជាព័ត៌មានពិតជាមតិយោបល់ផ្ទាល់ខ្លួនឬជាការលាយឡំគ្នារវាងធាតុទាំងពីរនេះ?

ង. ព័ត៌មានខុស ព័ត៌មានមិនពិត និងព័ត៌មានបង្កព្យសនកម្ម

កាលណានិយាយអំពីព័ត៌មានមិនត្រឹមត្រូវ ឬព័ត៌មានដែលមានគ្រោះថ្នាក់ ជាទូទៅអ្នកជំនាញប្រើប្រាស់ពាក្យចំនួនបី៖

- **ព័ត៌មានខុស**
- **ព័ត៌មានមិនពិត**
- **ព័ត៌មានបង្កព្យសនកម្ម**

យោងតាមអង្គការយូណេស្កូយើងគួរចៀសវាងការប្រើប្រាស់ពាក្យ ព័ត៌មានក្លែងក្លាយ ពីព្រោះពាក្យនេះបានក្លាយជាឧបករណ៍នយោបាយ។ ជាក់ស្តែងអ្នកនយោបាយមួយចំនួនបានយកពាក្យនេះទៅប្រើប្រាស់ដើម្បីបង្ខូចតម្លៃវិស័យសារព័ត៌មាន និងកាត់បន្ថយឥទ្ធិពលនៃសេចក្តីរាយការណ៍ណាដែលខ្លួនមិនពេញចិត្ត។ ប្រើប្រាស់វាដើម្បីបន្ទុះបង្អាប់វិស័យសារព័ត៌មាន និងកាត់បន្ថយឥទ្ធិពលនៃសេចក្តីរាយការណ៍ដំណឹងដែលពួកគេមិនចូលចិត្ត។

អង្គការយូណេស្កូផ្តល់និយមន័យសម្រាប់ពាក្យទាំងបីដូចខាងក្រោម៖



រូបភាព ៣.៣ គិតសិន មុនចែករំលែក

- **ព័ត៌មានខុស៖** សំដៅលើព័ត៌មានដែលនាំឱ្យមានការយល់ច្រឡំត្រូវបានគេបង្កើត ឬចែកចាយដោយអចេតនា និងគ្មានបំណងទុច្ចរិត។ ព័ត៌មានប្រភេទនេះមិនមានគោលដៅបង្កផលប៉ះពាល់ឡើយ ទោះបីជាជួនកាលវាអាចបង្កគ្រោះថ្នាក់ក៏ដោយ។
- **ព័ត៌មានមិនពិត៖** សំដៅលើការប៉ុនប៉ងដោយចេតនា (មានការរៀបចំទុកជាមុន) ដើម្បីបំភាន់ ឬបោកបញ្ឆោតសាធារណជន តាមរយៈការផ្តល់ព័ត៌មានមិនពិត។ ជួនកាលស្ថាប័នផ្សព្វផ្សាយ ក្រុមមនុស្ស ឬអ្នកប្រើប្រាស់បណ្តាញសង្គមផ្ទាល់បានចែកចាយព័ត៌មានប្រភេទនេះតាមរយៈការបង្កើតសាច់រឿងលម្អៀង ការរាយការណ៍អង្គហេតុមិនពិត ឬការផ្តល់ការពិតតែមួយចំណែកដើម្បីប្រយោជន៍នយោបាយ ហិរញ្ញវត្ថុ ឬមនោគមវិជ្ជា។ អ្នកបង្កើតព័ត៌មានក្លែងបន្លំ អាចមានបំណងជះឥទ្ធិពលដល់មតិសាធារណៈលើបញ្ហាណាមួយ។ ក្នុងករណីខ្លះទៀតពួកគេមានគោលដៅទាញទស្សនៈរបស់ប្រជាពលរដ្ឋទៅលើគណបក្សនយោបាយ ឬបេក្ខជនណាមួយព្រមទាំងចង់ផ្លាស់ប្តូរការសម្រេចចិត្តក្នុងការបោះឆ្នោតរបស់ពលរដ្ឋថែមទៀតផង។
- **ព័ត៌មានបង្កព្យសនកម្ម៖** សំដៅលើប្រភេទព័ត៌មានដែលអាចជារឿងពិត ប៉ុន្តែគេយកទៅប្រើប្រាស់ក្នុងគោលបំណងបង្កផលប៉ះពាល់ដល់បុគ្គល អង្គការស្ថាប័ន ឬប្រទេសជាតិណាមួយ។ ឧទាហរណ៍៖ ការទម្លាយឯកសារការទូតរវាងរដ្ឋាភិបាល និងស្ថានទូតរបស់ខ្លួននៅបរទេសដែលទង្វើនេះអាច

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ជះឥទ្ធិពលអវិជ្ជមានដល់រដ្ឋាភិបាល និងប្រជាពលរដ្ឋ។ លើសពីនេះគេចែកចាយព័ត៌មានអន្តរាយផ្សេងៗទៀតដើម្បីធ្វើបាបបុគ្គលណាម្នាក់ ឬបង្កឱ្យមានការស្អប់ខ្ពើម និងការបៀតបៀននៅលើអនឡាញ។

ជាទូទៅបណ្តាញសង្គមតែងមានព័ត៌មានល្អៗលាយឡំជាមួយធាតុទាំងបីនៃ «ភាពវឹកវរនៃព័ត៌មាន» ដែលអ្នកជំនាញចាត់ទុកថាជាប្រព័ន្ធព័ត៌មានដ៏ច្របូកច្របល់ និងគ្មានសណ្តាប់ធ្នាប់។

ការរៀនវាយតម្លៃព័ត៌មាន (ព័ត៌មានខុស និងព័ត៌មានមិនពិត)

ការបែងចែកឱ្យដាច់ថាខ្លឹមសារណាមួយពិត ឬមិនពិត គឺជារឿងដ៏មានសារៈសំខាន់។ ទោះបីជាការងារនេះមិនមែនសុទ្ធតែងាយស្រួលក៏ដោយ ប៉ុន្តែយើងមានវិធីសាស្ត្រមួយចំនួនដែលអាចជួយបាន។ សូមសង្កេតមើលសញ្ញាគួរឱ្យសង្ស័យនៃព័ត៌មានខុស និងព័ត៌មានមិនពិតដូចជា៖

- មានកំហុសអក្ខរាវិរុទ្ធ ឬកំហុសឆ្គងផ្សេងៗនៅក្នុងអត្ថបទ
- ការប្រើប្រាស់ចំណងជើងបែបទាក់ទាញអារម្មណ៍ បំផ្លើសការពិត ឬការដាក់សញ្ញាឧទានច្រើនដង “!!!”
- ខ្លឹមសារដែលបង្កការភ្ញាក់ផ្អើល ឬញុះញង់ឱ្យមានការផ្អើលឆោឡោខ្លាំងជ្រុលជាដើម។

នៅពេលដែលអ្នកឃើញសញ្ញាណាមួយខាងលើ ឬសញ្ញាគួរឱ្យសង្ស័យផ្សេងទៀត អ្នកគួរតែផ្ទៀងផ្ទាត់ព័ត៌មានដោយប្រើវិធីសាស្ត្រដូចខាងក្រោម៖

- ពិនិត្យមើលប្រភពនោះគួរឱ្យទុកចិត្តដែរទេ
- ស្វែងរកព័ត៌មានប្រភេទនេះបន្ថែមតាមអនឡាញ និងប្រភពដទៃទៀត។ ប្រសិនបើមិនមានប្រភពផ្សេងចុះផ្សាយព័ត៌មាននេះទេ នោះមានន័យថាអ្នកសារព័ត៌មានប្រហែលជាមិនអាចផ្ទៀងផ្ទាត់ភាពត្រឹមត្រូវរបស់វាបាន ឬមួយវាមិនមែនជារឿងពិតឡើយ។
- ពិនិត្យមើលអ្នកបង្ហោះសារ ឬខ្លឹមសារនោះ៖ សូមសង្កេតមើលថាតើវាត្រូវបានបង្កើតឡើងដោយបុគ្គលជាក់លាក់ណាម្នាក់ដែលគេស្គាល់ជាទូទៅ ឬក៏គ្មានប្រភពច្បាស់លាស់។ ប្រសិនបើគ្មានប្រភពច្បាស់លាស់ទេ គណនីនោះជួនកាលអាចគ្រប់គ្រងដោយប្រព័ន្ធស្វ័យប្រវត្តិ។



រូបភាព ៣.៤ ការរៀនវាយតម្លៃព័ត៌មាន

- ប្រសិនបើព័ត៌មាននេះត្រូវបានចែករំលែកនៅលើបណ្តាញសង្គម៖ យើងគួរស្វែងរកគណនីរបស់អ្នកបង្ហោះនោះនៅលើបណ្តាញសង្គមផ្សេងៗទៀត ដើម្បីពិនិត្យមើលប្រវត្តិនៃការសរសេររបស់គេ ក៏ដូចជាចង់ដឹងថាតើគេមានទំនោរទៅរកភាគីណាមួយ ជាពិសេសដែរឬទេ។
- កុំប្រញាប់៖ យើងមិនគួរជឿ ឬចែករំលែកព័ត៌មាន និងដំណឹងណាមួយលឿនរហ័សពេកនោះឡើយ។ ប្រសិនបើយើងចំណាយពេលបន្តិចដើម្បីគិតពិចារណាពីខ្លឹមសារ និងភាពត្រឹមត្រូវនៃព័ត៌មាន នោះយើងនឹងអាចបែងចែកបានកាន់តែច្បាស់រវាងរឿងដែលទំនងជាការពិត និងរឿងដែលទំនងជាការភូតកុហក។

នៅពេលណាមានមន្ត្រីសង្ស័យអំពីដំណឹង ឬព័ត៌មានណាមួយ សូមកុំចែករំលែកវាឱ្យសោះ!

មេរៀនសង្ខេប

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីចំណុចសំខាន់ៗដូចខាងក្រោម៖

- អ្នកសារព័ត៌មាន មានការទទួលខុសត្រូវលើភាពត្រឹមត្រូវ និងភាពច្បាស់លាស់នៃស្នាដៃរបស់ខ្លួន។ ពួកគេត្រូវស្រាវជ្រាវ និងសម្ភាសប្រភពចម្រុះ ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានមុននឹងចុះផ្សាយ។
- ព័ត៌មាន៖ រួមមាន ទិន្នន័យ អង្គហេតុ ចំណេះដឹង និងព័ត៌មានលម្អិតអំពីប្រធានបទដ៏ទូលំទូលាយ។ ព័ត៌មានមិនមែនតែងតែទាមទារភាពបន្ទាន់ ឬពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដែលទើបនឹងកើតឡើងនោះទេ។
- ដំណឹង៖ ជាផ្នែកមួយនៃព័ត៌មាន ដែលជាការបង្ហាញអង្គហេតុអំពីព្រឹត្តិការណ៍ ឬហេតុការណ៍ដែលទើបនឹងកើតឡើងថ្មីៗ ហើយមានតម្លៃជាព័ត៌មាន សម្រាប់ទស្សនិកជន។
- ការទទួលបានព័ត៌មានអំពីព្រឹត្តិការណ៍នានាដែលកំពុងកើតឡើង គឺជារឿងសំខាន់ក្នុងការស្វែងយល់ពីសង្គម ព្រមទាំងជួយយើងឱ្យចេះឆ្លើយតបទៅនឹងបញ្ហាប្រឈម និងឱកាសនានា។
- ដើម្បីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ យើងគួរអាន ទស្សនា ឬស្តាប់ ប្រភពព័ត៌មានដែលគួរឱ្យទុកចិត្តជាប្រចាំ។
- ព័ត៌មានខុស៖ ជាទូទៅសំដៅលើព័ត៌មានមិនត្រឹមត្រូវ ដែលគេបង្កើត ឬចែកចាយដោយគ្មានចេតនាបោកបញ្ឆោត។
- ព័ត៌មានមិនពិត៖ ជាទូទៅសំដៅលើការប៉ុនប៉ងដែលមានការរៀបចំទុកជាមុន ដើម្បីបំភាន់ ឬបោកបញ្ឆោតសាធារណជន តាមរយៈការផ្តល់ព័ត៌មានមិនត្រឹមត្រូវ។
- ព័ត៌មានបង្កព្យសនកម្ម៖ សំដៅលើប្រភេទព័ត៌មានដែលអាចជារឿងពិត ប៉ុន្តែគេយកទៅប្រើប្រាស់ក្នុងគោលបំណងបង្កផលប៉ះពាល់ដល់បុគ្គល អង្គការស្ថាប័ន ឬប្រទេសជាតិណាមួយ។

សទ្ទានុក្រម

- **គណនេយ្យភាព៖** កាតព្វកិច្ច ឬការស្ម័គ្រចិត្តទទួលខុសត្រូវចំពោះរាល់សកម្មភាពរបស់ខ្លួន។
- **ព័ត៌មានមិនពិត៖** គឺជាព័ត៌មានមិនត្រឹមត្រូវដែលគេចែកចាយក្នុងចេតនាបំភាន់ ឬបោកបញ្ឆោតសាធារណជន។
- **ក្រមសីលធម៌៖** សំដៅលើគោលការណ៍ វិធាន ឬច្បាប់ទម្លាប់ដែលតម្រង់ទិសការគិត និងអាកប្បកិរិយារបស់បុគ្គល ឬស្ថាប័ន ឱ្យបំពេញការងារប្រកបដោយភាពត្រឹមត្រូវ យុត្តិធម៌ និងការទទួលខុសត្រូវខ្ពស់ចំពោះសង្គម។ ឧទាហរណ៍៖ ក្រមសីលធម៌វិជ្ជាជីវៈនៃប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានក្នុងការផ្សាយព័ត៌មានពិត។
- **ព័ត៌មាន៖** ជាសំណុំទិន្នន័យ ឬអង្គហេតុនានា ដែលមិនកម្រិតត្រឹមតែព្រឹត្តិការណ៍ថ្មីៗ ឬទាមទារឱ្យមានតម្លៃសារព័ត៌មាន នោះឡើយ។
- **ភាពមិនលម្អៀង៖** ជាការប្រកាន់ជំហរអព្យាក្រឹត ដោយមិនឈរទៅខាងភាគីណាមួយ និងការផ្តល់តម្លៃ ឬការវិនិច្ឆ័យទៅលើគ្រប់ភាគីដោយសមភាព។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

- **ព័ត៌មានបង្កឲ្យសនកម្ម៖** ព័ត៌មានពិត ប៉ុន្តែគេយកទៅចែកចាយក្នុងគោលបំណងធ្វើបាបឬបង្កផលប៉ះពាល់ដល់ភាគីដទៃ។
- **ព័ត៌មានខុស៖** ព័ត៌មានមិនត្រឹមត្រូវដែលគេចែកចាយដោយអចេតនា។
- **ដំណឹង៖** ការបង្ហាញអង្គហេតុអំពីព្រឹត្តិការណ៍ថ្មីៗដែលគួរឱ្យកត់សម្គាល់ និងមានសារៈសំខាន់។
- **តម្លៃជាព័ត៌មាន៖** លក្ខណៈសម្បត្តិ ឬកម្រិតនៃភាពទាក់ទាញ និងសារៈសំខាន់នៃព្រឹត្តិការណ៍ណាមួយដែលធ្វើឱ្យវាស័ក្តិសមនឹងត្រូវយកមកផ្សព្វផ្សាយជាដំណឹង។
- **ការឃោសនា៖** ព័ត៌មានដែលជារឿយៗមានលក្ខណៈបំភាន់ភ្នែក ដែលគេបង្កើតឡើងក្នុងគោលបំណងជះឥទ្ធិពលលើមតិសាធារណៈដើម្បីបម្រើឱ្យគោលដៅណាមួយ។
- **ប្រភពដែលគួរឱ្យទុកចិត្ត៖** បុគ្គល ឬអង្គការស្ថាប័នដែលល្បីល្បាញ លើការផ្តល់ព័ត៌មានច្បាស់លាស់និងត្រឹមត្រូវ។

លំហាត់អនុវត្តន៍

១. ប្រភពដំណឹងរបស់អ្នក៖ តើប្រភពណាខ្លះដែលអ្នកទុកចិត្ត?

សូមគិតអំពីប្រភពទាំងអស់ដែលអ្នកប្រើប្រាស់ដើម្បីទទួលបានព័ត៌មានប្រចាំថ្ងៃ។ ចូរប្រាប់ឈ្មោះប្រភពព័ត៌មានដែលអ្នកប្រើជាប្រចាំឱ្យបានជាក់លាក់នៅលើក្រដាសផ្សេងៗគ្នា ដោយឆ្លុះបញ្ចាំងតើអ្នកទុកចិត្តប្រភពនីមួយៗ កម្រិតណា ហេតុអ្វី? បន្ទាប់មក សូមរៀបក្រដាសទាំងនោះ តាមលំដាប់លំដោយចាប់ពីប្រភពដែលអ្នកទុកចិត្តតិចបំផុត រហូតដល់ប្រភពដែលអ្នកទុកចិត្តខ្លាំងបំផុត។

២. ការវិភាគដំណឹង៖ ពិនិត្យមើលសំណួរ 5W1H

សូមជ្រើសរើសដំណឹងណាមួយពីអ៊ីនធឺណិត ឬពីបណ្តាញសង្គមដែលអ្នកចាប់អារម្មណ៍។ បន្ទាប់មក ព្យាយាមឆ្លើយសំណួរដូចខាងក្រោម៖

- អ្វី (What)៖ តើសាច់រឿងនោះនិយាយអំពីអ្វី?
- នៅឯណា (Where)៖ តើហេតុការណ៍នោះកើតឡើងនៅកន្លែងណា?
- ឯណា (When)៖ តើហេតុការណ៍នោះកើតឡើងនៅកន្លែងណា?
- នរណា (Who)៖ តើនរណាខ្លះដែលពាក់ព័ន្ធក្នុងព្រឹត្តិការណ៍នោះ?
- របៀបណា (How)៖ តើហេតុការណ៍នេះកើតឡើងយ៉ាងដូចម្តេចខ្លះ?
- ហេតុអ្វី (Why)៖ តើហេតុអ្វីបានជាព្រឹត្តិការណ៍នោះកើតឡើង?

ដំណឹងខ្លះអាចផ្តល់ចម្លើយយ៉ាងពេញលេញទៅនឹងសំណួរគោលទាំងប្រាំមួយខាងលើ ខណៈដែលដំណឹងខ្លះទៀតអាចឆ្លើយតបបានត្រឹមតែសំណួរមួយចំនួនប៉ុណ្ណោះ។ ផ្អែកលើចំណុចនេះ សូមឆ្លុះបញ្ចាំង តើអ្វីទៅជាគុណភាពនៃដំណឹង?

៣. ព័ត៌មានខុស និងព័ត៌មានមិនពិត៖ កំណត់រកការបង្ហោះដែលខុសឆ្គង និងនាំឱ្យមានការភាន់ច្រឡំ

សូមចូលទៅកាន់អ៊ីនធឺណិត ឬបណ្តាញសង្គមរបស់អ្នកហើយព្យាយាមស្វែងរកការបង្ហោះ ឬអត្ថបទព័ត៌មានណាមួយដែលអ្នកគិតថាជា «ព័ត៌មានខុស» ឬ «ព័ត៌មានមិនពិត» ។ សូមសង្កេតមើលចំណុចដូចជា៖

- កំហុសអក្ខរាវិរុទ្ធ
- ចំណងជើងដែលប្រើពាក្យបំផ្លើស ឬប៉ះពាល់អារម្មណ៍ខ្លាំង
- ខ្លឹមសារដែលបង្កឱ្យមានការភ្ញាក់ផ្អើលខ្លាំង
- ការបង្ហោះចេញពីប្រភពដែលមិនគួរឱ្យទុកចិត្ត

សូមថតរូបភាពអេក្រង់ រួចដាក់បញ្ចូលក្នុងឯកសារណាមួយ ជាមួយកំណត់ចំណាំនៃការស៊ើបអង្កេតរបស់អ្នក។

៤. ព័ត៌មានខុស និងព័ត៌មានមិនពិត៖ ទស្សនាវីដេអូ

សូមប្រើប្រាស់កម្មវិធីទូរសព្ទ SALA MIL ហើយចូលទៅកាន់ជំពូកទី១ មេរៀនទី១.៥៖ ព័ត៌មានក្លែងក្លាយ សូមទស្សនាវីដេអូ និងអានអត្ថបទ រួចឆ្លើយសំណួរខាងក្រោម៖

- តើអ្វីទៅជាព័ត៌មានខុស?
- តើអ្វីទៅជាព័ត៌មានមិនពិត?
- តើព័ត៌មានខុស និងព័ត៌មានមិនពិត បង្កផលប៉ះពាល់យ៉ាងដូចម្តេចខ្លះ?
- តើអ្វីខ្លះគឺជាសញ្ញាព្រមាន?
- តើធ្វើដូចម្តេចដើម្បីបញ្ឈប់ការរីករាលដាលនៃព័ត៌មានទាំងនេះ?

៥. គិតសិន ឬចែករំលែកបន្ត? ចូលរួមដោះស្រាយលំហាត់

ឥឡូវនេះ សូមចូលរួមដោះស្រាយលំហាត់ខ្លីដែលមានចំណងជើងថា «គិតសិន ឬចែករំលែកបន្ត?»។ ចំពោះឧទាហរណ៍នីមួយៗ សូមសម្រេចចិត្តថា តើអ្នកនឹង «ចែករំលែក» «ត្រួតពិនិត្យ» ឬក៏ «លុបវាចោល» ។ បន្ទាប់មក សូមសរសេរអត្ថបទមួយល្អះ ដើម្បីពន្យល់ពីរបៀបដែលអ្នកនឹងដោះស្រាយចំពោះរាល់ការបង្ហោះនានាដែលលេចឡើងនៅលើបណ្តាញសង្គមរបស់អ្នកចាប់ពីពេលនេះតទៅ។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

៦. ការផ្ទៀងផ្ទាត់ព័ត៌មាន៖ បង្កើតបញ្ជីផ្ទៀងផ្ទាត់

សូមប្រើប្រាស់កម្មវិធី MIL Chatbot ចូលទៅកាន់ជំពូកទី៤៖ ព័ត៌មានឥតសណ្តាប់ធ្នាប់។ អានអត្ថបទ និងទស្សនាវីដេអូ ដើម្បីស្វែងយល់អំពីព័ត៌មានខុស និងព័ត៌មានមិនពិត នៃផលប៉ះពាល់ដ៏គ្រោះថ្នាក់របស់វា និងរបៀបត្រួតពិនិត្យថាតើព័ត៌មាននោះជាការពិតឬយ៉ាងណា។ សូមកត់ត្រាទុកនូវចំណុចសំខាន់ៗនៅពេលកំពុងទស្សនា និងឆ្លើយសំណួរខាងក្រោម៖

- តើមានវិធីផ្សេងៗគ្នាអ្វីខ្លះ ដើម្បីផ្ទៀងផ្ទាត់ព័ត៌មាន?
- បង្កើតបញ្ជីត្រួតពិនិត្យសាមញ្ញមួយដែលអ្នកអាចប្រើដើម្បីផ្ទៀងផ្ទាត់ព័ត៌មានក្នុងជីវិតប្រចាំថ្ងៃ។

សំណួរសំរាប់ពិភាក្សា

១. តើអ្វីជាដំណឹង និងអ្វីជាព័ត៌មាន? តើអ្វីជាភាពខុសគ្នារវាងដំណឹង និងព័ត៌មាន?
២. តើអត្ថបទដំណឹងមួយដែលពេញលេញ គួរតែអាចឆ្លើយតបទៅនឹងសំណួរមូលដ្ឋានអ្វីខ្លះ?
៣. តើស្តង់ដាក្រមសីលធម៌សម្រាប់អ្នកសារព័ត៌មានមានអ្វីខ្លះ?
៤. ហេតុអ្វីបានជាការទទួលបានព័ត៌មានមានសារៈសំខាន់សម្រាប់អ្នក?
៥. តើអ្នកអាចទទួលបានព័ត៌មានល្អ និងគ្រប់គ្រាន់ដោយរបៀបណា?
៦. តើអ្វីជាព័ត៌មានខុស ព័ត៌មានមិនពិត និងព័ត៌មានបង្កព្យសនកម្ម?
៧. តើអ្នកអាចវាយតម្លៃព័ត៌មានខុស ឬព័ត៌មានមិនពិត ដោយរបៀបណា?

មេរៀនទី ៤ ការសរសេរដំណឹង

ជំពូកទី២ ទី៧

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

ក. ការជ្រើសរើសប្រធានបទសម្រាប់សរសេរ

ខ. ចំណុចសំខាន់ៗដែលត្រូវដឹងនៅពេលសរសេរដំណឹង

គ. ចំណុចសំខាន់ៗ ដែលត្រូវដឹងនៅពេលរៀបចំផែនការសម្ភាសន៍

ឃ. ការសរសេរដំណឹងដោយប្រើសំណួរមូលដ្ឋានទាំង ៦ និងទម្រង់ពីរ៉ាមីតធ្លាស់

ហេតុអ្វីបានជាមេរៀននេះសំខាន់?

ការរៀនពីរបៀបសរសេរដំណឹង ជួយសិស្សឱ្យយល់ពីរបៀបដែលអ្នកសារព័ត៌មានបង្ហាញព័ត៌មាន ច្បាស់លាស់ និងដោយសុក្រឹត។ ការសរសេរដំណឹងក៏ជួយក្នុងការកសាងជំនាញប្រាស្រ័យទាក់ទង និងការគិតបែបត្រិះរិះផងដែរ។

ក. ការជ្រើសរើសប្រធានបទសម្រាប់សរសេរ

ការជ្រើសរើសប្រធានបទគឺជាជំហានដំបូងបំផុតសម្រាប់អ្នកសរសេរព័ត៌មាន។ ប្រសិនបើយើងចង់សរសេរដំណឹងដើម្បីយកទៅចុះផ្សាយក្នុងប្រព័ន្ធផ្សព្វផ្សាយ យើងត្រូវយល់ពីប្រភេទប្រធានបទដែលអ្នកផលិតព័ត៌មានចង់បាន ពោលគឺប្រធានបទដែលគួរឱ្យចាប់អារម្មណ៍ និងមានភាពទាក់ទាញ។

ប្រសិនបើយើងចាប់អារម្មណ៍លើប្រធានបទណាមួយដែលមិនទាន់មានប្រព័ន្ធផ្សព្វផ្សាយណាចុះផ្សាយ យើងគួរពិចារណាសិនថា តើប្រធានបទនោះមាន «តម្លៃជាព័ត៌មាន» សម្រាប់សាធារណជនទូទៅដែរឬទេ។ យើងគួរសួរខ្លួនឯងថា៖

- តើប្រធានបទនេះផ្តល់ព័ត៌មានដែលមានអត្ថន័យ ឬមានសារៈសំខាន់ចំពោះមហាជនដែរឬទេ?
- ប្រសិនបើគ្មានទេ តើមកពីមូលហេតុអ្វី? តើកត្តាអ្វីខ្លះដែលធ្វើឱ្យវាមិនសូវពាក់ព័ន្ធ ឬមិនសូវសំខាន់?
- តើយើងអាចសម្របសម្រួលប្រធានបទនេះឱ្យពាក់ព័ន្ធ និងផ្សារភ្ជាប់ជាមួយសាធារណជន ដើម្បីប្រែក្លាយវាជាដំណឹងដែលមានតម្លៃ បានដោយរបៀបណា?

យើងអាចពិចារណាផ្សព្វផ្សាយអត្ថបទរឿងនេះទៅកាន់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកជាមុនសិន។ ជាទូទៅបណ្តាញផ្សព្វផ្សាយធំៗតែងតែតាមដានដំណឹងនានាដែលបានចុះផ្សាយរួចហើយក្នុងប្រព័ន្ធផ្សព្វផ្សាយថ្នាក់តំបន់។ នៅពេលពួកគេសង្កេតឃើញថា រឿងណាមួយត្រូវបានគេរាយការណ៍យ៉ាងទូលំទូលាយ និងទាក់ទាញចំណាប់អារម្មណ៍ខ្លាំង រឿងនោះក៏អាចក្លាយជាដំណឹងដ៏មានតម្លៃសម្រាប់ប្រព័ន្ធផ្សព្វផ្សាយធំៗផងដែរ។

លើសពីនេះយើងអាចសរសេរ និងចែករំលែកដំណឹងនេះនៅលើបណ្តាញសង្គម ដូចជា Facebook Twitter ឬ YouTube ដើម្បីផ្សព្វផ្សាយទៅកាន់មហាជនឱ្យបានកាន់តែទូលំទូលាយ។ ប្រសិនបើរឿងរបស់យើងទទួលបានការចាប់អារម្មណ៍ និងមានអ្នកទស្សនាច្រើនស្ថាប័នផ្សព្វផ្សាយធំៗក៏អាចនឹងយកព័ត៌មាននោះទៅចុះផ្សាយបន្តផងដែរ។

ខ. ចំណុចសំខាន់ៗដែលត្រូវដឹងនៅពេលសរសេរដំណឹង

អត្ថបទដំណឹងត្រូវបង្ហាញព័ត៌មានដែលសំខាន់បំផុតនៅផ្នែកខាងលើគេបង្អស់។ ចំណែកឯព័ត៌មានលម្អិតនៃសាច់រឿង ត្រូវដាក់នៅផ្នែកខាងក្រោម បន្ទាប់ពីអត្ថបទបានឆ្លើយតបនឹងសំណួរគន្លឹះដូចតទៅ៖

- តើនរណាខ្លះពាក់ព័ន្ធ? (Who)
- តើមានអ្វីកើតឡើង? (What)
- តើវាកើតឡើងនៅពេលណា? (When)
- តើវាកើតឡើងនៅឯណា? (Where)
- ហេតុអ្វីបានជាវាកើតឡើង? (Why)
- តើវាកើតឡើងដោយរបៀបណា? (How)

ខ្លឹមសារដំណឹងត្រូវតែច្បាស់លាស់ និងត្រឹមត្រូវតាមអង្គហេតុ។ ជាទូទៅអត្ថបទដំណឹងតែងតែបញ្ចូលសម្រង់សម្តីដើម ពីបុគ្គលដែលស្ថិតក្នុងព្រឹត្តិការណ៍ផ្ទាល់ ដូចជាសាក្សី ឬអ្នកពាក់ព័ន្ធដោយផ្ទាល់។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

លើសពីនេះអត្ថបទដំណឹងក៏តែងតែរួមបញ្ចូលនូវសេចក្តីថ្លែងការណ៍ ឬប្រតិកម្មពីសំណាក់អ្នកជំនាញ ឬភាគីពាក់ព័ន្ធ ដែលផ្តល់មតិយោបល់របស់ពួកគេជុំវិញព្រឹត្តិការណ៍ ឬបញ្ហានោះផងដែរ។ ប្រសិនបើសេចក្តីថ្លែងការណ៍ទាំងនេះគ្របដណ្តប់គ្រប់ជ្រុងជ្រោយនៃប្រធានបទ នោះសាធារណជនអាចវាយតម្លៃ និងសម្រេចចិត្តដោយខ្លួនឯងថាពួកគេស្របគំនិតជាមួយភាគីណា។

អត្ថបទដំណឹងមិនត្រូវលាយឡំនូវមតិផ្ទាល់ខ្លួនរបស់អ្នកសារព័ត៌មានឡើយ។ អ្នកសារព័ត៌មានមានតួនាទីរាយការណ៍តែអង្គហេតុប៉ុណ្ណោះ ហើយត្រូវប្រុងប្រយ័ត្នខ្ពស់នៅពេលបកស្រាយ ឬបញ្ចេញទស្សនៈផ្ទាល់ខ្លួន ព្រោះវាអាចជះឥទ្ធិពលដល់អារម្មណ៍ ឬការយល់ឃើញរបស់ទស្សនិកជន។



រូបភាព ៤.១ ចំណុចសំខាន់ៗដែលត្រូវសរសេរដំណឹង

គ. ចំណុចសំខាន់ៗដែលត្រូវដឹងនៅពេលរៀបចំផែនការសម្ភាសន៍

ការសម្ភាសន៍គឺជាមធ្យោបាយទូទៅដែលអ្នកសារព័ត៌មានប្រើប្រាស់ ដើម្បីប្រមូលព័ត៌មាន។ ពួកគាត់តែងចុះសម្ភាសន៍អ្នកដែលបានឃើញហេតុការណ៍ផ្ទាល់ភ្នែក ឬបុគ្គលដែលមានការពាក់ព័ន្ធនឹងបញ្ហាណាមួយ។ ម៉្យាងវិញទៀតពួកគេក៏អាចសម្ភាសន៍អ្នកជំនាញដែលមានចំណេះដឹងជ្រៅជ្រះជុំវិញប្រធានបទដែលខ្លួនកំពុងសរសេរនោះផងដែរ។

យើងគួរស្រាវជ្រាវជាមុនអំពីបុគ្គលដែលយើងត្រូវសម្ភាសន៍ ព្រមទាំងប្រធានបទដែលយើងគ្រោងនឹងសួរពួកគាត់។ ការរៀបចំទុកជាមុននេះជួយឱ្យកិច្ចសម្ភាសន៍របស់យើងកាន់តែមានភាពច្បាស់លាស់ និងចំគោលដៅ ព្រមទាំងធានាថាសំណួរដែលយើងសួរពិតជាពាក់ព័ន្ធនឹងគោលបំណងនៃកិច្ចសម្ភាសន៍។

យើងត្រូវតាក់តែងសំណួរឱ្យបានខ្លី និងច្បាស់លាស់ដើម្បីឱ្យអ្នកផ្តល់បទសម្ភាសន៍ឆាប់យល់ពីអ្វីដែលយើងចង់ដឹង។ ចំណុចនេះមានសារៈសំខាន់ណាស់ ក្នុងការជួយឱ្យអ្នកផ្តល់បទសម្ភាសន៍មានអារម្មណ៍ផាសុកភាព និងអាចផ្តោតអារម្មណ៍ទៅលើសំណួររបស់យើង។ ម៉្យាងវិញទៀតយើងគួរចោទសួរសំណួរគន្លឹះដែលយើងបានរៀបចំទុកជាមុននោះផងដែរ។

ក្នុងអំឡុងពេលសម្ភាសន៍យើងត្រូវស្តាប់ដោយយកចិត្តទុកដាក់ និងចោទសួរសំណួរបន្តប្រសិនបើអ្នកផ្តល់បទសម្ភាសន៍ឆ្លើយមិនទាន់អស់សេចក្តីឬប្រសិនបើពួកគាត់លើកឡើងពីចំណុចថ្មីណាមួយដែលយើងចង់ដឹងបន្ថែម។

ប្រសិនបើយើងមិនទាន់យល់ច្បាស់ពីចម្លើយរបស់ពួកគាត់ទេ យើងត្រូវសុំការបំភ្លឺបន្ថែមដើម្បីធានាថាយើងពិតជាទទួលបានព័ត៌មានច្បាស់លាស់ និងត្រឹមត្រូវ។

យើងគួរប្រើប្រាស់ «សំណួរបើក» ជាជាងការប្រើសំណួរដែលគ្រាន់តែទាមទារចម្លើយថា «បាទ/ចាស ឬ ទេ»។ ឧទាហរណ៍ យើងអាចផ្តើមសំណួរដោយពាក្យថា «របៀបណា?» ឬ «ហេតុអ្វី?» ដើម្បីជំរុញឱ្យពួកគាត់បកស្រាយបានលម្អិត និងផ្តល់ព័ត៌មានបានច្រើន។



រូបភាព ៤.២ ចំណុចសំខាន់ៗការរៀបចំសម្ភាសន៍

ឃ. ការសរសេរដំណឹងដោយប្រើសំណួរមូលដ្ឋានទាំង ៦ និងទម្រង់ពីរ៉ាមីដផ្ងារ

នៅពេលចាប់ផ្តើមសរសេរអត្ថបទដំណឹងយើងអាចប្រើប្រាស់សំណួរមូលដ្ឋានទាំង៦ ខាងក្រោមរួមផ្សំជាមួយទម្រង់ពីរ៉ាមីដផ្ងារ ដែលអ្នកសារព័ត៌មានទូទៅតែងតែយកធ្វើជាគំរូក្នុងការសរសេរសេចក្តីរាយការណ៍ព័ត៌មាន។

សំណួរទាំង៦នេះជួយយើងក្នុងការប្រមូលព័ត៌មានចាំបាច់ និងរៀបចំខ្លឹមសារទាំងនោះ ដោយដាក់ព័ត៌មានដែលសំខាន់បំផុតនៅខាងលើគេបង្អស់។ ហេតុនេះទោះបីជាមាននរណាម្នាក់គ្រាន់តែអាន ឬស្តាប់ប្រយោគពីរបីឃ្លាដំបូងនៃអត្ថបទក៏ដោយ ក៏ពួកគេនៅតែអាចចាប់បានន្ទូខ្លឹមសារជារួមនៃសាច់រឿងនោះបានដែរ។


សំណួរមូលដ្ឋានទាំង៦ នោះគឺ៖

- **អ្វី (What)**៖ តើមានអ្វីកើតឡើង?
- **នរណា (Who)**៖ តើនរណាខ្លះដែលពាក់ព័ន្ធ?
- **ឯណា (Where)**៖ តើវាកើតឡើងនៅកន្លែងណា?
- **ពេលណា (When)**៖ តើវាកើតឡើងនៅពេលណា?
- **ហេតុអ្វី (Why)**៖ ហេតុអ្វីបានជាវាកើតឡើង?
- **របៀបណា (How)**៖ តើហេតុការណ៍នេះកើតឡើងយ៉ាងដូចម្តេចខ្លះ?

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ការប្រើប្រាស់សំណួរទាំងនេះជួយធានាថាអត្ថបទដំណឹងរបស់យើងមានភាពច្បាស់លាស់ ត្រឹមត្រូវតាមអង្គហេតុ និងមានរចនាសម្ព័ន្ធល្អ ដែលបង្កលក្ខណៈងាយស្រួលដល់អ្នកអាន ក្នុងការយល់ពីចំណុចសំខាន់ៗបានភ្លាមៗ។

ទម្រង់ពីរ៉ាមីដធ្លាស់នេះជាគំរូពេញនិយមសម្រាប់ការសរសេរដំណឹង



១. ផ្តើមដោយសរសេរព័ត៌មានសំខាន់ និងចាប់អារម្មណ៍ជាងគេ៖ ឃ្លាដំបូងគេត្រូវឆ្លើយនឹងសំណួរ នរណា អ្វី ពេលណា ឯណា ហេតុអ្វី និងដូចម្តេច។

២. ព័ត៌មានពន្យល់បន្ថែម៖ ជួនកាល ចម្លើយទៅនឹងសំណួរ «ហេតុអ្វី?» និង «ដូចម្តេច?» ត្រូវបានយកមកដាក់នៅក្នុងផ្នែកនេះវិញ ជាជាងនៅក្នុងប្រយោគទីមួយ។

៣. ឯកសារយោង៖ ផ្តល់ព័ត៌មានគាំទ្រ សារតារឿង ឬសេចក្តីលម្អិតលំអិតបន្ទាប់បន្សំ ដើម្បីបំពេញបន្ថែមឱ្យព្រឹត្តិការណ៍កាន់តែពេញលេញ។

មេរៀនសង្ខេប

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីចំណុចសំខាន់ៗដូចខាងក្រោម៖

- ការជ្រើសរើសប្រធានបទ ព្រឹត្តិការណ៍ និងការវិវត្តថ្មីៗយកមកសរសេរ ដែលជាប្រធានបទទាក់ទាញចំណាប់អារម្មណ៍សាធារណជន និងស្របតាមចំណង់ចំណូលចិត្តរបស់ក្រុមទស្សនិកជនគោលដៅនៃស្ថាប័នផ្សព្វផ្សាយរបស់ខ្លួន។
- ការចាប់ផ្តើមសរសេរព័ត៌មាន ត្រូវអនុវត្តតាម “ទម្រង់ពីរ៉ាមីដធ្លាស់” ដោយបញ្ចាក់ព័ត៌មានសំខាន់បំផុត នៅក្នុងប្រយោគដំបូង។ សេចក្តីរាយការណ៍ដ៏រឹងមាំមួយ តែងឆ្លើយតបស្នើរតែទាំងអស់ ឬទាំងអស់ ទៅនឹងសំណួរ 5W1H ដូចជា៖
  - អ្វី (What)៖ តើមានអ្វីកើតឡើង?
  - នរណា (Who)៖ តើនរណាខ្លះពាក់ព័ន្ធ?
  - នៅឯណា (Where)៖ តើវាកើតឡើងនៅកន្លែងណា?
  - នៅពេលណា (When)៖ តើវាកើតឡើងនៅពេលណា?
  - ហេតុអ្វី (Why)៖ ហេតុអ្វីបានជាវាកើតឡើង?
  - របៀបណា (How)៖ តើហេតុការណ៍នេះកើតឡើងយ៉ាងដូចម្តេចខ្លះ?

សទ្ទានុក្រម

- **5W1H៖** សំណួរមូលដ្ឋាននៃដំណឹង រួមមាន នរណា អ្វី នៅពេលណា នៅឯណា ហេតុអ្វី និងដោយរបៀបណា។
- **ទម្រង់ពីរ៉ាមីដផ្ទារ៖** រចនាសម្ព័ន្ធនៃការសរសេរដែលចាប់ផ្តើមដោយព័ត៌មានសំខាន់បំផុត ហើយបន្តបង្ហាញព័ត៌មានដែលមិនសូវសំខាន់នៅផ្នែកខាងក្រោមនៃអត្ថបទ។
- **ការសម្ភាសន៍៖** ការចោទសួរសំណួរទៅកាន់បុគ្គលនានា ដើម្បីប្រមូលព័ត៌មាន។
- **ប្រធានបទ៖** សាច់រឿងគោលនៃសេចក្តីរាយការណ៍ដំណឹង។

លំហាត់អនុវត្តន៍

១. ការសម្ភាសអ្នកជំនាញ៖ ស្រាវជ្រាវ និងរៀបចំផែនការសម្ភាសន៍

សូមជ្រើសរើសប្រធានបទ ឬព្រឹត្តិការណ៍ណាមួយដែលពាក់ព័ន្ធនឹងខ្លួនអ្នកផ្ទាល់ ឬសហគមន៍។ បន្ទាប់មក សូមកំណត់យកអ្នក ជំនាញពិតប្រាកដ ឬអ្នកជំនាញក្នុងក្តីស្រមៃណាម្នាក់ ដែលទាក់ទងប្រធានបទនេះ។

- ស្រាវជ្រាវត្រួសៗអំពីប្រធានបទ និងអ្នកជំនាញនោះ។
- រៀបចំសំណួរបើកខ្លីៗចំនួន ៤ ទៅ ៥សំណួរ (ដែលផ្តើមដោយពាក្យ «យ៉ាងដូចម្តេច» ឬ «ហេតុអ្វី»)។
- សាកល្បងស្រមៃពីចម្លើយរបស់អ្នកជំនាញ ឬចុះសម្ភាសន៍គាត់ផ្ទាល់តែម្តង ប្រសិនបើមានលទ្ធភាព។
- ប្រសិនបើយើងចុះសម្ភាសន៍ផ្ទាល់ សូមស្តាប់ដោយយកចិត្តទុកដាក់ រួចសួរសំណួរបន្តបន្ទាប់ ដើម្បីស្វែងយល់បន្ថែម។
- ការថតសំឡេង គឺជាជម្រើស (យើងអាចថត ឬមិនថតក៏បាន)។

២. ព្រឹត្តិការណ៍ទៅជាដំណឹង៖ អនុវត្តការប្រើប្រាស់សំណួរ 5W1H

សូមជ្រើសរើសព្រឹត្តិការណ៍ណាមួយដែលយើងចង់ហ្វឹកហាត់ការសរសេរ។ សូមពិចារណា តើព្រឹត្តិការណ៍នោះមានអត្ថន័យ ឬមានសារៈសំខាន់សម្រាប់មនុស្សទូទៅដែរទេ។ ប្រសិនបើមាន សូមស្រាវជ្រាវ និងកត់ត្រាចម្លើយសម្រាប់សំណួរគន្លឹះ 5W1H ដូចខាងក្រោម៖

- នរណា (Who)៖ តើមាននរណាខ្លះពាក់ព័ន្ធ?
- អ្វី (What)៖ តើមានរឿងអ្វីកើតឡើង?
- ពេលណា (When)៖ តើហេតុការណ៍នេះកើតឡើងនៅពេលណា?
- ឯណា (Where)៖ តើហេតុការណ៍នេះកើតឡើងនៅកន្លែងណា?
- ហេតុអ្វី (Why)៖ ហេតុអ្វីបានជាហេតុការណ៍នេះកើតឡើង?
- របៀបណា (How)៖ តើហេតុការណ៍នេះកើតឡើងយ៉ាងដូចម្តេចខ្លះ?

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ឥឡូវនេះសូមប្រើប្រាស់ចម្លើយពីសំណួរទាំងនេះដើម្បីសរសេរជាអត្ថបទព័ត៌មានខ្លីមួយ។ សូមប្រាកដថា ព័ត៌មានដែលអ្នកសរសេរគឺមានភាពច្បាស់លាស់ ត្រឹមត្រូវតាមការពិត និងមិនបញ្ចូលមតិផ្ទាល់ខ្លួនឡើយ។

លំហាត់អនុវត្តន៍ជាមួយឧបករណ៍ | **MIL Chatbot | ជំពូកទី២៖ ដំណឹង និងព័ត៌មាន**

៣. ព័ត៌មាន និងដំណឹង៖ ស្វែងយល់បន្ថែម

សូមប្រើប្រាស់កម្មវិធី MIL Chatbot ហើយចូលទៅកាន់ជំពូកទី២៖ ព័ត៌មាន និងដំណឹង។ សូមឈ្វេងយល់អំពីភាពខុសគ្នារវាង ព័ត៌មាន និងដំណឹង ហើយអ្វីទៅជាប្រភពដែលគួរឱ្យទុកចិត្ត។

- សូមសាកល្បងសមត្ថភាពរបស់អ្នក ដើម្បីដោះស្រាយលំហាត់អំពីភាពជឿជាក់នៃប្រភពព័ត៌មាន។
- តើអ្នកអាចបែងចែករវាងប្រភពដែលគួរឱ្យទុកចិត្ត និងប្រភពដែលមិនគួរឱ្យទុកចិត្តបានដែរឬទេ?
- សូមពិនិត្យមើលការពន្យល់ ហើយមើលថាតើអ្នកអាចទទួលបានពិន្ទុចំនួនប៉ុន្មាន។

លំហាត់អនុវត្តន៍ជាមួយឧបករណ៍ | **MIL Chatbot | ជំពូកទី៧៖ ការសរសេរអត្ថបទព័ត៌មាន**

៤. ការសរសេរព័ត៌មាន និងការសម្ភាសន៍៖ រៀនសូត្រពីអ្នកជំនាញ

សូមប្រើប្រាស់កម្មវិធី MIL Chatbot ហើយចូលទៅកាន់ជំពូកទី៧៖ ការសរសេរព័ត៌មាន។ ចូលរៀនអំពីរបៀបសរសេរដំណឹង និងបច្ចេកទេសនៃការសម្ភាស ដោយទស្សនាវីដេអូទាំងពីរតាមរយៈតំណភ្ជាប់ ក្នុងជំពូកនោះ។

សំណួរសម្រាប់ពិភាក្សា

១. តើសំណួរមូលដ្ឋានទាំង៦ **(5W1H)** ដែលអត្ថបទព័ត៌មានគួរតែឆ្លើយតបមានអ្វីខ្លះ?
២. តើអ្វីទៅជាទម្រង់ **“ពីរ៉ាមីដផ្ទាល់”** ហើយហេតុអ្វីបានជាគេប្រើប្រាស់វាក្នុងការសរសេរព័ត៌មាន?
៣. តើកត្តាអ្វីខ្លះដែលធ្វើឱ្យប្រធានបទមួយមានតម្លៃជាព័ត៌មាន និងគួរឱ្យចាប់អារម្មណ៍ចំពោះសាធារណជនទូទៅ?
៤. តើអ្វីជាភាពខុសគ្នារវាង ការរាយការណ៍ផ្អែកលើអង្គហេតុ និងមតិផ្ទាល់ខ្លួន នៅក្នុងវិស័យសារព័ត៌មាន?
៥. ហេតុអ្វីបានជាការត្រៀមសំណួរទុកជាមុន មានសារៈសំខាន់មុនពេលធ្វើកិច្ចសម្ភាសន៍?
៦. តើសំណួរប្រភេទណាខ្លះដែលអ្នកគួរប្រើក្នុងអំឡុងពេលសម្ភាស ដើម្បីទទួលបានចម្លើយដែលមានព័ត៌មានលម្អិត?

ជំពូកទី២

អក្ខរកម្មឌីជីថល និងទំនួលខុសត្រូវ

មេរៀនទី១៖ អក្ខរកម្មឌីជីថល
មេរៀនទី២៖ អក្ខរកម្មទិន្នន័យ
មេរៀនទី៣៖ ក្រមសីលធម៌ និងទំនួលខុសត្រូវក្នុងប្រព័ន្ធផ្សព្វផ្សាយ
មេរៀនទី៤៖ សុខុមាលភាពឌីជីថល

មេរៀនទី ១ អក្ខរកម្មឌីជីថល



ជំពូកទី១

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

ក. តើអក្ខរកម្មឌីជីថលជាអ្វី?

ខ. សារៈសំខាន់នៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានក្នុងសម័យឌីជីថល

គ. តើអ៊ីនធឺណិត អ៊ីមែល និងបណ្តាញផ្សព្វផ្សាយសង្គមជាអ្វី?

ឃ. សុវត្ថិភាព និងឯកជនភាពនៅលើអ៊ីនធឺណិត

ហេតុអ្វីបានជាមេរៀននេះសំខាន់?

ការមានចំណេះដឹងអក្ខរកម្មឌីជីថល មានន័យថាអ្នកចេះប្រើប្រាស់អ៊ីនធឺណិត អ៊ីមែល និងបណ្តាញសង្គមដោយសុវត្ថិភាព និងមានប្រសិទ្ធភាព។ លើសពីនេះ អក្ខរកម្មឌីជីថលក៏ផ្តល់នូវចំណេះដឹងផ្នែកឯកជនភាព ដែលចាំបាច់សម្រាប់ការការពារខ្លួននៅលើប្រព័ន្ធអនឡាញផងដែរ។

ក. តើអក្ខរកម្មឌីជីថលជាអ្វី?

យោងតាមសមាគមបណ្ណាល័យអាមេរិក (ALA) អក្ខរកម្មឌីជីថល សំដៅលើសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ដើម្បីស្វែងរក វាយតម្លៃ បង្កើត និងប្រាស្រ័យទាក់ទងព័ត៌មាន។ សមត្ថភាពនេះ ទាមទារឱ្យមានទាំងចំណេះដឹង និងជំនាញបច្ចេកទេស។

សិស្សានុសិស្សដែលមានចំណេះដឹងឌីជីថលដឹងពីរបៀបស្វែងរក ប្រើប្រាស់ ទាក់ទង និងចែករំលែកមាតិកាឌីជីថលទាំងនោះផងដែរ។ សិស្សដែលកំពុងអភិវឌ្ឍជំនាញឌីជីថល នឹងយល់ដឹងពីមូលដ្ឋានគ្រឹះនៃសុវត្ថិភាពអនឡាញដូចជា ការបង្កើតពាក្យសម្ងាត់រឹងមាំ ការយល់ដឹងនិងការប្រើប្រាស់មុខងារឯកជនភាព ព្រមទាំងដឹងថាអ្វីគួរចែករំលែកនិងអ្វីដែលមិនគួរចែករំលែកនៅលើបណ្តាញសង្គម។ សិស្សអាចយល់ច្បាស់ពីគ្រោះថ្នាក់នៃការគំរាមកំហែងតាមអនឡាញ ហើយព្យាយាមបញ្ឈប់ការបង្កទុក្ខបុកម្នេញតាមអនឡាញដែលកំពុងកើតឡើង ព្រមទាំងជួយការពារអ្នកដទៃពីការគំរាមកំហែងទាំងនេះ។

នៅក្នុងពិភពឌីជីថលបច្ចុប្បន្នស្ទើរតែគ្រប់អាជីពការងារទាំងអស់ សុទ្ធតែទាមទារនូវជំនាញទំនាក់ទំនងបែបឌីជីថល។ ដូច្នេះការបំពាក់បំប៉នសិស្សានុសិស្សនូវជំនាញក្នុងការស្វែងរក វាយតម្លៃ ប្រាស្រ័យទាក់ទង និងចែករំលែកមាតិកាតាមអនឡាញគឺជាគន្លឹះដ៏សំខាន់បំផុតសម្រាប់អនាគតរបស់ពួកគេ។



រូបភាព ១.១ ទំនាក់ទំនងរវាងមនុស្ស និងប្រព័ន្ធឌីជីថល

ខ. សារៈសំខាន់នៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានក្នុងសម័យឌីជីថល

អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន គឺជាមូលដ្ឋានគ្រឹះសម្រាប់ការអាន សរសេរ វិភាគ វាយតម្លៃ និងការបង្កើតមាតិកានៅលើប្រភេទប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដូចជា កាសែត ទស្សនាវដ្តី ទូរទស្សន៍ វិទ្យុ និងអ៊ីនធឺណិត។ ដោយសារភាពជឿនលឿនផ្នែកឌីជីថល ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីជាច្រើន (កាសែត ទស្សនាវដ្តី ទូរទស្សន៍ និងវិទ្យុ) ក៏មានវត្តមាននៅលើថ្នាលឌីជីថលផងដែរ។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ដូច្នេះហើយអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់យើងទាំងអស់គ្នាក្នុងយុគសម័យឌីជីថល ដោយជួយឱ្យយើងទទួលបានសមត្ថភាព និងជំនាញក្នុងការបង្កើតការគិតបែបត្រិះរិះពិចារណា ព្រមទាំងយល់ពីរបៀបដែលប្រព័ន្ធផ្សព្វផ្សាយតាមអ៊ីនធឺណិតរួមចំណែកក្នុងការផ្លាស់ប្តូរ ការអភិវឌ្ឍវប្បធម៌ និងសង្គម។

ចំណេះដឹងអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ជួយយើងយល់ពីប្រភេទសារផ្សេងៗគ្នាតាមប្រព័ន្ធផ្សព្វផ្សាយ យល់ពីអ្វីដែលអ្នកផលិតមាតិកាចង់ឱ្យយើងជឿឬធ្វើតាម ព្រមទាំងអាចស្គាល់ពីយុទ្ធសាស្ត្រទីផ្សារ បច្ចេកទេសបញ្ចុះបញ្ចូល និងប្រភេទសារជាច្រើនទៀត ដូចដែលបានរៀបរាប់ក្នុងជំពូកអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានខាងលើ។

អ្វីដែលសំខាន់បំផុតនោះយើងអាចផ្តល់មតិកែលម្អដើម្បីផ្លាស់ប្តូរប្រព័ន្ធផ្សព្វផ្សាយឌីជីថល នៅពេលដែលយើងអាចកំណត់បានថា ព័ត៌មានដែលកំពុងត្រូវបានចែករំលែកនោះមានលក្ខណៈលម្អៀងប្រឌិត ខុសឆ្គង ឬក្លែងក្លាយ។ យើងក៏អាចបង្កើតនិងចែករំលែកសាររបស់យើងផ្ទាល់ ដោយផ្អែកលើចំណេះដឹង ជំនាញ ជំនឿ និងគុណតម្លៃផងដែរ។ យើងក៏អាចជួយទប់ស្កាត់ការរីករាលដាលនៃព័ត៌មានខុស ព័ត៌មានមិនពិត និងការបោកប្រាស់ផ្សេងៗនៅលើអ៊ីនធឺណិត។

គ. តើអ៊ីនធឺណិត អ៊ីមែល និងបណ្តាញផ្សព្វផ្សាយសង្គមជាអ្វី?

អ៊ីនធឺណិត

អ៊ីនធឺណិតគឺជាមធ្យោបាយទំនាក់ទំនង និងចែករំលែកព័ត៌មានដ៏ធំបំផុតនៅលើពិភពលោក។ វាជួយសម្រួលដល់ការទទួលបានព័ត៌មាន ដែលចែកចាយដោយអ្នកប្រើប្រាស់រាប់លានទាក់ ចាប់ពីបុគ្គលម្នាក់ៗ រហូតដល់ស្ថាប័ន និងក្រុមហ៊ុនធំៗ។ ព័ត៌មានភាគច្រើន ត្រូវបានបើកទូលាយសម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិតគ្រប់រូប។ លើសពីនេះវាក៏អនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចទាក់ទងគ្នាទៅវិញទៅមក តាមរយៈអក្សរ សំឡេង វីដេអូ។



រូបភាព ១.២ ការប្រើប្រាស់អ៊ីនធឺណិត

អ៊ីនធឺណិត គឺជាបណ្តាញកុំព្យូទ័ររូបវន្ត ដែលអាចចូលប្រើប្រាស់ និងដំណើរការព័ត៌មាន តាមរយៈឧបករណ៍ផ្សេងៗទៀតដូចជា ទូរសព្ទដៃ ដែលបានភ្ជាប់ទៅនឹងបណ្តាញនេះ។ ការភ្ជាប់កុំព្យូទ័រទៅកាន់អ៊ីនធឺណិត អាចធ្វើឡើងតាមរយៈខ្សែកាបបណ្តាញឥតខ្សែក្នុងតំបន់ (Wi-Fi) ឬតាមរយៈទូរសព្ទដៃ។

រាល់ព័ត៌មាននៅលើអ៊ីនធឺណិត ត្រូវបានរក្សាទុកនៅលើកុំព្យូទ័រណាមួយក្នុងចំណោមកុំព្យូទ័ររាប់លានគ្រឿងទូទាំងពិភពលោក ដែលតភ្ជាប់គ្នាបង្កើតបានជាបណ្តាញអ៊ីនធឺណិតនេះឡើង។ កុំព្យូទ័រទាំងនេះត្រូវបានគេហៅថា ម៉ាស៊ីនមេអ៊ីនធឺណិត (Internet Servers) ឬហៅកាត់ថា ម៉ាស៊ីនមេ ដែលតែងតែបើកដំណើរការជានិច្ចដើម្បីធានាថាព័ត៌មានដែលរក្សាទុកនៅក្នុងនោះ អាចចូលប្រើប្រាស់បានគ្រប់ពេលវេលា។

អ្នកប្រើប្រាស់ត្រូវបង់សេវាអ៊ីនធឺណិតដែលផ្តល់ដោយក្រុមហ៊ុនណាមួយដើម្បីអាចប្រើប្រាស់បាន។ អ្នកផ្តល់សេវាអាចជាក្រុមហ៊ុនឯកទេស (ក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត) ដែលផ្តល់សេវាភ្ជាប់អ៊ីនធឺណិតតាមរយៈខ្សែទូរសព្ទ តាមរយៈខ្សែកាបពិសេសដែលប្រើពន្លឺជំនួសចរន្តអគ្គិសនីដើម្បីបញ្ជូនព័ត៌មាន (ខ្សែកាបអុបទិក) ឬតាមរយៈបច្ចេកវិទ្យាឥតខ្សែ។ សេវាភ្ជាប់អ៊ីនធឺណិតនេះ ក៏អាចផ្តល់ដោយក្រុមហ៊ុនទូរសព្ទផងដែរ។ ដោយឡែក សម្រាប់អ្នកប្រើប្រាស់កុំព្យូទ័រយួរដៃ មានកន្លែងជាច្រើនដូចជា ភោជនីយដ្ឋាន និងហាងកាហ្វេ ដែលតែងតែផ្តល់សេវាអ៊ីនធឺណិតឥតខ្សែដោយឥតគិតថ្លៃជូនដល់អតិថិជនរបស់ពួកគេ។

អ៊ីមែល



រូបភាព ១.៣ ការប្រើប្រាស់អ៊ីមែល

អ៊ីមែលជាមធ្យោបាយទំនាក់ទំនងដ៏ពេញនិយមមួយដែលជាសេវាកម្មទំនាក់ទំនងអកម្ម ដែលមានន័យថា អ្នកផ្ញើ និងអ្នកទទួល មិនចាំបាច់ភ្ជាប់អ៊ីនធឺណិតក្នុងពេលតែមួយនោះទេ។ អ្នកផ្ញើ អាចសរសេរ និងផ្ញើសារនៅពេលណាក៏បានដែលពួកគេមានអ៊ីនធឺណិត ហើយសារនោះនឹងត្រូវបានរក្សាទុកនៅលើម៉ាស៊ីនមេ។ វានឹងត្រូវបានបញ្ជូនទៅកាន់អ្នកទទួល នៅពេលដែលពួកគេភ្ជាប់អ៊ីនធឺណិត។ ខ្លឹមសារអ៊ីមែលដែលបានផ្ញើនិងទទួលអាចរក្សាទុកអចិន្ត្រៃយ៍នៅលើម៉ាស៊ីនមេដែលដើរតួជាកន្លែងកត់ត្រានូវរាល់ព័ត៌មានដែលយើងបានផ្ញើ និងទទួល។ អ៊ីមែល ក៏អាចត្រូវបានប្រើប្រាស់ដើម្បីផ្ញើឯកសារ (ឯកសារសំណេរ រូបភាព វីដេអូ សំឡេង ។ល។) ពីអ្នកប្រើប្រាស់ម្នាក់ទៅកាន់អ្នកប្រើប្រាស់ម្នាក់ទៀតផងដែរ។ មានសេវាកម្មអ៊ីមែលឥតគិតថ្លៃជាច្រើនដូចជា Gmail របស់ក្រុមហ៊ុន Google ខណៈដែលសេវាកម្មមួយចំនួនទៀតទាមទារឱ្យអ្នកបង់ប្រាក់ដើម្បីអាចប្រើប្រាស់ ឬដើម្បីទទួលបានមុខងារកម្រិតខ្ពស់។

បណ្តាញផ្សព្វផ្សាយសង្គម

បណ្តាញសង្គមសំដៅលើគេហទំព័រ និងកម្មវិធីទូរសព្ទ ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចបង្កើតនិងចែករំលែកមាតិកាទៅកាន់បណ្តាញទំនាក់ទំនង ឬសហគមន៍របស់ពួកគេ។ អ្នកប្រើប្រាស់ត្រូវបង្កើតគណនីមួយ រួចទើបអាចភ្ជាប់ទំនាក់ទំនងជាមួយអ្នកប្រើប្រាស់ផ្សេងទៀតតាមវិធីជាច្រើនដូចជា ការចែករំលែករូបថត វីដេអូ ការជជែកកម្សាន្តតាមអនឡាញ និងការបង្កើតក្រុមជាមួយអ្នកដែលមានចំណូលចិត្តដូចគ្នា។

បណ្តាញសង្គមដូចជា Facebook បានក្លាយជាប្រភពផ្តល់ដំណឹងដ៏សំខាន់សម្រាប់មនុស្សទូទៅ។ ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ដូចជា កាសែត វិទ្យុ និងទូរទស្សន៍ តែងតែចែករំលែកមាតិកានៅលើបណ្តាញសង្គម ឬបង្កើតមាតិកាពិសេសសម្រាប់វេទិកាទាំងនេះ ពីព្រោះមនុស្សចំណាយពេលនៅទីនោះច្រើនជាងនៅលើវេបសាយផ្ទាល់របស់ស្ថាប័នទាំងនោះទៅទៀត។ ប្រសិនបើអ្នកប្រើប្រាស់ចូលចិត្តមាតិកាណាមួយ ពួកគេអាចចែករំលែកវាទៅកាន់បណ្តាញទំនាក់ទំនងរបស់ពួកគេ (មិត្តភក្តិ ឬអ្នកតាមដាន) បានដោយផ្ទាល់។ បណ្តាញសង្គមបានក្លាយជាវេទិកាចែកចាយព័ត៌មានដ៏មានសារៈសំខាន់បំផុត។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh



រូបភាព ១.៤ ការប្រើប្រាស់បណ្តាញសង្គម

ឧទាហរណ៍៖ បណ្តាញសង្គមដ៏ពេញនិយម មានដូចជា Facebook, YouTube, TikTok និង Instagram ដែលកំពុងនាំមុខគេនៅលើទីផ្សារពិភពលោក។

បណ្តាញសង្គមជាច្រើនមិនអាចចូលប្រើប្រាស់បាននៅទូទាំងសកលលោកនោះទេ ដោយសារប្រទេសមួយចំនួនបានហាមឃាត់បណ្តាញសង្គមជាក់លាក់ណាមួយ ហើយមានបណ្តាញសង្គមផ្ទាល់ខ្លួនរបស់ពួកគេ។ ឧទាហរណ៍៖ នៅក្នុងប្រទេសចិន សេវាកម្ម Facebook, Instagram និង Google ត្រូវបានហាមឃាត់។ ពួកវាត្រូវបានជំនួសដោយកម្មវិធីបណ្តាញសង្គមផ្ទាល់ខ្លួនរបស់ប្រទេសនេះ ដូចជា WeChat ជាដើម។

ឃ. សុវត្ថិភាព និងឯកជនភាពនៅលើអ៊ីនធឺណិត

ហានិភ័យដ៏ធំមួយដែលពាក់ព័ន្ធនឹងបណ្តាញសង្គម ជាការរីករាលដាលនៃព័ត៌មានខុស។ អ្នកប្រើប្រាស់បណ្តាញសង្គម អាចត្រូវបានគេបំភាន់យ៉ាងងាយឱ្យគិតថាព័ត៌មានដែលពួកគេឃើញនៅលើវេទិកាទាំងនេះអាចជឿទុកចិត្តបាន។ ដោយសារគ្រប់គ្នាអាចបង្ហោះព័ត៌មានអ្វីក៏បាន ដូច្នេះ ព័ត៌មានមិនពិត និងព័ត៌មានបំភាន់កើតមានជាទូទៅ ហើយអាចបង្កជាគ្រោះថ្នាក់ថែមទៀតផង។ ព័ត៌មានមិនពិតភាគច្រើន ត្រូវបានគេបង្កើតឡើង និងចែករំលែកដោយចេតនា ដើម្បីញុះញង់ឱ្យមានការស្អប់ខ្ពើម ការភ័យខ្លាច ឬគំនុំគុំកួន ដែលជារឿយៗតែងតែផ្តោតគោលដៅលើក្រុមជនជាតិភាគតិច អ្នកដែលមានជំនឿនយោបាយ សាសនាខុសគ្នា ឬសមាជិកនៃក្រុមជនជាតិផ្សេងៗ។



រូបភាព ១.៥ សុវត្ថិភាព និងឯកជនភាពនៅលើអ៊ីនធឺណិត

បណ្តាញសង្គម អនុញ្ញាតឱ្យអ្នកប្រើប្រាស់ចែករំលែកព័ត៌មានជាមួយគ្នាទៅវិញទៅមក។ ប៉ុន្តែ អ្នកប្រើប្រាស់ត្រូវតែពិចារណាឱ្យបានម៉ត់ចត់អំពីព័ត៌មានដែលពួកគេចែករំលែកនៅទីនោះ។ ប្រសិនបើនរណាម្នាក់ដែលអ្នកមិនស្គាល់បានឃើញអ្វីដែលអ្នកបានចែករំលែក វាអាចមានន័យថាជាការរំលោភបំពានលើឯកជនភាពរបស់អ្នក។

ដោយសារភាពងាយស្រួលនៃការចែករំលែករឿងរ៉ាវដោយអនាមិកនៅលើប្រព័ន្ធអនឡាញ ជំរុញការធ្វើទុក្ខបុកម្នេញ និងជនរាយប្រហារតាមអនឡាញក៏អាចបង្ហោះសារប្រមាថ ការគំរាមកំហែង ប្រមូលព័ត៌មាន ឬបង្កើតគណនីក្លែងក្លាយបានយ៉ាងងាយស្រួលផងដែរ។ ហានិភ័យចម្បងៗ គឺពាក់ព័ន្ធនឹងសុវត្ថិភាព និងឯកជនភាពរបស់អ្នក។ ការបង្ហោះ ឬការបញ្ចូលព័ត៌មានផ្ទាល់ខ្លួននៅលើប្រព័ន្ធអនឡាញអាចធ្វើឱ្យអ្នកប្រឈមនឹងហានិភ័យដែលទិន្នន័យរបស់អ្នកត្រូវបានគេលួចយក ដោយគ្មានការអនុញ្ញាត។

តើឯកជនភាពជាអ្វី? ហេតុអ្វីអ្នកគួរយកចិត្តទុកដាក់លើរឿងនេះ?

រឿងផ្ទាល់ខ្លួនសំដៅលើអ្វីមួយដែលមានភាពពិសេសសម្រាប់រូបអ្នក ឬជាអាថ៌កំបាំងដែលអ្នកមិនចង់ឱ្យអ្នកដទៃដឹង។ វិសាលភាពនិងខ្លឹមសារនៃការកំណត់រឿងផ្ទាល់ខ្លួន អាចមានការប្រែប្រួលអាស្រ័យលើវប្បធម៌ និងបុគ្គលម្នាក់ៗ តែមានចំណុចទូទៅមួយចំនួនដែលមនុស្សភាគច្រើនចាត់ទុកថាជារឿងឯកជន។ ឧទាហរណ៍៖ អ្នកមិនចង់ឱ្យអ្នកដទៃដឹងពីទីលំនៅ ថ្ងៃខែឆ្នាំកំណើត ឬប្រាក់ចំណូលរបស់អ្នកនោះទេ។ ឯកជនភាពជាសមត្ថភាព ឬសិទ្ធិរបស់បុគ្គលម្នាក់ៗក្នុងការគ្រប់គ្រង និងការពារផ្នែកខ្លះនៃជីវិត ក៏ដូចជាព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ ពីការដឹងឮរបស់អ្នកដទៃ។

បញ្ហាឯកជនភាពកើតឡើងនៅលើបណ្តាញសង្គមគ្រប់ពេលវេលា មិនមែនគ្រាន់តែនៅពេលអ្នកកែសម្រួលការកំណត់ឯកជនភាពលើបណ្តាញផ្សព្វផ្សាយសង្គមរបស់អ្នកប៉ុណ្ណោះទេ ប៉ុន្តែវាកើតមាននៅក្នុងរាល់សកម្មភាពទំនាក់ទំនងរបស់អ្នក។ នៅពេលអ្នកចែករំលែកព័ត៌មានកាន់តែច្រើននៅលើបណ្តាញផ្សព្វផ្សាយសង្គម និងចំណាយពេលកាន់តែច្រើនជាមួយវា ឯកជនភាពរបស់អ្នកនឹងកាន់តែតិចទៅ ហើយអ្នកកំពុងតែផ្តល់ទិន្នន័យរបស់អ្នកកាន់តែច្រើនទៅឱ្យគេ។ ទិន្នន័យរបស់អ្នកត្រូវបានរក្សាទុកនិងចែករំលែក ហើយអ្នកមិនអាចគ្រប់គ្រងបានទេថា តើក្រុមហ៊ុនអាជីវកម្ម ស្ថាប័ន ឬភ្នាក់ងារស៊ើបការណ៍សម្ងាត់ប្រើប្រាស់ទិន្នន័យនោះដោយរបៀបណា។ ទោះបីជាអ្នកគិតថាមិនមានអ្វីគួរឱ្យព្រួយបារម្ភនៅថ្ងៃនេះក៏ដោយ ក៏ស្ថានភាពអាចផ្លាស់ប្តូរបានដែរ។ ទិន្នន័យរបស់អ្នកបានរក្សាទុកដោយគ្មានពេលកំណត់ អ្នកមិនមានអំណាចគ្រប់គ្រងលើអ្វីដែលគេយកវាទៅធ្វើនោះទេ ហើយក៏គ្មានមធ្យោបាយណាមួយដើម្បីលុបវាចោលបានទាំងស្រុងនោះដែរ។



រូបភាព ១.៦ សុវត្ថិភាព និងឯកជនភាពនៅលើអ៊ីនធឺណិត

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

បទល្មើសបច្ចេកវិទ្យា សំដៅលើបទល្មើសឬសកម្មភាពខុសច្បាប់ ដែលត្រូវបានប្រព្រឹត្តឡើងនៅលើឬតាមរយៈការប្រើប្រាស់អ៊ីនធឺណិត។ បទល្មើសបច្ចេកវិទ្យាបានរីករាលដាលយ៉ាងខ្លាំង និងបង្កជាបញ្ហាប្រឈមដល់វិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិសកល។ នៅក្នុងវិស័យបច្ចេកវិទ្យាព័ត៌មានដែលមានការផ្លាស់ប្តូរឥតឈប់ឈរ អ្នកជំនាញផ្នែកសន្តិសុខប្តេជ្ញាប្រយុទ្ធប្រឆាំងនឹងបទល្មើសបច្ចេកវិទ្យាតាមរយៈបច្ចេកវិទ្យាទប់ស្កាត់ជាមុន ដូចជាប្រព័ន្ធចាប់សញ្ញាជ្រៀតចូលជាដើម។

បទល្មើសបច្ចេកវិទ្យាជាបញ្ហាសុគស្មាញព្រោះវាច្រើនពាក់ព័ន្ធនឹងមនុស្សមកពីតំបន់ និងទីតាំងភូមិសាស្ត្រផ្សេងៗគ្នា ដែលធ្វើឱ្យពិបាកក្នុងការស្វែងរក និងដាក់ទោសទណ្ឌដល់ជនល្មើស។ សកម្មភាពបទល្មើសបច្ចេកវិទ្យារួមមាន៖

- ការយាយី និងការបង្កទុក្ខបុកម្នេញតាមអនឡាញ
- ការសម្លុតទារប្រាក់
- ការគំរាមកំហែងតាមអនឡាញពីការបន្ទុះគ្រាប់បែក
- ការលួចទិន្នន័យសន្តិសុខ
- ការជួញដូរពាក្យសម្ងាត់
- ការលួចអាថ៌កំបាំងពាណិជ្ជកម្មរបស់ក្រុមហ៊ុន
- ការលួចទិន្នន័យផ្ទាល់ខ្លួន
- ការរំលោភលើកម្មសិទ្ធិបញ្ញា ដូចជាការលួចចម្លងកម្មវិធីកុំព្យូទ័រ
- ការប្រើប្រាស់ពាណិជ្ជសញ្ញាក្លែងក្លាយ
- ការជួញដូរអាវុធខុសច្បាប់
- ការចែករំលែករូបភាពអាសអាភាសកុមារតាមអនឡាញ
- ការលួច និងការបោកប្រាស់បណ្ណឥណទាន
- ការបោកប្រាស់តាមអ៊ីមែល
- ការចែកចាយមេរោគជាដើម។



រូបភាព ១.៧ បទល្មើសបច្ចេកវិទ្យា

តើការបង្កទុក្ខបុកម្នេញតាមអនឡាញជាអ្វី?

ការបង្កទុក្ខបុកម្នេញតាមអនឡាញជាទម្រង់នៃការសម្លុតនិងការយាយី ដែលប្រើប្រាស់មធ្យោបាយអេឡិចត្រូនិក។ ឧទាហរណ៍៖ ការផ្សព្វផ្សាយរឿងភូតកុហកនៅលើបណ្តាញផ្សព្វផ្សាយសង្គម ការផ្ញើសារស្អប់ខ្ពើម ឬសារគំរាមកំហែងទៅកាន់នរណាម្នាក់តាមទូរសព្ទ។ ការបង្កទុក្ខបុកម្នេញតាមអនឡាញតែងផ្តោតគោលដៅលើបុគ្គលណាម្នាក់។ ជនបង្កទុក្ខបុកម្នេញវាយប្រហារជនរងគ្រោះម្តងហើយម្តងទៀត ដោយមានបំណងបង្កឱ្យមានគ្រោះថ្នាក់ ដែលអាចកើតចេញពីមនុស្សតែម្នាក់ ឬជាក្រុមមនុស្សដែលធ្វើការរួមគ្នាដើម្បីវាយប្រហារជនរងគ្រោះ។

ការធ្វើទុក្ខបុកម្នេញតាមអនឡាញ អាចកើតឡើងក្នុងពេលដំណាលគ្នានឹងការធ្វើទុក្ខបុកម្នេញខាងក្រៅផ្ទាល់ផងដែរ ដូចជានៅសាលារៀនឬកន្លែងធ្វើការ។ វាអាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់មនុស្ស។ ជនរងគ្រោះមានអារម្មណ៍ថាពួកគេកំពុងរងការវាយប្រហារ២៤ម៉ោងក្នុងមួយថ្ងៃ និងគ្រប់ទីកន្លែងដែលធ្វើឱ្យពួកគេមានអារម្មណ៍ហត់នឿយ ភ័យខ្លាច និងខ្មាសអៀន។ ក្នុងករណីជាច្រើន អារម្មណ៍ខ្មាសអៀនទាំឱ្យពួកគេគេចវេសពីការប្រាប់អ្នកដទៃ ឬស្វែងរកជំនួយ។

ការវាយប្រហារតាមអនឡាញគឺជាការលំបាកសម្រាប់ជនរងគ្រោះ ប៉ុន្តែវាងាយស្រួលសម្រាប់ជនល្មើសក្នុងការចាប់ផ្តើម និងបន្តធ្វើ។ ជនបង្កទុក្ខបុកម្នេញគ្រាន់តែដើម្បីការកម្សាន្តផ្ទាល់ខ្លួន ឬដើម្បីចង់ឃើញប្រតិកម្មតបត។ នៅពេលដែលក្រុមបង្កទុក្ខបុកម្នេញ ផ្តោតគោលដៅលើជនរងគ្រោះ សមាជិកក្រុមម្នាក់ៗព្យាយាមធ្វើបាបម្តងហើយម្តងទៀតដល់ជនរងគ្រោះនៅខាងក្រៅផ្ទាល់ផងដែរ។ ទោះបីជាការជេរប្រមាថនីមួយៗជារឿងតូចតាចក៏ដោយ ប៉ុន្តែបន្តិចម្តងៗ ឥទ្ធិពលនេះអាចកើនឡើងយ៉ាងពិតប្រាកដ និងមានផលប៉ះពាល់ខ្លាំងដល់ជនរងគ្រោះ។

ដើម្បីទប់ស្កាត់ការបង្កទុក្ខបុកម្នេញតាមអនឡាញ អ្នកអប់រំចាំបាច់ក្នុងការធ្វើឱ្យយុវជនយល់ដឹងអំពីគ្រោះថ្នាក់ដែលបង្កឡើងដោយការបង្កទុក្ខបុកម្នេញតាមអនឡាញ ឱ្យពួកគេប្រព្រឹត្តប្រកបដោយក្រមសីលធម៌នៅលើអនឡាញ ឱ្យមានទំនាក់ទំនងប្រកបដោយការគោរព និងទទួលខុសត្រូវ។ ការប្រព្រឹត្តមិនសមរម្យនៅលើអនឡាញ ប៉ះពាល់ដល់របៀបដែលយើងប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកនៅខាងក្រៅ។ វាអាចបំផ្លាញទំនាក់ទំនងរបស់យើង និងកាត់បន្ថយទំនុកចិត្ត។ វាជារឿងសំខាន់ណាស់ដែលយើងទាំងអស់គ្នាចូលរួមក្នុងការបញ្ឈប់ការបង្កទុក្ខបុកម្នេញតាមអនឡាញ។ ជនរងគ្រោះគួរតែប្រាប់ឱ្យគេបានដឹងភ្លាមៗ នៅពេលដែលមានបញ្ហាកើតឡើង មុនពេលរឿងរ៉ាវហួសពីការគ្រប់គ្រងរបស់ខ្លួន។ យើងគួរតែថតរូបអេក្រង់ឬរក្សាទុកអ៊ីមែលដែលពួកគេទទួលបានដើម្បីប្រើជាភស្តុតាង។ ជនល្មើសត្រូវយល់ថាឥរិយាបថរបស់ពួកគេបង្កគ្រោះថ្នាក់ដល់អ្នកដទៃជាការខុសច្បាប់។ អ្នកឃើញហេតុការណ៍ គួរតែដឹងថាពួកគេត្រូវធ្វើអ្វីមួយដើម្បីបញ្ចាក់ឱ្យកាន់តែច្បាស់ការបង្កទុក្ខបុកម្នេញតាមអនឡាញ ជាទង្វើដែលមិនអាចទទួលយកបានឡើយ។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

មេរៀនសង្ខេប

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីចំណុចសំខាន់ៗដូចខាងក្រោម៖

- អក្ខរកម្មឌីជីថល ជាសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដើម្បីស្វែងរក ការវាយតម្លៃ បង្កើត និងការប្រាស្រ័យទាក់ទង ដែលទាមទារទាំងចំណេះដឹង និងជំនាញបច្ចេកទេស។
- អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន មានសារៈសំខាន់នៅក្នុងសម័យឌីជីថល ពីព្រោះវាជួយឱ្យយើងទទួលបានសមត្ថភាព និងជំនាញក្នុងការបង្កើត ការគិតបែបត្រិះរិះ ការយល់ដឹងពីរបៀបដែលសារព័ត៌មានតាមអនឡាញចូលរួមក្នុងការផ្លាស់ប្តូរ អភិវឌ្ឍវប្បធម៌ និងសង្គម។
- អ៊ីនធឺណិត ជាបណ្តាញកុំព្យូទ័រដែលអាចចូលប្រើនិងដំណើរការព័ត៌មានតាមរយៈកុំព្យូទ័រ ឬឧបករណ៍ផ្សេងទៀតដូចជា ទូរសព្ទដៃដែលបានភ្ជាប់ទៅវា។ ការតភ្ជាប់កុំព្យូទ័រទៅអ៊ីនធឺណិតអាចធ្វើឡើងតាមរយៈខ្សែទូរសព្ទ ខ្សែកាបអុបទិក ខ្សែកាបទូរទស្សន៍ ការតភ្ជាប់ឥតខ្សែក្នុងតំបន់ ឬទូរសព្ទដៃ។
- អ៊ីមែល ជាសេវាកម្មផ្ញើសារអេឡិចត្រូនិក ដែលអនុញ្ញាតឱ្យអ្នកផ្ញើសារទៅកាន់គ្នាទៅវិញទៅមក។
- បណ្តាញផ្សព្វផ្សាយសង្គម ជាវេបសាយ និងកម្មវិធីទូរសព្ទដៃ ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់បង្កើត និងចែករំលែកមាតិកា ដូចជាការចែករំលែករូបភាព និងវីដេអូ ការជជែកឆ្លើយឆ្លងគ្នា និងការបង្កើតក្រុមដែលរួមបញ្ចូលអ្នកប្រើប្រាស់ដែលមានចំណាប់អារម្មណ៍ដូចគ្នា។
- ហានិភ័យចម្បងមួយដែលពាក់ព័ន្ធនឹងបណ្តាញផ្សព្វផ្សាយសង្គម គឺការរីករាលដាលនៃព័ត៌មានខុស។ អ្នកប្រើប្រាស់បណ្តាញផ្សព្វផ្សាយសង្គមអាចងាយនឹងយល់ច្រឡំថា ព័ត៌មានដែលពួកគេឃើញនៅលើថ្នាលទាំងនេះគឺត្រឹមត្រូវ។ នេះហើយជាមូលហេតុដែលចំណេះដឹងអំពីប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ព្រមទាំងឯកជនភាព និងសុវត្ថិភាពអនឡាញ មានសារៈសំខាន់ខ្លាំងណាស់សម្រាប់មនុស្សគ្រប់រូប។

សទ្ទានុក្រម

- **ការបង្កទុក្ខបុកម្នេញតាមអនឡាញ៖** ករណី ឬយុទ្ធនាការចំអកឡកឡាយ និងការយាយីតាមអ៊ីនធឺណិត។
- **បទល្មើសបច្ចេកវិទ្យា៖** សកម្មភាពខុសច្បាប់ដែលត្រូវបានប្រព្រឹត្តនៅលើ ឬតាមរយៈការប្រើប្រាស់អ៊ីនធឺណិត។
- **អក្ខរកម្មឌីជីថល៖** សមត្ថភាពក្នុងការប្រើប្រាស់ឧបករណ៍ឌីជីថល ដូចជាកុំព្យូទ័រ និងវេទិកាអនឡាញដោយសុវត្ថិភាព និងមានប្រសិទ្ធភាព។
- **អ៊ីនធឺណិត៖** បណ្តាញសកលដែលតភ្ជាប់កុំព្យូទ័រ និងចែករំលែកព័ត៌មាន។
- **អ៊ីមែល៖** សារអេឡិចត្រូនិកដែលផ្ញើតាមអ៊ីនធឺណិត។
- **ឯកជនភាព៖** ការរក្សាព័ត៌មានផ្ទាល់ខ្លួនឱ្យមានសុវត្ថិភាពពីអ្នកដទៃ។
- **បណ្តាញផ្សព្វផ្សាយសង្គម៖** វេទិកាឌីជីថលដូចជា Facebook និង TikTok ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់បង្កើត និងចែករំលែកមាតិកាជាមួយបណ្តាញនានា។

លំហាត់អនុវត្តន៍

១. សកម្មភាពរបស់អ្នកលើបណ្តាញសង្គម៖ ការឆ្លុះបញ្ចាំងលើបណ្តាញផ្សព្វផ្សាយ ឬកម្មវិធីផ្សេងៗ

សូមយកបិក និងក្រដាស រួចសរសេរឈ្មោះបណ្តាញសង្គម និងកម្មវិធីទូរសព្ទផ្សេងៗ ដែលអ្នកប្រើប្រាស់។ បន្ទាប់មក សូមជ្រើសរើសយកបណ្តាញសង្គមណាមួយដែលអ្នកប្រើប្រាស់ច្រើនជាងគេបំផុត រួចឆ្លើយសំណួរខាងក្រោម និងកត់ត្រាទុក៖

- តើអ្នកមានអាយុប៉ុន្មាន នៅពេលដែលអ្នកចាប់ផ្តើមប្រើប្រាស់បណ្តាញសង្គម ឬកម្មវិធីនោះ?
- តើអ្នកប្រើប្រាស់បណ្តាញសង្គមឬកម្មវិធីនោះក្នុងកម្រិតញឹកញាប់កម្រិតណា?
- ហេតុអ្វីបានជាអ្នកប្រើប្រាស់វា?
- តើសកម្មភាពអ្វីដែលអ្នកចូលចិត្តធ្វើបំផុត?
- តើខ្លឹមសារប្រភេទណាខ្លះដែលអ្នកចូលចិត្ត និងមិនចូលចិត្ត?
- តើអ្នកមានមិត្តភក្តិ ឬអ្នកតាមដានចំនួនប៉ុន្មាននាក់?
- តើអ្នកមានអារម្មណ៍ថាមានសុវត្ថិភាពកម្រិតណា នៅពេលបង្ហោះឬចែករំលែកខ្លឹមសារនៅទីនោះ?
- តើអ្នកធ្លាប់ឃើញឬទទួលបានសារដែលគួរឱ្យសង្ស័យដែរឬទេ? ប្រសិនបើធ្លាប់ តើអ្នកបានធ្វើដូចម្តេច?

២. ទម្លាប់ឌីជីថល និងឯកជនភាពរបស់អ្នក៖ ការកំណត់ឯកជនភាពឡើងវិញ

សូមយកក្រដាសនិងបិក ហើយសរសេរឈ្មោះសេវាកម្មអនឡាញទាំងអស់ ដែលអ្នកបានចុះឈ្មោះ និងកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន ដូចជា គណនីអ៊ីមែល កម្មវិធីផ្សេងៗ និងបណ្តាញសង្គម។ បន្ទាប់មក សូមចូលទៅពិនិត្យមើល «ការកំណត់ឯកជនភាព» លើបណ្តាញ ឬកម្មវិធីចំនួន២ ដែលអ្នកប្រើប្រាស់ច្រើនជាងគេ ហើយធ្វើការកែតម្រូវវា ដើម្បីរក្សាសុវត្ថិភាព ខ្លឹមសារផ្ទាល់ខ្លួន។

សូមចតអេក្រង់ រួចបញ្ចូលវាទៅក្នុងឯកសារមួយដោយភ្ជាប់ជាមួយនឹងកំណត់ចំណាំពីការស្រាវជ្រាវរបស់អ្នក។

លំហាត់អនុវត្តន៍ជាមួយឧបករណ៍ | **MIL Chatbot | ជំពូកទី៥៖ សុវត្ថិភាព និងឯកជនភាព**

៣.ហេតុអ្វីបានជាឯកជនភាពមានសារៈសំខាន់? សូមទស្សនាវីដេអូ ហើយឆ្លើយសំណួរ។

សូមប្រើប្រាស់កម្មវិធីតេឡេក្រាម MIL Chatbot ហើយចូលទៅកាន់ជំពូកទី៥៖ សុវត្ថិភាព និងឯកជនភាព ដើម្បីស្វែងយល់អំពីសារៈសំខាន់របស់វា។ បន្ទាប់មកទស្សនាវីដេអូអំពីរបៀបរក្សាឯកជនភាពនៅលើបណ្តាញអ៊ីនធឺណិត និងឆ្លើយសំណួរខាងក្រោម៖

- តើសារៈសំខាន់ ឬខ្លឹមសារអប់រំចម្បងនៃវីដេអូនេះគឺជាអ្វី?
- តើអ្នកប្រើប្រាស់បណ្តាញសង្គមក្នុងវីដេអូ ចង់បង្ហោះ ឬចង់ធ្វើអ្វី?
- តើវីដេអូបានផ្តល់ដំបូន្មាន ឬការណែនាំអ្វីខ្លះ ដើម្បីឱ្យមានសុវត្ថិភាព និងការពារឯកជនភាព?
- តើអ្នកប្រើប្រាស់ម្នាក់នោះ បានផ្លាស់ប្តូរឥរិយាបថអនឡាញរបស់គេយ៉ាងដូចម្តេច បន្ទាប់ពីបានស្តាប់ដំបូន្មានរបស់តួអង្គ? តើគេបានធ្វើអ្វីខ្លះដែលខុសពីមុន?

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

សំណួររំលឹកមេរៀន

១. តើអក្ខរកម្មឌីជីថលមានន័យដូចម្តេច?
២. ហេតុអ្វីបានជាអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន មានសារៈសំខាន់នៅក្នុងសម័យឌីជីថល?
៣. តើអ៊ីនធឺណិត អ៊ីមែល និងបណ្តាញផ្សព្វផ្សាយសង្គមគឺជាអ្វី?
៤. តើបណ្តាញផ្សព្វផ្សាយសង្គមមានហានិភ័យអ្វីខ្លះសម្រាប់អ្នក?
៥. តើឯកជនភាពគឺជាអ្វី ហើយហេតុអ្វីបានជាអ្នកគួរខ្វល់ខ្វាយពីវា?
៦. តើបទល្មើសបច្ចេកវិទ្យាគឺជាអ្វី? ចូរលើកឧទាហរណ៍ពីសកម្មភាពបទល្មើសបច្ចេកវិទ្យាដែលអ្នកបានដឹង ឬធ្លាប់បានឃើញ។

មេរៀនទី ២ អក្ខរកម្មទិន្នន័យ

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

ក. តើអក្ខរកម្មទិន្នន័យ ជាអ្វី?

ខ. តើទិន្នន័យនោះគួរឱ្យទុកចិត្តដែរឬទេ?

គ. ការអានតារាងទិន្នន័យ

ហេតុអ្វីបានជាមេរៀននេះសំខាន់?

អក្ខរកម្មទិន្នន័យជួយសិស្សឱ្យយល់ដឹងពីគំនូសតាង តួលេខ និងស្ថិតិនានា ដែលត្រូវបានប្រើប្រាស់នៅក្នុងការសិក្សា កន្លែងធ្វើការ និងក្នុងការសម្រេចចិត្ត ប្រចាំថ្ងៃ។ លើសពីនេះ ជំនាញនេះបង្រៀនពីរបៀបវាយតម្លៃថាតើទិន្នន័យទាំងនោះ មានភាពត្រឹមត្រូវ និងគួរឱ្យទុកចិត្តបានកម្រិតណាផងដែរ។

ក. តើអក្ខរកម្មទិន្នន័យ ជាអ្វី?

អក្ខរកម្មទិន្នន័យសំដៅលើជំនាញចាំបាច់ក្នុងការស្វែងរក អាន យល់ និងប្រើប្រាស់ទិន្នន័យ។ ទិន្នន័យ ជាព័ត៌មានក្នុងទម្រង់ជាលេខ អង្គហេតុ ឬការសង្កេតដែលអាចប្រមូល និងវិភាគបានដើម្បីជួយយើងឱ្យយល់អំពីអ្វីមួយ។



រូបភាព ២.១ អក្ខរកម្មទិន្នន័យ

អក្ខរកម្មទិន្នន័យជាជំនាញមូលដ្ឋានសំខាន់សម្រាប់សតវត្សរ៍ទី២១នេះ មិនខុសពីជំនាញមូលដ្ឋានអាន និងសរសេរឡើយ។ ទិន្នន័យមានច្រើនទម្រង់ដូចជា អត្រាសិស្សប្រឡងជាប់ថ្នាក់ជាតិ ការប្រៀបធៀបទិន្នផលស្រូវឆ្នាំនេះទៅនឹងឆ្នាំមុន ឬការសម្រេចចិត្តជ្រើសរើសកញ្ចប់សេវាទូរសព្ទដៃលចំណេញជាងគេ។ ទិន្នន័យក៏មានវត្តមាននៅក្នុងរបាយការណ៍ព័ត៌មានស្តីពីកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យសុខាភិបាល របាយការណ៍សាលារៀនដែលបង្ហាញពីលទ្ធផលសិក្សារបស់សិស្ស និងក្នុងវិស័យជាច្រើនទៀត។

អ្នកមានចំណេះដឹងផ្នែកអក្ខរកម្មទិន្នន័យ ជាការអភិវឌ្ឍទំនុកចិត្តនិងជំនាញដើម្បីប្រឈមមុខនឹងតួលេខ ហើយអាចចេះពីរបៀបសួរសំណួរឱ្យបានត្រឹមត្រូវ៖

- តើលេខទាំងនេះបានមកពីណា?
- តើវាគួរឱ្យទុកចិត្តបានកម្រិតណា?
- តើវាពិតជាកំពុងប្រាប់រឿងរ៉ាវអ្វីខ្លះ?
- តើព័ត៌មានលម្អិតសំខាន់អ្វីខ្លះដែលបាត់? និងសំខាន់បំផុតនោះគឺ តើព័ត៌មាននេះអាចជួយខ្ញុំ គ្រួសារ និងសហគមន៍របស់ខ្ញុំបានយ៉ាងដូចម្តេច?

ជំនាញអក្ខរកម្មទិន្នន័យកម្រិតមូលដ្ឋានរួមមាន៖

- ការអានគំនូសតាង និងតួលេខសាមញ្ញៗ
- ការយល់ដឹងអំពីភាគរយមូលដ្ឋាន (៥០% = ១/២ ឬ៣ក់កណ្តាល រឺង ២៥% នៃមនុស្ស = ១/៤នាក់)
- ការអានក្រាបសសរ ក្រាបខ្សែ និងក្រាបផ្ទឹត
- ការយល់ដឹងអំពីអត្ថន័យនៃមធ្យមភាគ (ការបូកលេខបញ្ចូលគ្នា រួចចែកនឹងចំនួនតួលេខដែលអ្នកមាន ដើម្បីរកចំនួនមធ្យមភាគ)
- ការកំណត់អត្តសញ្ញាណការប្រើប្រាស់ទិន្នន័យ ឬស្ថិតិដែលបំភាន់

ឧទាហរណ៍៖ ក្រាបមួយបង្ហាញថា ៦០% នៃសិស្សបានប្រឡងជាប់។ នោះមានន័យថាសិស្ស៦នាក់ក្នុងចំណោម១០នាក់បានប្រឡងជាប់។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

នៅក្នុងប្រទេសកម្ពុជាទិន្នន័យត្រូវបានបង្ហាញជាទូទៅទាក់ទងនឹង៖

- ស្ថិតិសុខភាព៖ អត្រាចាក់វ៉ាក់សាំង ស្ថិតិជំងឺ
- ការអប់រំ៖ លទ្ធផលប្រឡងរបស់សិស្ស និងចំនួនសិស្សចុះឈ្មោះចូលរៀន
- សេដ្ឋកិច្ច៖ តម្លៃស្រូវ និងអត្រាអ្នកមានការងារធ្វើ
- ការបោះឆ្នោត៖ លទ្ធផលបោះឆ្នោត
- បណ្តាញផ្សព្វផ្សាយសង្គម៖ ចំនួនអ្នកចូលចិត្ត ចំនួនអ្នកតាមដាន និងចំនួនចែករំលែក។

ប្រភពទិន្នន័យនៅក្នុងប្រទេសកម្ពុជា បានមកពីប្រភពខាងក្រោម និងប្រភពផ្សេងទៀត៖ ដូចគ្នានឹងរាល់ព័ត៌មានដែលអ្នករកឃើញនៅលើអ៊ីនធឺណិតដែរ អ្នកត្រូវប្រាកដថាវាអាចទុកចិត្តបាន។ សូម្បីតែវេបសាយមួយចំនួនដែលមើលទៅហាក់ដូចជាស្របច្បាប់ក៏មានផ្ទុកព័ត៌មានមិនពិត ឬបំភាន់ផងដែរ។

ស្ថិតិរដ្ឋាភិបាល៖

- វិទ្យាស្ថានជាតិស្ថិតិនៃកម្ពុជា
- ទិន្នន័យក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការចុះឈ្មោះចូលរៀន និងការសិក្សា
- ទិន្នន័យក្រសួងសុខាភិបាល ស្តីពីសូចនាករសុខភាពសាធារណៈ

អង្គការអន្តរជាតិ៖

- សូចនាករអភិវឌ្ឍន៍របស់ធនាគារពិភពលោក
- ស្ថិតិអប់រំរបស់អង្គការយូណេស្កូ
- ទិន្នន័យសុខភាពរបស់អង្គការសុខភាពពិភពលោក
- ទិន្នន័យប្រជាជន និងការអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ

ប្រភពក្នុងស្រុក៖

- កំណត់ត្រា និងការរាយតម្លៃរបស់សាលារៀន
- របាយការណ៍រដ្ឋបាលខេត្ត
- ការស្រាវជ្រាវ និងការស្ទង់មតិរបស់អង្គការក្រៅរដ្ឋាភិបាល

ខ. តើទិន្នន័យនោះគួរឱ្យទុកចិត្តដែរឬទេ?

ដើម្បីកំណត់ថាទិន្នន័យមួយគួរឱ្យទុកចិត្តឬអត់ចូរសួរខ្លួនឯងនូវសំណួរខាងក្រោម៖


- តើនរណាជាអ្នកប្រមូលព័ត៌មាននេះ? តើពួកគេលម្អៀងដែរឬទេ?
- តើក្នុងទិន្នន័យនេះបង្ហាញថាមនុស្សប៉ុន្មាននាក់ត្រូវបានសាកសួរ? មនុស្ស១០នាក់ ឬ១,០០០នាក់? (១,០០០នាក់នឹងផ្តល់លទ្ធផលត្រឹមត្រូវជាង)
- តើព័ត៌មាននេះត្រូវបានប្រមូលនៅពេលណា? តើទិន្នន័យចាស់ហួសសម័យឬថ្មីៗនេះ? កាលណាកាន់តែថ្មីវាប្រហែលជាកាន់តែអាចទុកចិត្តបាន។

- ហេតុអ្វីបានជាព័ត៌មាននេះត្រូវបានចែករំលែក? ដើម្បីផ្តល់ព័ត៌មានដល់អ្នក ធ្វើឱ្យអ្នកគិតតាមរបៀបណាមួយ ឬធ្វើឱ្យអ្នកខឹង?

ឧទាហរណ៍៖ ប្រសិនបើអ្នកអានថា «៨0% នៃប្រជាជនកម្ពុជាចូលចិត្តក្រុមហ៊ុនផ្តល់សេវាទូរសព្ទ KhmerCALL» ចូរសួរខ្លួនឯងថា៖ តើមានមនុស្សប៉ុន្មាននាក់ត្រូវបានសាកសួរអំពីរឿងនេះ? តើពួកគេមកពីណា? តើនរណាជាអ្នកបង់ប្រាក់សម្រាប់ការស្ទង់មតិនេះ? ប្រសិនបើក្រុមហ៊ុន KhmerCALL ជាអ្នកធ្វើការស្ទង់មតិនេះ អ្នកគួរតែមានមន្ទិលសង្ស័យលើការរកឃើញនេះ។ ពួកគេមានផលប្រយោជន៍ផ្ទាល់ខ្លួនក្នុងការធ្វើឱ្យខ្លួនឯងមើលទៅមានប្រជាប្រិយភាព។

គ. ការអានតារាងទិន្នន័យ

ផ្នែកសំខាន់មួយនៃអក្ខរកម្មទិន្នន័យគឺសមត្ថភាពក្នុងការអានក្រាបព័ត៌មានមូលដ្ឋាន។ តារាងធម្មតាមួយគឺ ក្រាបផ្លិតដែលមើលទៅដូចជារង្វង់កាត់ជាចំណិតៗ។ ឧទាហរណ៍ខាងក្រោម (មិនមែនបានពីការស្ទង់មតិពិត ឬស្ថិតិពិតទេ) ចូរពិនិត្យមើល តើសិស្សកម្ពុជាចំណាយពេលរេលាជាមធ្យមរៀងរាល់សប្តាហ៍ដូចម្តេចខ្លះ។



រូបភាព ២.២ ការអានតារាងទិន្នន័យ

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

របៀបអានតារាង៖

- **មើលចំណងជើង និងប្រភព** តើឆាតនេះនិយាយអំពីអ្វី? តើនរណាជាអ្នកស្ទង់មតិសិស្សទាំងនេះ? តើវាត្រូវបានធ្វើឡើងនៅពេលណា?
- *ក្រសួងអប់រំ យុវជន និងកីឡា កម្ពុជាបានស្ទង់មតិសិស្សចំនួន ៣០០នាក់ក្នុងឆ្នាំ២០២៥។ នេះគឺជាទិន្នន័យមកពីប្រភពដែលអាចទុកចិត្តបាន ដោយមនុស្សមួយចំនួនធំត្រូវបានសាកសួរនាពេលថ្មីៗនេះអំពីទម្លាប់របស់ពួកគេ។*

ប្រៀបធៀបផ្នែកនីមួយៗនៅក្នុងក្រាប

- ទំហំនៃផ្នែកនីមួយៗបង្ហាញថាចំនួននោះធំប៉ុនណា បើធៀបនឹងចំនួនផ្សេងទៀត។ នៅលើក្រាបនេះ ផ្នែកធំបំផុតបង្ហាញពីរយៈពេលដេក។ ផ្នែកធំបន្ទាប់គឺរយៈពេលនៅសាលារៀន (៦ម៉ោង) ខណៈដែលការសិក្សានៅផ្ទះ (៤ម៉ោង)។ រយៈពេលប្រើបណ្តាញផ្សព្វផ្សាយសង្គម (២ម៉ោង) មានទំហំតូចជាងគេ។

គិតអំពីអត្ថន័យនៃទិន្នន័យនេះ


- សិស្សចំណាយពេលដេកច្រើនជាងនៅសាលារៀន។ ពួកគេចំណាយពេលសិក្សានៅផ្ទះច្រើនជាងពីរដងនៃពេលវេលាប្រើបណ្តាញសង្គម។

សញ្ញាព្រមានអំពីអ្វីដែលមិនអាចទុកចិត្តបាននៅក្នុងក្រាបប្រភេទនេះ

- ភាគរយដែលបូកចូលគ្នាហើយមិនស្មើ១០០%
- គ្មានព័ត៌មានអំពីចំនួនមនុស្សដែលត្រូវបានស្ទង់មតិ
- ការស្ទង់មតិខ្នាតតូចខ្លាំង (ដូចជាសិស្សតែ ២០ នាក់) ប៉ុន្តែអះអាងថាតំណាងឱ្យសិស្សកម្ពុជាទាំងអស់
- មិនបានបញ្ជាក់ថាសាលារៀន ឬតំបន់ណាត្រូវបានដាក់បញ្ចូល (ក្រាបខាងលើមិនបានបញ្ជាក់ឱ្យច្បាស់ទេ ដែលនេះគឺជាចំណុចខ្សោយ)
- សកម្មភាពដែលមើលទៅមិនសមហេតុផល ដូចជាការប្រើប្រាស់បណ្តាញផ្សព្វផ្សាយសង្គម ១២ម៉ោងក្នុងមួយថ្ងៃ

ក្រាបសសរ

ក្រាបសសរជាវិធីសាមញ្ញមួយទៀតក្នុងការបង្ហាញទិន្នន័យដែលយើងអាចដឹងពីរបៀបដែលចំណាត់ថ្នាក់ផ្សេងគ្នាមានទំនាក់ទំនងជាមួយគ្នា។ ឧទាហរណ៍ខាងក្រោមបង្ហាញពីចំនួនសិស្សក្នុងឆ្នាំ២០២៤ និងឆ្នាំ២០២៥ នៅសាលារៀនសន្ទតមួយក្នុងខេត្តបាត់ដំបង។



រូបភាព ២.៣ ក្រាសសរនៃចំនួនសិស្សតាមកម្រិតថ្នាក់

ប្រភព និងកាលបរិច្ឆេទនៃទិន្នន័យនេះ មើលទៅពិតជាគួរឱ្យទុកចិត្តបាន។ ចំណុចសំខាន់ដែលក្រាបសសរនេះបានបង្ហាញពីចំនួនសិស្សថ្នាក់ទី៩ដែលបានចុះឈ្មោះចូលរៀនមានការកើនឡើងចំនួន ១០នាក់ក្នុងឆ្នាំ២០២៥ បើធៀបនឹងឆ្នាំ២០២៤។ ចំណែកឯចំនួនសិស្សថ្នាក់ទី១២វិញ មិនមានការប្រែប្រួលនោះទេ ក្នុងរយៈពេលពីរឆ្នាំនេះ។

សូមចងចាំថាតួលេខក៏អាចបំភាន់យើងបានដែរ មិនខុសពីពាក្យសម្តីនោះឡើយ។ ដូច្នេះអ្នកត្រូវតែមានការត្រិះរិះពិចារណាជានិច្ចទៅលើទិន្នន័យនានា ដូចដែលអ្នកតែងតែអនុវត្តចំពោះព័ត៌មានផ្សេងៗ ដែលអ្នកបានឃើញនៅលើអ៊ីនធឺណិត ឬនៅក្នុងអត្ថបទសារព័ត៌មានដែរ។

មេរៀនសង្ខេប

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីចំណុចសំខាន់ៗដូចខាងក្រោម៖

- អក្ខរកម្មទិន្នន័យ៖ គឺជាសមត្ថភាពក្នុងការស្វែងរក អាន យល់ និងប្រើប្រាស់ទិន្នន័យ។ វាជាជំនាញមូលដ្ឋានដ៏សំខាន់ក្នុងសតវត្សទី២១ ដូចទៅនឹងការអាន និងការសរសេរដែរ។ មានន័យថាយើងអាចប្រើប្រាស់លេខ គំនូសតាង និងស្ថិតិផ្សេងៗក្នុងជីវភាពរស់នៅប្រចាំថ្ងៃដោយទំនុកចិត្ត។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

- ប្រភពព័ត៌មានដែលអាចទុកចិត្តនៅកម្ពុជា៖ ស្ថិតិរាជរដ្ឋាភិបាល អង្គការអន្តរជាតិ (អង្គការសហប្រជាជាតិ ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ) និងប្រភពក្នុងស្រុកដទៃទៀត។ ត្រូវផ្ទៀងផ្ទាត់ជានិច្ចថា ទិន្នន័យទាំងនោះបានមកពីប្រភពដែលត្រឹមត្រូវ។
- របៀបវាយតម្លៃភាពត្រឹមត្រូវនៃទិន្នន័យ៖ ត្រូវសួរសំណួរដូចជា តើអ្នកណាជាអ្នកប្រមូលទិន្នន័យនេះ? តើគេបានសម្ភាសន៍មនុស្សប៉ុន្មាននាក់? តើទិន្នន័យនេះប្រមូលនៅពេលណា? ហេតុអ្វីបានជាគេចែករំលែក?
- របៀបអានក្រាប៖ ត្រូវពិនិត្យមើលចំណងជើង ប្រភព និងកាលបរិច្ឆេទ។ ប្រៀបធៀបទំហំនៃចំណែកនីមួយៗឬរបារទិន្នន័យ។ ត្រូវប្រយ័ត្នចំពោះសញ្ញាមិនប្រក្រតីដូចជា ភាគរយបូកបញ្ចូលគ្នាមិនគ្រប់ ១០០% ចំនួនអ្នកចូលរួមសម្ភាសន៍តិចតួចពេក ឬខ្វះព័ត៌មានអំពីការស្ទង់មតិ។
- សូមចងចាំថា លេខក៏អាចបោកបញ្ឆោតយើងបានដែរ មិនខុសពីពាក្យសម្តីឡើយ។ ត្រូវគិតពិចារណាឱ្យបានដិតដល់ជានិច្ច មុននឹងជឿថាទិន្នន័យណាមួយជាការពិត។

សទ្ធានុក្រម

- **គំនូសតាង ឬក្រាប៖** ការបង្ហាញទិន្នន័យជារូបភាព។
- **ទិន្នន័យ៖** ព័ត៌មានដែលប្រមូលបានជាលេខ ឬលំដាប់ប្រភេទ។
- **ទិន្នន័យអាចទុកចិត្តបាន៖** ព័ត៌មានដែលសុក្រឹត និងអាចទុកចិត្តបាន។
- **និន្នាការ៖** លំនាំ ឬការវិវត្តដែលបង្ហាញនៅក្នុងទិន្នន័យតាមពេលវេលាណាមួយ។

លំហាត់អនុវត្តន៍

១. ការវិភាគ និងការប្រៀបធៀបតារាង៖ ការអនុវត្តអក្ខរកម្មទិន្នន័យ

សូមសាកល្បងគិតអំពីការប្រើប្រាស់ទិន្នន័យនៅក្នុងប្រទេសកម្ពុជា (ឧទាហរណ៍៖ ក្នុងវិស័យសុខាភិបាល អប់រំ បរិស្ថាន ឬសេដ្ឋកិច្ច) រួចសរសេរគំនិតទាំងនោះទុក។ សូមជ្រើសរើសឧទាហរណ៍មួយដើម្បីធ្វើជាប្រធានបទសិក្សា។ បន្ទាប់មកស្វែងរកតារាងពីរខុសគ្នានៅលើអ៊ីនធឺណិតដែលពាក់ព័ន្ធនឹងប្រធានបទដែលអ្នកបានជ្រើសរើស។

- វិភាគប្រភពនៃក្រាបនីមួយៗ៖ តើនរណាជាអ្នកចែករំលែក និងជាអ្នកប្រមូលទិន្នន័យ? តើពួកគេអាចទុកចិត្តបានដែរឬទេ? តើទិន្នន័យនោះត្រូវបានប្រមូល និងចែករំលែកក្នុងគោលបំណងអ្វី?
- វិភាគទិន្នន័យ៖ តើទិន្នន័យបានបង្ហាញឬមិនបង្ហាញពីអ្វីខ្លះ? តើមានមនុស្សចំនួនប៉ុន្មាននាក់ដែលត្រូវបានធ្វើស្ទង់មតិ ហើយការស្ទង់មតិនោះធ្វើឡើងនៅពេលណា?
- ប្រៀបធៀបគំនូសតាង៖ តើគំនូសតាងមួយណាដែលអ្នកទុកចិត្តជាង? ហេតុអ្វី? តើមានគំនូសតាងណាមួយដែលនាំឱ្យមានការភាន់ច្រឡំដែរឬទេ?

២. ផ្តើមចេញពីប្រធានបទបង្កើតទៅជាទិន្នន័យ៖ ការបង្ហាញគំនិតស្រាវជ្រាវរបស់អ្នក

សូមជ្រើសរើសប្រធានបទណាមួយដែលមានសារៈសំខាន់ចំពោះអ្នកឬសហគមន៍របស់អ្នក (ឧទាហរណ៍៖ សុខភាព ការអប់រំ បរិស្ថាន ការដឹកជញ្ជូន ឬការប្រើប្រាស់បណ្តាញសង្គម)។

- តើសំណួរអ្វីខ្លះដែលអ្នកចង់ឆ្លើយទាក់ទងនឹងប្រធានបទនេះ?
- តើទិន្នន័យប្រភេទណាខ្លះដែលអ្នកត្រូវការប្រមូល ដើម្បីឆ្លើយនឹងសំណួរនេះ?
- តើនរណាខ្លះដែលអាចផ្តល់ទិន្នន័យនេះដល់អ្នក ឬតើអ្នកអាចស្វែងរកវាបាននៅទីណា?
- តើទិន្នន័យនេះអាចបង្ហាញឱ្យបានច្បាស់លាស់តាមវិធីណាខ្លះ (ឧទាហរណ៍៖ តារាង ក្រាបសសរ ក្រាបខ្សែ ក្រាបព័ត៌មាន ឬផែនទី)?
- តើរបៀបនៃការបង្ហាញទិន្នន័យដូចគ្នា ក្នុងរូបភាពខុសគ្នា អាចធ្វើឱ្យការយល់ដឹងរបស់មនុស្សផ្លាស់ប្តូរយ៉ាងដូចម្តេច?

សូមត្រៀមការធ្វើបទបង្ហាញខ្លីដោយផ្ទាល់មាត់ ដើម្បីពន្យល់ពីប្រធានបទរបស់អ្នក ទិន្នន័យដែលអ្នកនឹងត្រូវប្រមូល និងបង្ហាញពីវិធីពីរខុសគ្នាដែលអ្នកអាចយកទិន្នន័យ។

សំណួរសម្រាប់ពិនិត្យមេរៀន

១. តើអក្ខរកម្មទិន្នន័យជាអ្វី?
២. ហេតុអ្វីបានជាអក្ខរកម្មទិន្នន័យមានសារៈសំខាន់?
៣. តើអ្វីខ្លះដែលជាជំនាញមូលដ្ឋាននៃអក្ខរកម្មទិន្នន័យ?
៤. តើអ្នកណាខ្លះដែលតែងតែចែករំលែកទិន្នន័យនៅកម្ពុជា?
៥. តើអ្នកគួរសួរសំណួរអ្វីខ្លះ ដើម្បីកំណត់ថាទិន្នន័យមួយគឺជាទិន្នន័យដែលគួរឱ្យទុកចិត្ត?
៦. តើអ្វីខ្លះជាសញ្ញាព្រមានដែលបញ្ជាក់ថា គំនូសតាង ឬស្ថិតិមួយអាចជាការបោកបញ្ឆោត ឬបង្កឱ្យមានការភាន់ច្រឡំ?

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

មេរៀនទី ៣ ក្រមសីលធម៌ និងទំនួលខុសត្រូវក្នុងប្រព័ន្ធផ្សព្វផ្សាយ



មេរៀនទី៣.១, ៣.២



មេរៀនទី៥

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

ក. សុក្រឹតភាព ការគិតបែបត្រិះរិះ និងសេរីភាពនៃការបញ្ចេញមតិ

ខ. ចំណុចសំខាន់ៗដែលត្រូវពិចារណា នៅពេលបញ្ចេញមតិ និងចែករំលែកព័ត៌មាន

ហេតុអ្វីបានជាមេរៀននេះសំខាន់?

មេរៀននេះជួយអ្នកសិក្សាឱ្យចេះប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយប្រកបដោយការទទួលខុសត្រូវ ចេះពិចារណាទៅលើផលប៉ះពាល់នៃពាក្យសម្តី និងទង្វើរបស់គេ។ បន្ថែមពីនេះ មេរៀននេះក៏បង្រៀនអំពីសារៈសំខាន់នៃសុក្រឹតភាព និងការប្រាស្រ័យទាក់ទងគ្នាប្រកបដោយការគោរព។

ក. សុក្រឹតភាព ការគិតបែបត្រិះរិះ និងសេរីភាពនៃការបញ្ចេញមតិ



រូបភាព ៣.១ ការគិតបែបត្រិះរិះ

អ៊ីនធឺណិតផ្តុកនូវព័ត៌មានដែលត្រឹមត្រូវនិងឈរលើអង្គហេតុច្រើនសន្ធឹកសន្ធាប់ ដែលត្រូវបានចែករំលែកដោយបុគ្គល ឬស្ថាប័នណាមួយ។វាក៏បញ្ចូលនូវមតិជាច្រើនដែលត្រូវបានប្រកាន់យកដោយសុទ្ធចិត្ត ទោះបីជាអ្នកមិនយល់ស្របជាមួយមតិទាំងនោះក៏ដោយ។ មតិយោបល់ទាំងនោះចាត់ទុកថាជាការពិត។ នេះគឺជាទង្វើខុសសីលធម៌ ហើយអាចនាំឱ្យមានការយល់ច្រឡំ និងធ្វើឱ្យផលវិបាកកាន់តែធ្ងន់ធ្ងរជាងនេះទៀត។

ឧទាហរណ៍៖ មនុស្សជុំវិញពិភពលោកមានជំនឿសាសនាផ្សេងៗគ្នា ដោយជឿជាក់ថាសាសនារបស់ពួកគេគឺជាសាសនាដែល «ត្រឹមត្រូវ»។ ពួកគេបង្ហោះព័ត៌មាននៅលើអ៊ីនធឺណិតដោយបញ្ជាក់ថាពួកគេដឹងពី «ការពិត» ប៉ុន្តែសម្រាប់មនុស្សដែលមានជំនឿសាសនាផ្សេង ឬគ្មានសាសនាសោះ នេះគឺមិនត្រឹមត្រូវនោះទេ។

សូម្បីតែព័ត៌មានដែលឈរលើការពិតក៏អាចត្រូវបានបង្ហាញ ឬបញ្ជូនតាមរបៀបផ្សេងៗគ្នាដើម្បីបង្កើតអារម្មណ៍ជាក់លាក់ណាមួយដល់អ្នកអានផងដែរ។ ឧទាហរណ៍៖ នៅក្នុងព្រឹត្តិការណ៍ដែលមានអ្នកចូលរួម១០០នាក់អ្នកសរសេរដែលចង់ឱ្យគេយល់ថាមានមនុស្សចូលរួមតិចអាចនឹងសរសេរថា «មានមនុស្សមិនដល់១០០នាក់ផងដែលមានវត្តមាន»។ ផ្ទុយទៅវិញប្រសិនបើអ្នកសរសេរដើម្បីបង្ហាញថាមានការចាប់អារម្មណ៍ខ្លាំងនៅក្នុងព្រឹត្តិការណ៍នោះ ពួកគេអាចសរសេរថា «នៅក្នុងបន្ទប់គឺពេញណែនដោយអ្នកចូលរួមយ៉ាងតិច១០០នាក់»។

នៅពេលអានព័ត៌មានយើងគួរតែអានដោយមានការត្រិះរិះពិចារណា ព្យាយាមស្វែងយល់ថាតើអ្វីដែលពួកគេកំពុងអាននោះឆ្ងុះបញ្ចាំងពីការពិតដែលផ្អែកលើភស្តុតាង ឬគ្រាន់តែជាទស្សនៈរបស់បុគ្គលណាម្នាក់។

វាជាគំនិតដ៏ល្អមួយក្នុងការពិនិត្យមើលប្រភពផ្សេងទៀតអំពីព័ត៌មានស្រដៀងគ្នានៅលើអនឡាញ ប្រៀបធៀបពួកវា និងមើលថាតើចំណុចណាដែលពួកគេរាយការណ៍ដូចគ្នា ឬចំណុចណាដែលពួកគេខុសគ្នា។ ដំណើរការនេះហៅថា ការផ្ទៀងផ្ទាត់ការពិតដែលមានន័យថាការវាយតម្លៃភាពអាចទុកចិត្តបានរបស់ព័ត៌មាន។

វេបសាយជាច្រើនផ្តុកព័ត៌មានដែលផ្សព្វផ្សាយដោយស្ថាប័ន ឬអង្គភាពឯកជនហើយព័ត៌មានបែបនេះច្រើនតែមិនត្រូវបានផ្ទៀងផ្ទាត់ឬពិនិត្យឡើងវិញដោយអ្នកដទៃនោះទេ។វេបសាយមួយចំនួនដូចជា Wikipedia អនុញ្ញាតឱ្យមនុស្សជាច្រើនសហការគ្នានៅលើព័ត៌មានតែមួយ និងមានអ្នកកែសម្រួលដែលវាយតម្លៃភាពជឿជាក់នៃមាតិកាដើម្បីធានាភាពត្រឹមត្រូវរបស់វា។ សូម្បីតែនៅលើ Wikipedia មិនមែនគ្រប់ព័ត៌មានសុទ្ធតែអាចទុកចិត្តបានទាំងស្រុងនោះទេ។ Wikipedia អនុញ្ញាតឱ្យអ្នកប្រើប្រាស់មើលឃើញថាមានមនុស្សប៉ុន្មាននាក់បានកែសម្រួលព័ត៌មានជាក់លាក់ណាមួយ ដែលជួយពួកគេក្នុងការវិនិច្ឆ័យកម្រិតនៃភាពអាចទុកចិត្តបាន។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ក្រៅពីការពិនិត្យមើលប្រភពអ្នកប្រើប្រាស់អ៊ីនធឺណិតគួរតែប្រើប្រាស់ហេតុផល និងការគិតបែបត្រិះរិះពិចារណាដើម្បីវាយតម្លៃថាអ្វីដែលអាចជាការពិត និងអ្វីដែលមិនអាចទៅរួចឬមិនពិត។ វិធានដ៏ល្អមួយដែលគួរអនុវត្តតាមគឺរាល់មាតិកាដែលមានលក្ខណៈអស្ចារ្យខ្លាំងទាមទារឱ្យមានភស្តុតាងដែលមានលក្ខណៈអស្ចារ្យខ្លាំងមកបញ្ជាក់ដែរ។ កុំចេះតែទទួលយកអ្វីដែលអ្នកឃើញនៅលើអនឡាញថាជាការពិត។

សេរីភាពក្នុងការបញ្ចេញមតិ

យោងតាមរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់ពួកគេ។ មាត្រា៤១ ចែងថា៖ «ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាព ខាងការប្រជុំ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ»។



រូបភាព ៣.២ សេរីភាពនៃការបញ្ចេញមតិ

ប្រជាជនកម្ពុជាមានសេរីភាពក្នុងការបញ្ចេញមតិលើបញ្ហានយោបាយ សាសនា ឬបញ្ហាផ្សេងៗ តាមរយៈការនិយាយ ការសរសេរ ឬតាមរយៈអ៊ីនធឺណិត។
សិទ្ធិនេះត្រូវបានកម្រិតដោយកាតព្វកិច្ចពីរផ្សេងទៀត ដែលប្រជាពលរដ្ឋគ្រប់រូបមានផងដែរគឺ កាតព្វកិច្ចមិនត្រូវផ្សព្វផ្សាយរឿងមិនពិតដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះនរណាម្នាក់ និងកាតព្វកិច្ចមិនត្រូវជេរប្រមាថឬមើលងាយអ្នកដទៃ។ ទាំងនេះគឺជាផ្នែកមួយនៃច្បាប់ក្នុងប្រទេសកម្ពុជា ហើយការរំលោភបំពានត្រូវទទួលទោសតាមច្បាប់។ ការរឹតបន្តឹងក៏អនុវត្តផងដែរទៅលើការនិយាយមិនពិតឬការជេរប្រមាថដែលធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ស្ថាប័ន។

សេរីភាពក្នុងការបញ្ចេញមតិត្រូវបានអនុវត្ត នៅពេលដែលបុគ្គលម្នាក់ចង់ចែករំលែកទស្សនៈរបស់ពួកគេអំពីសកម្មភាពណាមួយឬដើម្បីបង្ហាញពីជំនឿរបស់ពួកគេថាតើសកម្មភាពនោះត្រូវឬខុស។ ការចោទប្រកាន់ដោយផ្ទាល់ទៅលើបុគ្គលឬស្ថាប័នទាក់ទងនឹងបទល្មើសណាមួយ អាចបណ្តាលឱ្យមានការផ្តន្ទាទោស លុះត្រាតែមានភស្តុតាងជាក់លាក់។ ឧទាហរណ៍៖ យើងអាចនិយាយថាមានអ្វីមួយមិនល្អឬផ្តល់ដំបូន្មានដល់នរណាម្នាក់អំពីអ្វីដែលគួរ ឬមិនគួរធ្វើ ដែលនេះគឺជាទស្សនៈផ្ទាល់ខ្លួន និងបង្ហាញដោយសេរី។ វាជារឿងមិនត្រឹមត្រូវទាល់តែសោះ ក្នុងការចោទប្រកាន់នរណាម្នាក់ពីបទឧក្រិដ្ឋដោយគ្មានភស្តុតាង ដូចជាអំពើឃាតកម្មជាដើម ព្រោះការធ្វើបែបនេះនឹងធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់បុគ្គលនោះ។

យើងទទួលខុសត្រូវចំពោះទង្វើផ្ទាល់ខ្លួនរបស់យើង និងចំពោះព័ត៌មានដែលយើងចែករំលែកតាមផ្លូវច្បាប់។ វាគឺជាការទទួលខុសត្រូវផ្ទាល់ខ្លួនក្នុងការធានាថា ការបញ្ចេញមតិរបស់យើងគឺត្រឹមត្រូវ។ ទោះបីជារឿងរ៉ាវណាមួយហាក់ដូចជាការពិតដូចដែលអ្នកដទៃបានបង្ហាញក៏ដោយ ក៏គួរតែត្រូវផ្ទៀងផ្ទាត់មុននឹងចែករំលែកបន្តដែរ។ សម្រាប់អ្នកប្រើប្រាស់អ៊ីនធឺណិតវាជារឿងចាំបាច់ក្នុងការវាយតម្លៃការលើកឡើងណាមួយនៅលើអនឡាញ ដើម្បីកំណត់ថាតើវាឈរលើការពិតឬអត់ មុននឹងចែករំលែកបន្តទៅអ្នកដទៃ។ ប្រសិនបើយើងមិនបានធ្វើដូច្នោះទេ យើងអាចនឹងផ្សព្វផ្សាយព័ត៌មានមិនពិតដោយអចេតនា និងបង្កឱ្យមានការយល់ច្រឡំ មិនថាតាមរយៈពាក្យសម្តីឬជាលាយលក្ខណ៍អក្សរឡើយ។

សេរីភាពក្នុងការបញ្ចេញមតិគឺជាមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ។ ប្រជាជនកម្ពុជាត្រូវប្រើប្រាស់សិទ្ធិនេះប្រកបដោយការទទួលខុសត្រូវ បញ្ជាក់ឱ្យច្បាស់នូវអ្វីដែលពិត និងត្រូវប្រុងប្រយ័ត្នចំពោះការចែករំលែកព័ត៌មានដែលមិនទាន់បានផ្ទៀងផ្ទាត់ច្បាស់លាស់។ ការផ្លាស់ប្តូរមតិយោបល់ដោយមិនផ្សព្វផ្សាយរឿងមិនពិត ឬការជេរប្រមាថនាំទៅរកការពិភាក្សាប្រកបដោយអត្ថន័យ ដែលរួមចំណែកដល់ការអភិវឌ្ឍសង្គម។

ខ. ចំណុចសំខាន់ៗដែលត្រូវពិចារណា នៅពេលបញ្ចេញមតិ និងចែករំលែកព័ត៌មាន

ខាងក្រោមជាចំណុចមួយចំនួនដែលអ្នកគួរពិចារណា មុនពេលបញ្ចេញមតិ ឬចែករំលែកព័ត៌មានតាមអនឡាញ។

ដឹងពីអ្វីដែលអ្នកកំពុងនិយាយ

ពាក់ព័ន្ធកេរ្តិ៍ឈ្មោះអ្នកទទួលខុសត្រូវមិនត្រឹមតែចំពោះអ្វីដែលអ្នកនិយាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរបៀបដែលសាធារណជនទូទៅបកស្រាយវាផងដែរ។ អ្នកក៏ទទួលខុសត្រូវចំពោះការចែករំលែក ការលើកឡើងណាមួយឬខ្លឹមសារប៉ះពាល់កេរ្តិ៍ឈ្មោះដែលសរសេរដោយអ្នកផ្សេង ទោះបីជាអ្នកបានដកស្រង់សម្តីពួកគេយ៉ាងត្រឹមត្រូវក៏ដោយ។ អ្នកត្រូវពិចារណាថា តើអ្វីដែលអ្នកសរសេរអាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់នរណាម្នាក់ដែរឬទេ? តើមនុស្សទូទៅឬអ្នកដែលមានការគិតគូរកម្រិតធម្មតា នឹងយល់ពីអត្ថន័យនៃការចែករំលែកបន្តរបស់អ្នកយ៉ាងដូចម្តេច?

និយាយតែអ្វីដែលអ្នកមានភស្តុតាង

ជាធម្មតាការពិតជាការការពារដ៏សំខាន់បំផុតនៅក្នុងបណ្តឹងបរិហារកេរ្តិ៍។ សួរខ្លួនឯងថាតើភស្តុតាងអ្វីខ្លះដែលអ្នកអាចបង្ហាញនៅក្នុងតុលាការ ប្រសិនបើនរណាម្នាក់តម្រូវឱ្យអ្នកផ្តល់ភស្តុតាង ហើយតើភស្តុតាងនោះគួរឱ្យជឿជាក់កម្រិតណា។ តើអ្នកមានប្រភពទេ? តើប្រភពទាំងនោះគួរឱ្យទុកចិត្តដែរឬទេ? តើពួកគេមានចំណេះដឹង/បានឃើញផ្ទាល់ភ្នែកដែរឬទេ? តើពួកគេស្ម័គ្រចិត្តផ្តល់ភស្តុតាងដែរឬទេ? ប្រសិនបើអ្នកពឹងផ្អែកលើឯកសារ តើមាននរណាម្នាក់ដែលអាចផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារទាំងនោះបានដែរឬទេ?

ទទួលស្គាល់ពីអ្វីដែលអ្នកមិនដឹង

ប្រសិនបើអ្នកបើកចំហនិងស្មោះត្រង់ជាមួយសាធារណជនអំពីអ្វីដែលអ្នកមិនដឹង ហើយបញ្ជាក់យ៉ាងច្បាស់ថាអ្នកមិនចោទប្រកាន់នរណាម្នាក់នោះទេ វានឹងក្លាយជាការលំបាកមួយសម្រាប់ដើមបណ្តឹងក្នុងការអះអាងថា អ្នកបានបំភាន់ឬជះឥទ្ធិពលដល់ការយល់ដឹងរបស់អ្នកអាន។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ប្រើប្រាស់ភាសាដែលសមរម្យក្នុងការបញ្ចេញមតិ

មានការការពារមួយប្រភេទដែលហៅថា «មតិស្មោះត្រង់» សម្រាប់អ្នកដែលបញ្ចេញមតិពិតអំពីការពិតដែលត្រូវបានបង្ហាញឬយល់ដោយសាធារណជន។ ក្នុងករណីនេះអ្នកត្រូវបញ្ជាក់ឱ្យច្បាស់ថា តើអ្នកកំពុងបញ្ចេញមតិផ្ទាល់ខ្លួនរបស់អ្នក ឬគ្រាន់តែចែករំលែកបន្តនូវទស្សនៈរបស់អ្នកដទៃ។ អ្នកអាចប្រើភាសាដូចជា «ខ្ញុំគិតថា» «គាត់ជឿថា» «គាត់គិតថា» «ពួកគេអះអាងថា»។ល។ បញ្ជាក់ឱ្យច្បាស់ថារាជាមតិរបស់នរណា។ ប្រើការនិយាយបែបរាយតម្លៃជាជាងការថ្លែងអំពីការពិត ឧទាហរណ៍៖ «ខ្ញុំគិតថាឥរិយាបថរបស់គាត់គួរឱ្យស្អប់ខ្ពើម»។ សួរសំណួរបែបវោហាសាស្ត្រ ឬបែបវិភាគ ជំនួសឱ្យការអះអាងពីការពិត។ អ្នកក៏អាចប្រើរូបភាពជាសញ្ញាសម្រាប់អ្នកអានឱ្យយល់ថា ពួកគេកំពុងទទួលបានមតិយោបល់ស្រដៀងនឹងអ្វីដែលបានធ្វើនៅក្នុងសំបុត្រដែលផ្ញើទៅកាន់អ្នកនិពន្ធ។

ត្រូវមានសីលធម៌

ការអនុវត្តតាមស្តង់ដាក្រមសីលធម៌ជាវិធីល្អបំផុតដើម្បីការពារខ្លួនអ្នកពីការប្តឹងផ្តល់។ ប្រសិនបើអ្នកប្រព្រឹត្តទៅតាមសីលធម៌វិជ្ជាជីវៈ អ្នកមិនសូវមានកំហុសទាក់ទងនឹងការបរិហារកេរ្តិ៍ទេ ហើយក៏មិនសូវប្រឈមមុខនឹងបណ្តឹងបែបនេះដែរ។ ប្រសិនបើនរណាម្នាក់ប្តឹង អ្នកនឹងមានវិធានការដើម្បីការពារខ្លួន។ ទោះបីជាអ្នកមិនមានអ្វីច្រើនដើម្បីការពារខ្លួនក៏ដោយ ក៏ចៅក្រម និងគណៈវិនិច្ឆ័យអាចបង្ហាញការអនុគ្រោះ ហើយការខូចខាតអាចមិនសូវធ្ងន់ធ្ងរទេ។

ដឹងថាអ្នកកំពុងប្រឈមជាមួយអ្នកណាខ្លះ

នៅពេលចែករំលែកឬចុះផ្សាយព័ត៌មាន អ្នកត្រូវដឹងថាមនុស្សមួយចំនួនអាចនឹងប្តឹងអ្នកបាន។ ឧទាហរណ៍៖ អ្នកនយោបាយ អ្នកជំនួញ តារាល្បីៗ ឬបុគ្គល និងក្រុមល្បីឈ្មោះដែលមានធនធានអាចចាត់វិធានការផ្លូវច្បាប់ប្រឆាំងនឹងអ្នក។ អ្នកក៏គួរតែប្រុងប្រយ័ត្នជាពិសេសផងដែរ នៅពេលសរសេរ ឬចែករំលែកព័ត៌មានអំពីប៉ូលិស អ្នកសារព័ត៌មាន និងជាពិសេសមេធាវី ព្រោះពួកគេមានឥទ្ធិពល និងមានធនធានគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងអ្នក។

មេរៀនសង្ខេប

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីចំណុចសំខាន់ៗដូចខាងក្រោម៖

មាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការប្រជុំ។ ប្រជាជនកម្ពុជាមានសេរីភាពក្នុងការបញ្ចេញមតិលើបញ្ហានយោបាយ និងសាសនា ក៏ដូចជាបញ្ហាផ្សេងទៀតតាមរយៈការនិយាយ ការសរសេរលិខិត ឬការប្រើប្រាស់អ៊ីនធឺណិត។ ទោះជាយ៉ាងណាក៏ដោយ សិទ្ធិទាំងនេះត្រូវបានកម្រិតដោយកាតព្វកិច្ចពីរផ្សេងទៀតដែលប្រជាពលរដ្ឋគ្រប់រូបមានគឺ៖ កាតព្វកិច្ចមិនត្រូវផ្សព្វផ្សាយរឿងមិនពិតដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះ និងកាតព្វកិច្ចមិនត្រូវជេរប្រមាថឬមើលងាយអ្នកដទៃ។

មុនពេលបញ្ចេញមតិ ឬចែករំលែកព័ត៌មានណាមួយ អ្នកគួរពិចារណាលើចំណុចខាងក្រោម៖

- ដឹងពីអ្វីដែលអ្នកកំពុងនិយាយ
- និយាយអ្វីដែលអ្នកមានភស្តុតាង
- ត្រូវទទួលស្គាល់អំពីអ្វីដែលអ្នកមិនដឹង
- ប្រើប្រាស់ភាសាដែលឆ្លុះបញ្ចាំងពីមតិយោបល់
- អនុវត្តតាមស្តង់ដាសីលធម៌
- ដឹងថាអ្នកកំពុងប្រឈមជាមួយនរណាខ្លះ។

សទ្ទានុក្រម

- **ការគិតបែបត្រិះរិះពិចារណា៖** សមត្ថភាពក្នុងការវិភាគព័ត៌មាន សួរសំណួរនិងធ្វើការសម្រេចចិត្តដោយផ្អែកលើភស្តុតាងជាជាងផ្អែកលើអារម្មណ៍ឬការស្មាន។
- **សីលធម៌៖** គោលការណ៍ដែលណែនាំពីអាកប្បកិរិយាត្រូវនិងខុស។
- **សេរីភាពក្នុងការបញ្ចេញមតិ៖** សិទ្ធិក្នុងការចែករំលែកគំនិតដោយការគោរព។
- **មតិ៖** អ្វីដែលនរណាម្នាក់ជឿ ឬមានអារម្មណ៍។ វាមានលក្ខណៈអត្តនោម័តិ ជាជាងផ្អែកលើអង្គហេតុដែលមានមូលដ្ឋានច្បាស់លាស់។
- **ការចែករំលែកប្រកបដោយការទទួលខុសត្រូវ៖** ការផ្ទៀងផ្ទាត់ព័ត៌មានដើម្បីកំណត់សុក្រឹតភាព និងគ្រោះថ្នាក់ដែលអាចកើតមាន មុនពេលបង្ហោះវា។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

លំហាត់អនុវត្តន៍

១. ពិនិត្យអ្វីដែលអ្នកចែករំលែកលើបណ្តាញសង្គម៖

សូមចូលទៅកាន់គណនី Facebook ឬបណ្តាញសង្គមណាមួយដែលអ្នកប្រើប្រាស់ច្រើនជាងគេ។ សូមពិនិត្យមើលការបង្ហោះឬខ្លឹមសារដែលអ្នកធ្លាប់ចែករំលែកកន្លងមក ហើយឆ្លើយតបសំណួរខាងក្រោម៖

- តើអ្នកបានគិតពិចារណាដោយម៉ត់ចត់ មុនពេលចែករំលែក ឬបញ្ចេញមតិយោបល់របស់អ្នកដែរឬទេ?
- តើការបង្ហោះរបស់អ្នកអាចមានផលប៉ះពាល់វិជ្ជមានឬអវិជ្ជមានអ្វីខ្លះមកលើរូបអ្នកផ្ទាល់ អ្នកដទៃឬសង្គមជាតិ?
- តើអ្នកគួរតែបន្តចែករំលែកតាមរបៀបនេះទៀត ឬគួរផ្លាស់ប្តូរ? ហេតុអ្វី?

២. បច្ចេកវិទ្យា និងពេលវេលារបស់អ្នក៖ របៀបបង្កើតតុល្យភាពឱ្យកាន់តែប្រសើរ

សូមចំណាយពេល ១៥នាទី ដើម្បីពិនិត្យមើលការកំណត់ Settings នៅក្នុងទូរសព្ទដៃរបស់អ្នក រួចគណនាថាតើអ្នកបានចំណាយពេលជាមធ្យមប៉ុន្មានម៉ោងក្នុងមួយថ្ងៃ និងសរុបប៉ុន្មានម៉ោងក្នុងមួយសប្តាហ៍លើបណ្តាញសង្គមផ្សេងៗគ្នាកាលពីសប្តាហ៍មុន។ បន្ទាប់មកសូមឆ្លុះបញ្ចាំងលើសំណួរខាងក្រោម៖

- តើអ្នកគិតថាពេលវេលាដែលអ្នកបានចំណាយនោះ មានភាពសមស្រប ឬច្រើនជ្រុលហួសហេតុ?
- តើអ្នកអាចបង្កើតតុល្យភាពនៃការប្រើប្រាស់បណ្តាញសង្គមឱ្យបានល្អជាងមុនយ៉ាងដូចម្តេច ដើម្បីរក្សាកម្រិតនៃការប្រើប្រាស់មួយដែលល្អចំពោះសុខភាព និងសមហេតុផល?

លំហាត់អនុវត្តន៍ជាមួយឧបករណ៍ | **MIL Chatbot | ជំពូកទី២៖ ដំណឹង និងព័ត៌មាន**

ការពិតនិងមតិយោបល់៖ ឆ្លើយសំណួរសាកល្បង ហើយពិនិត្យមើលព័ត៌មានប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់អ្នក

សូមប្រើប្រាស់កម្មវិធីតេឡេក្រាម MIL Chatbot ហើយចូលទៅកាន់ជំពូកទី២៖ ដំណឹង និងព័ត៌មាន ដើម្បីរៀនពីរបៀបបែងចែករវាង «ការពិត» និង «មតិយោបល់» ។

- ចូលរួមដោះស្រាយលំហាត់ ដើម្បីសាកល្បងសមត្ថភាពខ្លួនឯង។ តើអ្នកទទួលបានពិន្ទុប៉ុន្មាន?
- ការឆ្លុះបញ្ចាំង៖ តើការបង្ហោះលើបណ្តាញសង្គមផ្ទាល់ខ្លួនរបស់អ្នកភាគច្រើនជា «ការពិត» ឬជា «មតិយោបល់»? ហេតុអ្វី?
- សូមពិនិត្យមើលបណ្តាញសង្គមរបស់អ្នក រួចកំណត់រកការបង្ហោះចំនួន៥ ដែលជាការពិត ឬជាមតិយោបល់ ហើយថតរូបភាពអេក្រង់ទុក។
- បង្កើតជាល្បែងកំសាន្តមួយដោយប្រើរូបភាពដែលអ្នកបានថត រួចយកទៅលេងជាមួយក្រុមគ្រួសាររបស់អ្នកដោយឱ្យពួកគាត់សម្រេចចិត្តថា តើរូបភាពនីមួយៗជា «ការពិត» ឬជា «មតិយោបល់»។

ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថលប្រកបដោយសីលធម៌៖ ស្វែងយល់បន្ថែម និងទស្សនាវីដេអូ

សូមប្រើប្រាស់កម្មវិធីទូរសព្ទ SALA MIL ហើយចូលទៅកាន់ជំពូកទី៣ មេរៀនទី៣.១៖ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថលប្រកបដោយសីលធម៌។ សូមអានខ្លឹមសារ ចូរឆ្លើយសំណួរខ្លី និងទស្សនាវីដេអូដោយយកចិត្តទុកដាក់។ បន្ទាប់ពីបញ្ចប់សកម្មភាពទាំងនេះ សូមឆ្លើយសំណួរខាងក្រោម៖

- តើការប្រព្រឹត្តចំពោះអ្នកដទៃនៅលើបណ្តាញអនឡាញ គួរមានលក្ខណៈបែបណាបើប្រៀបធៀបនឹងការប្រព្រឹត្តចំពោះគ្នានៅក្នុងជីវិតពិត?
- តើសំណួរអ្វីខ្លះដែលអ្នកគួរសួរខ្លួនឯង មុននឹងចែករំលែកអ្វីមួយនៅលើអនឡាញ?
- ហេតុអ្វីបានជាយើងគួរមានការប្រុងប្រយ័ត្នចំពោះអ្វីដែលបានបង្ហោះនៅលើអនឡាញ?

សាររបស់អ្នកអំពីការប្រើប្រាស់ប្រកបដោយសីលធម៌៖ រៀបចំផែនការ និងថតសំឡេង ឬវីដេអូខ្លី

សូមរៀបចំផែនការនិងថតសំឡេងឬវីដេអូខ្លីដែលមានរយៈពេល១នាទី សម្រាប់ផ្ញើទៅកាន់អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថលវ័យក្មេងដទៃទៀតអំពីសារៈសំខាន់នៃការប្រើប្រាស់ប្រកបដោយសីលធម៌៖

- ណែនាំខ្លួនអ្នក និងប្រធានបទដែលត្រូវនិយាយ
- ពន្យល់ពីអត្ថន័យនៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថលប្រកបដោយសីលធម៌
- លើកយកឧទាហរណ៍មួយអំពីឥរិយាបថអនឡាញដែលមានសីលធម៌ និងឧទាហរណ៍មួយទៀតអំពីឥរិយាបថដែលគ្មានសីលធម៌
- ផ្តល់ហេតុផល២-៣ចំណុចថា ហេតុអ្វីបានជាការប្រើប្រាស់ប្រកបដោយសីលធម៌មានសារៈសំខាន់
- បញ្ចប់ដោយសារដាស់តឿនឱ្យមានការចូលរួមអនុវត្ត។

សំណួរសម្រាប់ពិភាក្សា

១. យោងតាមមាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា តើប្រជាពលរដ្ឋខ្មែរមានសេរីភាពក្នុងការបញ្ចេញមតិយ៉ាងដូចម្តេចខ្លះ?

២. ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិសេរីភាពក្នុងបញ្ចេញមតិ តែត្រូវបានកម្រិតដោយកាតព្វកិច្ចអ្វីខ្លះ?

៣. តើមានចំណុចអ្វីខ្លះដែលអ្នកគួរពិចារណា មុនពេលបញ្ចេញមតិ ឬចែករំលែកព័ត៌មាននៅលើអ៊ីនធឺណិត?

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

មេរៀនទី ៤

សុខុមាលភាពឌីជីថល

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

ក. ទម្លាប់ឌីជីថលប្រកបដោយសុខុមាលភាព

ខ. ផលប៉ះពាល់អវិជ្ជមាននៃការចំណាយពេលច្រើនហួសកម្រិតលើអនឡាញ

គ. សញ្ញាព្រមាននៃការប្រើប្រាស់ឧបករណ៍ឌីជីថលច្រើនហួសកម្រិត

ឃ. ការស្តារតុល្យភាពឡើងវិញរវាងជីវិតឌីជីថល និងជីវិតពិត

ហេតុអ្វីបានជាមេរៀននេះសំខាន់?

ទម្លាប់ឌីជីថលល្អជួយទប់ស្កាត់ភាពតានតឹង ការរំខាន និងការញៀននឹងបច្ចេកវិទ្យា។ យុទ្ធសាស្ត្រសុខុមាលភាពឌីជីថលល្អ ជួយមនុស្សឱ្យទទួលស្គាល់សញ្ញាព្រមានប្រាប់អំពីការប្រើប្រាស់បច្ចេកវិទ្យាហួសកម្រិត និងរក្សាតុល្យភាពរវាងជីវិតឌីជីថល និងជីវិតពិតប្រចាំថ្ងៃរបស់ពួកគេ។

ក. ទម្លាប់ឌីជីថលប្រកបដោយសុខុមាលភាព

ជារៀងរាល់ថ្ងៃសិស្សានុសិស្សនៅកម្ពុជាប្រើប្រាស់ទូរសព្ទឆ្លាតវៃ កុំព្យូទ័រ និងអ៊ីនធឺណិតសម្រាប់ការសិក្សា ការកម្សាន្ត និងការរក្សាទំនាក់ទំនងជាមួយមិត្តភក្តិ និងក្រុមគ្រួសារ។ បច្ចេកវិទ្យាជួយឱ្យយើងរៀនសូត្រ ប្រាស្រ័យទាក់ទង និងទទួលបានការកម្សាន្តសប្បាយ។ ការប្រើប្រាស់បច្ចេកវិទ្យាច្រើនពេកក៏អាចបង្កឱ្យមានបញ្ហាផងដែរ ដូចគ្នាទៅនឹងការបរិភោគអាហារដែលឆ្ងាញ់ច្រើនពេកអាចធ្វើឱ្យយើងឈឺ។ នេះហើយជាមូលហេតុដែលយើងត្រូវរៀនអំពី «សុខុមាលភាពឌីជីថល»។

សុខុមាលភាពឌីជីថលមានន័យថាជាការប្រើប្រាស់បច្ចេកវិទ្យា ដែលធ្វើឱ្យជីវិតរបស់អ្នកកាន់តែប្រសើរឡើង មិនមែនកាន់តែអាក្រក់នោះទេ។ វាមានសារៈសំខាន់ណាស់ក្នុងការស្វែងរកតុល្យភាពរវាងជីវិតនៅលើអនឡាញ និងជីវិតនៅខាងក្រៅប្រព័ន្ធអនឡាញ។ ការចំណាយពេលនៅលើអនឡាញច្រើនពេក អាចនាំឱ្យប៉ះពាល់ដល់ការសិក្សា ទំនាក់ទំនងគ្រួសារនិងមិត្តភក្តិ ព្រមទាំងប៉ះពាល់ដល់សុខភាពផ្លូវចិត្តរបស់យើងទៀតផង។

ខ. ផលប៉ះពាល់អវិជ្ជមាននៃការចំណាយពេលច្រើនហួសកម្រិតលើអនឡាញ

នៅពេលដែលយើងចំណាយពេលច្រើនពេកក្នុងការសម្លឹងមើលអេក្រង់ ឬប្រើប្រាស់ទូរសព្ទនោះ រាងកាយ និងផ្លូវចិត្តរបស់យើងអាចនឹងទទួលរងផលប៉ះពាល់។ ប្រសិនបើអ្នកញ៉ាំស្ករគ្រាប់ច្រើនពេក អ្នកនឹងឈឺពោះ ប្រៀបដូចជាអ្នកប្រើប្រាស់បច្ចេកវិទ្យាច្រើនពេកដោយគ្មានការឈប់សម្រាក អ្នកអាចមានអារម្មណ៍អស់កម្លាំង តានតឹង និងមានអារម្មណ៍ថាឃ្លាតឆ្ងាយពីមនុស្សនៅជុំវិញខ្លួន។



រូបភាព ៤.១ ផលប៉ះពាល់នៃការចំណាយពេលច្រើនហួសកម្រិតលើអនឡាញ

មនុស្សជាច្រើនមិនបានដឹងថាពួកគេចំណាយពេលច្រើនប៉ុនណា នៅលើអនឡាញក្នុងមួយថ្ងៃៗ ដែលនាំឱ្យប៉ះពាល់ដល់ការគេង ភ្នែក និងទំនាក់ទំនងជាមួយគ្រួសារនិងមិត្តភក្តិ។ ការយល់ដឹងអំពីបញ្ហាទាំងនេះ អាចជួយអ្នកធ្វើការសម្រេចចិត្តបានល្អប្រសើរជាងមុនថាតើគួរប្រើប្រាស់បច្ចេកវិទ្យានៅពេលណា និងដោយរបៀបណា។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

- ការចំណាយពេលសម្លឹងមើលអេក្រង់ច្រើនពេកអាចធ្វើឱ្យប៉ះពាល់ដល់ភ្នែក ធ្វើឱ្យឈឺក្បាល និងរំខានដល់ដំណេក។
- ការទទួលបានសារជូនដំណឹងជាប់ជានិច្ចអាចបង្កភាពតានតឹង និងធ្វើឱ្យពិបាកក្នុងការផ្តោតអារម្មណ៍លើកិច្ចការអ្វីមួយ។
- ការប្រៀបធៀបជីវិតរបស់អ្នកទៅនឹងអ្វីដែលអ្នកដទៃបង្ហោះនៅលើបណ្តាញផ្សព្វផ្សាយសង្គម មិនល្អចំពោះទំនុកចិត្តលើខ្លួនឯង និងសុខភាពផ្លូវចិត្តរបស់អ្នកឡើយ។
- ការប្រើប្រាស់ទូរសព្ទច្រើនពេក ឆក់យកពេលវេលាពីទំនាក់ទំនងដ៏សំខាន់ក្នុងជីវិតពិតជាមួយគ្រួសារ និងមិត្តភក្តិរបស់អ្នក។
- ការទទួលបានព័ត៌មានច្រើនលើសលប់ អាចធ្វើឱ្យអ្នកហត់នឿយខ្លាំង និងថែមទាំងធ្វើឱ្យពិបាកផ្តោតអារម្មណ៍លើប្រធានបទណាមួយឱ្យបានយូរទៀតផង។

គ. សញ្ញាព្រមាននៃការប្រើប្រាស់ឧបករណ៍ឌីជីថលច្រើនហួសកម្រិត

នៅពេលណាដែលការប្រើប្រាស់ទូរសព្ទ ឬអ៊ីនធឺណិតរបស់យើងក្លាយជាបញ្ហា។ វាកើតឡើងដោយសន្សឹមៗដូចពេលដែលអ្នកបង្កើនការញ៉ាំអាហារផ្អែមបន្តិចម្តងៗ រហូតក្លាយទៅជាទម្លាប់។ យុវជនជាច្រើនគិតថា ការប្រើប្រាស់បច្ចេកវិទ្យារបស់ពួកគេជារឿងធម្មតា ដោយសារតែមិត្តភក្តិទាំងអស់របស់ពួកគេក៏ប្រើប្រាស់ទូរសព្ទ និងបណ្តាញផ្សព្វផ្សាយសង្គមដូចគ្នាដែរ។ ឧទាហរណ៍៖ មិត្តភក្តិមួយក្រុមជួបជុំគ្នានៅហាងកាហ្វេ ប៉ុន្តែម្នាក់ៗបែរជារវល់នឹងទូរសព្ទរៀងៗខ្លួនដោយមិននិយាយរកគ្នាផង។ ដូច្នេះពួកគេនៅជាមួយគ្នាតែរូបកាយប៉ុន្តែចិត្តវិញនៅឆ្ងាយពីគ្នា ដែលអាចបង្កផលប៉ះពាល់ដល់ទំនាក់ទំនងក្នុងរយៈពេលវែង។ វាជារឿងខុសឆ្គងដែលគិតថា បណ្តាញផ្សព្វផ្សាយសង្គមអាចជំនួសមិត្តភាពពិតប្រាកដបាន។ ខណៈដែលទំនាក់ទំនងជាមួយមនុស្សជាច្រើនទាំងនៅលើអនឡាញ និងជីវិតពិតសុទ្ធតែមានតម្លៃ ប៉ុន្តែមិត្តភាពតាមអនឡាញច្រើនតែមិនស្ថិតស្ថេរយូរអង្វែង ឬមានអត្ថន័យជ្រាលជ្រៅដូចការប្រាស្រ័យទាក់ទងដោយផ្ទាល់នោះទេ។ អ្នកប្រើប្រាស់បណ្តាញសង្គមមួយចំនួនយល់ថាខ្លួនឯងឯកា និងកម្សត់ទោះបីជាពួកគេមានមិត្តច្រើននៅលើបណ្តាញផ្សព្វផ្សាយសង្គមក៏ដោយ។



រូបភាព ៤.២ សញ្ញាព្រមាននៃការប្រើប្រាស់ឧបករណ៍ឌីជីថលច្រើនហួសកម្រិត

មានសញ្ញាជាច្រើនដែលបង្ហាញថាការប្រើប្រាស់បច្ចេកវិទ្យាកំពុងក្លាយជារឿងមិនល្អចំពោះសុខភាព។ ការរៀនសម្គាល់សញ្ញាទាំងនេះពីដំបូងអាចជួយអ្នកដោះស្រាយបញ្ហាមុនពេលវាកាន់តែអាក្រក់ទៅៗ។

- មានការថប់អារម្មណ៍ នៅពេលដែលអ្នកមិនអាចពិនិត្យមើលទូរសព្ទរបស់អ្នកបាន។
- អូសមើលទូរសព្ទដល់យប់ជ្រៅ ហើយមានអារម្មណ៍អស់កម្លាំងនៅថ្ងៃបន្ទាប់។
- មើលទូរសព្ទអំឡុងពេលញ៉ាំអាហារ ឬពេលសន្ទនាជាមួយក្រុមគ្រួសារ។
- ពិបាកផ្តោតអារម្មណ៍ក្នុងរយៈពេលយូរ។
- នៅលើអនឡាញច្រើនជាងចំណាយពេលជាមួយមិត្តភក្តិ និងក្រុមគ្រួសារ។
- មានអារម្មណ៍មិនល្អចំពោះខ្លួនឯង បន្ទាប់ពីប្រើប្រាស់បណ្តាញសង្គម។
- លើកទូរសព្ទឡើងដោយមិនបានគិត នៅពេលដែលការសន្ទនាចាប់ផ្តើមស្ងាត់ ឬពេលនៅម្នាក់ឯង។

ឃ. ការស្តារតុល្យភាពឡើងវិញរវាងជីវិតឌីជីថល និងជីវិតពិត

តើអ្នកត្រូវធ្វើដូចម្តេចប្រសិនបើរកឃើញថាទម្លាប់ប្រើប្រាស់បច្ចេកវិទ្យារបស់អ្នក លើសពីការគ្រប់គ្រង? ដំណឹងល្អគឺថាអ្នកអាចផ្លាស់ប្តូរវាបាន! ដូចគ្នាទៅនឹងការរៀនបរិភោគអាហារដែលមានសុខភាពល្អ ឬហាត់ប្រាណឱ្យបានទៀងទាត់ដែរ អ្នកអាចរៀនប្រើប្រាស់បច្ចេកវិទ្យាតាមរបៀបដែលជួយអ្នក ជាជាងធ្វើឱ្យអ្នកឈឺចាប់។

អ្នកមិនចាំបាច់ឈប់ប្រើទូរសព្ទឬអ៊ីនធឺណិតទាំងស្រុងនោះទេ ផ្ទុយទៅវិញអ្នកអាចផ្លាស់ប្តូរទម្លាប់តូចៗ ដែលនឹងបង្កើតភាពខុសប្លែកគ្នាយ៉ាងខ្លាំងដល់អារម្មណ៍របស់អ្នក និងលទ្ធផលល្អដែលអ្នកទទួលបាននៅសាលារៀន និងជាមួយគ្រួសាររបស់អ្នក។ យុទ្ធសាស្ត្រសាមញ្ញៗទាំងនេះមានប្រសិទ្ធភាពសម្រាប់យុវជននៅជុំវិញពិភពលោក។

- បង្កើតពេលវេលា និងទីកន្លែងដែលគ្មានទូរសព្ទ (ពេលញ៉ាំអាហារ មួយម៉ោងមុនពេលចូលគេង ពេលសិក្សា)។
- មុនពេលអ្នកលើកទូរសព្ទរបស់អ្នក ចូរសួរខ្លួនឯងថាតើខ្ញុំចង់ធ្វើអ្វីជាមួយវាឥឡូវនេះហើយហេតុអ្វី?
- បិទការជូនដំណឹងដែលមិនចាំបាច់។
- កំណត់ពេលពីរទៅបីដងក្នុងមួយថ្ងៃដើម្បីពិនិត្យមើលបណ្តាញផ្សព្វផ្សាយសង្គម បើមិនទាន់ដល់ពេលទេកុំចូលមើលវា។
- ព្យាយាមធ្វើ «ការបន្សាបជាតិពុលឌីជីថល» មួយថ្ងៃក្នុងមួយសប្តាហ៍ដោយប្រើប្រាស់ទូរសព្ទតិចតួចបំផុត ឬមិនប្រើសោះ។
- ប្រើឧបករណ៍ឌីជីថលដូចជា YouTube ដើម្បីរៀនជំនាញថ្មីៗ ឬប្រើកម្មវិធីទូរសព្ទដៃដើម្បីកែលម្អភាសាអង់គ្លេស ឬភាសាផ្សេងទៀតរបស់អ្នកជាជាងការអូសមើល Facebook ឬ TikTok ដោយមិនបានគិត។
- ព្យាយាមអានសៀវភៅ មុនពេលចូលគេង ជំនួសឱ្យការសម្លឹងមើលទូរសព្ទ។

ចូរចាំថា៖ គោលដៅមិនមែនដើម្បីចៀសវាងបច្ចេកវិទ្យាទាំងស្រុងនោះទេ ប៉ុន្តែត្រូវប្រើវាតាមរបៀបដែលមានប្រយោជន៍ដល់សុខភាព ទំនាក់ទំនង ការសិក្សា និងគោលដៅជីវិតទាំងមូលរបស់អ្នក។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh



រូបភាព ៤.៣ ការស្វែងរកតុល្យភាពឡើងវិញរវាងជីវិតឌីជីថល និងជីវិតពិត

មេរៀនសង្ខេប

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីចំណុចសំខាន់ៗដូចខាងក្រោម៖

- សុខុមាលភាពឌីជីថល មានន័យថាជាការប្រើប្រាស់បច្ចេកវិទ្យាក្នុងរបៀបមួយដែលធ្វើឱ្យជីវិតរបស់អ្នកកាន់តែប្រសើរឡើង មិនមែនកាន់តែអាក្រក់នោះទេ។ វាមានសារៈសំខាន់ណាស់ក្នុងការស្វែងរកតុល្យភាពរវាងជីវិតនៅលើអនឡាញ និងជីវិតពិត ពីព្រោះការចំណាយពេលនៅលើអនឡាញច្រើនពេក អាចនាំឱ្យប៉ះពាល់ដល់ការសិក្សា ការងារ ទំនាក់ទំនងគ្រួសារនិងមិត្តភក្តិ ព្រមទាំងប៉ះពាល់ដល់សុខភាពផ្លូវចិត្តទៀតផង។
- មុនពេលប្រើប្រាស់ទូរសព្ទឬនៅលើអនឡាញ អ្នកគួរពិចារណាលើចំណុចខាងក្រោម៖
  - សួរខ្លួនឯងថា «តើខ្ញុំចង់ធ្វើអ្វីឥឡូវនេះ? ហេតុអ្វី?»
  - ត្រូវដឹងអំពីពេលវេលាដែលអ្នកចំណាយនៅលើអនឡាញជារៀងរាល់ថ្ងៃ។
  - សង្កេតមើលថាតើការប្រើប្រាស់បច្ចេកវិទ្យាកំពុងប៉ះពាល់ដល់ការគេង ទំនាក់ទំនង ឬសមត្ថភាពក្នុងការផ្តោតអារម្មណ៍របស់អ្នកដែរឬទេ។
  - ស្គាល់សញ្ញាព្រមាននានា ដូចជាការថប់អារម្មណ៍នៅពេលគ្មានទូរសព្ទ ឬការពិនិត្យមើលទូរសព្ទអំឡុងពេលសន្ទនាជាមួយអ្នកដទៃ។
  - បង្កើតពេលវេលា និងទីកន្លែងដែលគ្មានទូរសព្ទ សម្រាប់ពេលញ៉ាំអាហារ ពេលសិក្សា និងមុនពេលចូលគេង។
  - ប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការសិក្សារៀនសូត្រ និងគោលបំណងប្រកបដោយអត្ថន័យ ជាជាងការអូសមើល ដោយគ្មានគោលដៅ។

សទ្ទានុក្រម

- **សុខុមាលភាពឌីជីថល៖** ការប្រើប្រាស់បច្ចេកវិទ្យាដែលមានតុល្យភាព និងល្អចំពោះសុខភាព។
- **តុល្យភាពឌីជីថល៖** ពេលវេលាចំណាយលើសកម្មភាពអនឡាញ ធៀបនឹងសកម្មភាពខាងក្រៅ។
- **ការបន្សាបជាតិពុលឌីជីថល៖** រយៈពេលចំណាយដោយប្រើប្រាស់បច្ចេកវិទ្យាតិចតួច ឬមិនប្រើសោះ។
- **ការប្រើប្រាស់បច្ចេកវិទ្យាហួសកម្រិត៖** ការចំណាយពេលច្រើនពេកនៅលើអ៊ីនធឺណិត។

លំហាត់អនុវត្តន៍

១. កំណត់ហេតុទូរសព្ទដៃ៖ កត់ត្រា និងឆ្លុះបញ្ចាំងលើពេលវេលាប្រើប្រាស់អេក្រង់

សូមធ្វើកំណត់ហេតុអំពីការប្រើប្រាស់ទូរសព្ទដៃក្នុងរយៈពេលមួយថ្ងៃហើយកត់ត្រានូវចំណុចដូចខាងក្រោម៖

- តើអ្នកបើកសោអេក្រង់ទូរសព្ទរបស់អ្នកញឹកញាប់ប៉ុណ្ណា?
- តើអ្នកចំណាយពេលប៉ុន្មានម៉ោងនៅលើអ៊ីនធឺណិតដោយប្រើទូរសព្ទដៃ?
- តើកម្មវិធី ឬសកម្មភាពណាខ្លះដែលអ្នកប្រើច្រើនជាងគេ ហើយប្រើក្នុងគោលបំណងអ្វី?
- តើអ្នកមានអារម្មណ៍យ៉ាងណាបន្ទាប់ពីប្រើប្រាស់រួច (ឧទាហរណ៍៖ អស់កម្លាំង រំខានអារម្មណ៍ មានទំនាក់ទំនងល្អជាមួយអ្នកដទៃ ឬសប្បាយចិត្ត)?

នៅថ្ងៃបន្ទាប់ សូមពិនិត្យមើលកំណត់ហេតុរបស់អ្នកឡើងវិញ ហើយឆ្លុះបញ្ចាំងលើសំណួរទាំងនេះ៖

- តើមានចំណុចណាមួយដែលធ្វើឱ្យអ្នកភ្ញាក់ផ្អើលដែរឬទេ?
- តើពេលវេលានៃការប្រើប្រាស់អេក្រង់ មានទំនាក់ទំនងយ៉ាងដូចម្តេចទៅនឹងអារម្មណ៍របស់អ្នក?
- តើអ្នកគួរកាត់បន្ថយពេលវេលាប្រើប្រាស់អេក្រង់ ឬផ្លាស់ប្តូរទម្លាប់ប្រើប្រាស់ទូរសព្ទដៃដែរឬទេ? តើត្រូវធ្វើដូចម្តេច?

២. ការព្យាបាលសុខុមាលភាពឌីជីថល៖ ការផ្លាស់ប្តូរទម្លាប់មិនល្អ

សូមគិតអំពីសុខុមាលភាពឌីជីថល៖

- តើបច្ចេកវិទ្យាឌីជីថលមានតួនាទីអ្វីខ្លះក្នុងជីវិតប្រចាំថ្ងៃ?
- តើសុខុមាលភាពឌីជីថលមានសារៈសំខាន់កម្រិតណាសម្រាប់អ្នក?
- សូមផ្តល់ពិន្ទុដល់សុខុមាលភាពឌីជីថលរបស់អ្នកចាប់ពីលេខ០ (ខ្សោយបំផុត) ដល់ ១០ (ល្អឥតខ្ចោះ)។

សូមជ្រើសរើសទម្លាប់ឌីជីថលអវិជ្ជមានមួយដែលអ្នកចង់ផ្លាស់ប្តូរ ហើយកត់សម្គាល់ពីផលប៉ះពាល់អវិជ្ជមានដែលវាមានចំពោះអ្នក។ ឥឡូវនេះសូមស្រមៃថាអ្នកគឺជាអ្នកឯកទេសព្យាបាលម្នាក់ដែលកំពុងជួយខ្លួនឯងឱ្យកែលម្អទម្លាប់នេះ។ ចូរសរសេរសកម្មភាពជាក់ស្តែងចំនួន៣ ដែលអ្នកអាចធ្វើបានដើម្បីកែលម្អសុខុមាលភាពឌីជីថលរបស់អ្នក។ ចូរចាប់ផ្តើមអនុវត្តសកម្មភាពនោះ រួចពិនិត្យមើលជាប្រចាំថាតើទម្លាប់ និងសុខុមាលភាពរបស់អ្នកមានភាពប្រសើរឡើងយ៉ាងដូចម្តេច។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

៣. យកចិត្តទុកដាក់លើសុខុមាលភាពឌីជីថល៖

សូមប្រើប្រាស់កម្មវិធីទូរសព្ទ SALA MIL ហើយចូលទៅកាន់ជំពូកទី៣ មេរៀនទី៣.៤៖ សុខុមាលភាពឌីជីថល។ សូមអានគន្លឹះនានា និងឆ្លុះបញ្ចាំងពីតរិយាបថឌីជីថលរបស់អ្នក៖

- តើគន្លឹះមួយណាខ្លះដែលអ្នកបានអនុវត្តរួចហើយនៅក្នុងជីវិតប្រចាំថ្ងៃ?
- តើគន្លឹះមួយណាខ្លះដែលពិបាកសម្រាប់អ្នកក្នុងការយកទៅអនុវត្ត?
- តើអ្វីដែលរារាំងអ្នកមិនឱ្យយកវាទៅអនុវត្ត?
- តើអ្នកអាចចាប់ផ្តើមជម្នះបញ្ហាប្រឈមទាំងនេះដោយរបៀបណា?

៤. ទិវាសុខុមាលភាពឌីជីថលរបស់អ្នក៖ ការឆ្លុះបញ្ចាំងពីទម្លាប់ប្រចាំថ្ងៃតាមរយៈរូបថត Selfie

ឆ្លើយសំណួរដោយជ្រើសរើសជម្រើសដែលល្អបំផុតសម្រាប់ស្ថានភាពនីមួយៗ និងស្វែងយល់ថាហេតុអ្វីបានជាវាមានសារៈសំខាន់ ចំពោះសុខុមាលភាពឌីជីថលរបស់អ្នក។ ចាប់ផ្តើមផ្លាស់ប្តូរទម្លាប់ចាស់ៗ ហើយសរសេរនូវទម្លាប់ថ្មីដែលអ្នកចង់បង្កើតឡើងសម្រាប់សកម្មភាពផ្សេងៗ (ពេលភ្ញាក់ពីគេង ពេលញ៉ាំអាហារពេលព្រឹក ពេលធ្វើការ ពេលសម្រាកអាហារថ្ងៃត្រង់ ពេលជួបមិត្តភក្តិ ពេលទំនេរ និងពេលចូលគេង)។ សរសេរទម្លាប់នីមួយៗនៅលើក្រដាសដាច់ដោយឡែក ដោយភ្ជាប់ជាមួយរូបថត Selfie របស់អ្នកដើម្បីចងចាំទម្លាប់របស់អ្នកសម្រាប់អនាគត។

សំណួរសំរាប់ពិនិត្យមេរៀន

១. តើសុខុមាលភាពឌីជីថលគឺជាអ្វី?
២. ហេតុអ្វីបានជាសុខុមាលភាពឌីជីថលមានសារៈសំខាន់?
៣. តើការចំណាយពេលច្រើនពេកនៅលើអនឡាញ មានផលប៉ះពាល់អវិជ្ជមានអ្វីខ្លះ?
៤. តើមានសញ្ញាព្រមានអ្វីខ្លះ ដែលបង្ហាញថាការប្រើប្រាស់បច្ចេកវិទ្យាប៉ះពាល់ចំពោះសុខភាព?
៥. តើ «ការបន្សាបជាតិពុលឌីជីថល» គឺជាអ្វី?
៦. តើអ្នកអាចប្រើប្រាស់វិធីអ្វីផ្សេងទៀត ដើម្បីស្តារតុល្យភាពរវាងជីវិតឌីជីថល និងជីវិតពិតរបស់អ្នកឡើងវិញ?
៧. តើសកម្មភាពកីឡា និងជីវិតពិតខាងក្រៅដើរតួនាទីយ៉ាងដូចម្តេចខ្លះក្នុងការរក្សាតុល្យភាពជីវិត?

ជំពូកទី៣

បញ្ញាសិប្បនិម្មិត

មេរៀនទី១៖ បញ្ញាសិប្បនិម្មិត គោលគំនិត និងការអនុវត្ត
មេរៀនទី២៖ ទំនួលខុសត្រូវក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិត
មេរៀនទី៣៖ ហានិភ័យ និងក្រមសីលធម៌បញ្ញាសិប្បនិម្មិត
មេរៀនទី៤៖ ការប្រើប្រាស់បញ្ញាសិប្បនិម្មិតក្នុងការបង្កើតមាតិកា

មេរៀនទី ១
បញ្ញាសិប្បនិម្មិត គោលគំនិត និងការអនុវត្ត



មេរៀនទី២.១



ជំពូកទី៦

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីៈ

ក. និយមន័យ និងប្រភេទផ្សេងៗនៃបញ្ញាសិប្បនិម្មិត

ខ. បញ្ញាសិប្បនិម្មិតក្នុងប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍

គ. បញ្ញាសិប្បនិម្មិត និងសាលារៀន

ឃ. បញ្ញាសិប្បនិម្មិតដែលយើងកំពុងប្រើប្រាស់

ហេតុអ្វីបានជាមេរៀននេះសំខាន់?

បញ្ញាសិប្បនិម្មិតកំពុងក្លាយជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់មនុស្ស ដូច្នេះអ្នកសិក្សាត្រូវស្វែងយល់ថាវាជាអ្វី រាំដំណើរការដោយរបៀបណា និងគួរចៀសវាងហានិភ័យយ៉ាងដូចម្តេច។ ការយល់ដឹងអំពីគោលគំនិតជាមូលដ្ឋានរបស់បញ្ញាសិប្បនិម្មិត ជួយសិស្សឱ្យប្រើប្រាស់ឧបករណ៍ទាំងនេះដោយឈ្លាសវៃ។

ក. និយមន័យ និងប្រភេទផ្សេងៗនៃបញ្ញាសិប្បនិម្មិត

នៅពេលដែលយើងមានជំនួយការដ៏ឆ្លាតវៃម្នាក់ដែលមិនចេះហត់នឿយអាចអានសៀវភៅរាប់ពាន់ក្បាលក្នុងរយៈពេលត្រឹមតែប៉ុន្មានវិនាទី និងអាចជួយឆ្លើយសំណួរស្មើរតែគ្រប់បែបយ៉ាង។ នោះហើយគឺជាបញ្ញាសិប្បនិម្មិត ដែលជាកម្មវិធីកុំព្យូទ័រអាចជួយបំពេញការងារនានា ដែលជាធម្មតាទាមទារនូវការប្រើប្រាស់បញ្ញារបស់មនុស្ស។ បញ្ញាសិប្បនិម្មិតមានរត្តមានរាប់ទសវត្សរ៍មកហើយ ប៉ុន្តែនាពេលថ្មីៗនេះវាបានក្លាយជាបច្ចេកវិទ្យាដ៏មានឥទ្ធិពល និងកាន់តែមានភាពងាយស្រួលសម្រាប់មនុស្សក្នុងការប្រើប្រាស់។

បញ្ញាសិប្បនិម្មិតមានភាពខុសប្លែកពីកម្មវិធីកុំព្យូទ័រធម្មតា ដែលដំណើរការទៅតាមតែការណែនាំជាក់លាក់របស់អ្នកសរសេរកម្មវិធី។ បញ្ញាសិប្បនិម្មិតដែលគេបានបង្រៀនហើយ អាចរៀនបន្ស៊ាំខ្លួន និងធ្វើការសម្រេចចិត្តដោយផ្អែកលើព័ត៌មានដែលវាបានរៀន។ សមត្ថភាពបញ្ញាសិប្បនិម្មិតនាពេលបច្ចុប្បន្នរួមមាន៖

- យល់នូវអ្វីដែលអ្នកនិយាយ ឬសរសេរជាភាសាផ្សេងៗគ្នាជាច្រើន
- បង្កើតរូបភាព វីដេអូ និងអត្ថបទដែលមានលក្ខណៈដូចទៅនឹងស្នាដៃរបស់មនុស្ស
- រៀនសូត្រពីព័ត៌មាន និងអភិវឌ្ឍសមត្ថភាពខ្លួនឯងឱ្យកាន់តែប្រសើរឡើងពីមួយថ្ងៃ ទៅមួយថ្ងៃ
- ជួយដោះស្រាយបញ្ហា និងឆ្លើយសំណួរលើគ្រប់ប្រធានបទ។

សូមចាត់ទុកបញ្ញាសិប្បនិម្មិតជា «ជំនួយការដ៏ឆ្លាតវៃ» ដែលអាចជួយការងារបានច្រើនយ៉ាង ចាប់តាំងពីការជួយធ្វើកិច្ចការសាលា រហូតដល់ការបង្កើតស្នាដៃសិល្បៈផ្សេងៗ។



រូបភាព ១.១ ការប្រើប្រាស់បញ្ញាសិប្បនិម្មិតជាជំនួយការដ៏ឆ្លាតវៃ

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

បញ្ញាសិប្បនិម្មិតមានប្រភេទផ្សេងៗគ្នាដែលប្រភេទនីមួយៗមានចំណុចខ្លាំង និងការប្រើប្រាស់រៀងខ្លួន។ ការយល់ដឹងពីភាពខុសគ្នាទាំងនេះ នឹងជួយយើងឱ្យជ្រើសរើសឧបករណ៍បញ្ញាសិប្បនិម្មិតបានត្រឹមត្រូវសម្រាប់កិច្ចការនីមួយៗ៖

សិក្ខាម៉ាស៊ីន៖ គឺជាការបង្រៀនកុំព្យូទ័រឱ្យស្គាល់នូវទម្រង់ផ្សេងៗ តាមរយៈការបង្ហាញឧទាហរណ៍ជាច្រើន។ ដូចគ្នាទៅនឹងមនុស្ស ដែលបានរៀនសម្គាល់ប្រភេទដើមឈើខុសៗគ្នា ដោយសារបានឃើញដើមឈើច្រើនប្រភេទ ការរៀនរបស់ម៉ាស៊ីនជួយឱ្យកុំព្យូទ័រសម្គាល់អ្វីៗផ្សេងទៀតបាន ដូចជាអ៊ីមែលឥតប្រយោជន៍ ការណែនាំតន្ត្រីដែលលោកអ្នកអាចនឹងចូលចិត្ត ឬជួយគ្រូពេទ្យក្នុងការវិភាគជំងឺពីរូបភាពវេជ្ជសាស្ត្រ។ វិស័យអប់រំ បច្ចេកវិទ្យានេះអាចតាមដានវឌ្ឍនភាពនៃការសិក្សា និងផ្តល់ការណែនាំលើចំណុចដែលយើងត្រូវហាត់រៀនបន្ថែម។

បញ្ញាសិប្បនិម្មិតបង្កើត៖ ជាប្រភេទបញ្ញាសិប្បនិម្មិតដែលអាចបង្កើតមាតិកាថ្មីៗបានទាំងស្រុងទៅតាមការចង់បានរបស់យើង។ វាប្រៀបដូចជាដៃគូបង្កើតថ្មីម្នាក់ ដែលអាចសរសេររឿង គូររូប ឬតាក់តែងបទភ្លេងតាមគំនិតរបស់យើង។ បញ្ញាសិប្បនិម្មិតបង្កើត អាចជួយបង្កើតមាតិកាដ៏ពេញនិយមបំផុតនាពេលបច្ចុប្បន្ន ជួយផ្តល់គំនិតសម្រាប់សរសេរអត្ថបទ ពន្យល់គោលគំនិតស្មុគស្មាញឱ្យងាយយល់ ឬជួយយើងហាត់សន្ទនាជាភាសាអង់គ្លេសជាដើម។ ប្រព័ន្ធបញ្ញាសិប្បនិម្មិតប្រភេទនេះ ត្រូវបានបណ្តុះបណ្តាលដោយការពិនិត្យមើលទិន្នន័យអត្ថបទ រូបភាព និងទិន្នន័យផ្សេងៗយ៉ាងច្រើនសន្ធឹកសន្ធាប់ពីអ៊ីនធឺណិត។

បច្ចេកវិទ្យាមើលឃើញរបស់កុំព្យូទ័រ៖ បច្ចេកវិទ្យានេះជួយឱ្យកុំព្យូទ័រមើលឃើញ និងយល់នូវរូបភាពឬវីដេអូ ដូចទៅនឹងអ្វីដែលមនុស្សមើលឃើញដែរ។ នៅពេលអ្នកថតរូបដោយប្រើទូរសព្ទ ហើយវាចាប់ចំណុចច្បាស់ លើផ្ទៃមុខដោយស្វ័យប្រវត្តិ នោះហើយគឺជាដំណើរការនៃបច្ចេកវិទ្យាមើលឃើញរបស់កុំព្យូទ័រ។

ការដំណើរការភាសាធម្មជាតិ៖ គឺជាបច្ចេកវិទ្យា ដែលអនុញ្ញាតឱ្យកុំព្យូទ័រយល់ និងឆ្លើយតបទៅនឹងភាសាមនុស្សមិនថាជា ភាសាខ្មែរ អង់គ្លេស ឬភាសាផ្សេងទៀតឡើយ។ បច្ចេកវិទ្យានេះគឺជាកម្លាំងចលករនៃកម្មវិធីបកប្រែភាសា និងជួយឱ្យកម្មវិធីបញ្ជាដោយសំឡេង អាចយល់នូវរាល់បទបញ្ជាដែលយើងនិយាយបាន។

ខ. បញ្ញាសិប្បនិម្មិតក្នុងប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍

បណ្តាញសង្គមត្រូវបានដំណើរការដោយក្បួនដោះស្រាយនៃបញ្ញាសិប្បនិម្មិត ដែលកំណត់ថា តើមាតិកាអ្វីខ្លះដែលត្រូវបង្ហាញនៅលើកញ្ចក់ទូរសព្ទរបស់យើង។ ប្រព័ន្ធទាំងនេះវិភាគលើសកម្មភាព ដូចជា៖ តើអ្នកចូលចិត្តចែករំលែកឬចំណាយពេលអានអត្ថបទប្រភេទណា ដើម្បីទស្សន៍ទាយនូវអ្វីដែលយើងចាប់អារម្មណ៍បំផុត។ ទោះបីវាផ្តល់ភាពងាយស្រួលក្នុងការស្វែងរកមាតិកាដែលត្រូវនឹងចំណង់ចំណូលចិត្តយើងក៏ដោយ ប៉ុន្តែវាអាចកម្រិតនូវមាតិកាព័ត៌មានដែលយើងត្រូវទទួលបាន ដែលស្របទៅនឹងជំនឿ ឬទស្សនៈផ្ទាល់ខ្លួនរបស់យើងតែប៉ុណ្ណោះ ហើយវានឹងផាត់ចេញនូវមាតិកាផ្សេងៗទៀត។

បញ្ញាសិប្បនិម្មិតក៏កំពុងផ្លាស់ប្តូររបៀបផលិតមាតិកាព័ត៌មានផងដែរ។ ទីភ្នាក់ងារសារព័ត៌មានអន្តរជាតិមួយចំនួន បានប្រើប្រាស់បញ្ញាសិប្បនិម្មិតដើម្បីបកប្រែព័ត៌មានទាន់ហេតុការណ៍ទៅជាភាសាផ្សេងៗធ្វើឱ្យទស្សនិកជនទទួលបានព័ត៌មានទាន់ហេតុការណ៍។

អង្គភាពផ្សព្វផ្សាយក្នុងស្រុកក៏កំពុងចាប់ផ្តើមប្រើប្រាស់ឧបករណ៍បញ្ញាសិប្បនិម្មិតសម្រាប់កិច្ចការ ដូចជាការផ្ទៀងផ្ទាត់ការពិត និងការបង្កើតមាតិកា។

- **បណ្តាញសង្គម៖** Facebook និង TikTok ប្រើប្រាស់បញ្ញាសិប្បនិម្មិតដើម្បីបង្ហាញមាតិកាដែលអ្នកអាចនឹងចូលចិត្តផ្អែកលើសកម្មភាពប្រើប្រាស់ពីមុនរបស់អ្នក។
- **ការបកប្រែ៖** Google Translate ប្រើប្រាស់បញ្ញាសិប្បនិម្មិតដើម្បីបកប្រែពីភាសាអង់គ្លេសមកខ្មែរបានភ្លាមៗ ដែលជួយដល់សិស្សានុសិស្សក្នុងការស្វែងរកឯកសារសិក្សា។
- **សារព័ត៌មាន៖** វេបសាយសារព័ត៌មានមួយចំនួន ប្រើប្រាស់បញ្ញាសិប្បនិម្មិតដើម្បីសរសេរអត្ថបទព័ត៌មានសាមញ្ញៗ និងបកប្រែព័ត៌មានអន្តរជាតិ។
- **កម្មវិធីផ្ញើសារ៖** Telegram និងកម្មវិធីផ្សេងៗទៀត ប្រើប្រាស់បញ្ញាសិប្បនិម្មិតដើម្បីផ្តល់យោបល់សម្រាប់ការឆ្លើយតប និងស្វែងរកសារំខាន ឬសារបោកប្រាស់។

គ. បញ្ញាសិប្បនិម្មិត និងសាលារៀន

ការបញ្ចូលបញ្ញាសិប្បនិម្មិតទៅក្នុងវិស័យអប់រំ គឺជាឱកាសដ៏សំខាន់សម្រាប់សាលារៀនក្នុងការកែលម្អបទពិសោធន៍នៃការរៀនសូត្រ និងផ្តល់ការអប់រំជាលក្ខណៈបុគ្គល។ ឧបករណ៍បញ្ញាសិប្បនិម្មិតអាចជួយផ្តល់ធនធានអប់រំ ដែលមានគុណភាពខ្ពស់ដល់សិស្សានុសិស្ស ទោះបីជាពួកគេស្ថិតនៅទីណាក៏ដោយ ឱ្យតែភ្ជាប់អ៊ីនធឺណិត។

បញ្ញាសិប្បនិម្មិតអាចដើរតួជាគ្រូជំនួយដែលនៅក្បែរយើងគ្រប់ពេលវេលា។ ខុសពីគ្រូដែលជាមនុស្ស បញ្ញាសិប្បនិម្មិតមិនមានអារម្មណ៍មួម៉ៅឬធុញទ្រាន់ឡើយ ទោះបីជាយើងសួរសំណួរច្រើនដងក៏ដោយ ហើយវាថែមទាំងអាចពន្យល់គោលគំនិតតាមរបៀបផ្សេងៗគ្នារហូតដល់យើងយល់ច្បាស់។ ចំណុចនេះមានសារៈសំខាន់ខ្លាំងសម្រាប់សិស្សដែលខ្វះខាតលទ្ធភាពទទួលបានការបង្រៀនពីគ្រូ ឬការរៀនបន្ថែមដែលគាត់ត្រូវការ។



រូបភាព ១.២ ការប្រើប្រាស់បញ្ញាសិប្បនិម្មិតនៅក្នុងសាលារៀន

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

- **ការជួយធ្វើកិច្ចការផ្ទះ៖** បញ្ញាសិប្បនិម្មិតអាចពន្យល់លំហាត់គណិតវិទ្យាពិបាកៗ ឬប្រធានបទប្រវត្តិសាស្ត្រតាមរបៀបងាយយល់។
- **ការរៀនភាសា៖** បញ្ញាសិប្បនិម្មិតអាចជួយលោកអ្នកហាត់បញ្ចេញសំឡេងភាសាបរទេស ឬរៀនវាក្យសព្ទថ្មីៗ។
- **ការរៀបចំឯកសារ៖** លោកគ្រូ អ្នកគ្រូអាចប្រើប្រាស់បញ្ញាសិប្បនិម្មិតជួយរៀបចំវិញ្ញាសាប្រឡង និងកិច្ចតែងការបង្រៀនបានយ៉ាងឆាប់រហ័ស ដែលជួយសន្សំសំចៃពេលវេលាសម្រាប់យកទៅផ្តោតលើការបង្រៀនផ្ទាល់។
- **ការស្រាវជ្រាវ៖** សិស្សានុសិស្សអាចប្រើប្រាស់បញ្ញាសិប្បនិម្មិតដើម្បីស្វែងរកព័ត៌មានសម្រាប់គម្រោងសិក្សា និងទទួលបានការពន្យល់លើប្រធានបទស្មុគស្មាញ។

ឃ. បញ្ញាសិប្បនិម្មិតដែលយើងកំពុងប្រើប្រាស់

មនុស្សជាច្រើនប្រហែលជាមានការភ្ញាក់ផ្អើល បើដឹងថាពួកគេបានប្រើប្រាស់បញ្ញាសិប្បនិម្មិតអស់រយៈពេលជាច្រើនឆ្នាំមកហើយដោយមិនដឹងខ្លួន។ បញ្ញាសិប្បនិម្មិតគឺជាផ្នែកមួយនៃជីវិតឌីជីថលរបស់យើងរួចទៅហើយ។ រាល់ពេលដែលយើងស្វែងរកអ្វីមួយតាមរយៈ Google បញ្ញាសិប្បនិម្មិតយល់ពីសំណួរនិងស្វែងរកលទ្ធផលដែលពាក់ព័ន្ធបំផុតចេញពីវេបសាយរាប់ពាន់លាន។ នៅលើ YouTube បញ្ញាសិប្បនិម្មិតនឹងវិភាគប្រវត្តិដែលអ្នកធ្លាប់ទស្សនា ដើម្បីផ្តល់នូវវីដេអូថ្មីៗដែលយើងអាចនឹងចូលចិត្ត។ សូម្បីតែកាមេរ៉ាទូរសព្ទរបស់អ្នកក៏ប្រើប្រាស់បញ្ញាសិប្បនិម្មិតដើម្បីកែតម្រូវមុខងារឱ្យថតរូបបានស្អាត និងស្គាល់ផ្ទៃមុខដើម្បីកំណត់អត្តសញ្ញាណផងដែរ។

ការយល់ដឹងពីការប្រើប្រាស់បញ្ញាសិប្បនិម្មិតទាំងនេះ ជួយឱ្យសិស្សានុសិស្សមើលឃើញថាការរៀនប្រើប្រាស់ឧបករណ៍ដូចជា ChatGPT ឬវេទិកាអប់រំដទៃទៀត គ្រាន់តែជាការបន្ថែមនូវជំនាញឌីជីថលដែលពួកគេមានស្រាប់តែប៉ុណ្ណោះ។



រូបភាព ១.៣ បញ្ញាសិប្បនិម្មិតដែលយើងកំពុងប្រើប្រាស់

មេរៀនសង្ខេប

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីចំណុចសំខាន់ៗដូចខាងក្រោម៖

- បញ្ញាសិប្បនិម្មិត គឺជាបច្ចេកវិទ្យាដែលអនុញ្ញាតឱ្យម៉ាស៊ីនកុំព្យូទ័រមានសមត្ថភាពរៀនគិត វិភាគ និងយល់ដឹងពីបញ្ហាជាក់លាក់ណាមួយ ដោយយកលំនាំតាមសមត្ថភាពរបស់ខួរក្បាលមនុស្ស។
- ប្រភេទសំខាន់ៗទាំង ៤នៃបញ្ញាសិប្បនិម្មិត៖
  - សិក្ខាម៉ាស៊ីន៖ រៀនសូត្រពីឧទាហរណ៍ (Facebook ស្គាល់ពីចំណាប់អារម្មណ៍របស់អ្នក)។
  - បញ្ញាសិប្បនិម្មិតបង្កើត៖ បង្កើតមាតិកាថ្មីៗ (ដូចជា ChatGPT Gemini)។
  - បច្ចេកវិទ្យាមើលឃើញរបស់កុំព្យូទ័រ៖ ជួយឱ្យកុំព្យូទ័រមើលឃើញ ដូចជា ការចាប់ចំណុចច្បាស់របស់កាមេរ៉ាទូរសព្ទ។
  - ការដំណើរការភាសាធម្មជាតិ៖ បច្ចេកវិទ្យា ដែលអនុញ្ញាតឱ្យកុំព្យូទ័រយល់ និងឆ្លើយតបទៅនឹងភាសាមនុស្សដូចជា ភាសាខ្មែរ អង់គ្លេស ឬភាសាផ្សេងទៀតឡើយ។
- បញ្ញាសិប្បនិម្មិតក្នុងជីវិតប្រចាំថ្ងៃ៖ Facebook និងTikTok ប្រើបញ្ញាសិប្បនិម្មិតសម្រាប់បង្ហាញមាតិកា។ ដោយឡែក YouTube ប្រើប្រាស់បញ្ញាសិប្បនិម្មិតសម្រាប់ណែនាំមាតិកាដល់អ្នកប្រើ។ Google Translate ប្រើប្រាស់បញ្ញាសិប្បនិម្មិតសម្រាប់បកប្រែភាសា។
- បញ្ញាសិប្បនិម្មិតក្នុងការអប់រំ៖ ដើរតួជាគ្រូជំនួយគ្រប់ពេលវេលា ពន្យល់លំហាត់គណិតវិទ្យា ជួយបង្រៀនភាសាអង់គ្លេស និងជួយគ្រូក្នុងការរៀបចំឯកសារបង្រៀន។

សទ្ទានុក្រម

- **បញ្ញាសិប្បនិម្មិត៖** ប្រព័ន្ធកុំព្យូទ័រដែលអាចរៀន និងបំពេញកិច្ចការបានដូចមនុស្ស។
- **ក្បួនដោះស្រាយ៖** សំណុំនៃវិធានឬជំហានដែលកុំព្យូទ័រអនុវត្តតាមដើម្បីដោះស្រាយបញ្ហា ឬសម្រេចចិត្តថាត្រូវបង្ហាញអ្វីនៅលើអ៊ីនធឺណិត។
- **បញ្ញាសិប្បនិម្មិតបង្កើត៖** ជាប្រភេទបញ្ញាសិប្បនិម្មិតដែលចេះបង្កើតមាតិកាថ្មី (អត្ថបទ រូបភាព សំឡេង)។ ឧទាហរណ៍រួមមាន ChatGPT Claude Gemini Copilot ជាដើម។
- **សិក្ខាម៉ាស៊ីន៖** ប្រព័ន្ធបញ្ញាសិប្បនិម្មិត ដែលចេះកែលម្អខ្លួនឯងតាមរយៈការសិក្សាទិន្នន័យ។
- **ការដំណើរការភាសាធម្មជាតិ៖** ប្រភេទនៃបញ្ញាសិប្បនិម្មិត ដែលជួយកុំព្យូទ័រឱ្យយល់ និងឆ្លើយតបទៅនឹងភាសារបស់មនុស្ស។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

លំហាត់អនុវត្តន៍

១. បញ្ញាសិប្បនិម្មិតប្រើប្រាស់ក្នុងជីវិតប្រចាំថ្ងៃ៖ ប្រាប់ឈ្មោះឧបករណ៍ទាំងនោះ។

តើអ្នកធ្លាប់ប្រើប្រាស់បញ្ញាសិប្បនិម្មិតដែរឬទេ? សូមសរសេរឈ្មោះឧបករណ៍បញ្ញាសិប្បនិម្មិតដែលអ្នកធ្លាប់បានប្រើ និងកម្រិតប្រើប្រាស់របស់វា។ បន្ទាប់មកសូមចាត់ក្រុមឧបករណ៍ទាំងនោះតាមមុខងារចម្បងៗដូចជា៖

- ការសិក្សារៀនសូត្រ និងការទទួលបានព័ត៌មាន
- ការបង្កើតខ្លឹមសារ
- ការបកប្រែភាសា
- ការរុករក និងការធ្វើដំណើរ
- ការប្រើក្នុងជីវភាពប្រចាំថ្ងៃ
- ការកម្សាន្ត និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ

ប្រសិនបើអ្នកចង់ស្វែងយល់បន្ថែម សូមស្រាវជ្រាវលើអ៊ីនធឺណិតដើម្បីរកមើលឧបករណ៍បញ្ញាសិប្បនិម្មិតថ្មីៗ។ សូមពិនិត្យមើលថាតើឧបករណ៍ណាខ្លះតម្រូវឱ្យចុះឈ្មោះ និងឧបករណ៍ណាខ្លះអាចប្រើបានដោយឥតគិតថ្លៃ។

លំហាត់អនុវត្តន៍ជាមួយឧបករណ៍ | **កម្មវិធី SALA MIL | ជំពូកទី២៖ បញ្ញាសិប្បនិម្មិត**

ពិនិត្យការយល់ដឹងរបស់អ្នកអំពីបញ្ញាសិប្បនិម្មិត៖ ចូរដោះស្រាយលំហាត់ និងឆ្លើយសំណួរ

សូមប្រើប្រាស់កម្មវិធីទូរសព្ទ SALA MIL ហើយចូលទៅកាន់ជំពូកទី២ មេរៀនទី២.១៖ តើអ្វីទៅជាបញ្ញាសិប្បនិម្មិត? សាកល្បងដោះស្រាយលំហាត់ ដើម្បីត្រួតពិនិត្យការយល់ដឹងរបស់អ្នក។ តើអ្នកទទួលបានពិន្ទុប៉ុន្មាន? សូមបង្កើតសំណួរជ្រើសរើស៣បន្ថែមទៀត៖

- សម្រាប់សំណួរនីមួយៗសូមបង្កើតចម្លើយចំនួន៤ ដោយធានាថាមានតែចម្លើយមួយគត់ដែលត្រឹមត្រូវ
- យកសំណួរទាំង៣ ដែលអ្នកបានបង្កើតទៅសួរមិត្តភក្តិ ឬសមាជិកគ្រួសារដើម្បីសាកល្បងសមត្ថភាពពួកគាត់ និងពិនិត្យថា តើអ្នកអាចកែលម្អសំណួរទាំងនោះឱ្យកាន់តែល្អដោយរបៀបណា។

លំហាត់អនុវត្តន៍ជាមួយឧបករណ៍ | **MIL Chatbot | ជំពូកទី៦៖ បញ្ញាសិប្បនិម្មិត**

ការយល់ដឹងអំពីបញ្ញាសិប្បនិម្មិត៖ សូមអានអត្ថបទ និងមើលវីដេអូ

ចូរប្រើប្រាស់កម្មវិធី MIL Chatbot ហើយចូលទៅកាន់ជំពូកទី៦៖ បញ្ញាសិប្បនិម្មិត ដោយអានអត្ថបទ និងទស្សនាវីដេអូ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីរបៀបដែលបញ្ញាសិប្បនិម្មិតដំណើរការ។

បន្ទាប់មកឆ្លើយសំណួរខាងក្រោម៖

- តើអ្វីទៅជាបញ្ញាសិប្បនិម្មិតបង្កើត? តើវាអាចបង្កើតខ្លឹមសារប្រភេទណាខ្លះ?
- តើអ្វីទៅជា Prompt?
- តើបញ្ញាសិប្បនិម្មិតបង្កើតដំណើរការយ៉ាងដូចម្តេច?
- តើបញ្ញាសិប្បនិម្មិតបង្កើត អាចត្រូវបានគេយកទៅប្រើប្រាស់ក្នុងផ្លូវខុស ឬអាចបង្កជាបញ្ហាដោយរបៀបណាខ្លះ?
- តើអ្វីទៅជាវិធីសាស្ត្រដ៏ល្អបំផុតក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិតបង្កើត?

ការពិភាក្សាដេញដោលគ្នាអំពីបញ្ញាសិប្បនិម្មិត៖ ការសម្តែងជាក្រុមតូច

ចូរស្វែងយល់ឱ្យកាន់តែស៊ីជម្រៅអំពីគ្រោះថ្នាក់នៃបញ្ញាសិប្បនិម្មិត និងរបៀបប្រើប្រាស់ ដោយការទទួលខុសត្រូវ។ យកក្រដាសមួយសន្លឹករួចសរសេរហានិភ័យនៃការប្រើបញ្ញាសិប្បនិម្មិតចំនួន៣។ បន្ទាប់មកយកក្រដាសមួយសន្លឹកទៀត រួចសរសេរវិធីសាស្ត្រចំនួន៣នៃការប្រើប្រាស់បញ្ញាសិប្បនិម្មិតដោយការទទួលខុសត្រូវ។ សូមរៀបចំកៅអី២ ដាក់ទល់មុខគ្នា៖

- កៅអីទីមួយ៖ លើកឡើងនូវអំណះអំណាងអំពីចំណុចអវិជ្ជមាននៃបញ្ញាសិប្បនិម្មិត។
- កៅអីទីពីរ៖ ផ្តោតសំខាន់លើសារៈសំខាន់នៃការប្រើប្រាស់បញ្ញាសិប្បនិម្មិតប្រកបដោយសីលធម៌។

សូមអង្គុយឆ្លាស់កៅអីគ្នាដើម្បីផ្លាស់ប្តូរអំណះអំណាង និងលើកឧទាហរណ៍ផ្សេងៗ។ អ្នកក៏អាចអញ្ជើញមិត្តភក្តិ ឬសមាជិកគ្រួសារឱ្យមកចូលរួមសម្តែងជាមួយគ្នាផងដែរ។

សំណួរសំរាប់ពិនិត្យមេរៀន

១. តើអ្វីទៅជាបញ្ញាសិប្បនិម្មិត?

២. តើបញ្ញាសិប្បនិម្មិតមានភាពខុសប្លែកពីកម្មវិធីកុំព្យូទ័រធម្មតាយ៉ាងដូចម្តេច?

៣. តើបញ្ញាសិប្បនិម្មិតប្រភេទអ្វីខ្លះដែលបានលើកឡើងក្នុងមេរៀន? សូមរៀបរាប់។

៤. តើបញ្ញាសិប្បនិម្មិត ត្រូវបានប្រើប្រាស់យ៉ាងដូចម្តេចក្នុងប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍? សូមផ្តល់ឧទាហរណ៍ជាក់លាក់។

៤. តើបញ្ញាសិប្បនិម្មិតអាចជួយដល់សិស្សានុសិស្ស និងគ្រូបង្រៀននៅក្នុងសាលារៀនបានយ៉ាងដូចម្តេចខ្លះ?

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

មេរៀនទី ២ ទំនួលខុសត្រូវក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិត

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

- ក. ការប្រើប្រាស់បញ្ញាសិប្បនិម្មិតជាជំនួយការ
- ខ. ភាពស្មោះត្រង់ក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិត
- គ. ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មានពីបញ្ញាសិប្បនិម្មិត
- ឃ. ការការពារឯកជនភាពក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិត

ហេតុអ្វីបានជាមេរៀននេះសំខាន់?

មេរៀននេះបង្រៀនសិស្សឱ្យចេះប្រើប្រាស់បញ្ញាសិប្បនិម្មិត ជាជំនួយការ មិនមែនជាការជំនួសការគិតផ្ទាល់ខ្លួនរបស់យើងនោះទេ។ វាក៏ពន្យល់ផងដែរថា ហេតុអ្វីបានជាភាពស្មោះត្រង់ និងឯកជនភាពមានសារៈសំខាន់នៅពេលប្រើប្រាស់ឧបករណ៍បញ្ញាសិប្បនិម្មិត។

ក. ការប្រើប្រាស់បញ្ញាសិប្បនិម្មិតជាជំនួយការ

គោលគំនិតសំខាន់បំផុតមួយយើងត្រូវយល់ដឹងថា បញ្ញាសិប្បនិម្មិតគឺជាអ្នកជំនួយមិនមែនជាអ្នកជំនួសឡើយ។ គោលការណ៍នេះមានសារៈសំខាន់ខ្លាំងណាស់ ដោយសារជំនាញត្រិះរិះពិចារណា និងជំនាញដោះស្រាយបញ្ហា គឺជាគ្រឹះចាំបាច់សម្រាប់ការសិក្សា និងអាជីពការងារនាពេលអនាគត។ បញ្ញាសិប្បនិម្មិត គឺជាឧបករណ៍ដ៏មានឥទ្ធិពលដែលអាចជួយយើងបំពេញកិច្ចការជាច្រើន ប៉ុន្តែវាមិនមែនជាការជំនួសឱ្យបញ្ញា និងការច្នៃប្រឌិតរបស់យើងបានឡើយ។

បញ្ញាសិប្បនិម្មិតដូចជាម៉ាស៊ីនគិតលេខ៖ វាអាចជួយគណនាការបូកដកលេខស្មុគស្មាញបានយ៉ាងលឿន ប៉ុន្តែយើងនៅតែត្រូវយល់អំពីគោលគំនិតគណិតវិទ្យា ដើម្បីដឹងថាត្រូវប្រើវិធីគណនាមួយណា ដែលទទួលបានលទ្ធផលត្រឹមត្រូវ ឬសមហេតុផលដែរឬទេ។ បញ្ញាសិប្បនិម្មិតអាចជួយយើងក្នុងការស្រាវជ្រាវប្រធានបទ រៀបចំគំនិត ឬផ្តល់យោបល់លើរបៀបសរសេរ ប៉ុន្តែយើងនៅតែត្រូវយល់ដឹងអំពីខ្លឹមសារនៃមេរៀន និងត្រូវចេះត្រិះរិះពិចារណាលើព័ត៌មានដែលបញ្ញាសិប្បនិម្មិតផ្តល់ឱ្យ។ វាជារឿងចាំបាច់ដែលសិស្សានុសិស្សត្រូវអភិវឌ្ឍចំណេះដឹង និងជំនាញផ្ទាល់ខ្លួន។ បញ្ញាសិប្បនិម្មិតគួរតែជួយឱ្យយើង «គិតបានកាន់តែប្រសើរ» មិនមែន «គិតជំនួស» យើងឡើយ។

របៀបប្រើប្រាស់បញ្ញាសិប្បនិម្មិតដែលត្រឹមត្រូវ៖

- ស្វែងរកគំនិតថ្មីៗសម្រាប់គម្រោងសាលា និងទិសដៅនៃការស្រាវជ្រាវ
- ស្វែងយល់ពីប្រធានបទពិបាកៗ តាមរយៈការពន្យល់បែបសាមញ្ញ
- ត្រួតពិនិត្យវេយ្យាករណ៍ និងរចនាបថនៃការសរសេរ
- ហ្វឹកហាត់ត្រៀមប្រឡង តាមរយៈសំណួរដែលបង្កើតដោយបញ្ញាសិប្បនិម្មិត
- ស្វែងរកដំណោះស្រាយច្នៃប្រឌិតចំពោះបញ្ហានានា
- សុំជំនួយក្នុងការរៀបចំលំដាប់លំដោយនៃគំនិត និងអំណះអំណាង

ខ. ភាពស្មោះត្រង់ក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិត

សិស្សជាច្រើនតែងមានចម្ងល់ថាតើពួកគេគួរប្រើប្រាស់បញ្ញាសិប្បនិម្មិតនៅពេលណា និងដោយរបៀបណា ដើម្បីចៀសវាងការបំពានវិន័យសាលា។ ចំណុចសំខាន់បំផុតក្នុងរឿងនេះ គឺតម្លាភាពដោយសិស្សគួរជម្រាបជូន និងពិភាក្សាជាមួយលោកគ្រូ អ្នកគ្រូ ឱ្យបានច្បាស់លាស់ ពីព្រោះអ្នកអប់រំផ្ទាល់ក៏កំពុងឈ្វេងយល់ពីរបៀបប្រើប្រាស់បញ្ញាសិប្បនិម្មិត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការអប់រំដូចគ្នាដែរ។

សាលារៀននិងគ្រូបង្រៀនអាចមានគោលការណ៍ខុសៗគ្នាទាក់ទងនឹងការប្រើប្រាស់បញ្ញាសិប្បនិម្មិត ហើយគោលការណ៍ទាំងនេះកំពុងបន្តវិវត្តទៅមុខ។ លោកគ្រូ អ្នកគ្រូខ្លះ អាចលើកទឹកចិត្តសិស្សឱ្យប្រើបញ្ញាសិប្បនិម្មិតសម្រាប់ការស្វែងរកគំនិត និងការស្រាវជ្រាវ ខណៈដែលគ្រូខ្លះទៀតអាចរឹតត្បិតការប្រើប្រាស់ចំពោះកិច្ចការមួយចំនួន។ ការខ្វះភាពស្មោះត្រង់ក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិត មិនត្រឹមតែជាការបំពានបទបញ្ជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យអ្នកបាត់បង់ឱកាសក្នុងការទទួលបានការកែលម្អពីគ្រូផងដែរ។ នៅពេលគ្រូដឹងពីរបៀបដែលអ្នកប្រើប្រាស់បញ្ញាសិប្បនិម្មិត ពួកគាត់នឹងអាចវាយតម្លៃកម្រិតយល់ដឹងរបស់អ្នកបានត្រឹមត្រូវ និងអាចផ្តល់ជំនួយបានចំគោលដៅ។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

អ្វីដែលមិនគួរធ្វើ

- កុំប្រើបញ្ញាសិប្បនិម្មិតសរសេរអត្ថបទទាំងមូលជំនួសអ្នក ដែលមិនបានគិតដោយខ្លួនឯង។
- កុំចម្លងចម្លើយពីបញ្ញាសិប្បនិម្មិតមកដាក់ភ្លាមៗ ដោយមិនបានយល់ឬមិនបានផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ។
- កុំបន្លំស្នាដៃដែលបង្កើតដោយបញ្ញាសិប្បនិម្មិតថាជាគំនិតច្នៃប្រឌិតផ្ទាល់ខ្លួនរបស់អ្នកទាំងស្រុង។
- កុំប្រើបញ្ញាសិប្បនិម្មិតធ្វើកិច្ចការសាលា ប្រសិនបើលោកគ្រូ អ្នកគ្រូបានហាមឃាត់។

អ្វីដែលគួរធ្វើ

- សួរបញ្ញាសិប្បនិម្មិតឱ្យពន្យល់ពីមេរៀន ឬប្រធានបទដែលអ្នកមិនយល់។
- ប្រើបញ្ញាសិប្បនិម្មិតដើម្បីស្វែងរកគំនិតថ្មីៗ និងទស្សនៈផ្សេងៗ។
- ប្រើបញ្ញាសិប្បនិម្មិតជួយរៀបចំគំនិតឱ្យមានលំដាប់លំដោយ និងមានរចនាសម្ព័ន្ធច្បាស់លាស់។
- សួរលោកគ្រូ អ្នកគ្រូថា តើការប្រើបញ្ញាសិប្បនិម្មិតកម្រិតណាដែលត្រូវបានអនុញ្ញាតសម្រាប់កិច្ចការនីមួយៗ។
- មានភាពស្មោះត្រង់ និងបង្ហាញឱ្យឃើញច្បាស់ពីចំណែកដែលបញ្ញាសិប្បនិម្មិតបានជួយក្នុងកិច្ចការរបស់អ្នក។

គ. ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មានពីបញ្ញាសិប្បនិម្មិត

ជំនាញដ៏សំខាន់ក្នុងយុគសម័យបញ្ញាសិប្បនិម្មិតគឺសមត្ថភាពបែងចែកព័ត៌មានពិត និងព័ត៌មានមិនពិត និងការត្រិះរិះពិចារណាលើមាតិកាដែលបង្កើតដោយបញ្ញាសិប្បនិម្មិត។ បញ្ញាសិប្បនិម្មិតអាចបង្កើតកំហុស ផ្តល់ព័ត៌មានហួសសម័យ ឬសូម្បីតែប្រឌិតព័ត៌មានមិនពិតទាំងស្រុងតែមើលទៅគួរឱ្យជឿជាក់។ ចំណុចនេះហើយដែលធ្វើឱ្យចំណេះដឹងប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន កាន់តែមានសារៈសំខាន់ជាងពេលណាៗទាំងអស់។



រូបភាព ២.១ ការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មានពីបញ្ញាសិប្បនិម្មិត

បញ្ញាសិប្បនិម្មិតត្រូវបានបណ្តុះបណ្តាលដោយទិន្នន័យពីអ៊ីនធឺណិត ដែលរួមមានទាំងព័ត៌មានត្រឹមត្រូវ និងមិនត្រឹមត្រូវ។ បញ្ញាសិប្បនិម្មិតអាចផ្តល់ព័ត៌មានខុសក្នុងទម្រង់ជឿជាក់បំផុត ដែលអាចធ្វើឱ្យមនុស្សមានការភាន់ច្រឡំ។ ឧទាហរណ៍៖ បញ្ញាសិប្បនិម្មិតអាចប្រឌិតចំណងជើងសៀវភៅ បង្កើតព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក្លែងក្លាយ ឬផ្តល់ព័ត៌មានវិទ្យាសាស្ត្រដែលមិនត្រឹមត្រូវ។

របៀបផ្ទៀងផ្ទាត់ព័ត៌មានពីបញ្ញាសិប្បនិម្មិត៖

- សួរបញ្ជាក់ខ្លួនឯងថា៖ តើព័ត៌មាននេះសមហេតុផលដែរឬទេ បើផ្អែកលើអ្វីដែលខ្ញុំបានដឹងកន្លងមក?
- ស្វែងរកព័ត៌មានដូចគ្នានេះ ពីប្រភពផ្សេងៗទៀតដែលគួរឱ្យទុកចិត្ត។
- យកចិត្តទុកដាក់លើទិន្នន័យស្ថិតិ កាលបរិច្ឆេទ និងការអះអាងជាក់លាក់ណាមួយ។
- ប្រសិនបើមានមន្ទិលសង្ស័យត្រូវហ៊ាននិយាយថា អ្នកមិនប្រាកដអំពីព័ត៌មាននោះជាជាងយកព័ត៌មានពីបញ្ញាសិប្បនិម្មិតមកផ្សព្វផ្សាយថាជាការពិត។

ឃ. ការការពារឯកជនភាពក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិត

នៅពេលយើងប្រើប្រាស់បញ្ញាសិប្បនិម្មិត យើងច្រើនតែចែករំលែកព័ត៌មានជាច្រើនដោយមិនដឹងខ្លួន។ ក្រុមហ៊ុនបញ្ញាសិប្បនិម្មិតអាចរក្សាទុកការសន្ទនារបស់អ្នក វិភាគសំណួររបស់អ្នកដើម្បីកែលម្អប្រព័ន្ធ និងក្នុងករណីខ្លះអាចចែករំលែកទិន្នន័យជាមួយភាគីទីបី។ ទោះបីជាក្រុមហ៊ុនបញ្ញាសិប្បនិម្មិតល្បីៗមានគោលការណ៍ការពារឯកជនភាពក៏ដោយ ក៏វាជារឿងប្រសើរដែលយើងត្រូវប្រុងប្រយ័ត្នចំពោះព័ត៌មានផ្ទាល់ខ្លួន។

កុំចែករំលែក៖

- ឈ្មោះពេញ និងអាសយដ្ឋានរស់នៅ
- លេខទូរសព្ទ ឬព័ត៌មានទំនាក់ទំនងរបស់គ្រួសារ
- លេខសម្ងាត់របស់សាលា ឬលេខអត្តសញ្ញាណសិស្ស
- ព័ត៌មានផ្ទាល់ខ្លួនរបស់គ្រួសារ ឬព័ត៌មានហិរញ្ញវត្ថុ
- រូបថតផ្ទាល់ខ្លួន ឬរូបថតសមាជិកគ្រួសារ
- ព័ត៌មានអំពីទីតាំងដែលអ្នករស់នៅ ឬសាលារៀនដែលអ្នករៀន

សូមចងចាំថានៅពេលអ្នកបញ្ចូលព័ត៌មានទៅក្នុងបញ្ញាសិប្បនិម្មិត វាមិនមែនជាព័ត៌មានឯកជនទៀតឡើយ ហើយវាអាចត្រូវបានរក្សាទុក ឬប្រើប្រាស់ដោយក្រុមហ៊ុនផ្តល់សេវាកម្មបញ្ញាសិប្បនិម្មិតនោះ។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

មេរៀនសង្ខេប

ក្នុងមេរៀននេះ យើងបានសិក្សានូវចំណុចសំខាន់ៗដូចខាងក្រោម៖

- បញ្ញាសិប្បនិម្មិត គឺជាអ្នកជំនួយមិនមែនជាអ្នកជំនួសការគិតរបស់អ្នកឡើយ។ បញ្ញាសិប្បនិម្មិតគួរតែជួយពង្រឹងការរៀនសូត្រ មិនមែនមកគិតជំនួសអ្នកឡើយ។
- ភាពស្មោះត្រង់ក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិត គឺជាកត្តាចាំបាច់សម្រាប់ការរៀនសូត្រ ប៉ុន្តែត្រូវសួរលោកគ្រូ អ្នកគ្រូអំពីអ្វីដែលត្រូវបានអនុញ្ញាត។ កុំឱ្យបញ្ញាសិប្បនិម្មិតសរសេរអត្ថបទទាំងមូល ឬបន្លំថាវាជាស្នាដៃផ្ទាល់ខ្លួន។
- ការផ្ទៀងផ្ទាត់ព័ត៌មានពីបញ្ញាសិប្បនិម្មិតជាការងារសំខាន់ ព្រោះបញ្ញាសិប្បនិម្មិតអាចបង្កកំហុស ឬប្រឌិតព័ត៌មានក្លែងក្លាយ។ ត្រូវសួរជានិច្ចថា តើវាសមហេតុផលដែរឬទេ? ផ្ទៀងផ្ទាត់ជាមួយប្រភពផ្សេងទៀត។
- ការការពារឯកជនភាពមានសារៈសំខាន់ណាស់ ក្រុមហ៊ុនបញ្ញាសិប្បនិម្មិតអាចរក្សាទុកការសន្ទនាដូចនេះកុំចែករំលែកឈ្មោះ អាសយដ្ឋាន លេខទូរសព្ទ លេខសម្ងាត់ ឬរូបថតទៅកាន់បញ្ញាសិប្បនិម្មិត។

មុនពេលប្រើប្រាស់បញ្ញាសិប្បនិម្មិត សូមចងចាំថា៖

- ត្រូវគិតពិចារណាយ៉ាងម៉ត់ចត់ចំពោះចម្លើយពីបញ្ញាសិប្បនិម្មិត ព្រោះពេលខ្លះវាអាចមិនត្រឹមត្រូវ
- ចែករំលែកតែព័ត៌មានដែលអ្នកអាចផ្ទៀងផ្ទាត់ពីប្រភពផ្សេងទៀត
- ត្រូវស្មោះត្រង់ចំពោះអ្វីដែលបញ្ញាសិប្បនិម្មិតបានជួយអ្នក
- អនុវត្តតាមបទបញ្ជាផ្ទៃក្នុងដែលទាក់ទងនឹងការប្រើប្រាស់ AI ក្នុងសាលារៀនរបស់អ្នក
- ត្រូវប្រុងប្រយ័ត្ន និងស្វែងយល់ពីហានិភ័យឯកជនភាពនៅពេលចែករំលែកព័ត៌មានជាមួយប្រព័ន្ធ AI។

សទ្ធានុក្រម

- **ការផ្ទៀងផ្ទាត់បញ្ញាសិប្បនិម្មិត៖** ក្នុងបរិបទនេះការផ្ទៀងផ្ទាត់ព័ត៌មានដែលបង្កើតដោយបញ្ញាសិប្បនិម្មិតជាមួយប្រភពដែលអាចទុកចិត្តបាន។
- **តម្លាភាព៖** ក្នុងបរិបទនេះ ត្រូវបង្ហាញភាពស្មោះត្រង់នៅពេលដែលបញ្ញាសិប្បនិម្មិត ត្រូវបានប្រើប្រាស់។

លំហាត់អនុវត្តន៍

១. បញ្ញាសិប្បនិម្មិតសម្រាប់ការរៀន និងការបង្រៀន៖ ការផ្លាស់ប្តូរបទពិសោធន៍ជាមួយអ្នកដទៃ

សូមធ្វើការជាដៃគូដោយសម្ភាសគ្នាទៅវិញទៅមក អំពីការប្រើប្រាស់បញ្ញាសិប្បនិម្មិតសម្រាប់ការរៀន និងការបង្រៀនដោយប្រើសំណួរដូចជា៖

- តើអ្នកប្រើឧបករណ៍បញ្ញាសិប្បនិម្មិតអ្វីខ្លះសម្រាប់ការរៀន?
- តើអ្នកប្រើបញ្ញាសិប្បនិម្មិតសម្រាប់កិច្ចការអ្វីខ្លះ?
- តើអ្នកធ្លាប់ប្រើប្រាស់បញ្ញាសិប្បនិម្មិតដែលអ្នកចាត់ទុកថាមានបញ្ហា ឬគ្មានសីលធម៌ដែរឬទេ?
- តើអ្នកចាត់ទុកថាការប្រើប្រាស់បញ្ញាសិប្បនិម្មិតមានសីលធម៌ និងអសីលធម៌យ៉ាងដូចម្តេច?

២. ការផ្ទៀងផ្ទាត់ដំណឹងដែលបង្កើតដោយបញ្ញាសិប្បនិម្មិត៖ អនុវត្តការត្រិះរិះពិចារណា

បញ្ញាសិប្បនិម្មិតបង្កើត អាចផ្តល់ចម្លើយដែលលម្អៀង មិនពិត ឬប្រឌិតឡើង។ អនុវត្តការត្រិះរិះពិចារណាតាមជំហានខាងក្រោម៖

- បង្កើត Prompt៖ សួរបញ្ញាសិប្បនិម្មិតរកព័ត៌មានណាមួយ (ឧទាហរណ៍៖ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក្នុងប្រទេសកម្ពុជា)។
- ចោទសួរលើលទ្ធផល៖ តើវាស្របនឹងអ្វីដែលអ្នកបានដឹងរួចមកហើយដែរឬទេ?
- ពិនិត្យប្រភពផ្សេងទៀត៖ សៀវភៅ វេបសាយផ្លូវការ ឬសារព័ត៌មាន។
- ពិនិត្យសេចក្តីលម្អិត៖ មើលកាលបរិច្ឆេទ ឈ្មោះ និងអង្គហេតុផ្សេងៗ។
- ការឆ្លុះបញ្ចាំង៖ ប្រសិនបើមិនប្រាកដ កុំយកវាទៅបង្ហាញថាជាការពិតឱ្យសោះ។
- ការប្រៀបធៀប៖ បញ្ចូល Prompt ទៅ បញ្ញាសិប្បនិម្មិតម្តងទៀត រួចប្រៀបធៀបលទ្ធផល។
- ការផ្ទៀងផ្ទាត់៖ ប្រើប្រាស់បញ្ញាសិប្បនិម្មិត ផ្សេងទៀត ដើម្បីចោទសួរ ឬត្រួតពិនិត្យចម្លើយនោះ។

ការឆ្លុះបញ្ចាំងចុងក្រោយ៖ តើអ្នកអាចគ្រប់គ្រងបញ្ញាសិប្បនិម្មិតយ៉ាងដូចម្តេច ដើម្បីធានាថាអ្នកទទួលបានព័ត៌មានត្រឹមត្រូវ និងមិនត្រូវបានគេបោកបញ្ឆោត?

៣. បញ្ញាសិប្បនិម្មិត និងការការពារឯកជនភាព៖ ការស្រាវជ្រាវ និងការឆ្លុះបញ្ចាំង

ការប្រើប្រាស់បញ្ញាសិប្បនិម្មិតអាចមានប្រយោជន៍ ប៉ុន្តែការចែករំលែកព័ត៌មានផ្ទាល់ខ្លួនអាចធ្វើឱ្យអ្នកជួបហានិភ័យ។

- ការស្រាវជ្រាវ៖ ហេតុអ្វីបានជាឯកជនភាពមានសារៈសំខាន់នៅពេលប្រើប្រាស់បញ្ញាសិប្បនិម្មិត? ស្វែងរកឧទាហរណ៍ ២-៣ នៃការបោកប្រាស់ ការលួចអត្តសញ្ញាណ ឬការបន្លំដែលពាក់ព័ន្ធនឹងបញ្ញាសិប្បនិម្មិត។
- ការឆ្លុះបញ្ចាំង៖ បង្កើតបញ្ជីនៃទិន្នន័យផ្ទាល់ខ្លួនដែលអ្នកមិនគួរចែករំលែកជាមួយបញ្ញាសិប្បនិម្មិតដាច់ខាត។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

៤. វិធីសាស្ត្រត្រឹមត្រូវក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិត៖ ការស្វែងយល់ ពិភាក្សា និងបង្កើតពាក្យស្លោក

ស្វែងរកនរណាម្នាក់ដើម្បីចែករំលែកបទពិសោធន៍អំពីវិធីសាស្ត្រក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិតសម្រាប់ការងារ កិច្ចការសាលា ឬការបង្កើតថ្មី។ បន្ទាប់មកសូមប្រើប្រាស់កម្មវិធីទូរសព្ទ SALA MIL ហើយចូលទៅកាន់ជំពូកទី២ មេរៀនទី២.៤៖ ក្រមសីលធម៌នៃការប្រើប្រាស់បញ្ញាសិប្បនិម្មិត ដើម្បីប្រៀបធៀបការពិភាក្សារបស់អ្នក ជាមួយនឹងឧទាហរណ៍ដែលមាននៅក្នុងកម្មវិធី។

- ធ្វើតេស្តសាកល្បង ដោយពិភាក្សាអំពីបញ្ហាចម្រូងចម្រាសនៃការប្រើប្រាស់បញ្ញាសិប្បនិម្មិតមុននឹងសម្រេចចិត្តជ្រើសរើសចម្លើយ។
- បញ្ចប់សកម្មភាពដោយការបង្កើតស្លោកមួយអំពី ការប្រើប្រាស់បញ្ញាសិប្បនិម្មិតដោយការទទួលខុសត្រូវ។ អ្នកអាចប្រើបញ្ញាសិប្បនិម្មិតដើម្បីជួយបំផុសគំនិតសម្រាប់ស្លោកនេះ។

សំណួរសម្រាប់ពិភាក្សា

១. តើពាក្យថាបញ្ញាសិប្បនិម្មិត គឺជាអ្នកជំនួយ មិនមែនជាអ្នកជំនួសមានន័យដូចម្តេច?
២. តើអ្នកអាចប្រើប្រាស់បញ្ញាសិប្បនិម្មិត ដោយការទទួលខុសត្រូវសម្រាប់កិច្ចការសាលាដោយរបៀបណា? សូមលើកឧទាហរណ៍។
៣. តើអ្វីខ្លះដែលអ្នកមិនគួរធ្វើ នៅពេលប្រើបញ្ញាសិប្បនិម្មិតសម្រាប់ធ្វើកិច្ចការដែលគ្រូដាក់ឱ្យ?
៤. ហេតុអ្វីបានជាការផ្ទៀងផ្ទាត់ព័ត៌មានដែលបង្កើតដោយបញ្ញាសិប្បនិម្មិត មានសារៈសំខាន់?
៥. តើអ្នកអាចផ្ទៀងផ្ទាត់ព័ត៌មានដែលបង្កើតដោយបញ្ញាសិប្បនិម្មិត តាមរបៀបណាខ្លះ?
៦. តើព័ត៌មានផ្ទាល់ខ្លួនប្រភេទណាខ្លះដែលអ្នកមិនត្រូវចែករំលែកជាមួយបញ្ញាសិប្បនិម្មិត?

មេរៀនទី ៣ ហានិភ័យ និងក្រមសីលធម៌បញ្ញាសិប្បនិម្មិត



មេរៀនទី២.២ និង២.៣



ជំពូកទី៦

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

ក. ភាពលម្អៀងនៃបញ្ញាសិប្បនិម្មិត

ខ. បញ្ហានានាដែលអាចបង្កឡើងដោយបញ្ញាសិប្បនិម្មិត

គ. ការប្រើប្រាស់បញ្ញាសិប្បនិម្មិតប្រកបដោយសីលធម៌

ហេតុអ្វីបានជាមេរៀននេះសំខាន់?

មេរៀននេះជួយអ្នកសិក្សាឱ្យចេះការពារខ្លួន និងប្រុងប្រយ័ត្នចំពោះកំហុសឆ្គងភាពលម្អៀង ឬផលប៉ះពាល់អវិជ្ជមាននានា ដែលអាចកើតចេញពីបញ្ញាសិប្បនិម្មិត។ មេរៀននេះក៏ជួយតម្រង់ទិសអ្នកសិក្សាឱ្យចេះប្រើប្រាស់បញ្ញាសិប្បនិម្មិត ប្រកបដោយសុវត្ថិភាព និងទំនួលខុសត្រូវខ្ពស់។

ក. ភាពលម្អៀងនៃបញ្ញាសិប្បនិម្មិត

បញ្ញាសិប្បនិម្មិតអាចមានភាពលម្អៀង ឬមិនយុត្តិធម៌ ព្រោះវាអាចបានរៀនពីព័ត៌មានមិនល្អពីមនុស្ស និងជួនកាលវាបង្ហាញចេញមកគំនិតអវិជ្ជមាននូវការយល់ឃើញ ឬផ្នត់គំនិតបែបអគតិ ដែលបង្កគ្រោះថ្នាក់។ នេះជាបញ្ហាមួយ ព្រោះបច្ចុប្បន្នបញ្ញាសិប្បនិម្មិតត្រូវបានគេយកមកប្រើដើម្បីធ្វើការសម្រេចចិត្តសំខាន់ៗលើការជ្រើសរើសបុគ្គលិក ការសិក្សា និងប្រភេទព័ត៌មានដែលមនុស្សមើលឃើញ។



រូបភាព ៣.១ ភាពលម្អៀងនៃបញ្ញាសិប្បនិម្មិត

បញ្ញាសិប្បនិម្មិតភាគច្រើនត្រូវបានបង្កើតឡើងនៅក្នុងប្រទេសបស្ចិមលោក ដូច្នេះវាអាចនឹងមិនបានឆ្លុះបញ្ចាំងឱ្យបានត្រឹមត្រូវនូវទស្សនៈ វប្បធម៌ ឬបរិបទរបស់ប្រទេសកម្ពុជានោះទេ។

ការយល់ដឹងអំពីភាពអយុត្តិធម៌ ឬលម្អៀងនៃបញ្ញាសិប្បនិម្មិតជួយឱ្យសិស្សានុសិស្សមានការត្រិះរិះពិចារណាកាន់តែខ្លាំងលើព័ត៌មានដែលវាបង្កើតឡើង និងដឹងថាតើព័ត៌មាននោះហួសសម័យ ឬឆ្លុះបញ្ចាំងពីផ្នត់គំនិតបែបអគតិ។ ឧទាហរណ៍៖ បញ្ញាសិប្បនិម្មិតអាចបង្ហាញរូបភាពវេជ្ជបណ្ឌិតជាបុរស ឯគិលានុបដ្ឋាកជាស្ត្រី ទោះបីជាការពិតទាំងបុរសនិងស្ត្រី សុទ្ធតែអាចធ្វើជាវេជ្ជបណ្ឌិតឬគិលានុបដ្ឋាកក៏ដោយ។ ករណីនេះកើតឡើងដោយសារទិន្នន័យដែលប្រើសម្រាប់បង្រៀនបញ្ញាសិប្បនិម្មិតឆ្លុះបញ្ចាំងពីទស្សនៈចាស់គំរិលជាជាងការពិតនាពេលបច្ចុប្បន្ន។

អ្វីដែលអ្នកអាចធ្វើបាន៖

- កត់សម្គាល់នៅពេលដែលបញ្ញាសិប្បនិម្មិតបង្ហាញភាពអយុត្តិធម៌ ឬមិនបានឆ្លុះបញ្ចាំងពីភាពចម្រុះឱ្យបានត្រឹមត្រូវ។
- ត្រិះរិះពិចារណាលើការផ្តល់យោបល់របស់បញ្ញាសិប្បនិម្មិតនិងពិនិត្យ ថាតើវាសមស្របនឹងបរិបទវប្បធម៌របស់អ្នកដែរឬទេ។
- ចងចាំថាបញ្ញាសិប្បនិម្មិតឆ្លុះបញ្ចាំងពីការយល់ឃើញលម្អៀងរបស់មនុស្សដែលបានបង្កើតវា និងទិន្នន័យដែលវាបានរៀន។
- ចៀសវាងការប្រើប្រាស់ចម្លើយពីបញ្ញាសិប្បនិម្មិត ណាដែលពង្រឹងការយល់ឃើញបែបអគតិលើបញ្ហាយេនឌ័រ រើសអើងជាតិសាសន៍ ឬស្រទាប់វណ្ណៈក្នុងសង្គម។

ខ. បញ្ហានានាដែលអាចបង្កឡើងដោយបញ្ញាសិប្បនិម្មិត

នៅពេលដែលបញ្ញាសិប្បនិម្មិតត្រូវបានគេប្រើប្រាស់កាន់តែទូលំទូលាយ មនុស្សត្រូវយល់ដឹងពីផលវិបាកអវិជ្ជមាននានា ដែលបច្ចេកវិទ្យានេះអាចបង្កឡើង។ ការដឹងពីហានិភ័យទាំងនេះមិនមែនមានន័យថាត្រូវបោះបង់បញ្ញាសិប្បនិម្មិតទាំងស្រុងនោះទេ ប៉ុន្តែត្រូវប្រើប្រាស់ដោយការត្រិះរិះពិចារណា។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ហានិភ័យចម្បងដែលបង្កដោយបញ្ញាសិប្បនិម្មិត៖

មាតិកាក្លែងក្លាយ៖ បញ្ញាសិប្បនិម្មិតអាចបង្កើតមាតិកាដែលមើលទៅហាក់ដូចជាការពិតបំផុត។ វាអាចបង្កើតរូបថតក្លែងក្លាយដែលស្ទើរតែមិនអាចបែងចែកដាច់ពីរូបថតពិតបង្កើតវីដេអូបន្លំសំឡេង និងសកម្មភាពមនុស្ស (Deepfake) និងសរសេរអត្ថបទព័ត៌មានអំពីព្រឹត្តិការណ៍ដែលមិនដែលបានកើតឡើង។ ចំណុចនេះធ្វើឱ្យយើងពិបាកក្នុងការបែងចែករវាងព័ត៌មានពិត និងក្លែងក្លាយដែលមាតិកាទាំងនេះភាគច្រើនលេចឡើងនៅលើបណ្តាញសង្គម។ សម្រាប់សិស្សានុសិស្ស ចាំបាច់ត្រូវអភិវឌ្ឍជំនាញត្រិះរិះពិចារណា និងចេះផ្ទៀងផ្ទាត់ព័ត៌មានតាមរយៈប្រភពគួរឱ្យទុកចិត្តជាច្រើន។ ទន្ទឹមនឹងនេះ យើងត្រូវប្រុងប្រយ័ត្នមុននឹងចែករំលែកនូវមាតិកាដែលទាក់ទាញចំណាប់អារម្មណ៍ឬរំជើបរំជួលណាមួយដោយមិនបានបញ្ជាក់ពីភាពត្រឹមត្រូវជាមុន។

ការផ្លាស់ប្តូរទីផ្សារការងារ៖ បញ្ញាសិប្បនិម្មិតនឹងជះឥទ្ធិពលយ៉ាងខ្លាំងដល់ទីផ្សារការងារ ដោយវាអាចនឹងជំនួសការងារបែបប្រពៃណីមួយចំនួន ប៉ុន្តែក៏បង្កើតការងារថ្មីៗផងដែរ។ ការងារដែលប្រឈមនឹងហានិភ័យខ្ពស់ គឺជាការងារដែលទាក់ទងនឹងកិច្ចការដដែលៗ ឬការដំណើរការទិន្នន័យ។ ទោះជាយ៉ាងណា បញ្ញាសិប្បនិម្មិតក៏នឹងបង្កើតឱកាសថ្មីៗផងដែរ ដូច្នេះការយល់ដឹង និងការចេះប្រើប្រាស់បញ្ញាសិប្បនិម្មិតមុនពេលឈានជើងចូលទីផ្សារការងារ គឺជាគំនិតដ៏ល្អដែលធ្វើឱ្យនិយោជកចាប់អារម្មណ៍លើអ្នក។

ការពឹងផ្អែកលើបញ្ញាសិប្បនិម្មិតខ្លាំងពេក៖ ហានិភ័យមួយទៀតដែលមនុស្សពឹងផ្អែកលើបញ្ញាសិប្បនិម្មិតខ្លាំងពេកអាចហួតដល់ឈប់អភិវឌ្ឍសមត្ថភាពគិត និងដោះស្រាយបញ្ហាដោយខ្លួនឯង។ នេះគឺជាកង្វល់ជាក់ស្តែងក្នុងបរិបទសាលារៀន ដែលគោលដៅចម្បងគឺបណ្តុះបណ្តាលឱ្យសិស្សចេះគិតដោយឯករាជ្យ។

បញ្ហាឯកជនភាព៖ នៅពេលដែលបញ្ញាសិប្បនិម្មិតកាន់តែទំនើប វានឹងប្រមូល វិភាគព័ត៌មានលម្អិតអំពីអ្នកប្រើប្រាស់។ ក្រុមហ៊ុនទានាប្រើប្រាស់ព័ត៌មានទាំងនេះដើម្បីកែលម្អប្រព័ន្ធរបស់ខ្លួន ប៉ុន្តែក៏អាចប្រើសម្រាប់ការផ្សព្វផ្សាយពាណិជ្ជកម្ម ឬគោលដៅអាជីវកម្មផ្សេងទៀត។

គ. ការប្រើប្រាស់បញ្ញាសិប្បនិម្មិតប្រកបដោយសីលធម៌

អ្នកដែលយល់ដឹងពីសីលធម៌នៃបញ្ញាសិប្បនិម្មិត អាចនឹងត្រៀមខ្លួនបានល្អក្នុងការរួមចំណែកជាវិជ្ជមានដល់ការផ្លាស់ប្តូរក្នុងយុគសម័យឌីជីថល។ ការប្រើប្រាស់បញ្ញាសិប្បនិម្មិតប្រកបដោយសីលធម៌តម្រូវឱ្យមានការពិចារណា និងការពិភាក្សាជាបន្តបន្ទាប់។ ខាងក្រោមនេះគឺជាគោលការណ៍ណែនាំខ្លះៗ៖

- **មានភាពស្មោះត្រង់៖** ត្រូវប្រាប់ឱ្យគេដឹងនៅពេលដែលយើងប្រើបញ្ញាសិប្បនិម្មិតដើម្បីជួយក្នុងកិច្ចការរបស់យើង ជាពិសេសក្នុងស្ថានភាពសិក្សា ឬការងារ។
- **មានការប្រុងប្រយ័ត្ន៖** កុំប្រើបញ្ញាសិប្បនិម្មិតដើម្បីធ្វើបាប ឬបោកប្រាស់អ្នកដទៃរួមទាំងការបង្កើតមាតិកាក្លែងក្លាយ ឬប្រើបញ្ញាសិប្បនិម្មិតដើម្បីផ្សព្វផ្សាយព័ត៌មានមិនពិត។
- **មានភាពឆ្លាតវៃ៖** ត្រូវត្រិះរិះពិចារណាជានិច្ចថា តើព័ត៌មានពីបញ្ញាសិប្បនិម្មិតត្រឹមត្រូវដែរឬទេ ហើយត្រូវស្វែងរកការបញ្ជាក់ពីប្រភពដែលគួរឱ្យទុកចិត្ត។
- **មានការគោរព៖** កុំប្រើបញ្ញាសិប្បនិម្មិតដើម្បីចម្លងស្នាដៃអ្នកដទៃ ឬបង្កើតមាតិកាដែលអាចបង្កគ្រោះថ្នាក់ដល់បុគ្គល ឬសហគមន៍។
- **មានការទទួលខុសត្រូវ៖** ត្រូវពិចារណាពីផលប៉ះពាល់នៃការប្រើប្រាស់បញ្ញាសិប្បនិម្មិតរបស់អ្នកមកលើការសិក្សា ការជ្រាស្រ័យទាក់ទង និងសហគមន៍របស់អ្នក។

មេរៀនសង្ខេប

ក្នុងមេរៀននេះ យើងបានសិក្សានូវចំណុចសំខាន់ៗដូចខាងក្រោម៖

- បញ្ញាសិប្បនិម្មិតអាចមានភាពអយុត្តិធម៌៖ ព្រោះវាបានរៀនពីព័ត៌មានដែលមានទស្សនៈមិនត្រឹមត្រូវ។ ឧទាហរណ៍៖ បើយើងឱ្យបញ្ញាសិប្បនិម្មិតបង្កើតរូបភាព នោះវានឹងប្រើការសន្មតថា បុរសគឺជាវេជ្ជបណ្ឌិត ឯស្ត្រីគឺជាគិលានុបដ្ឋាយិកាជាដើម។
- បញ្ហាដែលបញ្ញាសិប្បនិម្មិតបង្កឡើង៖ រួមមានការបង្កើតមាតិកាក្លែងក្លាយ (រូបភាព វីដេអូ ព័ត៌មាន) ការបាត់បង់ការងារមួយចំនួន ការធ្វើឱ្យមនុស្សពឹងផ្អែកខ្លាំងពេកដែលនាំឱ្យបាត់បង់ការត្រិះរិះពិចារណា និងការប្រមូលព័ត៌មានផ្ទាល់ខ្លួន។
- សីលធម៌នៃការប្រើប្រាស់បញ្ញាសិប្បនិម្មិត៖ ត្រូវមានភាពស្មោះត្រង់ កុំប្រើវាដើម្បីធ្វើបាបអ្នកដទៃ ឬផ្សព្វផ្សាយព័ត៌មានមិនពិត និងត្រូវចេះត្រិះរិះពិចារណាជានិច្ច។

មុននឹងប្រើប្រាស់បញ្ញាសិប្បនិម្មិត ប្រកបដោយក្រមសីលធម៌ សូមចងចាំនូវចំណុចទាំងនេះ៖

- ស្វែងយល់និងប្រុងប្រយ័ត្ន៖ អំពីរបៀបដែលប្រព័ន្ធបញ្ញាសិប្បនិម្មិត អាចបង្ហាញនូវភាពលម្អៀង ឬបង្កឱ្យមានផលប៉ះពាល់អវិជ្ជមាន។
- ចែករំលែកតែព័ត៌មានដែលត្រឹមត្រូវ៖ ចែករំលែកតែព័ត៌មានដែលទទួលបានពីបញ្ញាសិប្បនិម្មិតណាដែលអ្នកអាចផ្ទៀងផ្ទាត់បានថាត្រឹមត្រូវ តាមរយៈប្រភពដែលគួរឱ្យទុកចិត្ត។
- គោរពបទដ្ឋានសីលធម៌៖ អនុវត្តតាមបទដ្ឋានសីលធម៌ដែលការពារសិទ្ធិបុគ្គល និងសហគមន៍។

សព្ទានុក្រម

- **ភាពលម្អៀងរបស់បញ្ញាសិប្បនិម្មិត៖** ការវិនិច្ឆ័យមិនត្រឹមត្រូវយុត្តិធម៌ មានទំនោរទៅម្ខាង ឬផ្តត់គំនិតលម្អៀងដែលត្រូវបានបង្កើតឡើងនៅក្នុងបញ្ញាសិប្បនិម្មិត។
- **Deepfake៖** រូបភាព វីដេអូ ឬសំឡេងក្លែងក្លាយដែលបង្កើតឡើងដោយបញ្ញាសិប្បនិម្មិត ។
- **ការប្រើប្រាស់ប្រកបដោយសីលធម៌៖** ទង្វើដោយស្មោះត្រង់ និងទទួលខុសត្រូវ ដើម្បីចៀសវាងគ្រោះថ្នាក់ដល់ខ្លួនឯង និងអ្នកដទៃ។
- **ការពឹងផ្អែកលើបច្ចេកវិទ្យា៖** ការពឹងផ្អែកខ្លាំងពេកលើបច្ចេកវិទ្យា ដែលអាចធ្វើឱ្យជំនាញផ្សេងទៀតចុះខ្សោយ (ឧទាហរណ៍៖ ការគិតបែបត្រិះរិះ)។

លំហាត់អនុវត្តន៍

១. ការស៊ើបអង្កេតអំពីភាពលម្អៀងរបស់បញ្ញាសិប្បនិម្មិត៖

សូមប្រើប្រាស់បញ្ញាសិប្បនិម្មិតដែលអ្នកស្គាល់ ដើម្បីបង្កើតជាអត្ថបទ ឬរូបភាព។ ចូរបង្កើត Prompt អំពីប្រធានបទណាមួយ ដើម្បីពិនិត្យរកមើលភាពលម្អៀង (ឧទាហរណ៍៖ អំពីអាហារដែលពេញនិយមបំផុត បញ្ហាសង្គម ការដាក់បញ្ចូលក្រុមជនជាតិភាគតិច ការផ្លាស់ប្តូរតួនាទីរបស់បុរស និងស្ត្រី ក្តីស្រមៃរបស់យុវជន Gen Z ឬការងារដែលពេញនិយម)។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

សូមប្រើប្រាស់ Prompt ដដែលនោះ ជាមួយបញ្ញាសិប្បនិម្មិតផ្សេងៗគ្នា រួចប្រៀបធៀបលទ្ធផល៖

- តើអ្នកកត់សម្គាល់ឃើញអ្វីខ្លះ?
- តើចម្លើយទាំងនោះមានភាពត្រឹមត្រូវសម្រាប់សង្គមកម្ពុជាដែរឬទេ?
- តើលទ្ធផលទាំងនោះមានផ្នត់គំនិតអគតិដែរឬទេ?

ចូរប្រមូលរាល់ភាពលម្អៀងដែលអ្នកបានរកឃើញហើយពិចារណា ថាតើនរណាខ្លះដែលអាចមានអារម្មណ៍ថាត្រូវបានគេបង្ហាញរូបភាពមិនត្រឹមត្រូវ ឬត្រូវបានដកចេញ?

២. ការប្រើប្រាស់បញ្ញាសិប្បនិម្មិតដើម្បីស្វែងយល់ពីហានិភ័យ៖ ការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន

សូមប្រើប្រាស់បញ្ញាសិប្បនិម្មិតបង្កើត (ដូចជា ChatGPT ឬ Gemini) ដើម្បីបង្កើត Prompt និងរៀនសូត្រអំពីហានិភ័យនៃបញ្ញាសិប្បនិម្មិតដូចខាងក្រោម៖

- ភាពលម្អៀងរបស់បញ្ញាសិប្បនិម្មិត៖ ការផ្តល់ព័ត៌មានដែលលម្អៀងទៅរកក្រុមណាមួយ។
- ខ្លឹមសារក្លែងក្លាយ៖ ការបង្កើតព័ត៌មាន ឬ Deepfake។
- ការផ្លាស់ប្តូរទីផ្សារការងារ៖ ការបាត់បង់ការងារដោយសារការជំនួសដោយស្វ័យប្រវត្តិកម្ម។
- ការពឹងផ្អែកជ្រុល៖ ការបាត់បង់សមត្ថភាពត្រិះរិះពិចារណាដោយខ្លួនឯង។
- បញ្ហាឯកជនភាព៖ ការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនដោយគ្មានការអនុញ្ញាត។

- សូមពិចារណា តើហានិភ័យមួយណាដែលអាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់អ្នក សហគមន៍របស់អ្នក និងប្រទេសកម្ពុជា?
- ចំពោះហានិភ័យដែលមានផលប៉ះពាល់ធ្ងន់ធ្ងរ សូមសួរបញ្ញាសិប្បនិម្មិតពីរបៀបកាត់បន្ថយគ្រោះថ្នាក់។

៣. បញ្ញាសិប្បនិម្មិតជាមិត្ត ឬជាសត្រូវ៖ ការស្វែងយល់ ការឆ្លុះបញ្ចាំង និងការដោះស្រាយលំហាត់

សូមប្រើប្រាស់កម្មវិធីទូរសព្ទ SALA MIL ហើយចូលទៅកាន់ជំពូកទី២ មេរៀនទី២.២៖ អត្ថប្រយោជន៍ និងហានិភ័យនៃបញ្ញាសិប្បនិម្មិត។ សូមអានអំពីរបៀបដែលបញ្ញាសិប្បនិម្មិតអាចជួយ និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស។ បន្ទាប់មក សូមឆ្លុះបញ្ចាំងពីការប្រើប្រាស់បញ្ញាសិប្បនិម្មិតផ្ទាល់ខ្លួនរបស់អ្នក ដោយសរសេរចំណុចដូចខាងក្រោម៖

- ឧទាហរណ៍ចំនួន៣ ដែលបញ្ញាសិប្បនិម្មិតបានជួយអ្នក ដូចជាមិត្តភក្តិ
- ឧទាហរណ៍ចំនួន៣ ដែលបញ្ញាសិប្បនិម្មិតបានបង្កផលវិបាក ឬបញ្ហាដល់អ្នក ដូចជាសត្រូវ។

នៅពេលអ្នកសរសេររួចរាល់ សូមដោះស្រាយលំហាត់ ដើម្បីស្វែងយល់ពីស្ថានភាពផ្សេងៗបន្ថែមទៀត។ សម្រាប់ស្ថានភាពនីមួយៗ សូមសម្រេចចិត្តថា តើបញ្ញាសិប្បនិម្មិតកំពុងដើរតួជាមិត្ត ឬជាសត្រូវ។

៤. តើមាតិកានេះបង្កើតដោយមនុស្ស ឬម៉ាស៊ីន?

សូមប្រើប្រាស់កម្មវិធីទូរសព្ទ SALA MIL ហើយចូលទៅកាន់ជំពូកទី២ មេរៀនទី២.៣៖ បញ្ញាសិប្បនិម្មិត និងព័ត៌មានមិនពិត។ ចូររៀនពីរបៀបសម្គាល់ថាតើអត្ថបទ ចំណងជើងព័ត៌មាន រូបភាព ឬវីដេអូត្រូវបានបង្កើតឡើងដោយមនុស្ស ឬដោយបញ្ញាសិប្បនិម្មិត។ សូមអានខ្លឹមសារដោយយកចិត្តទុកដាក់ដើម្បីត្រៀមខ្លួនក្នុងការបែងចែកភាពខុសគ្នា។ នៅពេលអ្នកមានអារម្មណ៍ថាត្រៀមខ្លួនរួចរាល់ហើយ សូមឆ្លើយសំណួរដើម្បីសាកល្បងសមត្ថភាពរបស់អ្នក។ តើអ្នកទទួលបានពិន្ទុប៉ុន្មាន?

ប្រសិនបើអ្នកមានទំនុកចិត្ត សូមចូលទៅកាន់បណ្ដាញសង្គមរបស់អ្នក រួចអូសពិនិត្យមើលការបង្ហោះនានា ហើយកំណត់រកឱ្យឃើញនូវ អត្ថបទ រូបភាព ឬវីដេអូមួយ ដែលអ្នកគិតថាច្បាស់ជាត្រូវបានបង្កើតឡើងដោយបញ្ញាសិប្បនិម្មិត។

សំណួរសំរាប់ពិភាក្សា

១. ការលើកឡើងថាបញ្ញាសិប្បនិម្មិតមានភាពអយុត្តិធម៌ ឬលម្អៀង តើមានន័យដូចម្តេច? សូមលើកឧទាហរណ៍មកបញ្ជាក់។

២. ហេតុអ្វីបានជាការត្រិះរិះពិចារណាលើព័ត៌មាន ដែលបង្កើតដោយបញ្ញាសិប្បនិម្មិត មានសារៈសំខាន់?

៣. ចូរប្រាប់ពីបញ្ហាចំនួនពីរដែលបញ្ញាសិប្បនិម្មិតអាចបង្កឡើង និងពន្យល់ពីមូលហេតុដែលជាក្តីកង្វល់។

៤. តើគោលការណ៍សីលធម៌សម្រាប់ការប្រើប្រាស់បញ្ញាសិប្បនិម្មិតក្នុងសាលារៀន ឬជីវិតប្រចាំថ្ងៃមានអ្វីខ្លះ?

៥. តើលោកអ្នកអាចផ្សៀងផ្ទាត់ដោយរបៀបណាថា ព័ត៌មានពីបញ្ញាសិប្បនិម្មិតត្រឹមត្រូវ និងមិនបង្កគ្រោះថ្នាក់ ឬនាំឱ្យមានការយល់ច្រឡំ?

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

មេរៀនទី ៤

ការប្រើប្រាស់បញ្ញាសិប្បនិម្មិត ក្នុងការបង្កើតមាតិកា

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីៈ

ក. ការបង្កើតអត្ថបទដោយប្រើបញ្ញាសិប្បនិម្មិត

ខ. ការបង្កើតរូបភាពដោយប្រើបញ្ញាសិប្បនិម្មិត

គ. ការបង្កើតវីដេអូ និងសំឡេងដោយប្រើបញ្ញាសិប្បនិម្មិត

ឃ. គោលការណ៍ណែនាំសម្រាប់ការបង្កើតមាតិកាដោយប្រើបញ្ញាសិប្បនិម្មិត

ហេតុអ្វីបានជាមេរៀននេះសំខាន់?

សិស្សត្រូវយល់ពីរបៀបដែលបញ្ញាសិប្បនិម្មិតបង្កើតអត្ថបទ រូបភាព និងវីដេអូដើម្បីឱ្យពួកគេអាចផលិតមាតិកាប្រកបដោយការទទួលខុសត្រូវ។ មេរៀននេះបង្រៀនពីច្បាប់ដើម្បីបង្ការគ្រោះថ្នាក់ ការប្រើប្រាស់ខុស ឬភាពមិនស្មោះត្រង់។

ក. ការបង្កើតអត្ថបទដោយប្រើបញ្ញាសិប្បនិម្មិត

ការបង្កើតអត្ថបទគឺជាកម្មវិធីប្រើប្រាស់មួយក្នុងចំណោមកម្មវិធី ដែលមានប្រយោជន៍បំផុតនៃបញ្ញាសិប្បនិម្មិតសម្រាប់សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ។ ឧបករណ៍ទាំងនេះអាចជួយជម្នះឧបសគ្គផ្នែកភាសា ផ្តល់ជំនួយដល់ការសរសេរ និងជួយលោកអ្នកក្នុងការរៀបចំរចនាសម្ព័ន្ធនៃកិច្ចការសរសេរផ្សេងៗ។

ដើម្បីធ្វើកិច្ចការនេះឱ្យបានល្អគឺត្រូវការជំនាញសរសេរ Prompt។ មានន័យថាអ្នកត្រូវចេះពីរបៀបបញ្ចូលការណែនាំឱ្យបានត្រឹមត្រូវទៅកាន់បញ្ញាសិប្បនិម្មិតដើម្បីទទួលបានចម្លើយដែលមានគុណភាពល្អ។ ជំនាញនេះកំពុងក្លាយជាជំនាញ ដែលមានតម្រូវការខ្ពស់នាពេលបច្ចុប្បន្ន។ ប៉ុន្តែសូមចងចាំថាការប្រើប្រាស់បញ្ញាសិប្បនិម្មិតគឺដើម្បីពង្រឹងសមត្ថភាព មិនមែនដើម្បីជំនួសការអភិវឌ្ឍខ្លួនឯងលើការគិតនិងការសរសេរនោះឡើយ។

កម្មវិធីបង្កើតអត្ថបទដោយបញ្ញាសិប្បនិម្មិតដូចជា ChatGPT អាចឆ្លើយសំណួរ និងផ្តល់ការពន្យល់ដោយផ្អែកលើតម្រូវការ និងកម្រិតយល់ដឹងរបស់អ្នកសិក្សា។ កម្មវិធីទាំងនេះអាចជួយអ្នកក្នុងការបំផុសគំនិត ស្វែងយល់ពីគោលគំនិតពិបាកៗ និងកែលម្អការសរសេររបស់អ្នក។ ប៉ុន្តែឧបករណ៍ទាំងនេះអាចផ្តល់លទ្ធផលបានល្អ លុះត្រាតែអ្នកបញ្ចូលនូវចំណេះដឹង ការច្នៃប្រឌិត និងការត្រិះរិះពិចារណាផ្ទាល់ខ្លួនទៅក្នុងដំណើរការនោះដែរ។

របៀបប្រើប្រាស់អត្ថបទបញ្ញាសិប្បនិម្មិតឱ្យមានប្រសិទ្ធភាព៖

- ផ្តល់ការណែនាំឱ្យបានច្បាស់លាស់ និងជាក់លាក់អំពីអ្វីដែលអ្នកចង់ឱ្យបញ្ញាសិប្បនិម្មិតជួយ។
- សួរសំណួរបន្ត ប្រសិនបើអ្នកមិនយល់ចំណុចណាមួយ ឬចង់បានព័ត៌មានលម្អិតបន្ថែម។
- ត្រូវកែសម្រួល និងអភិវឌ្ឍមាតិកាដែលបញ្ញាសិប្បនិម្មិតបង្កើតឡើង ជាជាងការយកមកប្រើទាំងស្រុង។
- ផ្ទៀងផ្ទាត់រាល់ទិន្នន័យពិត និងព័ត៌មានដែលបញ្ញាសិប្បនិម្មិតបង្កើត ជាមួយប្រភពដែលគួរឱ្យទុកចិត្តជានិច្ច។
- ប្រើប្រាស់លទ្ធផលពីបញ្ញាសិប្បនិម្មិតជាចំណុចចាប់ផ្តើមសម្រាប់គំនិតខ្លួនឯង មិនមែនជាចម្លើយចុងក្រោយឡើយ។

ឧទាហរណ៍នៃការសរសេរ Prompts៖

- សូមពន្យល់អំពីដំណើរការស្មើសំយោគ តាមបែបសាមញ្ញដែលសិស្សវិទ្យាល័យអាចយល់បាន។
- សូមជួយខ្ញុំរកគំនិតសម្រាប់ធ្វើគម្រោងអំពីសិល្បករកម្ពុជា ដែលបញ្ចូលទម្រង់សិល្បៈសម័យជាមួយតន្ត្រី និងរបាំបុរាណ។
- តើមានវិធីល្អៗអ្វីខ្លះក្នុងការរៀបចំរចនាសម្ព័ន្ធអត្ថបទស្តីពីការការពារបរិស្ថានក្នុងប្រទេសកម្ពុជា?

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ខ. ការបង្កើតរូបភាពដោយប្រើបញ្ញាសិប្បនិម្មិត



រូបភាព ៤.១ ការប្រើប្រាស់បញ្ញាសិប្បនិម្មិត

បញ្ញាសិប្បនិម្មិតបង្កើតរូបភាពអាចជួយឱ្យយើងមើលឃើញនូវរូបភាពនៃគោលគំនិតនានា ការបង្កើតបទបង្ហាញ និងស្វែងយល់ពីការបញ្ចេញមតិផ្នែកសិល្បៈ។

ដើម្បីប្រើបញ្ញាសិប្បនិម្មិត បង្កើតរូបភាពឱ្យមានប្រសិទ្ធភាព យើងចាំបាច់ត្រូវរៀនពីរបៀបពណ៌នាអំពីគោលគំនិតដែលចង់បានឱ្យបានច្បាស់លាស់ និងយល់អំពីសមត្ថភាពក៏ដូចជាកម្រិតកំណត់នៃប្រព័ន្ធទាំងនេះ។ បញ្ញាសិប្បនិម្មិតអាចបង្កើតរូបភាពដែលគួរឱ្យភ្ញាក់ផ្អើល ប៉ុន្តែវាមិនមែនសុទ្ធតែផ្តល់ព័ត៌មានលម្អិតបានត្រឹមត្រូវ ឬបង្កើតបានតាមអ្វីដែលលោកអ្នកមានក្នុងចិត្តជានិច្ចនោះទេ។

ការសាកល្បង និងការកែសម្រួលច្រើនដង គឺជាការងារចាំបាច់។

DALL-E និងឧបករណ៍ស្រដៀងគ្នា៖ ឧបករណ៍ទាំងនេះអនុញ្ញាតឱ្យយើងដែលមិនមានជំនាញសិល្បៈអាចបង្ហាញពីគំនិតច្នៃប្រឌិតរបស់ខ្លួនតាមរយៈរូបភាព។ ឧទាហរណ៍៖ យើងអាចសុំឱ្យបញ្ញាសិប្បនិម្មិតបង្កើត «រូបភាពប្រាសាទអង្គរវត្តពេលព្រះអាទិត្យរះ ដោយមានសិស្សានុសិស្សកំពុងរៀននៅខាងមុខ» ឬ «រូបភាពតុក្កតាដំរីស្លៀកសម្លៀកបំពាក់ប្រពៃណីខ្មែរ កំពុងបង្រៀនមេរៀនគណិតវិទ្យា»។

ការប្រើប្រាស់បញ្ញាសិប្បនិម្មិតបង្កើតរូបភាពតាមរបៀបត្រឹមត្រូវ៖

- ការបង្កើតរូបភាពលម្អិត៖ សម្រាប់បទបង្ហាញនៅសាលាអំពីប្រវត្តិសាស្ត្រ ឬវប្បធម៌ខ្មែរ។
- ការបង្កើតជំនួយស្មារតីជារូបភាព៖ សម្រាប់គម្រោងវិទ្យាសាស្ត្រ ឬមេរៀនគណិតវិទ្យា។
- ការរចនាផ្ទាំងរូបភាព៖ សម្រាប់ព្រឹត្តិការណ៍សាលា ឬគម្រោងសហគមន៍ផ្សេងៗ។
- ការស្រមៃមើលគំនិតសម្រាប់គម្រោងសិល្បៈ៖ ដើម្បីសាកល្បងមើលគំនិតជាមុន មុននឹងចាប់ផ្តើមគូរដោយដៃផ្ទាល់។
- ការបង្កើតសម្ភារៈហ្វឹកហាត់៖ សម្រាប់ការរៀនពិពណ៌នារូបភាពជាភាសាអង់គ្លេស។
- ការបង្កើរូបភាពគំរូ៖ សម្រាប់កិច្ចពិភាក្សាអំពីប្រព័ន្ធផ្សព្វផ្សាយរូបភាព និងការតំណាងឱ្យអ្វីមួយ

សូមចងចាំថា៖ ជួនកាលបញ្ញាសិប្បនិម្មិត អាចបង្កើតរូបភាពដែលចម្លែក ឬមិនត្រឹមត្រូវ ដូច្នេះអ្នកត្រូវត្រៀមខ្លួនក្នុងការសាកល្បងប្រើពាក្យពិពណ៌នាផ្សេងៗ ប្រសិនបើអ្នកមិនទាន់ទទួលបានរូបភាពដែលអ្នកចង់បាន។

គ. ការបង្កើតវីដេអូ និងសំឡេងដោយប្រើបញ្ញាសិប្បនិម្មិត

បញ្ញាសិប្បនិម្មិតសម្រាប់បង្កើតវីដេអូ និងសំឡេង កំពុងមានភាពងាយស្រួលក្នុងការប្រើប្រាស់ និងមានឥទ្ធិពលកាន់តែខ្លាំងឡើង។ ឧបករណ៍ទាំងនេះ អនុញ្ញាតឱ្យមនុស្សអាចបង្កើតវីដេអូដែលមើលទៅមានលក្ខណៈវិជ្ជាជីវៈ និងមានគុណភាពសំឡេងល្អ។

ឧបករណ៍ទាំងនេះអាចបង្កើតបាននូវ៖

- វីដេអូខ្លីៗសម្រាប់បទបង្ហាញ ដែលបញ្ចូលទាំងអត្ថបទ រូបភាព និងការអត្ថាធិប្បាយ។
- ការថតសំឡេងជាភាសាផ្សេងៗ ដែលជួយដល់ការរៀនភាសា។
- Background music សម្រាប់គម្រោងផ្សេងៗឱ្យសមស្របតាមបរិបទ។
- មាតិកាសំឡេងបែបផតខាស់ សម្រាប់ចែករំលែកព័ត៌មាន ឬរឿងរ៉ាវនានា។
- Subtitles ការបកប្រែសម្រាប់មាតិការីដេអូ។

ឃ. គោលការណ៍ណែនាំសម្រាប់ការបង្កើតមាតិកាដោយប្រើបញ្ញាសិប្បនិម្មិត

ការរៀបចំគោលការណ៍ក្រមសីលធម៌សម្រាប់ការបង្កើតមាតិកាដោយបញ្ញាសិប្បនិម្មិត គឺជារឿងចាំបាច់បំផុត ស្របពេលដែលឧបករណ៍ទាំងនេះកាន់តែមានសមត្ថភាពខ្ពស់ និងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ។ ជាការពិតណាស់ គោលការណ៍ទាំងនេះមិនមែនគ្រាន់តែសម្រាប់ការអនុវត្តតាមវិន័យប៉ុណ្ណោះទេ ប៉ុន្តែវាជាការបណ្តុះនូវទម្លាប់ល្អៗដែលអាចផ្តល់ប្រយោជន៍នាពេលអនាគត នៅពេលដែលឧបករណ៍៖ បញ្ញាសិប្បនិម្មិតក្លាយជាផ្នែកដ៏សំខាន់នៅក្នុងវិស័យអប់រំ និងការងារប្រចាំថ្ងៃ។ ដូច្នេះហើយគោលដៅចម្បងនៃគោលការណ៍នេះ គឺការជំរុញឱ្យមានការប្រើប្រាស់បញ្ញាសិប្បនិម្មិតក្នុងរបៀបមួយដែលជួយពង្រឹងការរៀនសូត្ររបស់អ្នក ផ្តល់ការគោរពដល់អ្នកដទៃ និងចូលរួមចំណែកជាវិជ្ជមានដល់សហគមន៍ និងសង្គមជាតិ។

ការគោរពអ្នកដទៃ៖ ការបង្កើតមាតិកាដោយប្រើបញ្ញាសិប្បនិម្មិតត្រូវភ្ជាប់មកជាមួយនូវការទទួលខុសត្រូវចំពោះអ្នកដទៃ និងសហគមន៍។ វាមានសារៈសំខាន់ណាស់ក្នុងការគិតគូរថាតើខ្លឹមសារដែលបង្កើតដោយបញ្ញាសិប្បនិម្មិតរបស់អ្នក អាចជះឥទ្ធិពលដល់អ្នកដទៃយ៉ាងដូចម្តេចខ្លះ ហើយត្រូវចៀសវាងការប្រើប្រាស់ឧបករណ៍ដ៏មានឥទ្ធិពលទាំងនេះក្នុងផ្លូវដែលបង្កគ្រោះថ្នាក់ ឬផលប៉ះពាល់អវិជ្ជមាន។

- កុំបង្កើតរូបភាពក្លែងក្លាយរបស់មនុស្សពិត ដោយគ្មានការអនុញ្ញាតពីសាមីខ្លួន។
- កុំបង្កើតមាតិកាដែលអាចប៉ះពាល់ដល់កិត្តិយស ឬអារម្មណ៍របស់អ្នកដទៃ។
- ត្រូវបញ្ជាក់ពីប្រភព នៅពេលអ្នកប្រើបញ្ញាសិប្បនិម្មិតជួយបង្កើតអ្វីមួយ ជាពិសេសសម្រាប់កិច្ចការសាលា។
- ត្រូវមានភាពហ្មត់ចត់លើការបង្ហាញពីរឬធម៌ និងចៀសវាងការប្រើរូបភាពបែបអគតិ។

ការបង្កើតស្នាដៃដោយខ្លួនឯង៖ បញ្ញាសិប្បនិម្មិតគួរតែជួយពង្រឹងការច្នៃប្រឌិតរបស់យើងមិនមែនមកជំនួសវាឡើយ។ វិធីសាស្ត្រដែលមានប្រសិទ្ធភាព និងប្រកបដោយសីលធម៌បំផុត គឺការប្រើប្រាស់បញ្ញាសិប្បនិម្មិតជា ដៃគូសហការ ក្នុងដំណើរការបង្កើតថ្មី ខណៈដែលគំនិត ទស្សនៈ និងការយល់ដឹងផ្ទាល់ខ្លួនរបស់យើងនៅតែជាស្នូលនៃស្នាដៃនោះ។

- ប្រើប្រាស់បញ្ញាសិប្បនិម្មិតជាចំណុចចាប់ផ្តើម មិនមែនជាចម្លើយចុងក្រោយសម្រាប់កិច្ចការច្នៃប្រឌិត។
- បញ្ចូលគំនិត ចំណេះដឹងរឬធម៌ និងការច្នៃប្រឌិតផ្ទាល់ខ្លួនទៅក្នុងមាតិកាដែលបញ្ញាសិប្បនិម្មិតបង្កើត។
- ធានាថា ស្នាដៃរបស់អ្នកនៅតែឆ្លុះបញ្ចាំងពីគំនិត និងការរៀនសូត្រផ្ទាល់ខ្លួនរបស់អ្នក។
- ការរួមបញ្ចូលគ្នារវាងជំនួយពីបញ្ញាសិប្បនិម្មិតជាមួយការស្រាវជ្រាវបែបប្រពៃណី និងវិធីសាស្ត្រ

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

- **សួរសំណួរទៅកាន់គ្រូ៖** មុននឹងប្រើប្រាស់បញ្ញាសិប្បនិម្មិត សម្រាប់កិច្ចការសាលា ហើយត្រូវបញ្ជាក់ឱ្យច្បាស់ថា តើអ្វីខ្លះដែលត្រូវបានអនុញ្ញាត និងអ្វីខ្លះដែលមិនត្រូវបានអនុញ្ញាត។
- **មានភាពស្មោះត្រង់៖** អំពីកម្រិតដែលបញ្ញាសិប្បនិម្មិតបានជួយអ្នក និងការផ្តល់ជំនួយជាក់លាក់ណាមួយដែលអ្នកបានប្រើប្រាស់។
- **អនុវត្តតាមគោលការណ៍បច្ចេកវិទ្យា៖** ជាគោលការណ៍ណែនាំនៃការប្រើប្រាស់អ៊ីនធឺណិតរបស់សាលារបស់អ្នក។

តើខ្ញុំអាចប្រើប្រាស់ឧបករណ៍បញ្ញាសិប្បនិម្មិតអ្វីខ្លះបាន?

ឧបករណ៍បញ្ញាសិប្បនិម្មិតថ្មីៗត្រូវបានដាក់ឱ្យប្រើប្រាស់ជាបន្តបន្ទាប់ ហើយបញ្ជីឈ្មោះឧបករណ៍ទាំងនោះនឹងឆាប់ហួសសម័យ។ ដើម្បីស្វែងរកឧបករណ៍បញ្ញាសិប្បនិម្មិត ដែលមាន និងគោលបំណងនៃការប្រើប្រាស់របស់វា សូមវាយពាក្យថា “list of AI tools” ទៅក្នុងប្រព័ន្ធស្វែងរក។ អ្នកនឹងឃើញជម្រើសជាច្រើន។

មេរៀនសង្ខេប

ក្នុងមេរៀននេះ យើងបានសិក្សានូវចំណុចសំខាន់ៗដូចខាងក្រោម៖

- **ការបង្កើតអត្ថបទដោយប្រើបញ្ញាសិប្បនិម្មិត៖** ជួយជម្លះឧបសគ្គផ្នែកភាសា និងរៀបចំរចនាសម្ព័ន្ធសំណេរ។ ការធ្វើជាអ្នកជំនាញសរសេរ Prompt មានន័យថាត្រូវចេះផ្តល់ការណែនាំឱ្យបានច្បាស់លាស់។ ប្រើប្រាស់បញ្ញាសិប្បនិម្មិត ដូចជា ChatGPT ដើម្បីស្វែងរកគំនិតថ្មីៗ ប៉ុន្តែត្រូវកែសម្រួលលទ្ធផលដែលទទួលបាន និងត្រួតពិនិត្យជាប្រចាំ។
- **ការបង្កើតរូបភាពដោយប្រើបញ្ញាសិប្បនិម្មិត៖** ជួយបង្ហាញរូបភាពនៃគោលគំនិតសម្រាប់គម្រោងសាលា។ ទោះជាយ៉ាងណាបញ្ញាសិប្បនិម្មិត ជួនកាលបង្កើតលទ្ធផលចម្លែកៗ ដូច្នេះត្រូវសាកល្បងប្រើការពណ៌នាផ្សេងៗគ្នា។
- **ការបង្កើតវីដេអូ និងសំឡេងដោយប្រើបញ្ញាសិប្បនិម្មិត៖** អនុញ្ញាតឱ្យបង្កើតវីដេអូបទបង្ហាញ ការថតសំឡេងជាច្រើនភាសា តន្ត្រី និងអត្ថបទរត់លើអេក្រង់។
- **វិធានការសម្រាប់ការបង្កើតមាតិកា៖** ផ្តោតលើការគោរពអ្នកដទៃ និងការបង្កើតស្នាដៃដើម។ កុំបង្កើតរូបភាពក្លែងក្លាយរបស់បុគ្គលណាម្នាក់ ឬប្រើប្រាស់ផ្នត់គំនិតអគតិវាយតម្លៃជារួមនោះឡើយ។ សូមប្រើប្រាស់បញ្ញាសិប្បនិម្មិត ត្រឹមតែជាចំណុចចាប់ផ្តើមប៉ុណ្ណោះ ដោយត្រូវបញ្ចូលគំនិតផ្ទាល់ខ្លួនបន្ថែម និងត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាលាជានិច្ច។

មុននឹងបង្កើតខ្លឹមសារដោយប្រើប្រាស់បញ្ញាសិប្បនិម្មិតសូមចងចាំនូវចំណុចទាំងនេះ៖

- ចែករំលែកតែមាតិកាណា ដែលអ្នកបានផ្ទៀងផ្ទាត់ និងកែលម្អរួចរាល់ប៉ុណ្ណោះ។
- មានភាពស្មោះត្រង់ក្នុងការប្រើប្រាស់បញ្ញាសិប្បនិម្មិតចូលរួមចំណែកក្នុងការបង្កើតស្នាដៃរបស់អ្នក។
- ត្រូវអនុវត្តតាមស្តង់ដាក្រមសីលធម៌ ដែលផ្តល់ការគោរពដល់អ្នកដទៃ និងចៀសវាងមាតិកាដែលបង្កផលប៉ះពាល់អវិជ្ជមាន។
- ត្រូវឈ្វេងយល់ឱ្យបានច្បាស់ពីគោលការណ៍របស់សាលារៀន ជុំវិញការប្រើប្រាស់បញ្ញាសិប្បនិម្មិតសម្រាប់ធ្វើកិច្ចការ។

សទ្ទានុក្រម

- **មាតិកាដែលបង្កើតដោយបញ្ញាសិប្បនិម្មិត៖** អត្ថបទ រូបភាព ឬវីដេអូដែលបង្កើតឡើងដោយបញ្ញាសិប្បនិម្មិត។
- **Prompt៖** សំណួរ ឬការណែនាំដែលផ្តល់ទៅឱ្យឧបករណ៍បញ្ញាសិប្បនិម្មិត។
- **អ្នកជំនាញសរសេរ Prompt៖** អ្នករចនាការណែនាំច្បាស់លាស់សម្រាប់បញ្ញាសិប្បនិម្មិតដើម្បីឱ្យវាផ្តល់ចម្លើយត្រឹមត្រូវ និងមានប្រយោជន៍ ដែលអ្នកប្រើប្រាស់ចង់បាន។

លំហាត់អនុវត្តន៍

១. ការប្រើប្រាស់ Prompt ប្រកបដោយប្រសិទ្ធភាព៖ Prompt កាន់តែល្អ ចម្លើយកាន់តែប្រសើរ

សូមប្រើប្រាស់កម្មវិធីបញ្ញាសិប្បនិម្មិតណាមួយ រួចជ្រើសរើសប្រធានបទដែលអ្នកចង់ស្វែងយល់៖

- សាកល្បងសរសេរ Prompt៖ សួរបញ្ញាសិប្បនិម្មិតដោយប្រើ Prompt ងាយៗ ឧទាហរណ៍៖ «ពន្យល់ពី...»។
- កែលម្អ Prompt៖ បន្ថែមព័ត៌មានលម្អិត ដូចជា កំណត់អ្នកអាន ប្រវែងអត្ថបទ ឬទម្រង់លម្អិត ឧទាហរណ៍៖ «ពន្យល់ពី... ឱ្យក្មេងអាយុ ១៥ឆ្នាំ ស្តាប់ក្នុងភាសាងាយយល់»។
- ប្រៀបធៀបចម្លើយ៖ តើចម្លើយមួយណាមានប្រយោជន៍ជាង? ហេតុអ្វី?
- ការឆ្លុះបញ្ចាំង៖ តើអ្វីដែលធ្វើឱ្យ Prompt មួយមានគុណភាពល្អ? ហេតុអ្វីបានជាយើងនៅតែត្រូវផ្ទៀងផ្ទាត់ចម្លើយរបស់បញ្ញាសិប្បនិម្មិត?

សូមសួរបញ្ញាសិប្បនិម្មិតឱ្យប្រាប់ពីគន្លឹះដើម្បីសរសេរ Prompt ឱ្យមានប្រសិទ្ធភាព។ តើវាផ្តល់គន្លឹះបន្ថែមអ្វីខ្លះដល់អ្នក? ចូរសាកល្បងអនុវត្តតាម។

២. ការប្រៀបធៀបរវាងបញ្ញាសិប្បនិម្មិតផ្សេងៗគ្នា

ឧបមាថាអ្នកត្រូវធ្វើបទបង្ហាញលើប្រធានបទអ្វីមួយ ហើយចង់ប្រើបញ្ញាសិប្បនិម្មិតដើម្បីរកគំនិតរៀបចំរចនាសម្ព័ន្ធមេរៀន។ សួរសំណួរដូចគ្នាទៅកាន់បញ្ញាសិប្បនិម្មិតពីរឬច្រើន។ ប្រៀបធៀបចម្លើយ៖

- តើអ្វីទៅដែលស្រដៀងគ្នា?
- តើមានអ្វីខុសគ្នា?
- តើចម្លើយមួយណាដែលច្បាស់ជាង ឬមានប្រយោជន៍ជាង?
- តើបញ្ញាសិប្បនិម្មិតណាមួយបានផ្តល់ព័ត៌មានមិនច្បាស់លាស់ ឬគួរឱ្យសង្ស័យដែរឬទេ?
- តើអ្នកចូលចិត្តបញ្ញាសិប្បនិម្មិត មួយណាហើយហេតុអ្វី?

ឆ្លុះបញ្ចាំង៖ តើលំហាត់នេះប្រាប់អ្នកអ្វីខ្លះអំពីការបង្កើតខ្លឹមសារដោយមានការទទួលខុសត្រូវដោយប្រើប្រាស់បញ្ញាសិប្បនិម្មិត?

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

៣. ការអនុវត្តបង្កើតខ្លឹមសារដោយបញ្ញាសិប្បនិមិ្ត៖ ប្រើបញ្ញាសិប្បនិមិ្តសម្រាប់បង្កើតមាតិកាអប់រំ

ជ្រើសរើសហានិភ័យនៃបញ្ញាសិប្បនិមិ្តណាមួយមកធ្វើជាចំណុចដៅ រួចប្រើបញ្ញាសិប្បនិមិ្ត ដើម្បីបង្កើតខ្លឹមសារអប់រំអ្នកដទៃអំពីបញ្ហានោះ៖

- សម្រាប់អត្ថបទ៖ ប្រើ Prompt ឱ្យមានប្រសិទ្ធភាព ដើម្បីទទួលបាន «ពាក្យស្លោក» ដែលខ្លីខ្លឹម និងទាក់ទាញ រួមជាមួយអត្ថបទអប់រំ ២-៣ប្រយោគ អំពីរបៀបដោះស្រាយហានិភ័យនោះដោយ ការទទួលខុសត្រូវ។
- សម្រាប់រូបភាព៖ ប្រើឧបករណ៍បង្កើតរូបភាពដោយបញ្ញាសិប្បនិមិ្តដើម្បីបង្កើតរូបភាព ១-២សន្លឹក ដែលឆ្លុះបញ្ចាំងពីគោលបំណងនៃការអប់រំរបស់អ្នក។
- ត្រួតពិនិត្យការងារ៖ តើខ្លឹមសារនោះច្បាស់លាស់ត្រឹមត្រូវ និងមានការទទួលខុសត្រូវដែរឬទេ? តើ វាមានបង្កផលប៉ះពាល់ដល់នរណាម្នាក់ដែរឬទេ? តើរូបភាពដែលបង្កើតមក ស្របគ្នានឹងសារអប់រំ របស់អ្នកដែរឬទេ?

សំណួរសំរាប់ពិភាក្សា

១. ហេតុអ្វីបានជាការផ្តល់ការណែនាំ Prompt ឱ្យបានច្បាស់លាស់ និងជាក់លាក់ មាន សារៈសំខាន់នៅពេលប្រើប្រាស់បញ្ញាសិប្បនិមិ្តដូចជា ChatGPT?

២. តើការប្រើប្រាស់រូបភាពដែលបង្កើតដោយបញ្ញាសិប្បនិមិ្ត ក្នុងកិច្ចការសាលា មានផល ប្រយោជន៍អ្វីខ្លះ ហើយតើសិស្សគួរប្រុងប្រយ័ត្នលើចំណុចខ្វះខាតអ្វីខ្លះ?

៣. តើបញ្ញាសិប្បនិមិ្តបង្កើតវីដេអូ និងសំឡេង អាចជួយដល់ការសិក្សាដោយរបៀបណា? សូមផ្តល់ឧទាហរណ៍បញ្ជាក់។

៤. តើគោលការណ៍សីលធម៌អ្វីខ្លះដែលលោកអ្នកគួរអនុវត្តតាម នៅពេលបង្កើតមាតិកាដោយប្រើ បញ្ញាសិប្បនិមិ្ត ជាពិសេសពាក់ព័ន្ធនឹងស្នាដៃដើម ការគោរពអ្នកដទៃ និងបទបញ្ជារបស់ សាលារៀន?

ជំពូកទី៤

ឯកជនភាព
និងសន្តិសុខអនឡាញ

មេរៀនទី១៖ ដានជើងឌីជីថល និងឯកជនភាពលើអនឡាញ
មេរៀនទី២៖ ការគំរាមកំហែងតាមអនឡាញ
មេរៀនទី៣៖ ការបង្កើនសុវត្ថិភាពគណនី
មេរៀនទី៤៖ ការបង្កទុក្ខបុកម្នេញតាមអនឡាញ និងសម្ដីស្អប់ខ្ពើម
មេរៀនទី៥៖ ជនងាយរងគ្រោះ និងសុវត្ថិភាពលើអនឡាញ

មេរៀនទី ១ ដានជើងឌីជីថល និង ឯកជនភាពលើអនឡាញ



មេរៀនទី៤.១



ជំពូកទី៥

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

ក. តើដានជើងឌីជីថលជាអ្វី?

ខ. ការគ្រប់គ្រងដានជើងឌីជីថលរបស់អ្នក

គ. ការពារឯកជនភាពឌីជីថលរបស់អ្នក

ហេតុអ្វីបានជាមេរៀននេះសំខាន់?

រាល់សកម្មភាពដែលបុគ្គលម្នាក់ធ្វើនៅលើអ៊ីនធឺណិត សុទ្ធតែបន្សល់ទុកនូវដានជើងឌីជីថល។ ការយល់ដឹងច្បាស់អំពីដាននេះគឺជាគន្លឹះដ៏សំខាន់ក្នុងការការពារឯកជនភាពបានយូរអង្វែង។ ការគ្រប់គ្រងដានជើងឌីជីថលឱ្យបានល្អ នឹងជួយការពារទិន្នន័យផ្ទាល់ខ្លួនមិនឱ្យរងការកេងប្រវ័ញ្ច ឬយកទៅប្រើប្រាស់ក្នុងគោលដៅមិនល្អណាមួយ។

ក. តើដានជើងឌីជីថលជាអ្វី?

ដានជើងឌីជីថលសំដៅលើដាននៃទិន្នន័យ ឬព័ត៌មាន ដែលអ្នកប្រើប្រាស់បន្សល់ទុកនៅពេលប្រើប្រាស់អ៊ីនធឺណិត។ មិនដូចដានជើងនៅលើខ្សាច់ដែលអាចរលុបបាត់ទៅវិញនោះទេ ដានជើងឌីជីថលរបស់អ្នកអាចស្ថិតនៅជារៀងរហូត។ ការស្វែងយល់និងការគ្រប់គ្រងដានជើងឌីជីថល មានសារៈសំខាន់ណាស់ក្នុងការរក្សាសុវត្ថិភាព នៅពេលប្រើប្រាស់អ៊ីនធឺណិត។



រូបភាព ១.១ ដាន់ជើងឌីជីថល

ព័ត៌មានទាំងឡាយណាដែលទាក់ទងនឹងរូបអ្នកនៅលើអ៊ីនធឺណិត ដូចជាវេបសាយដែលអ្នកបានចូលមើល រូបភាព ដែលអ្នកបានចែករំលែកនៅលើបណ្តាញសង្គម ជាអត្តសញ្ញាណរបស់អ្នកនៅលើអនឡាញ ឬហៅម្យ៉ាងទៀតថាដានជើងឌីជីថល។

ដានជើងឌីជីថលមានពីរប្រភេទ៖

ដានជើងឌីជីថលសកម្ម៖ ព័ត៌មានដែលអ្នកចែករំលែកដោយចេតនានៅលើអ៊ីនធឺណិតមានដូចជា៖

- ការបង្ហោះ និងរូបភាពនៅលើបណ្តាញផ្សព្វផ្សាយសង្គម
- ការបញ្ចេញមតិលើវីដេអូ ឬអត្ថបទនានា
- សារ និងមាតិកាវាយតម្លៃ
- ការដាក់ពាក្យស្នើសុំតាមអនឡាញ

ដានជើងឌីជីថលអកម្ម៖ ព័ត៌មានដែលគេប្រមូលយក ដោយអ្នកមិនដឹង មានដូចជា៖

- ការតាមដានសកម្មភាពរបស់អ្នកនៅលើវេបសាយ
- ទិន្នន័យអំពីទីតាំងតាមរយៈកម្មវិធី
- កំណត់ត្រានៃការស្វែករកព័ត៌មាននៅលើម៉ាស៊ីនស្វែងរកផ្សេងៗ
- ទិន្នន័យនៃការប្រើប្រាស់កម្មវិធីផ្សេងៗ

ហេតុអ្វីបានជាដានជើងឌីជីថលរបស់អ្នកសំខាន់?

ការសិក្សាអប់រំនិងការងារ៖ សាកលវិទ្យាល័យ និងនិយោជកអាចនឹងពិនិត្យមើលប្រវត្តិនៃសកម្មភាពរបស់អ្នកដាក់ពាក្យនៅលើបណ្តាញផ្សព្វផ្សាយសង្គម។ ដានជើងឌីជីថលដែលមានលក្ខណៈវិជ្ជមាន នឹងជំរុញឱកាសរបស់អ្នកក្នុងការទទួលបានការសិក្សា ឬការងារនោះ ចំណែកឯការមានមាតិកាមិនសមរម្យអាចនឹងបំផ្លាញឱកាសទាំងនោះទៅវិញ។

សុវត្ថិភាពផ្ទាល់ខ្លួន៖ ព័ត៌មានដែលអ្នកចែករំលែក អាចត្រូវបានប្រើប្រាស់ដោយជនដែលមានបំណងអាក្រក់ដើម្បីដឹងពីទម្លាប់ប្រចាំថ្ងៃឬព័ត៌មានលម្អិតផ្ទាល់ខ្លួន ដែលធ្វើឱ្យពួកគេងាយស្រួលក្នុងការបោកប្រាស់ ឬបង្កគ្រោះថ្នាក់ដល់អ្នក។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ផលប៉ះពាល់នៅថ្ងៃអនាគត៖ អ៊ីនធឺណិតចងចាំបានយូរណាស់។ អ្វីដែលអ្នកបង្ហោះនៅពេលជាយុវវ័យ អាចនឹងនៅតែមាននៅលើអ៊ីនធឺណិតជារៀងរហូត។ អ្នកប្រាកដជាមិនចង់ឱ្យមាតិកាមិនល្អ ឬគួរឱ្យខ្មាសអៀនលេចចេញមកវិញនៅពេលក្រោយនោះទេ។

ហានិភ័យឌីជីថលសំខាន់ៗសម្រាប់សិស្ស

- ការចែករំលែកព័ត៌មានច្រើនពេក៖ ដូចជាព័ត៌មានផ្ទាល់ខ្លួន រូបភាពគួរឱ្យខ្មាសអៀន ឬមតិយោបល់មិនសមរម្យ។
- ការតាមដានទីតាំង៖ កម្មវិធីដែលដឹងពីទម្លាប់ប្រចាំថ្ងៃ និងទីតាំងរបស់អ្នក។
- ការធ្វើទុក្ខបុកម្នេញតាមអ៊ីនធឺណិត៖ អ្នកក្លាយជាគោលដៅនៃការយាយី ឬគំរាមកំហែងតាមអនឡាញ។
- ការលួចអត្តសញ្ញាណ៖ ឧក្រិដ្ឋជនប្រើប្រាស់ព័ត៌មានលម្អិតផ្ទាល់ខ្លួនរបស់អ្នក ដើម្បីលួចប្រាក់ឬបោកប្រាស់អ្នកដទៃ។

ខ. ការគ្រប់គ្រងដានជើងឌីជីថលរបស់អ្នក

ដានជើងឌីជីថលរបស់អ្នកអាចបន្សល់នៅរហូតប៉ុន្តែអ្នកនៅតែអាចគ្រប់គ្រងវាបានដែរ។ អ្នកគួរតែពិនិត្យមើលដានជើងឌីជីថលរបស់អ្នក និងគ្រប់គ្រងវាយ៉ាងហោចណាស់ឱ្យបានជាប្រចាំ។ ជំហានខាងក្រោមនេះ នឹងជួយឱ្យអ្នកបានដឹងថា តើមានព័ត៌មានអ្វីខ្លះអំពីអ្នកនៅលើអ៊ីនធឺណិតជួយដោះស្រាយបញ្ហានានា ព្រមទាំងជួយអ្នកឱ្យធ្វើការសម្រេចចិត្តបានកាន់តែត្រឹមត្រូវមុននឹងចែករំលែកព័ត៌មានអ្វីមួយនាពេលអនាគត។

ពិនិត្យមើលថាតើមានព័ត៌មានអ្វីខ្លះអំពីអ្នកនៅលើអ៊ីនធឺណិត

- ស្វែងរកឈ្មោះរបស់អ្នកនៅលើ Google ដោយសរសេរឈ្មោះនៅក្នុងចន្លោះសញ្ញា (“ ”) ហើយសង្កេតមើលថាតើមានអ្វីបង្ហាញចេញមក។
- ពិនិត្យមើលកន្លែងរករូបភាពដើម្បីរកមើលរូបថតរបស់អ្នក
- បង្កើត Google Alerts សម្រាប់ឈ្មោះរបស់អ្នក ដើម្បីតាមដានមាតិកាថ្មីៗ

ពិនិត្យមើលការកំណត់ឯកជនភាពរបស់អ្នកនៅលើបណ្តាញសង្គម៖

- កំណត់គណនីទៅជាឯកជនបើអាចធ្វើទៅបាន
- ជ្រើសរើសអ្នកណាខ្លះដែលអាចឃើញការបង្ហោះរបស់អ្នក (សម្រាប់តែមិត្តភក្តិ មិនមែនសាធារណៈ)
- គ្រប់គ្រងសំណើសុំធ្វើមិត្ត ឬសំណើសុំតាម
- បិទការចែករំលែកទីតាំង
- ពិនិត្យមើលមាតិកាដែលមានគេ Tag ឈ្មោះរបស់អ្នកមុនពេលវាបង្ហាញចេញ

គិតសិនមុននឹងបង្ហោះ ដោយសួរខ្លួនឯងថា៖

- តើនឹងមានអ្វីកើតឡើងប្រសិនបើឪពុកម្តាយ ឬគ្រូរបស់ខ្ញុំឃើញ?
- តើវាអាចប៉ះពាល់ដល់នរណាម្នាក់ ឬធ្វើឱ្យខ្ញុំអាម៉ាស់មុខនៅថ្ងៃក្រោយទេ?
- តើខ្ញុំកំពុងតែចែករំលែកព័ត៌មានផ្ទាល់ខ្លួនច្រើនពេកទេដឹង?

ព័ត៌មានដែលអ្នកមិនត្រូវចែករំលែកទាល់តែសោះ៖

- លេខអត្តសញ្ញាណ ឬឯកសារផ្ទាល់ខ្លួន
- ទីតាំងរូបវន្តជាក់លាក់ ឬទម្លាប់ប្រចាំថ្ងៃរបស់អ្នក
- ព័ត៌មានធនាគារ ឬលេខសម្ងាត់
- ព័ត៌មានឯកជនរបស់គ្រួសារ

គ. ការពារឯកជនភាពឌីជីថលរបស់អ្នក

ឯកជនភាពមានន័យថាជាការមានសិទ្ធិគ្រប់គ្រងលើព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក និងការសម្រេចចិត្តថាអ្នកណាអាចដឹងរឿងរ៉ាវអ្វីខ្លះអំពីជីវិតរបស់អ្នក។ នៅក្នុងពិភពឌីជីថល សកម្មភាពអនឡាញរបស់អ្នកបង្កើតបានជារូបភាពលម្អិតថាអ្នកជានរណា រាប់បញ្ចូលទាំងចំណាប់អារម្មណ៍ ទំនាក់ទំនង ទម្លាប់ប្រចាំថ្ងៃ និងគំនិតរបស់អ្នក។ ព័ត៌មាននេះអាចប៉ះពាល់ដល់រឿងជាច្រើន ដូចជាការសិក្សា ការងារ និងកេរ្តិ៍ឈ្មោះរបស់អ្នកក្នុងក្រសែភ្នែកមនុស្សជុំវិញខ្លួន។



រូបភាព ១.២ ការពារឯកជនភាពឌីជីថល

បណ្តាញសង្គមបានកែប្រែវិធីយោបល់ និងការយល់ឃើញរបស់មនុស្សចំពោះការចែករំលែកព័ត៌មានផ្ទាល់ខ្លួន។ មនុស្សជាច្រើនចែករំលែករឿងរ៉ាវលម្អិតផ្ទាល់ខ្លួននៅលើអ៊ីនធឺណិត ដូចជាទីតាំង បញ្ហាទំនាក់ទំនង ជម្លោះក្នុងគ្រួសារ និងការលំបាកផ្ទាល់ខ្លួនរបស់ពួកគេ។ ពួកគេចែករំលែករឿងរ៉ាវដែលពួកគេនឹងមិនប្រាប់មនុស្សចម្លែកឡើយប្រសិនបើជួបមុខផ្ទាល់។ ទោះបីជាការធ្វើបែបនេះអាចជួយឱ្យយើងមានអារម្មណ៍ថាមានទំនាក់ទំនងនឹងគ្នាក៏ដោយ ប៉ុន្តែវាក៏ធ្វើឱ្យកាន់តែពិបាកក្នុងការរក្សាឯកជនភាពផងដែរ។

បញ្ហាប្រឈមគឺថាការការពារឯកជនភាពរបស់អ្នក ទាមទារឱ្យមានការយកចិត្តទុកដាក់ជានិច្ច។ គ្រប់វេបសាយ កម្មវិធីទូរសព្ទត្រូវបានបង្កើតឡើងដើម្បីប្រមូលព័ត៌មានអំពីអ្នកឱ្យបានច្រើនបំផុត តាមដែលអាចធ្វើទៅបាន។ ទោះបីជាអ្នកគិតថាអ្នកកំពុងរក្សាឯកជនភាពក៏ដោយ ក៏ទិន្នន័យរបស់អ្នកកំពុងត្រូវបានប្រមូល រក្សាទុក និងជាញឹកញាប់ ត្រូវបានលក់ទៅឱ្យក្រុមហ៊ុនផ្សេងទៀត។

ក្រុមហ៊ុននានាប្រមូលព័ត៌មានរបស់អ្នកដើម្បីផ្សាយពាណិជ្ជកម្ម។ សកម្មភាពអនឡាញរបស់អ្នកត្រូវបានគេតាមដានហើយយកទៅប្រើប្រាស់បង្កើតជាទិន្នន័យ អំពីចំណាប់អារម្មណ៍ និងអាកប្បកិរិយារបស់អ្នក ដែលអនុញ្ញាតឱ្យអ្នកផ្សាយពាណិជ្ជកម្មអាចកំណត់គោលដៅសម្រាប់បង្ហាញផលិតផលដែលពួកគេគិតថាអ្នកនឹងចូលចិត្ត។ ប៉ុន្តែវាក៏មានន័យថាពួកគេដឹងរឿងជាច្រើនអំពីអ្នកប្រហែលជាច្រើនជាងអ្វីដែលអ្នកចង់ឱ្យគេដឹងទៅទៀត។ ព័ត៌មាននោះជួនកាលអាចធ្លាក់ទៅក្នុងដៃជនទុច្ចរិតហើយត្រូវបានប្រើប្រាស់ក្នុងផ្លូវដែលបង្កគ្រោះថ្នាក់ក៏ថាបាន។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ការកសាងវត្តមានឌីជីថលបែបវិជ្ជមាន៖

ជំនួសឱ្យការចៀសវាងបញ្ហា ចូរបង្កើតមាតិការវិជ្ជមានដោយសកម្ម៖

- ចែករំលែកសមិទ្ធផលសិក្សា ឬការងាររបស់អ្នក
- បង្ហោះអំពីសេវាកម្មសហគមន៍ និងការងារស្ម័គ្រចិត្ត
- បង្ហាញពីចំណាប់អារម្មណ៍ និងចំណូលចិត្តរបស់អ្នក
- គាំទ្របុព្វហេតុ ឬបញ្ហាសង្គមដែលអ្នកយកចិត្តទុកដាក់
- ជួយមិត្តភក្តិឱ្យយល់ដឹងអំពីសុវត្ថិភាពឌីជីថល

ប្រសិនបើមានបញ្ហាកើតឡើង៖

ប្រសិនបើមានមាតិកាមិនសមរម្យអំពីអ្នកលេចឡើងនៅលើអ៊ីនធឺណិត៖

១. កុំស្លន់ស្លោ ត្រូវចតរូបអេក្រង់ទុកជាភស្តុតាង
២. រាយការណ៍បញ្ហានេះទៅកាន់វេទិកានោះ
៣. រកជំនួយពីមនុស្សចាស់ទុំដែលអ្នកទុកចិត្ត
៤. ទាក់ទងអាជ្ញាធរ ប្រសិនបើមានការគំរាមកំហែង
៥. ត្រូវអត់ធ្មត់ ព្រោះការលុបមាតិកាចេញត្រូវការពេលវេលា

ចំណុចសំខាន់ៗដែលត្រូវចងចាំ

១. គ្រប់យ៉ាងនៅលើអ៊ីនធឺណិតសុទ្ធតែបន្សល់ទុកនូវដាន។ គ្មានការទំនាក់ទំនងតាមអ៊ីនធឺណិតណា ដែលឯកជនពិតប្រាកដនោះទេ។
២. ដានឌីជីថល របស់អ្នកនឹងនៅជាប់ជាមួយអ្នកមួយជីវិត។ សូមគិតអំពីអនាគតរបស់អ្នកមុនពេលបង្ហោះអ្វីមួយ។
៣. អ្នកត្រូវតែការពារឯកជនភាពរបស់អ្នកឱ្យបានសកម្ម។ វាគឺជាទំនួលខុសត្រូវរបស់អ្នក។
៤. ប្រើប្រាស់បច្ចេកវិទ្យាដើម្បីធ្វើឱ្យពិភពលោកកាន់តែប្រសើរឡើង។ ត្រូវធ្វើជាពលរដ្ឋឌីជីថលដ៏ល្អម្នាក់។
៥. ប្រសិនបើមានមន្ទិលសង្ស័យ កុំបង្ហោះឱ្យសោះ។ ការប្រុងប្រយ័ត្នគឺជាជម្រើសដ៏ល្អបំផុត។

ដានជើងឌីជីថលរបស់អ្នកប្រៀបបាននឹងកេរ្តិ៍ឈ្មោះរបស់អ្នកដែរ។ វាត្រូវការពេលវេលាដើម្បីកសាង ប៉ុន្តែអាចខូចខាតបានក្នុងមួយប៉ព្រិចភ្នែក។ ចូរថែរក្សាវត្តមានរបស់អ្នកនោះលើអ៊ីនធឺណិតឱ្យដូចដែលអ្នកថែរក្សាកេរ្តិ៍ឈ្មោះរបស់អ្នកនៅសាលារៀន និងក្នុងសហគមន៍ដែរ។

មេរៀនសង្ខេប

នៅក្នុងមេរៀននេះ យើងបានសិក្សានូវចំណុចសំខាន់ៗដូចខាងក្រោម៖

- ដានជើងឌីជីថលរបស់អ្នកសំដៅលើដាននៃទិន្នន័យឬព័ត៌មាន ដែលអ្នកបន្សល់ទុកនៅពេលប្រើប្រាស់អ៊ីនធឺណិត។ ដានសកម្មគឺជាអ្វីដែលអ្នកចែករំលែកដោយចេតនា (ការបង្ហោះលើបណ្តាញផ្សព្វផ្សាយសង្គម)។ ដានអកម្មជាព័ត៌មានត្រូវបានគេប្រមូលដោយអ្នកមិនដឹងខ្លួន (ការតាមដានរបស់វេបសាយ និងទិន្នន័យទីតាំង)។

- ដានជើងឌីជីថលរបស់អ្នកមានសារៈសំខាន់ព្រោះសាកលវិទ្យាល័យ និងនិយោជកអាចនឹងពិនិត្យមើលប្រវត្តិនៃសកម្មភាពរបស់អ្នកដាក់ពាក្យនៅលើបណ្តាញផ្សព្វផ្សាយសង្គម។ ដានជើងឌីជីថលដែលមានលក្ខណៈវិជ្ជមាន នឹងជំរុញឱកាសរបស់អ្នកក្នុងការទទួលបានការសិក្សា ឬការងារនោះ ចំណែកឯការមានមាតិកាមិនសមរម្យអាចនឹងបំផ្លាញឱកាសទាំងនោះទៅវិញ។
- ការគ្រប់គ្រងដានជើងឌីជីថលរបស់អ្នក តម្រូវឱ្យមានការត្រួតពិនិត្យជាប្រចាំ។ ស្វែងរកឈ្មោះរបស់អ្នកក្នុង Google ពិនិត្យមើលការស្វែងរកតាមរូបភាព កំណត់ការជូនដំណឹង និងកែសម្រួលការកំណត់ឯកជនភាពក្នុងបណ្តាញសង្គម។
- មុនពេលបង្ហោះសូមសួរខ្លួនឯងថា តើនឹងមានអ្វីកើតឡើងប្រសិនបើឪពុកម្តាយឬគ្រូបានឃើញ? តើវានឹងធ្វើឱ្យខ្ញុំអាម៉ាស់មុខនៅពេលក្រោយដែរឬទេ? តើខ្ញុំកំពុងចែករំលែកព័ត៌មានផ្ទាល់ខ្លួនច្រើនពេកដែរឬទេ?
- ការការពារឯកជនភាពទាមទារការយកចិត្តទុកដាក់ជាប្រចាំព្រោះរបបសាយ និងកម្មវិធីប្រមូលព័ត៌មានរបស់អ្នកដើម្បីរកប្រាក់ពីការផ្សាយពាណិជ្ជកម្ម ហើយទិន្នន័យអាចធ្លាក់ទៅក្នុងដៃជនខិលខូច។
- ហាមចែករំលែកលេខអត្តសញ្ញាណបណ្ណ ទីតាំងជាក់លាក់ ព័ត៌មានធនាគារ ពាក្យសម្ងាត់ ឬព័ត៌មានឯកជនរបស់គ្រួសារនៅលើអ៊ីនធឺណិតឱ្យសោះ។
- កសាងវត្តមានវិជ្ជមាននៅលើអនឡាញ ដោយការចែករំលែកសមិទ្ធផល ការងារសង្គម និងចំណង់ចំណូលចិត្ត ព្រមទាំងជួយមិត្តភក្តិឱ្យយល់ដឹងអំពីសុវត្ថិភាពឌីជីថល។

សទ្ទានុក្រម

- **ដានជើងឌីជីថល៖** សំដៅលើដាននៃទិន្នន័យ ឬព័ត៌មាន ដែលអ្នកប្រើប្រាស់បន្សល់ទុកនៅពេលប្រើប្រាស់អ៊ីនធឺណិត។
- **ដានជើងឌីជីថលអកម្ម៖** ព័ត៌មានដែលត្រូវបានប្រមូលអំពីអ្នកដោយអ្នកមិនដឹងខ្លួន ដូចជាការតាមដានការរុករករបស់អ្នក ទិន្នន័យទីតាំងពីកម្មវិធីផ្សេងៗរបស់អ្នកជាដើម។
- **ទិន្នន័យផ្ទាល់ខ្លួន៖** ព័ត៌មានអំពីអ្នក ដូចជា ឈ្មោះ ថ្ងៃកំណើត ឬទីតាំង។
- **ការកំណត់ឯកជនភាព៖** ការគ្រប់គ្រងដែលកំណត់ថាអ្នកណាខ្លះអាចមើលឃើញព័ត៌មានរបស់អ្នក។

លំហាត់អនុវត្តន៍

១. ដានជើងឌីជីថលរបស់អ្នកក្នុងរយៈពេលមួយថ្ងៃ៖ គូរ និងឆ្លុះបញ្ចាំង
យកក្រដាសពីរសន្លឹក ហើយគូរស្តាមជើងឆ្វេង និងស្តាំរបស់អ្នក។

- **ដានជើងស្តាំ (ដានសកម្ម)៖** ចូរសរសេររាល់ព័ត៌មានដែលអ្នកបានចែករំលែកដោយចេតនានៅលើអ៊ីនធឺណិតក្នុងរយៈពេលមួយថ្ងៃ៖
  - ការបង្ហោះរូបភាព ឬអត្ថបទលើបណ្តាញសង្គម។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

- ការចុចចូលចិត្ត បញ្ចេញមតិ ឬការចែករំលែក។
- សារដែលអ្នកបានផ្ញើ និងការយល់ព្រមទទួលមិត្តភក្តិថ្មីៗ។
- កម្មវិធីទូរសព្ទដែលអ្នកបានប្រើ និងព័ត៌មានដែលអ្នកបានផ្តល់ឱ្យកម្មវិធីទាំងនោះ។

• **ដានជើងឆ្វេង (ដានអកម្ម)៖** ចូរសរសេរព័ត៌មានដែលត្រូវបានប្រមូលពីអ្នកដោយមិនដឹងខ្លួន៖
- វេបសាយដែលអ្នកចូលមើល (ដែលអាចតាមដានប្រវត្តិរុករករបស់អ្នក)។
- ពាក្យគន្លឹះដែលអ្នកបានវាយបញ្ចូលក្នុងម៉ាស៊ីនស្វែងរក។
- បណ្តាញ WiFi ដែលអ្នកបានភ្ជាប់។
- ទីតាំង របស់អ្នកដែលអាចត្រូវបានចែករំលែកតាមរយៈកម្មវិធីផ្សេងៗ។

ជាចុងក្រោយ បន្ទាប់ពីគូររួចសូមពិនិត្យមើលដានជើងទាំងពីរ ឬពិភាក្សាជាមួយមិត្តភក្តិ៖ តើមានអ្វីខ្លះដែលធ្វើឱ្យអ្នកភ្ញាក់ផ្អើល? តើផ្នែកណាខ្លះដែលមានហានិភ័យ? តើអ្នកអាចការពារឯកជនភាពឌីជីថលរបស់អ្នកឱ្យកាន់តែប្រសើរឡើងយ៉ាងដូចម្តេច?

២. ការសម្ភាសការងារ និងដានជើងឌីជីថលរបស់អ្នក៖ ការសម្តែងជាតួអង្គ

សូមសុំឱ្យមិត្តភក្តិឬសមាជិកគ្រួសារម្នាក់សម្តែងជា ម្ចាស់ក្រុមហ៊ុន ហើយអ្នកដើរតួជាបេក្ខជនមកដាក់ពាក្យសុំធ្វើការ។ សូមផ្តល់ដានជើងឌីជីថលដែលអ្នកបានគូរក្នុងលំហាត់មុនឱ្យទៅគាត់ រួចឆ្លើយសំណួរខាងក្រោម៖

ក. យើងបានរកឃើញការបង្ហោះទាំងនេះនៅលើអ៊ីនធឺណិត តើអ្នកអាចពន្យល់ពីវាបានទេ?

ខ. តើយើងយល់ឃើញថាអ្នកជាមនុស្សបែបណា នៅពេលយើងមើលសកម្មភាពអនឡាញរបស់អ្នក?

គ. តើអ្នកគិតថាសកម្មភាពអនឡាញរបស់អ្នក បង្ហាញពីចំណុចខ្លាំងរបស់អ្នកយ៉ាងដូចម្តេច?

បន្ទាប់ពីសម្តែងរួចសូមឆ្លុះបញ្ចាំង៖ តើនីយោជកអាចរៀនសូត្រអ្វីខ្លះពីដានជើងឌីជីថលរបស់អ្នក? តើវាអាចប៉ះពាល់ដល់អាជីពការងាររបស់អ្នកយ៉ាងដូចម្តេច? តើអ្នកអាចការពារផលប៉ះពាល់អវិជ្ជមាន និងធ្វើឱ្យដានជើងរបស់អ្នកមានភាពវិជ្ជមានយ៉ាងដូចម្តេច?

លំហាត់អនុវត្តន៍ជាមួយឧបករណ៍ | **កម្មវិធី SALA MIL | ជំពូកទី៤៖ សុវត្ថិភាព និងឯកជនភាព លើអ៊ីនធឺណិត**

៣. តើអ្នកគួរចែករំលែករឿងនេះទេ? ចូរឆ្លើយសំណួរវាយតម្លៃទំនុកចិត្តរបស់អ្នក

សូមប្រើប្រាស់កម្មវិធីទូរសព្ទ SALA MIL ហើយចូលទៅកាន់ជំពូកទី៤ មេរៀនទី៤.១៖ ទិន្នន័យរបស់អ្នក និងអ្វីដែលអ្នកចែករំលែក។

- វាយតម្លៃខ្លួនឯង៖ មុនពេលចាប់ផ្តើម តើអ្នកមានទំនុកចិត្តកម្រិតណាលើប្រធានបទនេះ? (ពិន្ទុ ០ = មិនមានទំនុកចិត្តទាល់តែសោះ ១០ = មានទំនុកចិត្តខ្លាំងបំផុត)។
- ចូរឆ្លើយសំណួរខ្លី៖ រាល់ការបង្ហោះនីមួយៗដែលសំណួរបង្ហាញឡើង សូមសម្រេចចិត្តថាតើអ្នកគួរចែករំលែក ឬមិនគួរ រួមទាំងអានការពន្យល់ផងដែរ។ សូមកត់ត្រាពិន្ទុដែលអ្នកទទួលបាន។
- ឆ្លុះបញ្ចាំង៖ បន្ទាប់ពីបញ្ចប់សកម្មភាពនេះ សូមវាយតម្លៃកម្រិតទំនុកចិត្តរបស់អ្នកម្តងទៀត។ តើវាមានការផ្លាស់ប្តូរដែរឬទេ? ហេតុអ្វី?

៤. ព័ត៌មានឯកជន និងព័ត៌មានផ្ទាល់ខ្លួន៖ អានអត្ថបទ និងទស្សនាវីដេអូ

សូមប្រើប្រាស់កម្មវិធីទូរសព្ទ MIL Chatbot ហើយចូលទៅកាន់ជំពូកទី៥៖ សុវត្ថិភាព និងឯកជនភាពលើអ៊ីនធឺណិត។

សូមទស្សនាវីដេអូដែលមានចំណងជើងថា “Private and Personal Information”។ បន្ទាប់ពីទស្សនាចប់ សូមឆ្លើយសំណួរខាងក្រោម៖

- តើការចែករំលែកព័ត៌មាននៅលើបណ្តាញសង្គម មានចំណុចវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះ?
- តើអ្វីទៅជាភាពខុសគ្នារវាង ព័ត៌មានឯកជន និងព័ត៌មានផ្ទាល់ខ្លួន ?
- ហេតុអ្វីបានជាអ្នកគួរតែគិតពិចារណាឱ្យបានច្បាស់ មុនពេលអ្នកចែករំលែក?
- តើព័ត៌មានប្រភេទណាខ្លះដែលអ្នកតែងតែចែករំលែកនៅលើបណ្តាញសង្គម?

សំណួរសម្រាប់ពិភាក្សា

១. តើដានជើងឌីជីថលជាអ្វី?

២. តើអ្វីជាភាពខុសគ្នារវាង ដានជើងឌីជីថលសកម្ម និងដានជើងឌីជីថលអកម្ម?

៣. ហេតុអ្វីបានជា ដានជើងឌីជីថលរបស់អ្នក សំខាន់សម្រាប់ការសិក្សាអប់រំ ឬឱកាសរកការងារធ្វើរបស់អ្នកនៅថ្ងៃអនាគត?

៤. អ្វីខ្លះដែលអ្នកគួរគិត មុននឹងបង្ហោះព័ត៌មានអ្វីមួយទៅលើអនឡាញ?

៥. តើព័ត៌មានឯកជនអ្វីខ្លះដែលអ្នកមិនត្រូវចែករំលែកលើអនឡាញ?

៦. តើមានជំហានជាក់ស្តែងអ្វីខ្លះ ដែលអ្នកអាចធ្វើដើម្បី ពិនិត្យ សម្អាត និងគ្រប់គ្រងដានជើងឌីជីថលរបស់អ្នក?

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

មេរៀនទី ២

ការគំរាមកំហែងតាមអនឡាញ



មេរៀនទី៤.៣ ៥.១ ៥.២ ៥.៣



ជំពូកទី៥

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីៈ

ក. ការសម្គាល់ និងការចៀសវាងគ្រោះថ្នាក់ក្នុងប្រព័ន្ធឌីជីថល

ខ. ប្រភេទនៃការគំរាមកំហែងតាមអ៊ីនធឺណិតដែលកើតមានញឹកញាប់

គ. ការពារខ្លួនអ្នកនៅលើអនឡាញ

ហេតុអ្វីបានជាមេរៀននេះសំខាន់?

ការស្គាល់ការគំរាមកំហែងតាមអ៊ីនធឺណិតជួយសិស្សចៀសវាងការបោកប្រាស់ដែលអាចលួចប្រាក់ ទិន្នន័យ ឬអត្តសញ្ញាណរបស់ពួកគេ។ ការរៀនយុទ្ធសាស្ត្រការពារជួយបង្កើនសុវត្ថិភាពរបស់មនុស្សនៅលើគ្រប់វេទិកាឌីជីថល។

ក. ការសម្គាល់ និងការចៀសវាងគ្រោះថ្នាក់ក្នុងប្រព័ន្ធឌីជីថល

អ៊ីនធឺណិតផ្តល់នូវឱកាសដ៏អស្ចារ្យដើម្បីរៀនសូត្រ ភ្ជាប់ទំនាក់ទំនង និងស្វែងយល់អំពីពិភពលោក។ ប៉ុន្តែវាក៏នាំមកនូវគ្រោះថ្នាក់ពិតប្រាកដដែលអាចប៉ះពាល់ដល់ការសិក្សា ហិរញ្ញវត្ថុ និងសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកផងដែរ។ ការយល់ដឹងអំពីការគំរាមកំហែងទាំងនេះ និងការដឹងពីរបៀបការពារខ្លួន គឺមានសារៈសំខាន់សម្រាប់ការរក្សាសុវត្ថិភាពតាមអ៊ីនធឺណិត។

មូលហេតុដែលនាំឱ្យការគំរាមកំហែងតាមអនឡាញកើនឡើង

ការឆបោកនិងការវាយប្រហារតាមអ៊ីនធឺណិតកំពុងកើតឡើងកាន់តែញឹកញាប់ និងកាន់តែមានកលល្បិចខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំ។ ការកើនឡើងនៃទីតាំងឆបោកតាមប្រព័ន្ធឌីជីថល នៅតាមប្រទេសកំពុងអភិវឌ្ឍ បានធ្វើឱ្យរឿងនេះក្លាយជាបញ្ហាដ៏ធ្ងន់ធ្ងរ និងជាបញ្ហាក្នុងស្រុកផ្ទាល់តែម្តង។ ប្រតិបត្តិការឆបោកទាំងនេះច្រើនតែតម្រង់គោលដៅលើយុវជនជាមួយនឹងការផ្តល់ជូនការងារក្លែងក្លាយ បន្ទាប់មកបង្ខំជនរងគ្រោះឱ្យធ្វើការឆបោកតាមអ៊ីនធឺណិតទៅលើអ្នកដទៃនៅជុំវិញពិភពលោក។

ការរីកចម្រើននៃបញ្ញាសិប្បនិម្មិតបានធ្វើឱ្យការឆបោកជាច្រើន កាន់តែមើលទៅគួរឱ្យជឿជាងពេលណាៗទាំងអស់។ ឧក្រិដ្ឋជនអាចបង្កើតសំឡេង វីដេអូ និងរបេសាយក្លែងក្លាយដែលមើលនិងស្តាប់ទៅដូចជារបស់ពិតមែនទែន។ ដូច្នេះអ្នកត្រូវតែប្រុងប្រយ័ត្នជាងមុន នៅពេលវាយតម្លៃលើអ្វីដែលអ្នកឃើញនៅលើអ៊ីនធឺណិត។

ផលប៉ះពាល់ក្នុងពិភពពិត

ការគំរាមកំហែងតាមអ៊ីនធឺណិតមិនគ្រាន់តែជាសារៈខានធម្មតានោះទេ ប៉ុន្តែពួកវាអាចនាំឱ្យមានផលវិបាកធ្ងន់ធ្ងរ រួមទាំងការបាត់បង់ប្រាក់កាស ការលួចអត្តសញ្ញាណ ការខូចខាតកំណត់ត្រាសិក្សា និងថែមទាំងគ្រោះថ្នាក់ដល់រាងកាយទៀតផង។ សិស្សជាច្រើនបានបាត់បង់ប្រាក់អាហារូបករណ៍ ត្រូវបានគេលួចព័ត៌មានផ្ទាល់ខ្លួន ឬត្រូវបានគេបញ្ឆោតឱ្យចែករំលែករូបថត ដែលក្រោយមកគេយកទៅប្រើប្រាស់ដើម្បីធ្វើបាបពួកគេវិញ។

ខ. ប្រភេទនៃការគំរាមកំហែងតាមអ៊ីនធឺណិតដែលកើតមានញឹកញាប់

- **ការបន្លំលួចទិន្នន័យ**

ការបន្លំលួចទិន្នន័យកើតឡើងនៅពេលដែលឧក្រិដ្ឋជនបន្លំធ្វើជាស្ថាប័នស្របច្បាប់ណាមួយ ដើម្បីលួចព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។ ពួកគេអាចបន្លំខ្លួនជាសាលារៀន ធនាគារ វេទិកាបណ្តាញផ្សព្វផ្សាយសង្គម ឬជាទីភ្នាក់ងាររដ្ឋាភិបាលទៀតផង។

របៀបសម្គាល់៖ សារបន្លំលួចទិន្នន័យជាញឹកញាប់បង្កើតនូវភាពបន្ទាន់។ ឧទាហរណ៍៖ គណនីរបស់អ្នកនឹងត្រូវបិទនៅថ្ងៃស្អែក សំណេរមានកំហុសអក្ខរាវិរុទ្ធ ស្នើសុំព័ត៌មានសំខាន់ៗដូចជាពាក្យសម្ងាត់ ឬលេខអត្តសញ្ញាណបណ្ណ ឬនាំអ្នកទៅកាន់រេបសាយដែលមានតំណភ្ជាប់គួរឱ្យសង្ស័យដែលមិនត្រូវគ្នាជាមួយនឹងអាសយដ្ឋានរេបសាយពិតរបស់ស្ថាប័ននោះ។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ឧទាហរណ៍៖ សារអ៊ីមែលក្លែងក្លាយដែលអះអាងថាមកពីសាលារបស់អ្នក ដោយស្នើឱ្យអ្នកផ្ទៀងផ្ទាត់គណនីសិស្សតាមរយៈការបញ្ចូលព័ត៌មានចូលគណនី។ សារខ្លីៗដែលជូនដំណឹងថាអ្នកបានឈ្នះអាហារូបករណ៍ ប៉ុន្តែតម្រូវឱ្យផ្តល់ព័ត៌មានលម្អិតផ្ទាល់ខ្លួន។ សារតាមបណ្តាញសង្គមដែលសន្យាផ្តល់ប្រាក់ចំណូលងាយៗ តាមរយៈការធ្វើការងារអនឡាញសាមញ្ញៗ។



រូបភាព ២.១ ការគំរាមកំហែងតាមអ៊ីនធឺណិត

- **ការឆបោកតាមរយៈការបង្កើតទំនាក់ទំនង និងស្នេហា**

ជនឆបោកបង្កើតប្រូហ្វាលក្លែងក្លាយលើអនឡាញដើម្បីកសាងទំនាក់ទំនងស្នេហា ជាមួយជនរងគ្រោះ បន្ទាប់មកស្នើសុំប្រាក់ ឬព័ត៌មានផ្ទាល់ខ្លួន បន្ទាប់ពីពួកគេបានបង្កើតទំនុកចិត្តជាមួយគ្នារួច។



រូបភាព ២.២ ការឆបោកតាមអ៊ីនធឺណិត

របៀបសម្គាល់៖ ជនឆបោកភាគច្រើនតែងតែចៀសវាងការជួបមុខផ្ទាល់ ឬការនិយាយគ្នាតាមវីដេអូ។ ពួកគេច្រើនតែប្រើប្រាស់រូបថតដែលមើលទៅល្អឥតខ្ចោះពេក ឆាប់ពោលពាក្យសន្យាស្នេហា និងព្យាយាមស៊ើបសួរពីស្ថានភាពហិរញ្ញវត្ថុរបស់អ្នក។

ហេតុអ្វីវាមានគ្រោះថ្នាក់៖ ការឆបោកទាំងនេះអាចបណ្តាលឱ្យមានការឈឺចាប់ផ្នែកអារម្មណ៍យ៉ាងខ្លាំងព្រមទាំងការខាតបង់ផ្នែកហិរញ្ញវត្ថុផងដែរ។ ជនរងគ្រោះច្រើនតែមានអារម្មណ៍ខ្មាសអៀន ហើយមិនហ៊ានរាយការណ៍ពីបទល្មើសនេះដែលធ្វើឱ្យជនឆបោកបានចិត្តហើយបន្តធ្វើសកម្មភាពទៅលើអ្នកដទៃទៀត។

- **ការឆបោកប្រើលេសវិនិយោគ «ឆាប់ក្លាយជាអ្នកមាន»**

ជនបោកប្រាស់សន្យាថានឹងរកលុយបានដោយងាយ តាមរយៈការវិនិយោគរូបិយបណ្ណគ្រីបតូ ការជួញដូរតាមអនឡាញ ឬឱកាសការងារធ្វើនៅផ្ទះដែលតម្រូវឱ្យមានការបង់ប្រាក់មុន ឬផ្តល់ព័ត៌មានផ្ទាល់ខ្លួន។

របៀបសម្គាល់៖ ការសន្យាថានឹងទទួលបានប្រាក់ចំណេញមកវិញដោយគ្មានហានិភ័យ ការដាក់សម្ពាធឱ្យធ្វើសកម្មភាពភ្លាមៗ ការស្នើសុំប្រាក់ ឬរូបិយបណ្ណគ្រីបតូ ជាថ្លៃចំណាយចាប់ផ្តើម ឬឱកាសដែលស្តាប់ទៅល្អពេកដែលពិបាកជឿទៅវិញ។

ទម្រង់ទូទៅផ្សេងៗទៀត៖ ទីផ្សារជួញដូររូបិយបណ្ណគ្រីបតូក្លែងក្លាយ គម្រោងឆបោកបែបពីរ៉ាមីតដែលបន្លំជាអាជីវកម្មស្របច្បាប់ ការងារអនឡាញក្លែងក្លាយដែលតម្រូវឱ្យអ្នកបង់ប្រាក់ថ្លៃសម្ភារៈបណ្តុះបណ្តាល និងការផ្សាយពាណិជ្ជកម្មតាមបណ្តាញសង្គម ដែលផ្សព្វផ្សាយពីផលចំណេញវិនិយោគដែលមិនសមហេតុផល។

- **ការឆបោកពាក់ព័ន្ធនឹងការសិក្សា**

ការឆបោកដែលមានគោលដៅទៅលើសិស្សតាមរយៈការផ្តល់អាហារូបករណ៍ សេវាកម្មអប់រំ ឬវគ្គសិក្សាអនឡាញដែលបោកបញ្ឆោត។

របៀបសម្គាល់៖ ការផ្តល់អាហារូបករណ៍ដែលតម្រូវឱ្យបង់ប្រាក់កម្រៃជាមុន សាលារៀន ឬកម្មវិធីសិក្សាដែលមិនមានការទទួលស្គាល់គុណភាពត្រឹមត្រូវសន្យាធានាថាបានចូលរៀននៅសាកលវិទ្យាល័យល្បីៗ ឬសេវាកម្មអប់រំដែលមើលទៅមានតម្លៃថោកគួរឱ្យសង្ស័យបើធៀបនឹងសាកលវិទ្យាល័យស្របច្បាប់។

សញ្ញាព្រមាន៖ អាហារូបករណ៍ស្របច្បាប់ណាមួយ នឹងមិនស្នើសុំឱ្យអ្នកបង់ប្រាក់ជាមុននោះទេ។ គ្រឹះស្ថានអប់រំពិតប្រាកដនឹងមានការទទួលស្គាល់ត្រឹមត្រូវ ដែលអ្នកអាចផ្ទៀងផ្ទាត់បានដោយខ្លួនឯង។

- **ការបោកប្រាស់ដោយបន្លំខ្លួនជារដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច**

ជនឆបោកបន្លំខ្លួនជាមន្ត្រីរដ្ឋាភិបាល ប៉ូលិសដើម្បីបំភ័យអ្នកឱ្យបង់ប្រាក់ ឬផ្តល់ព័ត៌មានផ្ទាល់ខ្លួន។

របៀបសម្គាល់៖ ការហៅទូរសព្ទដែលមិនបានរំពឹងទុកពីជនឆបោក ដែលថាអ្នកនៅជំពាក់ពន្ធ ឬប្រាក់ពិន័យ ការគំរាមចាប់ខ្លួន ការទាមទារឱ្យបង់ប្រាក់តាមរយៈកាតទឹកប្រាក់ ឬការស្នើសុំព័ត៌មានផ្ទាល់ខ្លួនតាមទូរសព្ទ។

ឧទាហរណ៍ទូទៅ៖ មន្ត្រីពន្ធដារក្លែងក្លាយទាមទារឱ្យបង់ប្រាក់ភ្លាមៗ សារប្រាប់ថាអត្តសញ្ញាណបណ្ណរបស់អ្នកត្រូវបន្តសុពលភាពជាបន្ទាន់ដោយត្រូវបង់ថ្លៃសេវាឬជនឆបោកបន្លំខ្លួនជាប៉ូលិសទាមទារប្រាក់ពិន័យ។

ត្រូវចងចាំ៖ ស្ថាប័នរដ្ឋាភិបាលពិតប្រាកដ មិនសុំឱ្យបង់ប្រាក់តាមរយៈកាតទឹកប្រាក់ ឬការផ្ទេរប្រាក់នោះទេ។

- **ការលួចអត្តសញ្ញាណ**

ជនល្មើសលួចយកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកដើម្បីបើកគណនី ទិញទំនិញ ឬប្រព្រឹត្តបទល្មើសបច្ចេកវិទ្យាក្នុងនាមរូបអ្នក។ ករណីនេះអាចកើតឡើងតាមរយៈការលេចធ្លាយទិន្នន័យ ការបន្លំភូតកុហក ការលួចឯកសារផ្ទាល់ខ្លួន ឬនៅពេលជនល្មើសបញ្ឆោតអ្នកឱ្យផ្តល់ព័ត៌មានសម្ងាត់តាមទូរសព្ទ ឬប្រព័ន្ធអ៊ីនធឺណិត។

សញ្ញាព្រមាន៖

- ទទួលបានវិក្កយបត្រ ឬរបាយការណ៍កាតឥណទានដែលអ្នកមិនធ្លាប់បានប្រើប្រាស់។
- ធនាគារបដិសេធការស្នើសុំប្រាក់កម្ចីរបស់អ្នក ឬគណនីរបស់អ្នកកំពុងជាប់បំណុលដោយមិនបានដឹង។
- បាត់សំបុត្រ ឬកញ្ចប់ទំនិញ។
- រកឃើញគណនីថ្មី ឬមានការកាត់ប្រាក់ដែលអ្នកមិនបានប្រព្រឹត្ត

របៀបដែលជនឆបោកដាក់គោលដៅលើយុវជន

- **យុទ្ធសាស្ត្រតាមបណ្តាញផ្សព្វផ្សាយសង្គម**

ជនឆបោកប្រើបណ្តាញផ្សព្វផ្សាយសង្គម ដើម្បីប្រមូលព័ត៌មានអំពីគោលដៅដែលគេមើលទៅទំនងនិងដើម្បីធ្វើឱ្យមើលទៅកាន់តែគួរឱ្យទុកចិត្ត។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ពួកគេអាចសិក្សាទម្លាប់នៃការបង្ហោះរបស់អ្នកដើម្បីស្វែងយល់ពីចំណង់ចំណូលចិត្ត មិត្តភក្តិ និងគ្រួសារ របស់អ្នក បន្ទាប់មកប្រើប្រាស់ព័ត៌មាននេះដើម្បីបង្កើត ការឆបោក ដែលកាន់តែគួរឱ្យជឿជាក់។

ពួកគេក៏បង្កើតប្រូហ្វាលក្លែងក្លាយ ដែលមើលទៅដូចយុវវ័យដែលមានរូបសម្រស់ទាក់ទាញ ឬអ្នកជំនាញដែលជោគជ័យដើម្បីកសាងទំនុកចិត្ត និងភាពគួរឱ្យជឿជាក់។ ខ្លះថែមទាំងលួច Hack ចូលគណនីពិតរបស់មនុស្សដែលអ្នកស្គាល់ និងប្រើប្រាស់គណនីទាំងនោះ ដើម្បីទាក់ទងអ្នក ជាមួយនឹងការផ្តល់ជូនបោកប្រាស់។

- **ការកេងចំណេញលើទំនុកចិត្ត**

យុវជនតែងតែជាគោលដៅព្រោះពួកគេអាចមិនសូវមានបទពិសោធន៍ពាក់ព័ន្ធនឹងបញ្ហាហិរញ្ញវត្ថុ និងឆាប់ទុកចិត្តលើការប្រាស្រ័យទាក់ទងតាមអ៊ីនធឺណិត។ ជនឆបោកកេងចំណេញលើសិស្សានុសិស្ស ដែលតែងតែស្វែងរកជំនួយហិរញ្ញវត្ថុ ឱកាសការងារ ឬមធ្យោបាយដើម្បីរកប្រាក់។

ពួកគេក៏កេងចំណេញពីសម្ពាធសង្គមដែរ ដោយបង្កើតភាពបន្ទាន់ក្លែងក្លាយ ឬលើកឡើងថាអ្នកផ្សេងទៀតបានចូលរួមអស់ហើយនៅក្នុងឱកាសណាមួយដែលពួកគេកំពុងផ្សព្វផ្សាយ។ ហាមឆ្លើយតបចំពោះការទាមទារ ឬសំណើណាមួយបែបនេះដោយមិនបានពិគ្រោះជាមួយមនុស្សចាស់ដែលអ្នកទុកចិត្តជាមុនសិន។

គ. ការពារខ្លួនអ្នកនៅលើអនឡាញ

ផ្ទៀងផ្ទាត់មុននឹងជឿ

កុំជឿទាំងស្រុងលើការប្រាស្រ័យទាក់ទងតាមអនឡាញភ្លាមៗ ជាពិសេសនៅពេលពាក់ព័ន្ធរឿងហិរញ្ញវត្ថុ ព័ត៌មានផ្ទាល់ខ្លួន ឬការសម្រេចចិត្តសំខាន់ៗ។ ត្រូវផ្ទៀងផ្ទាត់ជានិច្ច ដោយប្រើប្រាស់វេបសាយផ្លូវការ លេខទូរសព្ទ ឬការទៅជួបផ្ទាល់។

ប្រសិនបើមាននរណាម្នាក់ទាក់ទងអ្នកដោយអះអាងថាមកពីសាលារៀន ធនាគារ ឬស្ថាប័នផ្សេងទៀត សូមកុំប្រើប្រាស់ព័ត៌មានទំនាក់ទំនងដែលពួកគេផ្តល់ឱ្យ ផ្ទុយទៅវិញអ្នកត្រូវស្វែងរកព័ត៌មានទំនាក់ទំនងផ្លូវការដោយខ្លួនឯង ហើយហៅទូរសព្ទទៅដើម្បីផ្ទៀងផ្ទាត់ថាតើការប្រាស្រ័យទាក់ទងដែលអ្នកទទួលបាននោះស្របច្បាប់ដែរឬទេ។

- **កុំប្រញាប់! គិតសិន!**

ជនឆបោកបង្កើតភាពបន្ទាន់ក្លែងក្លាយដើម្បីដាក់សម្ពាធឱ្យអ្នកសម្រេចចិត្តរហ័ស ដោយមិនបានគិតឱ្យបានល្អិតល្អន់។ ឧទាហរណ៍៖ អ្នកត្រូវតែឆ្លើយតបថ្ងៃនេះ បើមិនដូច្នេះទេ រឿងមិនល្អណាមួយនឹងអាចកើតឡើងចំពោះអ្នក ព្រោះបើស្ថាប័នស្របច្បាប់ គេនឹងផ្តល់ពេលវេលាឱ្យអ្នកពិចារណាលើការសម្រេចចិត្តសំខាន់ៗ ហើយនឹងមិនដាក់សម្ពាធឱ្យអ្នកធ្វើសកម្មភាពភ្លាមៗនោះទេ។

នៅពេលអ្នកទទួលបានការផ្តល់ជូន ឬសំណើណាមួយដែលមិននឹកស្មានដល់ សូមចំណាយពេលដើម្បីស្រាវជ្រាវសិន ពិភាក្សាជាមួយមិត្តភក្តិ ឬសមាជិកគ្រួសារដែលទុកចិត្ត ហើយពិចារណាថាតើវាសមហេតុផលដែរឬទេ។ ប្រសិនបើអ្វីមួយមើលទៅល្អពេកដែលមិនអាចជាការពិតបាននោះវាទំនងជាការបោកប្រាស់ហើយ។

- **ការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក**

ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការចែករំលែកព័ត៌មានផ្ទាល់ខ្លួននៅលើអនឡាញ រួមទាំងឈ្មោះ អាសយដ្ឋាន លេខទូរសព្ទ លេខអត្តសញ្ញាណបណ្ណសិស្ស ឬព័ត៌មានហិរញ្ញវត្ថុ។ ព័ត៌មាននេះអាចត្រូវបានគេប្រើដើម្បីលួចអត្តសញ្ញាណរបស់អ្នក ឬកំណត់គោលដៅលើអ្នកសម្រាប់ធ្វើការឆបោក ដែលមានកលល្បិចខ្ពស់។

តើធ្វើដូចម្តេចប្រសិនបើអ្នកបានក្លាយជាមុខសញ្ញារបស់ជនឆបោក

- **ប្រសិនបើអ្នកទទួលបានសារគួរឱ្យសង្ស័យ**



រូបភាព ២.៣ ការពារខ្លួនពីការឆបោកតាមអ៊ីនធឺណិត

ហាមចុចលើតំណភ្ជាប់ហាមទាញយកឯកសារភ្ជាប់ឬផ្តល់ព័ត៌មានណាមួយ។ ប្រសិនបើសារនោះអះអាងថាមកពីស្ថាប័នដែលអ្នកស្គាល់ និងធ្លាប់ទាក់ទងកាលពីពេលមុន សូមទាក់ទងទៅកាន់ស្ថាប័ននោះដោយផ្ទាល់ដោយប្រើប្រាស់ព័ត៌មានទំនាក់ទំនងផ្លូវការ នៅលើវេបសាយរបស់ពួកគេ ដើម្បីផ្ទៀងផ្ទាត់ថាតើសារនោះស្របច្បាប់ដែរឬទេ។

រាយការណ៍អំពីសារដែលគួរឱ្យសង្ស័យនោះ ទៅកាន់អាជ្ញាធរមានសមត្ថកិច្ច និងដាស់តឿនមិត្តភក្តិ ព្រមទាំងក្រុមគ្រួសាររបស់អ្នក ព្រោះជនឆបោកច្រើនតែដៅទៅលើមនុស្សជាច្រើន នៅក្នុងបណ្តាញទំនាក់ទំនងតែមួយ។

- **ប្រសិនបើអ្នកគិតថាអ្នកត្រូវបានគេបោកប្រាស់**

បញ្ឈប់រាល់ការទាក់ទងជាមួយជនឆបោកនោះភ្លាមៗហើយកុំផ្ញើប្រាក់ ឬផ្តល់ព័ត៌មានបន្ថែមទៀតឱ្យសោះ។ ទាក់ទងធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុរបស់អ្នកជាបន្ទាន់ ប្រសិនបើអ្នកបានផ្តល់ព័ត៌មានហិរញ្ញវត្ថុ ឬបានផ្ញើប្រាក់រួចហើយ។ ផ្លាស់ប្តូរពាក្យសម្ងាត់ទាំងអស់របស់អ្នកជាពិសេសសម្រាប់គណនីដែលអាចរងផលប៉ះពាល់។ តាមដានគណនីរបស់អ្នកឱ្យបានដិតដល់ និងរាយការណ៍ពីសកម្មភាពគួរឱ្យសង្ស័យណាមួយភ្លាមៗ។

- **ចំណុចសំខាន់ៗដែលត្រូវចងចាំ**

១. ត្រូវមានមន្ទិលសង្ស័យចំពោះការផ្តល់ជូនដែលអ្នកមិនបានស្នើសុំ៖ មិនថាវាមកតាមរយៈអ៊ីមែល បណ្តាញផ្សព្វផ្សាយសង្គម ឬការហៅទូរសព្ទនោះទេ។

២. ផ្ទៀងផ្ទាត់ដោយខ្លួនឯង៖ កុំទុកចិត្តព័ត៌មានទំនាក់ទំនងដែលបានផ្តល់ឱ្យនៅក្នុងសារដែលគួរឱ្យសង្ស័យ។

៣. ចំណាយពេលគិតបន្តិចសិន៖ រឿងដែលត្រឹមត្រូវស្របច្បាប់មិនតម្រូវឱ្យមានសកម្មភាពឆ្លើយតបភ្លាមៗនោះទេ។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

៤. ការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក៖ ត្រូវប្រុងប្រយ័ត្នឱ្យបានខ្ពស់បំផុត ចំពោះអ្វីដែលអ្នកចែករំលែកតាមអ៊ីនធឺណិត។
៥. ប្រើប្រាស់បណ្តាញផ្លូវការ៖ ចូលទៅកាន់វេបសាយផ្លូវការដោយផ្ទាល់ ជាជាងការចុចលើតំណភ្ជាប់នៅក្នុងសារ។
៦. ទុកចិត្តលើសភាវគតិរបស់អ្នក៖ ប្រសិនបើមានសង្ស័យថា មានអ្វីមិនប្រក្រតី ឬល្អពេកដែលមិនអាចជាការពិតបាន សូមធ្វើការស្រាវជ្រាវបន្ថែម។
៧. កុំខ្មាសអៀនក្នុងការរកជំនួយ៖ មនុស្សជាជនរងគ្រោះ ហើយការរាយការណ៍អំពីការឆបោកអាចជួយការពារអ្នកដទៃពីការឆបោកដែរ។

មេរៀនសង្ខេប

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីចំណុចសំខាន់ៗដូចខាងក្រោម៖

- **ការគំរាមកំហែងតាមអនឡាញ** កាន់តែមានភាពស្មុគស្មាញ ដោយសារបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងទីតាំងប្រតិបត្តិការបោកប្រាស់នៅជុំវិញពិភពលោក។ ទាំងនេះអាចបណ្តាលឱ្យអ្នកបាត់បង់ប្រាក់ ត្រូវបានគេលួចអត្តសញ្ញាណ ខូចខាតកំណត់ត្រាការសិក្សា និងធ្វើឱ្យមានគ្រោះថ្នាក់ដល់រាងកាយ។
- **ការគំរាមកំហែងតាមអនឡាញជាទូទៅ រួមមាន៖**
  - ការលួចបន្លំយកទិន្នន័យ៖ ឧក្រិដ្ឋជនបន្លំធ្វើជាសាលារៀន ឬធនាគាររបស់អ្នក។
  - ការឆបោកតាមទំនាក់ទំនងស្នេហា៖ ទំនាក់ទំនងស្នេហាក្លែងក្លាយតាមអនឡាញ។
  - ការឆបោកជាការវិនិយោគ៖ ការសន្យាថាអ្នកអាចរកប្រាក់បានដោយងាយ។
  - ការឆបោកពាក់ព័ន្ធនឹងការសិក្សា៖ អាហារូបករណ៍ក្លែងក្លាយដែលតម្រូវឱ្យអ្នកបង់ថ្លៃសេវា។
  - ការឆបោកដោយបន្លំខ្លួនធ្វើជាមន្ត្រីរដ្ឋាភិបាល៖ មន្ត្រីក្លែងក្លាយទាមទារឱ្យអ្នកបង់ប្រាក់ពិន័យ។
  - ការលួចអត្តសញ្ញាណ។
- **ជនឆបោកដាក់គោលដៅលើសិស្ស** ដោយមើលការបង្ហោះរបស់អ្នកក្នុងបណ្តាញផ្សព្វផ្សាយសង្គម កេងចំណេញពីកង្វះបទពិសោធន៍របស់អ្នកលើរឿងហិរញ្ញវត្ថុ ដាក់សម្ពាធឱ្យអ្នកធ្វើសកម្មភាពបន្ទាន់ និងកំណត់ពេលវេលាវាយប្រហារឱ្យចំព្រឹត្តិការណ៍សំខាន់ៗ ដូចជាការចុះឈ្មោះចូលរៀន ឬនៅពេលអ្នកកំពុងស្នើសុំជំនួយហិរញ្ញវត្ថុ។
- **អ្នកអាចការពារខ្លួនអ្នកបាន** ដោយធ្វើការពិនិត្យរាល់សារទាំងអស់តាមរយៈព័ត៌មានទំនាក់ទំនងផ្លូវការចំណាយពេលគិតមុននឹងធ្វើសកម្មភាពតាមសំណើបន្ទាន់នានា និងមានការប្រុងប្រយ័ត្នចំពោះព័ត៌មានផ្ទាល់ខ្លួនដែលអ្នកចែករំលែកតាមអនឡាញ។
- **ប្រសិនបើអ្នកក្លាយជាគោលដៅនៃការឆបោក** ហាមចុចតំណភ្ជាប់ ឬផ្តល់ព័ត៌មានឱ្យសោះ ត្រូវផ្ទៀងផ្ទាត់សារតាមរយៈបណ្តាញផ្លូវការ ហើយប្រសិនបើអ្នកត្រូវបានគេឆបោក សូមបញ្ឈប់ការទាក់ទងភ្លាម ប្រាប់ទៅធនាគាររបស់អ្នក ផ្លាស់ប្តូរពាក្យសម្ងាត់ និងតាមដានគណនីរបស់អ្នកឱ្យបានដិតដល់។

- **គោលការណ៍សំខាន់ៗ៖** ត្រូវមានមន្ទិលសង្ស័យចំពោះការផ្តល់ជូនដែលមិនបានរំពឹងទុក ផ្ទៀងផ្ទាត់អ្វីៗដោយខ្លួនឯង ចំណាយពេលគិតសិន ការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ប្រើប្រាស់វេបសាយផ្លូវការ ទុកចិត្តលើអារម្មណ៍របស់អ្នក និងកុំខ្មាសអៀនក្នុងការរកជំនួយ។

 សទ្ទានុក្រម

- **ការវាយប្រហារតាមអ៊ីនធឺណិត៖** ការព្យាយាមចូលទៅក្នុងកុំព្យូទ័រ ទូរសព្ទ ឬបណ្តាញសង្គម ដើម្បីលួចព័ត៌មាន បង្កការខូចខាត ឬរំខានសេវាកម្ម។
- **ការលួចអត្តសញ្ញាណ៖** នៅពេលដែលនរណាម្នាក់លួចព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកហើយប្រើវាដើម្បីក្លែងបន្លំជាអ្នក ជាញឹកញាប់ដើម្បីយកទៅធ្វើការក្លែងបន្លំ ឬយកប្រាក់របស់អ្នក។
- **មេរោគ៖** កម្មវិធីដែលមានគ្រោះថ្នាក់អាចបំផ្លាញឧបករណ៍ ឬលួចព័ត៌មាន។
- **ការបញ្ឆោតលួចព័ត៌មាន៖** សារក្លែងក្លាយដែលត្រូវបានរចនាឡើងដើម្បីលួចព័ត៌មាន ឬប្រាក់ពីអ្នក។
- **ការបោកប្រាស់៖** ល្បិចដែលប្រើដើម្បីលួចប្រាក់ ឬទិន្នន័យ។
- **តំណភ្ជាប់គួរឱ្យសង្ស័យ៖** តំណភ្ជាប់ដែលអ្នកមិនប្រាកដ និងដែលអាចនាំទៅរកគ្រោះថ្នាក់នៅលើអ៊ីនធឺណិត។

 លំហាត់អនុវត្តន៍

១. សារដែលគួរឱ្យសង្ស័យ និងការបោកប្រាស់តាមប្រព័ន្ធអនឡាញ៖ បទពិសោធន៍ផ្ទាល់ខ្លួន

តើអ្នកធ្លាប់ទទួលបានសារដែលគួរឱ្យសង្ស័យតាមប្រព័ន្ធអនឡាញ ដែលមើលទៅហាក់ដូចជាការបោកប្រាស់ដែរឬទេ? សូមកត់ត្រាទុក ហើយប្រសិនបើអាចធ្វើទៅបាន សូមចែករំលែក និងពិភាក្សាជាមួយអ្នកដទៃ៖

- តើអ្នកទទួលបានសារនោះតាមរយៈប្រភពណា?
- តើប្រភពធ្វើសារនោះ បន្លំធ្វើជាអ្នកណា?
- តើខ្លឹមសារនៃសារនោះ តម្រូវឱ្យអ្នកធ្វើអ្វីខ្លះ?
- តើអ្នកយល់ថា សារនោះគឺជាការគំរាមកំហែងដ៏គ្រោះថ្នាក់ដែរឬទេ? ហេតុអ្វី?
- តើសញ្ញាព្រមានជាក់លាក់ណាមួយដែលអ្នកបានកត់សម្គាល់ឃើញ (ឧទាហរណ៍៖ ការប្រើពាក្យពេចន៍បន្ទាន់ខ្លាំង ការទាមទារប្រាក់ ឬព័ត៌មានផ្ទាល់ខ្លួន តំណភ្ជាប់ដែលគួរឱ្យសង្ស័យ ឬការប្រើប្រាស់អក្ខរាវិរុទ្ធមិនត្រឹមត្រូវ)?
- តើអ្នកបានឆ្លើយតបទៅវិញយ៉ាងដូចម្តេច?

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

២. មគ្គុទ្ទេសក៍បង្ការការបោកប្រាស់៖ របៀបការពារខ្លួន

សូមជ្រើសរើសប្រភេទនៃសកម្មភាពបោកប្រាស់ ឬការលួចបន្លំយកព័ត៌មានសម្ងាត់ណាមួយមកធ្វើជាចំណុចដៅ រួមមាន៖

- ការវាយប្រហារតាមរយៈការលួចបន្លំយកព័ត៌មាន។
- ការបោកប្រាស់តាមរយៈរូបភាពស្នេហា និងទំនាក់ទំនង។
- ការបោកប្រាស់តាមរយៈការវិនិយោគ ឬការសន្យាថានឹងក្លាយជាអ្នកមានក្នុងរយៈពេលខ្លី។
- ការបន្លំធ្វើជាមន្ត្រីរដ្ឋាភិបាល ឬអាជ្ញាធរ។
- ការបោកប្រាស់ក្នុងវិស័យសិក្សាធិការ និងការអប់រំ។

ចូររៀបចំជាមគ្គុទ្ទេសក៍បង្ការខ្លួនខ្លីមួយដើម្បីកុំឱ្យធ្លាក់ក្នុងអន្ទាក់នៃការបោកប្រាស់ប្រភេទនេះ។ អ្នកអាចរចនាដោយភាពច្នៃប្រឌិត និងជ្រើសរើសព័ត៌មានដែលចង់ដាក់បញ្ចូលក្នុងមគ្គុទ្ទេសក៍នោះ។

ឧទាហរណ៍ដូចជា៖

- តើអ្វីទៅជាលក្ខណៈសម្គាល់ទូទៅនៃការបោកប្រាស់ប្រភេទនេះ?
- ហេតុអ្វីបានជាការបោកប្រាស់ប្រភេទនេះមានគ្រោះថ្នាក់?
- តើជនបោកប្រាស់ប្រើប្រាស់យុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីកំណត់គោលដៅលើជនរងគ្រោះ?
- តើអ្វីខ្លះជាសញ្ញាព្រមានសំខាន់ៗ ដែលជួយឱ្យអ្នកសម្គាល់ដឹងពីការបោកប្រាស់នេះ?
- តើអ្នកអាចការពារខ្លួនដោយរបៀបណា ដើម្បីកុំឱ្យក្លាយជាជនរងគ្រោះ?

៣. ល្បែងកម្សាន្ត «សម្គាល់សញ្ញាព្រមាន»៖ អនុវត្ត និងរចនាសញ្ញាព្រមានបន្ថែម

សូមប្រើប្រាស់កម្មវិធីទូរសព្ទ SALA MIL រួចចូលទៅកាន់ជំពូកទី៤ មេរៀនទី៤.៣៖ ការគំរាមកំហែងតាមអនឡាញ។

ចូរស្វែងយល់អំពីប្រភេទផ្សេងៗនៃការគំរាមកំហែងតាមអនឡាញ និងសិក្សាពីឧទាហរណ៍ជាក់ស្តែងដើម្បីរៀនសម្គាល់សញ្ញាព្រមាន។ បន្ទាប់មកចូរឆ្លើយសំណួរខ្លី និងកត់ត្រាពិន្ទុដែលលោកអ្នកទទួលបាន។ កិច្ចការបន្ទាប់សូមសាកល្បងបង្កើតឧទាហរណ៍ថ្មីៗចំនួន៣បន្ថែមទៀតអំពីការវាយប្រហារតាមរយៈការលួចបន្លំយកព័ត៌មានសម្ងាត់ ឬការបោកប្រាស់តាមអនឡាញដែលមានរៀបរាប់នៅក្នុងមេរៀននេះ។

៤. ជនចម្លែកតាមប្រព័ន្ធអនឡាញ៖ ឆ្លើយសំណួរ និងការបង្កើតរូបភាពអប់រំដើម្បីសុវត្ថិភាព និងការសម្គាល់សញ្ញាព្រមាន

សូមពិចារណាទៅលើសំណួរខាងក្រោម៖

- តើអ្នកធ្លាប់ជជែកកម្សាន្តតាមអនឡាញជាមួយនរណាម្នាក់ដែលអ្នកមិនដែលស្គាល់ពីមុនមកដែរឬទេ?
- តើអ្នកមានទំនុកចិត្តកម្រិតណាថាបុគ្គលដែលនៅពីក្រោយគណនីនោះគឺជាមនុស្សពិតប្រាកដ?
- តើអ្នកធ្លាប់កត់សម្គាល់ឃើញឥរិយាបថគួរឱ្យសង្ស័យណាមួយដែរឬទេ? ប្រសិនបើធ្លាប់តើអ្នកបានធ្វើអ្វីខ្លះក្នុងស្ថានភាពនោះ?

សូមប្រើប្រាស់កម្មវិធី SALA MIL រួចចូលទៅកាន់ជំពូកទី៥ មេរៀនទី៥.១៖ បុគ្គលមិនស្គាល់អត្តសញ្ញាណលើអនឡាញ។ ចូរស្វែងយល់អំពីមូលហេតុដែលយើងចាំបាច់ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ចំពោះជនចម្លែកតាមអនឡាញ និងរបៀបការពារសុវត្ថិភាពខ្លួនឯង។

បន្ទាប់មក ចូរឆ្លើយសំណួរខ្លី និងកត់ត្រាទុកនូវរាល់សញ្ញាព្រមាន ដែលអ្នកបានរកឃើញ។ តើអ្នកទទួលបានពិន្ទុប៉ុន្មាន? បន្ទាប់មកសូមជ្រើសរើសសញ្ញាព្រមាន ដែលមានសារៈសំខាន់បំផុត រួចបង្កើតរូបភាពអប់រំមួយដើម្បីលើកកម្ពស់ការយល់ដឹងនេះ។

សំណួរសម្រាប់ពិភាក្សា

១. តើអ្វីខ្លះជាការឆបោក ការបន្លំយកទិន្នន័យ និងការលួចអត្តសញ្ញាណតាមអនឡាញ?
២. តើការឆបោកតាមអនឡាញប្រភេទណាខ្លះ ដែលជនឆបោកនិយមប្រើប្រាស់ជាងគេ?
៣. ហេតុអ្វីបានជាសព្វថ្ងៃនេះ ការឆបោកតាមអនឡាញ កាន់តែពិបាកទឹងសម្គាល់ជាងមុន?
៤. ហេតុអ្វីបានជាយុវជនតែងតែក្លាយជាគោលដៅរបស់ជនឆបោក?
៥. តើអ្នកអាចនឹងប្រឈមមុខនឹងផលវិបាកធ្ងន់ធ្ងរអ្វីខ្លះ ប្រសិនបើអ្នកក្លាយជាជនរងគ្រោះ?
៦. តើអ្នកអាចសម្គាល់ការគំរាមតាមអនឡាញ និងការពារខ្លួនដោយរបៀបណា?
៧. តើអ្នកគួរធ្វើដូចម្តេច ប្រសិនបើអ្នកទទួលបានសារដែលគួរឱ្យសង្ស័យ?
៨. តើមានជំហានដំបូងអ្វីខ្លះដែលអ្នកគួរធ្វើ ប្រសិនបើអ្នកដឹងខ្លួនថាត្រូវបានគេឆបោក?

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

មេរៀនទី ៣

ការបង្កើនសុវត្ថិភាពគណនី



មេរៀនទី៤.២



ជំពូកទី៥

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពី៖

ក. យុទ្ធសាស្ត្រការពារសុវត្ថិភាពឌីជីថល

ខ. របៀបសម្គាល់ការលួចចូលគណនី

គ. ការបណ្តុះទម្លាប់ការពារសុវត្ថិភាព

ហេតុអ្វីបានជាមេរៀននេះសំខាន់?

សុវត្ថិភាពគណនីរឹងមាំការពារកុំឱ្យអ្នកវាយប្រហារតាមអនឡាញ ឬហៅថា ក្រុម Hacker ពីការចូលទៅមើលសារឯកជន ព័ត៌មានផ្ទាល់ខ្លួន និងហិរញ្ញវត្ថុ របស់អ្នក។ មេរៀននេះបង្រៀន ពីជំហានដែលអាចអនុវត្តបានសម្រាប់ការការពារ ប្រព័ន្ធផ្សព្វផ្សាយសង្គម អ៊ីមែល និងអត្តសញ្ញាណឌីជីថល។

ក. យុទ្ធសាស្ត្រការពារសុវត្ថិភាពឌីជីថល

នៅពេលដែលក្រុម Hacker ចូលលួចគណនីរបស់អ្នកពួកគេនឹងស្វែងរកអ្វីដែលមានតម្លៃដូចជារូបថតផ្ទាល់ខ្លួនដើម្បីគំរាមកំហែង ឬព័ត៌មានធនាគារដើម្បីលួចលុយជាដើម។ នៅក្នុងប្រទេសកម្ពុជាការទូទាត់តាមប្រព័ន្ធធនាគារឌីជីថលកំពុងតែពេញនិយមយ៉ាងខ្លាំង ដូច្នេះសុវត្ថិភាពគណនីមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសុវត្ថិភាពហិរញ្ញវត្ថុរបស់អ្នក។

នៅពេលដែលគណនីរបស់អ្នកត្រូវបានគេលួចចូល ជនខិលខូចអាចលួចលុយរបស់អ្នកបង្ហោះមាតិកាមិនសមរម្យដើម្បីបំផ្លាញកេរ្តិ៍ឈ្មោះរបស់អ្នក ឬប្រើគណនីរបស់អ្នកដើម្បីបោកប្រាស់មិត្តភក្តិ និងក្រុមគ្រួសាររបស់អ្នក។



រូបភាព ៣.១ យុទ្ធសាស្ត្រការពារសុវត្ថិភាពឌីជីថល

ការផ្ទៀងផ្ទាត់ពីរកត្តា

ការផ្ទៀងផ្ទាត់ពីរកត្តាគឺប្រៀបដូចជាការបន្ថែមសោសុវត្ថិភាពមួយជាន់ទៀតទៅលើគណនីរបស់អ្នកដូច្នេះដែរ។ ទោះបីជាមានគេលួចបានពាក្យសម្ងាត់របស់អ្នកក៏ដោយ ក៏ពួកគេនៅតែត្រូវការកូដសម្ងាត់ពីទូរសព្ទរបស់អ្នកទើបអាចចូលប្រើប្រាស់គណនីនោះបាន។ វាប្រៀបបានទៅនឹងការមានទាំងកូនសោនិងលេខកូដសុវត្ថិភាពដើម្បីបើកទ្វារផ្ទះរបស់អ្នកដែរ។ វាអាចមើលទៅហាក់ដូចជាកិច្ចការច្រើនបន្តិចដោយសារតែត្រូវការឆ្លងកាត់ពីរជំហាននៅពេលចូលប្រើគណនី ប៉ុន្តែការចំណាយពេលបន្តិចបន្តួចនេះពិតជាមានតម្លៃណាស់សម្រាប់ការការពារសុវត្ថិភាពបន្ថែម។

របៀបដំណើរការ៖

១. បញ្ចូលឈ្មោះគណនី និងពាក្យសម្ងាត់របស់អ្នក
២. ទទួលកូដដែលបានផ្ញើទៅកាន់ទូរសព្ទរបស់អ្នក
៣. បញ្ចូលកូដនោះជាការស្រេចដើម្បីចូលប្រើប្រាស់

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ការប្រើត្រឹមតែពាក្យសម្ងាត់ គឺមិនទាន់គ្រប់គ្រាន់ទេ។ ក្រុម Hacker អាចលួច ឬទាយពាក្យសម្ងាត់បាន ប៉ុន្តែពួកគេមិនអាចលួចទូរសព្ទរបស់អ្នកបានងាយៗនោះទេ។ អ្នកអាចដំឡើងការផ្ទៀងផ្ទាត់ពីរកត្តានៅលើបណ្តាញសង្គម ដែលកំពុងប្រើច្រើននៅកម្ពុជា។

ការអនុវត្តល្អបំផុតសម្រាប់ពាក្យសម្ងាត់

- **គន្លឹះបង្កើតពាក្យសម្ងាត់រឹងមាំ**
  - យ៉ាងហោចណាស់មាន ១២តួអក្សរ
  - ប្រើលាយគ្នារវាងអក្សរធំ អក្សរតូច លេខ និងនិមិត្តសញ្ញា
  - ឧទាហរណ៍៖ “KhmerPride2025!@” ឬ “AngkorWat#Sunrise7”
  - កុំប្រើពាក្យសម្ងាត់ដូចគ្នាសម្រាប់គណនីច្រើនផ្សេងគ្នា

- **ហេតុអ្វីបានជាពាក្យសម្ងាត់ផ្សេងគ្នាមានសារៈសំខាន់?**

ប្រសិនបើ Hacker លួចបានពាក្យសម្ងាត់មួយពួកគេនឹងមិនអាចចូលប្រើគណនីផ្សេងទៀតរបស់អ្នកបានទេ កាលណាអ្នកប្រើពាក្យសម្ងាត់ផ្សេងៗគ្នាសម្រាប់គណនីនីមួយៗ។ នេះពិតជាសំខាន់ខ្លាំងណាស់សម្រាប់គណនីធនាគារ និងអ៊ីមែល។

- **ការកំណត់សុវត្ថិភាពទូរសព្ទដៃ៖**
  - ប្រើការចាក់សោអេក្រង់ (លេខកូដ PIN ពាក្យសម្ងាត់ ឬស្កេនក្រយៅដៃ)
  - ធ្វើបច្ចុប្បន្នភាពទូរសព្ទរបស់អ្នកជានិច្ច
  - ដំឡើងកម្មវិធីដែលមានប្រភពច្បាស់លាស់តែប៉ុណ្ណោះ
  - បិទការតភ្ជាប់ដោយស្វ័យប្រវត្តិជាមួយ Wi-Fi ដែលមិនស្គាល់ប្រភព។

ខ. របៀបសម្គាល់ការលួចចូលគណនី

សញ្ញាព្រមានអំពីការបន្លំដើម្បីលួចទិន្នន័យ

- អ៊ីមែល ដែលអះអាងថាគណនីមានបញ្ហាបន្ទាន់
- ទំព័រចូលប្រើក្លែងក្លាយដែលមានអាសយដ្ឋានវេបសាយខុសប្រក្រតី
- សារដែលសុំពាក្យសម្ងាត់ ឬកូដសម្ងាត់
- ការព្រមានអំពីការផ្អាកគណនី ដែលមិនទឹកស្មានដល់

គន្លឹះការពារ

- វាយអាសយដ្ឋានវេបសាយ ចូលទៅក្នុងកម្មវិធីរុករករបស់អ្នក
- កុំផ្តល់កូដនៃ ការផ្ទៀងផ្ទាត់ពីរកត្តា ទៅឱ្យនរណាឱ្យសោះ
- ក្រុមហ៊ុនពិតប្រាកដមិនដែលសុំពាក្យសម្ងាត់តាមទូរសព្ទទេ

គ. ការបណ្តុះទម្លាប់ការពារសុវត្ថិភាព

សុវត្ថិភាពល្អមិនមែនជាអ្វីដែលអ្នកធ្វើតែម្តងហើយបំភ្លេចចោលនោះទេ។ ដូចគ្នានឹងការដុសធ្មេញ ឬការចាក់សោទ្វារផ្ទះដែរ ការការពារគណនីរបស់អ្នកត្រូវតែក្លាយជាទម្លាប់ជាប្រចាំដើម្បីមានប្រសិទ្ធភាព។ គំនិតដ៏ល្អ គឺគួរធ្វើការត្រួតពិនិត្យប្រចាំខែ៖

- ពិនិត្យមើលឧបករណ៍ដែលកំពុងចូលប្រើលើគណនីសំខាន់ៗ
- លុបការចូលប្រើសម្រាប់ឧបករណ៍ចាស់ៗ
- ធ្វើបច្ចុប្បន្នភាពពាក្យសម្ងាត់សំខាន់ៗ
- ពិនិត្យមើលសកម្មភាពគួរឱ្យសង្ស័យ
- លុបកម្មវិធីទូរសព្ទដែលអ្នកលែងប្រើ

វិធានការសុវត្ថិភាពសំខាន់ៗ៖

១. ប្រើពាក្យសម្ងាត់ដែលរឹងមាំ និងមិនជាន់គ្នាសម្រាប់គណនីសំខាន់ៗ
២. បើកដំណើរការ ការផ្ទៀងផ្ទាត់ពីរកត្តាគ្រប់ទីកន្លែង នេះជាការការពារដ៏ល្អបំផុតរបស់អ្នក
៣. ធ្វើបច្ចុប្បន្នភាពកម្មវិធីដើម្បីជួសជុលបញ្ហាសុវត្ថិភាព
៤. ត្រូវមានការសង្ស័យចំពោះសារប្លែកៗ ដែលសុំព័ត៌មានចូលប្រើគណនី
៥. ពិនិត្យមើលសកម្មភាពគណនីឱ្យបានទៀងទាត់
៦. ជឿជាក់លើវិចារណញ្ញាណរបស់អ្នក ប្រសិនបើមានអារម្មណ៍ថាមានអ្វីខុសប្រក្រតីត្រូវស្រាវជ្រាវភ្លាម

មេរៀនសង្ខេប

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីចំណុចសំខាន់ៗដូចខាងក្រោម៖

- សុវត្ថិភាពគណនី ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះ Hacker តែងតែកំណត់គោលដៅលើរូបចតផ្ទាល់ខ្លួន ដើម្បីធ្វើការគំរាមកំហែង និងលួចព័ត៌មានធនាគារដើម្បីលួចប្រាក់។
- ការផ្ទៀងផ្ទាត់ពីរកត្តា បន្ថែមសោសុវត្ថិភាពមួយជាន់ទៀតទៅលើគណនីរបស់អ្នក ដោយតម្រូវឱ្យមានទាំងពាក្យសម្ងាត់ និងកូដសម្ងាត់ពីទូរសព្ទរបស់អ្នក ទើបអាចចូលប្រើប្រាស់បាន។
- ការការពារបណ្តាញផ្សព្វផ្សាយសង្គម តម្រូវឱ្យមានការបើកដំណើរការផ្ទៀងផ្ទាត់ពីរកត្តានៅលើ Facebook និង TikTok ការកំណត់ការបង្ហោះជាមួយតែសម្រាប់តែមិត្តភក្តិ ការកំណត់ ថានរណាខ្លះអាចស្វែងរកអ្នកបានតាមរយៈលេខទូរសព្ទ និងការបិទសេវាកម្មទីតាំង។
- សុវត្ថិភាពអ៊ីមែល គឺសំខាន់បំផុតព្រោះគណនីអ៊ីមែលអាចប្រើដើម្បីកំណត់ពាក្យសម្ងាត់ឡើងវិញសម្រាប់គណនីផ្សេងៗទៀតបាន។ ត្រូវបើកដំណើរការពីកត្តានៅលើ អ៊ីមែល និង Telegram ព្រមទាំងប្រើពាក្យសម្ងាត់ដែលរឹងមាំ និងមិនជាន់គ្នា។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

- ពាក្យសម្ងាត់ដែលរឹងមាំ គួរតែមានប្រវែងយ៉ាងតិច ១២តួអក្សរដោយលាយបញ្ចូលគ្នារវាងអក្សរធំ អក្សរតូច លេខ និងនិមិត្តសញ្ញា ហើយត្រូវតែខុសៗគ្នាសម្រាប់គណនីនីមួយៗ។ ហាមដាច់ខាតការប្រើប្រាស់ពាក្យសម្ងាត់ដូចគ្នាសម្រាប់គណនីច្រើន ជាពិសេសសម្រាប់គណនីធនាគារ និងអ៊ីមែល។
- សន្តិសុខឧបករណ៍ចល័ត ទាមទារឱ្យមានការប្រើប្រាស់ការចាក់សោអេក្រង់ ការធ្វើបច្ចុប្បន្នភាពទូរសព្ទជាប្រចាំការដំឡើងកម្មវិធីតែពីប្រភពផ្លូវការប៉ុណ្ណោះ និងការបិទការតភ្ជាប់ដោយស្វ័យប្រវត្តិទៅកាន់បណ្តាញ Wi-Fi ដែលមិនស្គាល់។
- ការសម្គាល់ការលួចចូលគណនី រួមមានការសង្កេតមើលសញ្ញាព្រមាននៃការបញ្ឆោតដូចជាអ៊ីមែលដែលប្រាប់ថាគណនីមានបញ្ហាបន្ទាន់ទំព័រចូលប្រើក្លែងក្លាយ និងសារដែលស្នើសុំពាក្យសម្ងាត់ ឬកូដ។
- ប្រសិនបើគណនីអ្នកត្រូវគេលួចចូល សូមដូរពាក្យសម្ងាត់ភ្លាមដាក់ដំណើរការផ្ទៀងផ្ទាត់ពីរកត្តា ពិនិត្យមើលគណនីផ្សេងទៀត ព្រមានមិត្តភក្តិឱ្យបានដឹងហើយរាយការណ៍អំពីសកម្មភាពគ្មានការអនុញ្ញាតទាំងនោះ។

សទ្ទានុក្រម

- **ពាក្យសម្ងាត់៖** ជាបណ្តុំតួអក្សរសម្ងាត់ ដែលប្រើសម្រាប់ការពារគណនី។
- **ការផ្ទៀងផ្ទាត់ពីរកត្តា៖** វិធីសាស្ត្រសុវត្ថិភាពដែលតម្រូវឱ្យបញ្ចូលកូដទីពីរ (ជាធម្មតាផ្ញើទៅទូរសព្ទរបស់អ្នក) មុនពេលអ្នកអាចចូលប្រើវេបសាយមួយ។
- **គណនីដែលត្រូវបានគេលួចចូល៖** គណនីដែលត្រូវបានគេលួចចូលប្រើដោយគ្មានការអនុញ្ញាត។
- **ទម្លាប់សុវត្ថិភាព៖** ទង្វើទៀងទាត់ដែលរក្សាសុវត្ថិភាពគណនី។

លំហាត់អនុវត្តន៍

១. ការការពារសុវត្ថិភាពគណនី៖ ការកំណត់មុខងារសុវត្ថិភាព

សូមជ្រើសរើសគណនីអនឡាញមួយដែលអ្នកប្រើប្រាស់ញឹកញាប់ដូចជា Facebook TikTok ឬ Telegram។ បន្ទាប់មកចូលទៅកាន់ការកំណត់ រួចស្វែងរកផ្នែកសុវត្ថិភាព។ បើកដំណើរការមុខងារផ្ទៀងផ្ទាត់ពីរកត្តា៖ សូមអនុវត្តតាមការណែនាំដើម្បីភ្ជាប់គណនីជាមួយលេខទូរសព្ទ ឬកម្មវិធីផ្ទៀងផ្ទាត់ពិនិត្យឡើងវិញនូវការកំណត់ឯកជនភាព៖

- កំណត់អ្នកដែលអាចមើលឃើញការបង្ហោះរបស់អ្នក
- បិទមុខងារចែករំលែកទីតាំង ប្រសិនបើអាចធ្វើទៅបាន។
- បិទមុខងារសម្គាល់ផ្ទៃមុខ ប្រសិនបើអាចធ្វើទៅបាន។
- កំណត់អ្នកដែលអាចស្វែងរកអ្នកតាមលេខទូរសព្ទ ឬអ៊ីមែល

២. ការបង្កើតលេខសម្ងាត់រឹងមាំ និងមានសុវត្ថិភាព៖

សូមត្រួតពិនិត្យមើលលេខសម្ងាត់ដែលអ្នកកំពុងប្រើប្រាស់សម្រាប់ការពារគណនីណាមួយ ដើម្បីដឹងថាវាមានសុវត្ថិភាពកម្រិតណា៖

- តើវាមានយ៉ាងហោចណាស់ ១២ តួអក្សរដែរឬទេ? ( ) បាទ/ចាស ( ) ទេ
- តើអ្នកមានប្រើលាយគ្នារវាងអក្សរធំនិងអក្សរតូចដែរឬទេ? ( ) បាទ/ចាស ( ) ទេ
- តើវាមានលេខដែរឬទេ? ( ) បាទ/ចាស ( ) ទេ
- តើវាមាននិមិត្តសញ្ញា (ដូចជា @, #, $, % ...) ដែរឬទេ? ( ) បាទ/ចាស ( ) ទេ

ប្រសិនបើអ្នកមានចម្លើយថា «ទេ» សូម្បីតែមួយចំណុច សូមបង្កើតលេខសម្ងាត់ថ្មីសម្រាប់គណនីនេះឱ្យមានសុវត្ថិភាពជាងមុន។ អ្នកក៏អាចបង្កើតពាក្យគន្លឹះ ដើម្បីជួយឱ្យអ្នកចងចាំវាផងដែរ ឧទាហរណ៍៖ មុខវិជ្ជាដែលខ្ញុំចូលចិត្តបំផុតទាំង៣គឺ៖ គណិតវិទ្យា ភាសាខ្មែរ និងបច្ចេកវិទ្យា អាចបំប្លែងជាលេខសម្ងាត់៖ Mk3ict:KKMM! ។

ការឆ្លុះបញ្ចាំង៖ តើហេតុអ្វីបានជាលេខសម្ងាត់ថ្មីនេះរឹងមាំ និងមានសុវត្ថិភាពជាងលេខសម្ងាត់ចាស់របស់អ្នក?

លំហាត់អនុវត្តន៍ជាមួយឧបករណ៍ | **កម្មវិធី SALA MIL | ជំពូកទី៤៖ សុវត្ថិភាព និងឯកជនភាពលើអ៊ីនធឺណិត**

៣. ឆ្លើយសំណួរខ្លី «បញ្ជីត្រួតពិនិត្យឯកជនភាពទិន្នន័យ»៖ ការការពារឧបករណ៍ឌីជីថល និងគណនីរបស់អ្នក

សូមប្រើប្រាស់កម្មវិធីទូរសព្ទ SALA MIL រួចចូលទៅកាន់ជំពូកទី៤ មេរៀនទី៤.២៖ ការបង្កើនសុវត្ថិភាពគណនី។ ចូរសាកល្បងវាស់ស្ទង់មើលថា តើអ្នកមានសុវត្ថិភាពកម្រិតណានៅក្នុងពិភពឌីជីថល។ សូមឆ្លើយដោយស្មោះត្រង់៖

- តើអ្នកទទួលបានពិន្ទុប៉ុន្មាន?
- តើអ្នកអាចកែលម្អសុវត្ថិភាពរបស់អ្នកឱ្យកាន់តែប្រសើរជាងនេះបានដែរឬទេ?

សូមសរសេររៀបរាប់អំពីចំណុចដែលអ្នកនឹងផ្លាស់ប្តូរ ដើម្បីបង្កើនសុវត្ថិភាពឌីជីថលរបស់អ្នក និងកំណត់ថាតើអ្នកនឹងពិនិត្យមើលការកំណត់ទាំងនេះឡើងវិញញឹកញាប់កម្រិតណា។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

៤. ការពន្យល់អំពីសុវត្ថិភាពអនឡាញ៖ ផលិតវីដេអូអប់រំខ្លី

សូមប្រើប្រាស់កម្មវិធីទូរសព្ទ MIL Chatbot រួចចូលទៅកាន់ជំពូកទី៥៖ សុវត្ថិភាព និងឯកជនភាព លើបណ្តាញអ៊ីនធឺណិត។ ចូរស្វែងយល់លើប្រធានបទផ្សេងៗដូចជា ពាក្យសម្ងាត់ការផ្ទៀងផ្ទាត់ពីរកត្តា និងសុវត្ថិភាពទូរសព្ទ រួចកត់ត្រាចំណុចសំខាន់ៗទុក។

បន្ទាប់មកសូមសន្មតថា អ្នកចង់ជួយយុវជនដទៃទៀតឱ្យចេះការពារសុវត្ថិភាពរបស់ពួកគេនៅលើប្រព័ន្ធអនឡាញ។ ចូរសាកល្បងបកស្រាយគោលការណ៍ទាំងនោះ ដោយប្រើប្រាស់ពាក្យពេចន៍សាមញ្ញ ព្រមទាំងលើកយកឧទាហរណ៍ជាក់ស្តែងក្នុងជីវិតរស់នៅប្រចាំថ្ងៃដើម្បីឱ្យងាយយល់។ នៅពេលដែលអ្នកត្រៀមខ្លួនរួចរាល់ សូមពឹងនរណាម្នាក់ឱ្យជួយថតវីដេអូពន្យល់ខ្លីនេះឱ្យអ្នក។

គន្លឹះសម្រាប់ការថតវីដេអូ៖

- ជ្រើសរើសទីកន្លែងស្ងប់ស្ងាត់៖ ដើម្បីចៀសវាងការរំខានដោយសំឡេងពីខាងក្រៅ។
- ថតឱ្យនៅជិតកាមេរ៉ា៖ ដើម្បីឱ្យអ្នកទស្សនាមើលឃើញទឹកមុខ និងកាយវិការរបស់អ្នកបានច្បាស់។
- សាកល្បងសម្លេងមុនពេលថត៖ ត្រូវប្រាកដថាសម្លេងរបស់អ្នកឮច្បាស់ល្អ។
- ប្រើប្រាស់កាយវិការ៖ ប្រើប្រាស់ដៃ និងទឹកមុខ ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់អ្នកទស្សនា។

សំណួរសំរាប់ពិភាក្សា

១. ហេតុអ្វីបានជាសុវត្ថិភាពគណនីមានសារៈសំខាន់?
២. តើព័ត៌មានផ្ទាល់ខ្លួនប្រភេទណាខ្លះ ដែល Hacker កំណត់ជាគោលដៅ?
៣. តើការផ្ទៀងផ្ទាត់ពីរកត្តាគឺជាអ្វី?
៤. តើពាក្យសម្ងាត់ដែលរឹងមាំ និងមានសុវត្ថិភាពមានលក្ខណៈសម្បត្តិសំខាន់ៗអ្វីខ្លះ?
៥. ហេតុអ្វីបានជាអ្នកគួរប្រើប្រាស់ពាក្យសម្ងាត់ខុសៗគ្នា សម្រាប់គណនីផ្សេងគ្នា?
៦. តើអ្នកអាចធ្វើឱ្យទូរសព្ទដៃរបស់អ្នក កាន់តែមានសុវត្ថិភាពដោយរបៀបណា?
៧. តើអ្នកអាចការពារខ្លួនអ្នកពីការបោកបញ្ឆោត បានដោយរបៀបណា?
៨. តើទម្លាប់ជាប្រចាំអ្វីខ្លះ ដែលអ្នកគួរធ្វើ ដើម្បីរក្សាសុវត្ថិភាពឌីជីថលឱ្យបានល្អ?

មេរៀនទី ៤

ការបង្កទុក្ខបុកម្នេញតាមអនឡាញ និងសម្តីស្អប់ខ្ពើម



មេរៀនទី៣.៣



ជំពូកទី៥

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីៈ

ក. ការបង្កទុក្ខបុកម្នេញតាមអនឡាញ និងសម្តីស្អប់ខ្ពើម

ខ. ការបង្កទុក្ខបុកម្នេញតាមអនឡាញ និងសម្តីស្អប់ខ្ពើមប៉ះពាល់លើមនុស្ស

គ. យុទ្ធសាស្ត្របង្ការ និងការពារ

ឃ. ការស្វែងរកជំនួយ និងការគាំទ្រ

ហេតុអ្វីបានជាមេរៀននេះសំខាន់?

ការបង្កទុក្ខបុកម្នេញតាមអ៊ីនធឺណិត គឺជាការយាយីតាមអនឡាញ ដែលអាចប៉ះពាល់ដល់សុខភាពផ្លូវចិត្តរបស់មនុស្ស និងបំផ្លាញទំនាក់ទំនងទាំងនៅក្នុងសាលារៀននិងសហគមន៍។ ការយល់ដឹងអំពីរបៀបការពារ រាយការណ៍ និងឆ្លើយតបចំពោះអាកប្បកិរិយា ដែលបង្កគ្រោះថ្នាក់ធ្វើឱ្យអ្នកប្រើប្រាស់ឧបករណ៍ឌីជីថលឱ្យកាន់តែមានសុវត្ថិភាព និងរីករាយជាងមុន។

ក. ការបង្កទុក្ខបុកម្នេញតាមអនឡាញ និងសម្តីស្អប់ខ្ពើម

- **តើអ្វីទៅជាការបង្កទុក្ខបុកម្នេញតាមអនឡាញ?**

ការបង្កទុក្ខបុកម្នេញតាមអនឡាញគឺជាការធ្វើបាបដែលកើតឡើងតាមរយៈឧបករណ៍ឌីជីថល ដូចជា ទូរសព្ទ កុំព្យូទ័រ ឬថាប្លេត ។ វាកើតឡើងនៅលើបណ្តាញផ្សព្វផ្សាយសង្គម សារអក្សរ អ៊ីមែល វេទិកាហ្គេម និងកម្មវិធីផ្ញើសារផ្សេងៗ។ ការបង្កទុក្ខបុកម្នេញតាមអនឡាញអាចកើតមានឡើងនៅគ្រប់ទីកន្លែងសូម្បីក្នុងផ្ទះរបស់អ្នកផ្ទាល់ក៏អាចកើតឡើងដែរ។

ទម្រង់នៃការបង្កទុក្ខបុកម្នេញតាមអនឡាញដែលកើតមានជាញឹកញាប់រួមមាន៖

- ការធ្វើសារច្រើនលើកច្រើនសា ដែលមានលក្ខណៈមើលងាយ គំរាមកំហែង ឬធ្វើឱ្យអាម៉ាស់មុខ
- ការចែករំលែករូបថត ឬព័ត៌មានឯកជនដោយគ្មានការអនុញ្ញាត
- ការបង្កើតគណនីក្លែងក្លាយ ដើម្បីបន្លំខ្លួន ឬយាយីនរណាម្នាក់
- ការផ្សព្វផ្សាយពាក្យចចាមអារ៉ាម ឬរឿងមិនពិតនៅលើអ៊ីនធឺណិត
- ការដកនរណាម្នាក់ចេញពីក្រុមអនឡាញដោយចេតនាមិនឱ្យចូលរួម
- ការគំរាមកំហែងប្រើអំពើហិង្សា ឬការធ្វើបាបខ្លួន

- **តើអ្វីទៅជាសម្តីស្អប់ខ្ពើម?**

សម្តីស្អប់ខ្ពើម គឺជាការប្រើប្រាស់ពាក្យសម្តី អត្ថបទ រូបភាព ឬកាយវិការ ដែលវាយប្រហារ គំរាមកំហែង ប្រមាថ ឬបន្ទាបបន្ថោកបុគ្គល ឬក្រុមណាមួយដោយផ្អែកលើអត្តសញ្ញាណរបស់ពួកគេ។ ទាំងនោះរួមមាន ពូជសាសន៍ សាសនា ពណ៌សម្បុរ អត្តសញ្ញាណយេនឌ័រ ផ្លូវភេទ ពិការភាព និងឋានៈសង្គមជាដើម។ សម្តីស្អប់ខ្ពើមតាមអនឡាញបានក្លាយជារឿងសាមញ្ញ ព្រោះវាអាចត្រូវបានចែករំលែកយ៉ាងងាយស្រួល ហើយជួនកាលដោយមិនបញ្ចេញឈ្មោះ ដែលអាចទៅដល់មនុស្សជាច្រើនយ៉ាងឆាប់រហ័ស។



រូបភាព ៤.១ ការពារការបង្កទុក្ខបុកម្នេញតាមអនឡាញ

ខ. ការបង្កទុក្ខបុកម្នេញតាមអនឡាញ និងសម្តីស្អប់ខ្ពើមប៉ះពាល់លើមនុស្ស

- **ផលប៉ះពាល់ភ្លាមៗ**

ផលប៉ះពាល់ពីការបៀតបៀនតាមអនឡាញលើសពីការធ្វើឱ្យមានអារម្មណ៍តូចចិត្តទៅទៀត។ នៅពេលមានការបង្កទុក្ខបុកម្នេញកើតឡើងតាមអនឡាញ វាអាចធ្វើឱ្យមានអារម្មណ៍ថាអ្នកកំពុងត្រូវបានគេវាយប្រហារគ្រប់ទីកន្លែង សូម្បីតែនៅក្នុងផ្ទះរបស់អ្នកផ្ទាល់ទៀតផង។ វាហាក់ដូចជាគ្មានកន្លែងគេចខ្លួនឡើយ។ ឥទ្ធិពលរបស់វាអាចមានរយៈពេលយូរ ហើយប៉ះទង្គិចទៅលើមនុស្សម្នាក់តាមវិធីជាច្រើនយ៉ាងដូចជា៖

- ផ្លូវចិត្ត៖ មានអារម្មណ៍តូចចិត្ត អាម៉ាស់ ល្ងង់ខ្លៅ ឬខឹងសម្បារ។
- ផ្លូវអារម្មណ៍៖ មានអារម្មណ៍ខ្មាសអៀន ឬបាត់បង់ចំណាប់អារម្មណ៍លើអ្វីដែលអ្នកស្រលាញ់។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

- រាងកាយ៖ អស់កម្លាំង គេងមិនលក់ ឬជួបប្រទះរោគសញ្ញាដូចជាឈឺពោះ និងឈឺក្បាល។

- **ជីវិតសិក្សា និងជីវិតផ្ទាល់ខ្លួន**
  - លទ្ធផលនៃការសិក្សាធ្លាក់ចុះ
  - គេចសាលាដើម្បីចៀសវាងជនបង្កទុក្ខបុកម្នេញ
  - ការបាត់បង់ចំណាប់អារម្មណ៍លើចំណូលចិត្ត និងសកម្មភាពនានា
  - ការដកខ្លួនចេញពីមិត្តភក្តិ និងក្រុមគ្រួសារ

- **ការសាយភាយរូបភាពស្និទ្ធស្នាល ឬអាសអាភាស**

Sexting គឺជាការចែករំលែកដោយចេតនានូវសារឆ្លើយឆ្លង រូបភាព ឬវីដេអូអាសអាភាសទៅកាន់គ្នាទៅវិញទៅមក។ សកម្មភាពនេះច្រើនតែធ្វើឡើងដោយមានការព្រមព្រៀងគ្នា។ ការផ្ញើរូបភាព ឬវីដេអូស្និទ្ធស្នាលបានក្លាយជារឿងសាមញ្ញក្នុងចំណោមយុវវ័យ និងគូស្នេហ៍នៅក្នុងសង្គមជាច្រើន ប៉ុន្តែសកម្មភាពនេះក៏បង្កជាហានិភ័យដ៏ធ្ងន់ធ្ងរផងដែរ។ នៅពេលនរណាម្នាក់ទម្លាយសារឆ្លើយឆ្លង រូបភាព ឬវីដេអូស្និទ្ធស្នាលទាំងនោះទៅកាន់ក្រុមជជែក ឬទៅលើបណ្តាញសង្គមជាសាធារណៈ ទំហំនៃការខូចខាតគឺមិនអាចប៉ាន់ស្មានបានឡើយ។ បុគ្គលដែលមានវត្តមានក្នុងរូបថត ឬវីដេអូទាំងនោះ នឹងមានអារម្មណ៍ថារងការរំលោភបំពានសិទ្ធិឯកជន និងទទួលរងភាពអាម៉ាស់យ៉ាងខ្លាំងដែលអាចនាំឱ្យជនរងគ្រោះប្រឈមនឹងការថប់បារម្ភ ឬជំងឺបាក់ទឹកចិត្ត។

របៀបដែលវាកើតឡើង៖ មនុស្សថតរូប ឬវីដេអូអាសអាភាសរបស់ខ្លួនឯងជាមួយទូរសព្ទដៃ ហើយផ្ញើទៅកាន់ដៃគូស្នេហារបស់ពួកគេ។ ប៉ុន្តែនៅពេលនរណាម្នាក់ផ្ញើសារប្រភេទនេះទៅកាន់អ្នកផ្សេងដោយគ្មានការយល់ព្រមជាមុន ទង្វើនេះអាចត្រូវបានចាត់ទុកថាជាការបំពានលើភាពថ្លៃថ្នូរ។ មនុស្សមួយចំនួនក៏ចែករំលែកមាតិកាមិនល្អរបស់ដៃគូពួកគេដោយគ្មានការអនុញ្ញាតទៅកាន់មិត្តភក្តិ ឬក្រុមរបស់ពួកគេដើម្បីអួតអាង។ មានករណីជាច្រើនដែលមនុស្សម្នាក់ចែករំលែកសារស្និទ្ធស្នាលទាំងនោះ បន្ទាប់ពីទំនាក់ទំនងបានបញ្ចប់ ដោយមានបំណងធ្វើឱ្យប៉ះពាល់ដល់កិត្តិយសអតីតដៃគូរបស់ពួកគេ។

សញ្ញាព្រមាន៖ ប្រសិនបើដៃគូស្នេហា ស្នើសុំរូបភាព ឬវីដេអូអាសអាភាស សូមគិតឱ្យបានហ្មត់ចត់មុននឹងធ្វើ។ ទំនាក់ទំនងអាចនឹងបញ្ចប់ប៉ុន្តែរូបថតនិងវីដេអូ នឹងនៅតែមាននៅលើអ៊ីនធឺណិតជារៀងរហូត។ ប្រសិនបើអ្នកមិនស្គាល់នរណាម្នាក់ច្បាស់លាស់កុំផ្ញើមាតិកាទាំងនោះទៅពួកគេឱ្យសោះ។

- **ការសម្គាល់សញ្ញាព្រមាននៃការបង្កទុក្ខបុកម្នេញតាមអនឡាញ**

សញ្ញាព្រមានដែលបង្ហាញថាអ្នកកំពុងទទួលរងការបង្កទុក្ខបុកម្នេញតាមអនឡាញ៖

- ការទទួលរងនូវសារប្រមាថ សារគំរាមកំហែង ឬសារដែលធ្វើឱ្យអាម៉ាស់មុខជាបន្តបន្ទាប់
- ឃើញការបង្ហោះ រូបភាព ឬវីដេអូអំពីអ្នកនៅលើអ៊ីនធឺណិតដែលធ្វើឱ្យអ្នកមិនស្រួលចិត្ត
- ត្រូវបានដកចេញពីការជជែកជាក្រុម ឬសកម្មភាពអនឡាញ
- ទទួលបានសារមិនល្អពីគណនីដែលមិនស្គាល់ ឬប្រហ្វាលក្លែងក្លាយ
- មាននរណាម្នាក់បន្លំធ្វើជារូបអ្នកនៅលើអ៊ីនធឺណិត

សញ្ញាដែលបង្ហាញថាមិត្តភក្តិណាម្នាក់អាចនឹងកំពុងទទួលរងការបង្កទុក្ខបុកម្នេញតាមអនឡាញ៖

- សុខៗ ស្រាប់តែចៀសវាងការប្រើទូរសព្ទ ឬកុំព្យូទ័ររបស់ពួកគេ
- មើលទៅមានអារម្មណ៍តូចចិត្តបន្ទាប់ពីប្រើឧបករណ៍ ឬបណ្តាញផ្សព្វផ្សាយសង្គម
- ដកខ្លួនចេញពីមិត្តភក្តិ និងសកម្មភាពសង្គម
- មានការប្រែប្រួលអារម្មណ៍ អាកប្បកិរិយា ឬលទ្ធផលសិក្សា
- បាត់បង់ចំណាប់អារម្មណ៍លើបណ្តាញផ្សព្វផ្សាយសង្គមដែលពួកគេធ្លាប់ចូលចិត្ត



រូបភាព ៤.២ ការបង្កទុក្ខបុកម្នេញតាមអនឡាញ

គ. យុទ្ធសាស្ត្របង្ការ និងការពារ

- **ការពារគណនីរបស់អ្នក**
  - ប្រើពាក្យសម្ងាត់រឹងមាំ និងខុសគ្នាសម្រាប់គណនីផ្សេងៗគ្នា
  - បើកដំណើរការមុខងារផ្ទៀងផ្ទាត់ពីរកត្តា
  - ពិនិត្យ និងធ្វើបច្ចុប្បន្នភាពការកំណត់ឯកជនភាពជាប្រចាំ
  - ជ្រើសរើសដោយប្រុងប្រយ័ត្នថានរណាអាចទាក់ទងអ្នក ឬឃើញការបង្ហោះរបស់អ្នក

- **គិតសិន មុនចែករំលែក**
  - ចៀសវាងបង្ហោះព័ត៌មានផ្ទាល់ខ្លួន ដែលគេអាចយកមកវាយប្រហារអ្នក
  - ប្រុងប្រយ័ត្នខ្ពស់ក្នុងការចែករំលែកទីតាំង ឬទម្លាប់ប្រចាំថ្ងៃ
  - ពិចារណាជាមុន ចៀសវាងការបង្ហោះដែលអាចធ្វើឱ្យគេយល់ខុស ឬយកទៅប្រើក្នុងផ្លូវអវិជ្ជមាន
  - ចងចាំថា អ្វីដែលបានបង្ហោះលើអ៊ីនធឺណិតហើយ គឺពិបាកនឹងលុបចោលវិញណាស់

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ការឆ្លើយតបទៅនឹងការបង្កទុក្ខបុកម្នេញតាមអនឡាញ និងសម្តីស្អប់ខ្ពើម

- **រក្សាភស្តុតាង**
  - ថតអេក្រង់នៃសារបៀតបៀន មុនពេលរាយការណ៍ ឬ ប្លុកចោលតែម្តង
  - រក្សាទុកតំណភ្ជាប់ និងកត់ត្រាពេលវេលាកើតហេតុ
  - រក្សាទុកកំណត់ត្រាអំពីឈ្មោះអ្នកប្រើប្រាស់ និងព័ត៌មានគណនី
- **ប្រើប្រាស់ឧបករណ៍ដែលមាននៅលើបណ្តាញផ្សព្វផ្សាយសង្គម**
  - ប្លុកចោលអ្នកប្រើប្រាស់ដែលកំពុងបៀតបៀនអ្នក
  - រាយការណ៍ពីការបៀតបៀនទៅកាន់ក្រុមហ៊ុនបណ្តាញផ្សព្វផ្សាយសង្គម
  - ប្រើការកំណត់ឯកជនភាពដើម្បីកំណត់ថាអ្នកណាខ្លះអាចទាក់ទងអ្នកបាន
- **ស្វែងរកការគាំទ្រ៖** ប្រសិនបើអ្នកគិតថាអ្នកកំពុងទទួលរងការបង្កទុក្ខបុកម្នេញ ជំហានដំបូងគឺត្រូវស្វែងរកជំនួយពីនរណាម្នាក់ដែលអ្នកទុកចិត្ត ដូចជា ឪពុកម្តាយ សមាជិកគ្រួសារជិតស្និទ្ធ ឬមនុស្សពេញវ័យដែលគួរឱ្យទុកចិត្តផ្សេងទៀត។ នៅក្នុងសាលារៀនអ្នកអាចនិយាយជាមួយគ្រូដែលអ្នកចូលចិត្តបាន។
- **កុំសងសឹក៖** ការឆ្លើយតបដោយកំហឹង ឬដោយការបៀតបៀនវិញ ជារឿយៗតែងធ្វើឱ្យស្ថានភាពកាន់តែអាក្រក់ថែមទៀត។ គ្រាន់តែផ្តោតលើការការពារខ្លួនឯងបានហើយ ជាជាងការវាយបកវិញ ហើយទុកឱ្យអាជ្ញាធរ និងក្រុមហ៊ុនបណ្តាញផ្សព្វផ្សាយសង្គមដោះស្រាយផលវិបាកនោះវិញ។
- **ប្រសិនបើអ្នកឃើញការបង្កទុក្ខបុកម្នេញតាមអនឡាញណាមួយ ចូរធ្វើជាអ្នកសង្កេតការណ៍ដ៏សកម្ម**
  - កុំព្រងើយកន្តើយចំពោះការបៀតបៀន នៅពេលអ្នកឃើញវាកំពុងកើតឡើង
  - រាយការណ៍មាតិកាមិនសមរម្យទៅកាន់ក្រុមហ៊ុនបណ្តាញសង្គម
  - ផ្តល់ការគាំទ្រដល់អ្នកដែលត្រូវបានគេបៀតបៀន
  - ហ៊ាននិយាយអំពីរឿងនេះ
- **កុំចូលរួម**
  - កុំចែករំលែក កុំចុចចូលចិត្ត ឬបញ្ចេញមតិលើមាតិកាដែលបៀតបៀនអ្នកដទៃ
  - កុំបញ្ជូនបន្តពាក្យចចាមអារ៉ាម ឬរឿងមិនពិតនៅពេលដែលអ្នកមិនច្បាស់ថាវាជាការពិតកម្រិតណា។
  - បដិសេធចូលរួមក្រុម ដែលមានបំណងវាយប្រហារទៅលើនរណាម្នាក់

ឃ. ការស្វែងរកជំនួយ និងការគាំទ្រ

អ្នកគួរស្វែងរកជំនួយពីមនុស្សពេញវ័យដែលគួរឱ្យទុកចិត្ត ឬអ្នកជំនាញ ប្រសិនបើ៖

- ការបៀតបៀនតាមអនឡាញកំពុងប៉ះពាល់ដល់ជីវិតប្រចាំថ្ងៃ ការសិក្សា ឬទំនាក់ទំនងរបស់អ្នក។
- អ្នកកំពុងជួបប្រទះរោគសញ្ញានៃជំងឺបាក់ទឹកចិត្ត ឬថប់អារម្មណ៍
- អ្នកកំពុងមានគំនិតចង់ធ្វើបាបខ្លួនឯង ឬសម្លាប់ខ្លួន
- ការបៀតបៀនពាក់ព័ន្ធនឹងការគំរាមកំហែងប្រើអំពើហិង្សាលើរាងកាយ
- ស្ថានការណ៍កំពុងកើនខ្លាំងឡើង បើទោះបីជាអ្នកព្យាយាមបញ្ឈប់វាយ៉ាងណាក៏ដោយ

ចំណុចសំខាន់ៗដែលត្រូវចងចាំ

- ការបង្កទុក្ខបុកម្នេញតាមអនឡាញ និងសម្តីស្អប់ខ្ពើម គឺជាបញ្ហាធ្ងន់ធ្ងរ ដែលកំពុងប៉ះពាល់ដល់យុវជនជាច្រើននៅក្នុងប្រទេសកម្ពុជា។
- ផលប៉ះពាល់គឺលើសពីការមានអារម្មណ៍តូចចិត្ត វាអាចប៉ះពាល់ដល់សុខភាពផ្លូវចិត្ត លទ្ធផលសិក្សា និងសុខុមាលភាពយូរអង្វែង។
- ការការពារគណនីរបស់អ្នក ដោយគិតសិនមុនចែករំលែកបន្ត។
- មនុស្សគ្រប់រូបមានតួនាទីក្នុងការបង្កើតបរិយាកាសឌីជីថលដែលមានសុវត្ថិភាពជាងមុន តាមរយៈសកម្មភាពបុគ្គលរបស់ពួកគេ។
- ស្វែងរកការគាំទ្រពីមនុស្សពេញវ័យដែលគួរឱ្យទុកចិត្ត មិត្តភក្តិ ឬអ្នកជំនាញ។
- រក្សាទុករាល់ភស្តុតាងនៃការបៀតបៀន ដើម្បីជួយក្នុងការរាយការណ៍ និងទទួលបានការគាំទ្រ។
- កុំសងសឹក ផ្តោតលើការការពារ និងស្វែងរកជំនួយសមស្របជាជាងការវាយបក។

មេរៀនសង្ខេប

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីចំណុចសំខាន់ៗដូចខាងក្រោម៖

- **ការបង្កទុក្ខបុកម្នេញតាមអនឡាញ** គឺជាការធ្វើបាបតាមរយៈឧបករណ៍ឌីជីថល និងអាចកើតឡើងគ្រប់ទីកន្លែង ដែលរួមបញ្ចូលទាំងការផ្ញើសារមិនល្អ ការចែករំលែករូបថតឯកជន ការបង្កើតគណនីក្លែងក្លាយ និងការផ្សព្វផ្សាយពាក្យចចាមអារ៉ាម។
- **សម្តីស្អប់ខ្ពើម** ជាការប្រើប្រាស់ពាក្យសម្តី អត្ថបទ រូបភាព ឬកាយវិការដែលវាយប្រហារ គំរាមកំហែង ប្រមាថ ឬបន្ទាបបន្ថោកបុគ្គល ឬក្រុមណាមួយដោយផ្អែកលើអត្តសញ្ញាណរបស់ពួកគេ។
- **ផលប៉ះពាល់** រួមមានបញ្ហាផ្លូវចិត្ត ការបាត់បង់ចំណាប់អារម្មណ៍លើអ្វីដែលអ្នកចូលចិត្ត រោគសញ្ញាផ្លូវកាយ និងលទ្ធផលសិក្សាមិនល្អ។
- **យុទ្ធសាស្ត្រការពារ** រួមមានការប្រើពាក្យសម្ងាត់រឹងមាំ ការកំណត់ឯកជនភាព ការប្រុងប្រយ័ត្នចំពោះការទំនាក់ទំនង និងការគិតមុនបង្ហោះព័ត៌មានផ្ទាល់ខ្លួនតាមអ៊ីនធឺណិត។
- **ការឆ្លើយតបទៅនឹងការបៀតបៀន** ការរក្សាទុកភស្តុតាងដូចជា ការកត់ត្រាដោយរូបថតអេក្រង់ ប្លុក ចោល និងរាយការណ៍អំពីអ្នកប្រើប្រាស់ ការស្វែងរកជំនួយពីមនុស្សដែលគួរឱ្យទុកចិត្ត និងការមិនវាយបកវិញ។
- **ការធ្វើជាអ្នកសង្កេតការណ៍សកម្ម** ជាការរាយការណ៍ពីការបៀតបៀន ការការពារជនរងគ្រោះ និងការមិនចូលរួមចែករំលែក ឬចុចចូលចិត្តមាតិកាបៀតបៀន។

ការប្រើប្រាស់បណ្តាញសង្គមដោយសុវត្ថិភាព

- ប្រើការកំណត់ប្រព័ន្ធសុវត្ថិភាពរឹងមាំ និងគិតសិនមុនចែករំលែក។
- ស្វែងរកជំនួយពីមនុស្សដែលគួរឱ្យទុកចិត្តនៅពេលអ្នកជួបបញ្ហា។
- រក្សាភស្តុតាងនៃការបៀតបៀន ប៉ុន្តែកុំវាយបក។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

សទ្ទានុក្រម

- **ការបង្កទុក្ខបុកម្នេញតាមអនឡាញ៖** គឺជាការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដូចជាបណ្តាញសង្គម សារខ្លី ឬអ៊ីនធឺណិត ដើម្បីយាយី គំរាមកំហែង បំភិតបំភ័យ ឬធ្វើឱ្យអ្នកដទៃទទួលរងភាពអាម៉ាស់ដោយចេតនា។
- **សម្តីស្អប់ខ្ពើម៖** គឺជាសារ ឬការបញ្ចេញមតិដែលវាយប្រហារលើបុគ្គលណាម្នាក់ ដោយផ្អែកលើអត្តសញ្ញាណរបស់ពួកគេ ដូចជា ពូជសាសន៍ សាសនា យេនឌ័រ និន្នាការផ្លូវភេទ ឬលក្ខណៈសម្គាល់ផ្ទាល់ខ្លួនផ្សេងៗទៀត។
- **ការបៀតបៀន៖** អាកប្បកិរិយាមិនគួរគប្បីចំពោះមនុស្ស ដែលធ្វើឱ្យពួកគេអាម៉ាស់ រងការគំរាមកំហែង ឬធ្វើឱ្យពួកគេឈឺចាប់។
- **Sexting៖** ការចែករំលែកអត្ថបទ រូបភាព ឬវីដេអូអាសអាភាសដោយចេតនាជាមួយអ្នកដទៃ។

លំហាត់អនុវត្តន៍

១. ការប្រៀបធៀបទំនាក់ទំនងក្នុងជីវិតពិត និងជីវិតនៅលើអនឡាញ៖ ឆ្លុះបញ្ចាំងដើម្បីកែលម្អ

សូមសរសេររៀបរាប់នូវអ្វីដែលអ្នកចង់ឱ្យអ្នកដទៃប្រព្រឹត្តចំពោះអ្នកនៅក្នុងជីវិតពិត។ បន្ទាប់មក សូមសរសេរនូវអ្វីដែលអ្នកចង់ឱ្យគេប្រព្រឹត្តចំពោះអ្នកវិញលើបណ្តាញសង្គម។ ចូរប្រៀបធៀបបញ្ជីទាំងពីរ។ សូមឆ្លុះបញ្ចាំងពីឥរិយាបថនៅលើអនឡាញរបស់អ្នក ដោយឆ្លើយនូវសំណួរខាងក្រោម៖

- តើខ្ញុំបានប្រព្រឹត្តចំពោះអ្នកដទៃនៅលើអនឡាញ ដូចអ្វីដែលខ្ញុំចង់ឱ្យគេប្រព្រឹត្តចំពោះខ្ញុំដែរឬទេ?
- តើខ្ញុំមានបានគិតពិចារណាទេថា សារ ឬការបង្ហោះរបស់ខ្ញុំអាចធ្វើឱ្យអ្នកដទៃមានអារម្មណ៍បែបណា?
- តើខ្ញុំធ្លាប់ប្រតិកម្មតបតនៅលើអនឡាញ ដោយមិនបានគិតពិចារណាឱ្យបានដិតដល់ដែរឬទេ?
- តើខ្ញុំគួរធ្វើដូចម្តេច ដើម្បីកុំធ្វើឱ្យនរណាម្នាក់ឈឺចាប់នៅលើអនឡាញ?
- តើខ្ញុំមានប្រតិកម្មបែបណា នៅពេលឃើញគេកំពុងធ្វើឱ្យនរណាម្នាក់ឈឺចាប់?

សូមពិភាក្សាជាមួយមិត្តភក្តិ ឬសមាជិកគ្រួសារ អំពីអ្វីដែលអ្នកចង់កែលម្អទំនាក់ទំនងតាមអនឡាញរបស់អ្នកឱ្យកាន់តែប្រសើរឡើង។

២. ការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិត និងសម្តីស្អប់ខ្ពើម៖ ការការពារខ្លួនអ្នក និងអ្នកដទៃ

សូមជ្រើសរើសការគំរាមកំហែងតាមអនឡាញណាមួយ ដើម្បីធ្វើការស្វែងយល់។ សូមឆ្លុះបញ្ចាំង

- ហេតុអ្វីបានជាមនុស្សមួយចំនួនចូលចិត្តធ្វើសកម្មភាពអវិជ្ជមានទាំងនេះតាមអនឡាញ?
- តើវាមានផលវិបាកអ្វីខ្លះដល់បុគ្គលដែលជាគោលដៅនៃការវាយប្រហារ?
- តើវាមានផលវិបាកអ្វីខ្លះដល់អ្នកដែលបានឃើញសកម្មភាពទាំងនោះ?
- តើការគំរាមកំហែងទាំងនោះអាចបង្ការបានដែរឬទេ? តាមរបៀបណា?
- តើបុគ្គលដែលរងការវាយប្រហារគួរធ្វើអ្វីខ្លះ ប្រសិនបើវាបានកើតឡើង?
- តើអ្នកដែលបានឃើញហេតុការណ៍គួរធ្វើអ្វីខ្លះ?

៣. រឿងនិទានដាស់តឿនស្មារតី

ចំពោះប្រធានបទដែលអ្នកបានជ្រើសរើសខាងលើ សូមបង្កើតសាច់រឿងខ្លីមួយដែលបញ្ចូលនូវទស្សនៈខុសៗគ្នា រួមមាន អ្នកដែលបង្កផលប៉ះពាល់ អ្នកដែលរងគ្រោះ អ្នកដែលឃើញហេតុការណ៍តែមិនអើពើនិងអ្នកដែលឃើញហេតុការណ៍ហើយហ៊ានចេញមុខជួយ។ សូមរៀបចំសាច់រឿងឱ្យមានចំណុចចាប់ផ្តើម សាច់រឿងសំខាន់ និងចំណុចបញ្ចប់ឱ្យបានច្បាស់លាស់។ អ្នកអាចថតសំឡេងនិទានរឿងនេះដោយប្រើទូរសព្ទដៃ រួចចែករំលែកទៅកាន់មិត្តភក្តិ ឬសមាជិកគ្រួសារ ដើម្បីសុំមតិយោបល់កែលម្អ។

លំហាត់អនុវត្តន៍ជាមួយឧបករណ៍	កម្មវិធី SALA MIL | ជំពូកទី៣៖ ភាពជាពលរដ្ឋឌីជីថល

៤. ការបៀតបៀនតាមអ៊ីនធឺណិត៖ ពីការយល់ដឹងឈានដល់ការក្រោកឈរប្រឆាំង

សូមប្រើប្រាស់កម្មវិធី SALA MIL រួចចូលទៅកាន់ជំពូកទី៣ មេរៀនទី៣.៣៖ ការធ្វើទុក្ខបុកម្នេញតាមអ៊ីនធឺណិត។ សូមទស្សនាវីដេអូ និងឆ្លើយសំណួរខាងក្រោម៖

- តើអ្វីជាភាពខុសគ្នារវាងការលេងសើចអសុរោះ និងការធ្វើទុក្ខបុកម្នេញ?
- តើអ្វីទៅជាការបៀតបៀនតាមប្រព័ន្ធអ៊ីនធឺណិត?
- តើទិដ្ឋភាពណាខ្លះ ដែលធ្វើឱ្យការធ្វើទុក្ខបុកម្នេញនៅលើអនឡាញ មានសភាពធ្ងន់ធ្ងរជាងការធ្វើទុក្ខបុកម្នេញក្នុងជីវិតពិត?
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីប្រឆាំងនឹងការធ្វើទុក្ខបុកម្នេញតាមអនឡាញ? សូមសរសេររៀបរាប់នូវជម្រើសចំនួន៣។
- តើអ្នកនឹងធ្វើអ្វី ប្រសិនបើអ្នកបានឃើញការធ្វើទុក្ខបុកម្នេញតាមអនឡាញកើតឡើង?

សំណួរសម្រាប់ពិភាក្សា

១. តើការបង្កទុក្ខបុកម្នេញតាមអនឡាញគឺជាអ្វី? តើវាខុសពីការបង្កទុក្ខបុកម្នេញផ្ទាល់ដូចម្តេច?
២. តើទម្រង់ទូទៅនៃការបង្កទុក្ខបុកម្នេញតាមអនឡាញមានអ្វីខ្លះ?
៣. តើសម្តីស្អប់ខ្ពើមគឺជាអ្វី? ចូរឱ្យឧទាហរណ៍។
៤. តើការបង្កទុក្ខបុកម្នេញតាមអនឡាញ និងសម្តីស្អប់ខ្ពើមតាមអនឡាញ អាចប៉ះពាល់ដល់បុគ្គលម្នាក់ៗបែបណាខ្លះ?
៥. តើសញ្ញាព្រមានអ្វីខ្លះនៃការបង្កទុក្ខបុកម្នេញតាមអនឡាញ និងការបៀតបៀនតាមអនឡាញ?
៦. តើអ្នកអាចអនុវត្តជំហានអ្វីខ្លះ ដើម្បីការពារខ្លួនអ្នកពីការបង្កទុក្ខបុកម្នេញតាមអនឡាញ?
៧. តើអ្នកគួរឆ្លើយតបយ៉ាងដូចម្តេច បើអ្នកឬមិត្តភក្តិរបស់អ្នករងគ្រោះដោយការបង្កទុក្ខបុកម្នេញតាមអនឡាញ?
៨. តើការធ្វើជាអ្នកសង្កេតការណ៍ដ៏សកម្ម មានន័យយ៉ាងដូចម្តេច?
៩. តើអ្នកគួរស្វែងរកជំនួយ និងការគាំទ្រ នៅពេលណា និងពីនរណា?

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

មេរៀនទី ៥

ជនងាយរងគ្រោះ និង សុវត្ថិភាពលើអនឡាញ



ជំពូកទី៥

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាអំពីៈ

ក. ក្រុមមនុស្សងាយរងគ្រោះ

ខ. ប្រភេទនៃការបៀតបៀនតាមអនឡាញ ដែលដាក់គោលដៅលើក្រុមមនុស្សងាយរងគ្រោះ

គ. យុទ្ធសាស្ត្រការពារសម្រាប់ក្រុមមនុស្សងាយរងគ្រោះ

ឃ. ការគាំទ្រដល់ក្រុមមនុស្សងាយរងគ្រោះតាមអនឡាញ

ហេតុអ្វីបានជាមេរៀននេះសំខាន់?

ក្រុមមនុស្សមួយចំនួនប្រឈមនឹងហានិភ័យខ្ពស់នៅលើអ៊ីនធឺណិត ហើយការសិក្សាអំពីហានិភ័យទាំងនេះជួយការពារពួកគេពីការយាយី ឬការកេងប្រវ័ញ្ញផ្សេងៗ។ មេរៀននេះកសាងការយល់ចិត្ត និងពង្រឹងសុវត្ថិភាពក្នុងសហគមន៍។



រូបភាព ៥.១ ក្រុមមនុស្សងាយរងគ្រោះ

ក. ក្រុមមនុស្សងាយរងគ្រោះ

ក្រុមមនុស្សងាយរងគ្រោះគឺជាក្រុមមនុស្សដែលប្រឈមមុខនឹងហានិភ័យខ្ពស់នៃការរើសអើង ការយាយីអំពើហិង្សាទាំងនៅក្នុងអនឡាញ និងក្នុងជីវិតពិត ដោយសារតែអត្តសញ្ញាណ សារតារ ឬ ចរិតលក្ខណៈរបស់ពួកគេ។ នៅក្នុងអនឡាញក្រុមទាំងនេះតែងតែជាគោលដៅនៃការវាយប្រហារលើសម្តី ស្អប់ខ្ពើម និងទម្រង់ផ្សេងៗនៃការរំលោភបំពានតាមឌីជីថលក្នុងកម្រិតខ្ពស់ជាងប្រជាជនទូទៅ។

ក្រុមមនុស្សងាយរងគ្រោះសំខាន់ៗ រួមមាន៖

- ស្ត្រី និងក្មេងស្រី
- បុគ្គល LGBTQ+
- ជនជាតិភាគតិច និងក្រុមរងការរើសអើងពូជសាសន៍
- ជនជាតិដើមភាគតិច
- ជនមានពិការភាព
- ក្រុមសាសនាភាគតិច។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ក្រុមទាំងនេះតែងតែប្រឈមមុខនឹងការយាយីដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ដែលមានន័យថាមនុស្សដែលស្ថិតនៅក្នុងក្រុមងាយរងគ្រោះច្រើនជាងមួយ (ឧទាហរណ៍៖ ស្ត្រីដែលជាជនជាតិភាគតិចហើយជាអ្នកស្រលាញ់ភេទដូចគ្នា) នឹងជួបប្រទះការរំលោភបំពានតាមអនឡាញក្នុងកម្រិតខ្ពស់ជាងនេះទៅទៀត។

ខ. ប្រភេទនៃការបៀតបៀនតាមអនឡាញដែលដាក់គោលដៅលើក្រុមមនុស្សងាយរងគ្រោះ

អំពើហិង្សាក្នុងអនឡាញផ្អែកលើយេនឌ័រ

- ការបៀតបៀនផ្លូវភេទ និងការផ្ញើសារអាសអាភាស
- ការចែករំលែករូបភាពស្និទ្ធស្នាលដោយគ្មានការអនុញ្ញាត
- ការតាមដាន និងឃ្លាំមើលតាមអនឡាញ
- ការគំរាមកំហែងប្រើអំពើហិង្សាផ្លូវភេទ
- ការប្រើប្រាស់បច្ចេកវិទ្យាដើម្បីគ្រប់គ្រង និងរំលោភបំពាននៅក្នុងទំនាក់ទំនងស្នេហា។

ការបៀតបៀនអត្តសញ្ញាណ

- សម្តីស្អប់ខ្ពើមដែលសំដៅលើពូជសាសន៍ ជាតិសាសន៍ សាសនា ឬនិន្នាការផ្លូវភេទ
- ការចោទសួរ ឬរើសអើងអត្តសញ្ញាណរបស់នរណាម្នាក់
- ការប្រើប្រាស់ពាក្យមើលងាយ និងភាសាបន្ទុះបង្អាប់
- ការគំរាមកំហែងប្រើអំពើហិង្សាដោយផ្អែកលើអត្តសញ្ញាណ
- ការផ្សព្វផ្សាយព័ត៌មានមិនពិតអំពីក្រុមភាគតិច។

អំពើហិង្សាតាមអនឡាញទៅលើក្រុមជនជាតិដើមភាគតិច

សហគមន៍ជនជាតិដើមភាគតិចអាចប្រឈមមុខនឹងការបៀតបៀនតាមអនឡាញ នៅពេលដែលពួកគេនិយាយអំពីវប្បធម៌ ដីធ្លី ឬសិទ្ធិរបស់ពួកគេ។

- **សម្តីស្អប់ខ្ពើម និងការចំអកឡកឡាយ៖** ភាសាប្រពៃណី ឬសម្លៀកបំពាក់របស់ជនជាតិដើមភាគតិចជួនកាលត្រូវបានគេយកមកចំអកនៅក្នុងមតិយោបល់ ឬការបង្ហោះផ្សេងៗ។
- **ព័ត៌មានមិនពិត៖** ពាក្យចចាមអារ៉ាមអាចត្រូវបានគេផ្សព្វផ្សាយតាមអនឡាញ ដើម្បីបង្ខូចកេរ្តិ៍ឈ្មោះជនជាតិដើមភាគតិច ឬសិទ្ធិរបស់ពួកគេលើដីធ្លី និងធនធានធម្មជាតិ។
- **ការផាត់ចេញ និងការបំបិទមាត់៖** នៅពេលដែលយុវជនជនជាតិដើមភាគតិច ចែករំលែកសំឡេងរបស់ពួកគេតាមអនឡាញ ពួកគេអាចនឹងត្រូវបានគេប្រាប់ថា ទស្សនៈរបស់ពួកគេមិនសំខាន់ ឬត្រូវបានគេមើលរំលងតែម្តង។
- **ការវាយប្រហារលើវប្បធម៌៖** ការបង្ហោះដែលមានលក្ខណៈអរិជ្ឈមានអាចតម្រង់គោលដៅលើជំនឿប្រពៃណី ពិធីសាសនា ឬរបៀបរស់នៅដែលធ្វើឱ្យពួកគេមានអារម្មណ៍ខ្មាសអៀនចំពោះអត្តសញ្ញាណរបស់ខ្លួន។

ហេតុអ្វីបានជាក្រុមងាយរងគ្រោះប្រឈមមុខនឹងហានិភ័យខ្ពស់?

- **ការរើសអើងជាប្រវត្តិសាស្ត្រ៖** ក្រុមងាយរងគ្រោះជាច្រើនបានប្រឈមមុខនឹងការរើសអើង និងអំពើហិង្សារាប់សតវត្សមកហើយនៅក្នុងជីវិតពិតដែលបន្តចូលមកក្នុងប្រព័ន្ធអនឡាញ។ វេទិកាឌីជីថលអាចពង្រីកការរើសអើងដែលមានស្រាប់ និងធ្វើឱ្យមនុស្សកាន់តែងាយស្រួលក្នុងការវាយប្រហារលើអ្នកដែលពួកគេចាត់ទុកថា **ខុសពីគេ**។
- **កង្វះការការពារ៖** ក្រុមមនុស្សងាយរងគ្រោះជាច្រើនមិនសូវទទួលបានធនធាន ការការពារផ្លូវច្បាប់ និងប្រព័ន្ធគាំទ្រនៅពេលពួកគេជួបប្រទះការរំលោភបំពានតាមអនឡាញទេ។ ពួកគេមិនសូវហ៊ានរាយការណ៍អំពីការបៀតបៀនទាំងនោះ ដោយសារខ្លាចគេមិនជឿ ឬខ្លាចប្រឈមមុខនឹងការរើសអើងបន្ថែមទៀត។
- **ភាពអនាមិកនិងគម្លាត៖** អ៊ីនធឺណិតអនុញ្ញាតឱ្យជនល្មើសលាក់ខ្លួននៅពីក្រោយគណនីក្លែងក្លាយ ហើយវាយប្រហារមនុស្សដោយមិនប្រឈមមុខនឹងផលវិបាកភ្លាមៗ។

ផលប៉ះពាល់លើសហគមន៍ងាយរងគ្រោះ

- ផលប៉ះពាល់លើសុខភាពផ្លូវចិត្ត៖ ផលប៉ះពាល់ផ្លូវចិត្តលើក្រុមងាយរងគ្រោះជាញឹកញាប់មានសភាពធ្ងន់ធ្ងរជាង ដោយសារការបៀតបៀននោះដាក់គោលដៅលើអត្តសញ្ញាណស្នូលរបស់ពួកគេ។
- ឥទ្ធិពលនៃការមិនហ៊ានបញ្ចេញមតិ៖ ការបៀតបៀនតាមអនឡាញអាចធ្វើឱ្យក្រុមងាយរងគ្រោះមិនហ៊ានចូលរួមយ៉ាងពេញលេញនៅក្នុងប្រព័ន្ធអនឡាញ។ពួកគេអាចចៀសវាងការបញ្ចេញមតិ ការចែករំលែកបទពិសោធន៍ ឬការចូលរួមក្នុងសហគមន៍អនឡាញ ដោយសារតែខ្លាចការរំលោភបំពាន។
- ភាពឯកាក្នុងសង្គម៖ ការបៀតបៀនអាចបង្ខំឱ្យបុគ្គលងាយរងគ្រោះ ដកខ្លួនចេញពីសហគមន៍អនឡាញ ដែលកាត់បន្ថយលទ្ធភាពទទួលបានបណ្តាញគាំទ្រព័ត៌មាន និងឱកាសផ្សេងៗ។

គ. យុទ្ធសាស្ត្រការពារសម្រាប់ក្រុមមនុស្សងាយរងគ្រោះ

បង្កើនវិធានការសុវត្ថិភាព

- ប្រើពាក្យសម្ងាត់រឹងមាំ និងខុសគ្នាសម្រាប់គណនីផ្សេងៗគ្នា
- បើកដំណើរការការផ្ទៀងផ្ទាត់ពីរកត្តា
- ពិនិត្យ និងធ្វើបច្ចុប្បន្នភាពការកំណត់ឯកជនភាពជាប្រចាំ
- ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការចែករំលែកព័ត៌មានផ្ទាល់ខ្លួន
- ពិចារណាប្រើគណនីដាច់ដោយឡែកសម្រាប់គោលបំណងផ្សេងៗគ្នា។

បណ្តាញគាំទ្រសហគមន៍

- ភ្ជាប់បណ្តាញជាមួយក្រុមគាំទ្រ និងអង្គការនានាសម្រាប់សហគមន៍របស់អ្នក
- កសាងបណ្តាញជាមួយអ្នកផ្សេងទៀត ដែលមានបទពិសោធន៍ស្រដៀងគ្នា
- ស្វែងរកវេទិកាអនឡាញជាក់លាក់ណាមួយដែលបង្កលក្ខណៈសមស្រប និងមានសុវត្ថិភាពសម្រាប់ក្រុមរបស់អ្នក។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

ការរក្សាភស្តុតាង និងការរាយការណ៍

- ថតរូបអេក្រង់ នៃការបៀតបៀនទាំងអស់
- រាយការណ៍ទៅកាន់ក្រុមហ៊ុនបណ្តាញសង្គមឱ្យបានជាប់លាប់ ទោះបីជាការរាយការណ៍ពីមុនត្រូវបានគេមិនអើពើក៏ដោយ
- ពិចារណារាយការណ៍ទៅអាជ្ញាធរមូលដ្ឋានអំពីការគំរាមកំហែងធ្ងន់ធ្ងរ
- រក្សាកំណត់ត្រាលម្អិតនៃរាល់ឧប្បត្តិហេតុ។

អក្ខរកម្មឌីជីថល និងការយល់ដឹង

- ស្វែងយល់អំពីមុខងារសុវត្ថិភាពជាក់លាក់នៃវេទិកានីមួយៗ
- តាមដានព័ត៌មានអំពីទម្រង់ថ្មីៗនៃការបៀតបៀន និងរបៀបឆ្លើយតប
- ចែករំលែកចំណេះដឹងអំពីសុវត្ថិភាពជាមួយអ្នកដទៃនៅក្នុងសហគមន៍របស់អ្នក។

ឃ. ការគាំទ្រដល់ក្រុមមនុស្សងាយរងគ្រោះតាមអនឡាញ

ការបង្កើតប្រព័ន្ធអនឡាញដែលមានសុវត្ថិភាពជាងមុនសម្រាប់សហគមន៍ងាយរងគ្រោះ ទាមទារឱ្យមានការចូលរួមពីមនុស្សគ្រប់គ្នា។ មិនថាអ្នកស្ថិតនៅក្នុងក្រុមងាយរងគ្រោះ ឬចង់គាំទ្រអ្នកដទៃនោះទេ មានវិធីជាច្រើនដើម្បីជួយកាត់បន្ថយការបៀតបៀនតាមអនឡាញ។ ការចងសម្ព័ន្ធភាព មានន័យថាការប្រើប្រាស់សំឡេង និងគណនីរបស់អ្នកដើម្បីការពារអ្នកដែលប្រឈមមុខនឹងហានិភ័យខ្ពស់។ វាក៏មានន័យថាការរៀនអំពីបទពិសោធន៍របស់សហគមន៍ផ្សេងៗគ្នា និងចាត់វិធានការជាក់ស្តែងដើម្បីធ្វើឱ្យវេទិកាឌីជីថលកាន់តែមានភាពកក់ក្តៅ និងរីឆ្ងមានសម្រាប់មនុស្សគ្រប់គ្នា។

ការធ្វើជាអ្នកគាំទ្រដ៏សកម្ម

- កុំព្រងើយកន្តើយនៅពេលឃើញការបៀតបៀនកើតឡើងចំពោះអ្នកដទៃ
- ប្រើប្រាស់គណនីរបស់អ្នក ដើម្បីជួយលើកស្ទួយ និងផ្សព្វផ្សាយរឿងរ៉ាវរីឆ្ងមានរបស់ក្រុមមនុស្សដែលងាយរងគ្រោះ និងគេមើលរំលង។
- ហ៊ានិយាយប្រឆាំងនឹងការរើសអើង ទោះបីជាវាមិនបានតម្រង់មកលើអ្នកដោយផ្ទាល់ក៏ដោយ
- ហ៊ានតតាំងនឹងមតិយោបល់ និងការបង្ហោះដែលមានលក្ខណៈរើសអើង

ការជួយផ្សព្វផ្សាយបន្ថែមដោយសុវត្ថិភាព

- ចែករំលែកមាតិកា ឬរឿងរ៉ាវពីសមាជិកនៃក្រុមងាយរងគ្រោះក្នុងស្ថានភាពដែលសមស្រប
- ត្រូវប្រុងប្រយ័ត្ន កុំចែករំលែករឿងរ៉ាវទាំងនោះ ធ្វើឱ្យពួកគេកាន់តែប្រឈមនឹងហានិភ័យបន្ថែម។
- ត្រូវសុំការអនុញ្ញាតពីសាមីខ្លួនជាមុន មុននឹងយករឿងរ៉ាវផ្ទាល់ខ្លួនរបស់ពួកគេទៅចែករំលែកបន្ត។

ចំណុចសំខាន់ៗដែលត្រូវចងចាំ

១. ក្រុមមនុស្សដែលប្រឈមហានិភ័យខ្ពស់ជាងគេ៖ ក្រុមងាយរងគ្រោះដូចជា ស្ត្រី បុគ្គល LGBTQ+ ជនជាតិភាគតិច និងជនជាតិដើមភាគតិច គឺជាអ្នកដែលជួបប្រទះអត្រានៃការបៀតបៀន និងការរំលោភបំពានតាមឌីជីថលខ្ពស់ជាងគេបំផុត។

២. ផលប៉ះពាល់មានលើសពីគ្រោះថ្នាក់ដល់បុគ្គលម្នាក់ៗ៖ ការបៀតបៀនតាមអនឡាញអាចបំបិទសំឡេងសហគមន៍ទាំងមូល និងរារាំងដល់ការចូលរួមក្នុងវេទិកាឌីជីថល។

៣. ការការពារទាមទារវិធីសាស្ត្រច្រើន៖ ការបង្កើនសុវត្ថិភាព ការគាំទ្រពីសហគមន៍ ការរក្សាភស្តុតាង និងការទទួលខុសត្រូវរបស់ក្រុមហ៊ុនបច្ចេកវិទ្យាសុទ្ធតែចាំបាច់។

៤. មនុស្សគ្រប់រូបសុទ្ធតែមានភារកិច្ចចូលរួម៖ សម្ព័ន្ធភាពអាចជួយបង្កើតវេទិកាឌីជីថលឱ្យមានសុវត្ថិភាពជាងមុន ដើម្បីតតាំងនឹងការរើសអើង និងគាំទ្រសហគមន៍ងាយរងគ្រោះ។

សូមចងចាំថា៖ ក្នុងនាមជាសមាជិកនៃក្រុមមនុស្សងាយរងគ្រោះ អ្នកមានសិទ្ធិទទួលបានការគោរព និងអាចប្រើប្រាស់អនឡាញដោយសុវត្ថិភាព។ ម៉្យាងវិញទៀត ប្រសិនបើអ្នកឃើញគេកំពុងបៀតបៀនលើជនរងគ្រោះណាម្នាក់ អ្នកមានសិទ្ធិពេញលេញក្នុងការជួយបង្កើតវេទិកាឌីជីថលមួយ ដែលមានសុវត្ថិភាព និងប្រកបដោយបរិយាបន្នសម្រាប់យើងទាំងអស់គ្នា។

មេរៀនសង្ខេប

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីចំណុចសំខាន់ៗដូចខាងក្រោម៖

ក្រុមងាយរងគ្រោះ គឺជាក្រុមមនុស្សដែលទំនងជាប្រឈមមុខនឹងការរើសអើង ការបៀតបៀន និងអំពើហិង្សាតាមអនឡាញ ដោយសារតែអត្តសញ្ញាណ សារតារ ឬចរិតលក្ខណៈរបស់ពួកគេ។

- ឧទាហរណ៍៖ ស្ត្រី ក្មេងស្រី បុគ្គល LGBTQ+ ក្រុមជនជាតិភាគតិច និងសាសនាភាគតិច ជនជាតិដើមភាគតិច និងជនមានពិការភាព។
- ប្រភេទនៃការបៀតបៀន៖ ការរំលោភបំពានផ្អែកលើយេនឌ័រ សម្តីស្អប់ខ្ពើម ការតាមដានឃ្លាំមើល ការគំរាមកំហែង ការចែករំលែករូបភាពឯកជន និងការរាយប្រហារផ្សេងៗ។
- មូលហេតុដែលមានហានិភ័យខ្ពស់ជាងគេ៖ ការរើសអើងដែលមានរយៈពេលវែង ការការពារនៅមានកម្រិត និងភាពអនាមិកនៅលើអនឡាញ។
- ផលប៉ះពាល់៖ គ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត ឥទ្ធិពលនៃការមិនហ៊ានបញ្ចេញមតិ និងភាពឯកាក្នុងសង្គម។
- ការការពារ៖ ប្រើប្រាស់ប្រព័ន្ធសុវត្ថិភាពឱ្យបានរឹងមាំ ភ្ជាប់ទំនាក់ទំនងជាមួយបណ្តាញគាំទ្រ រក្សាភស្តុតាង និងរាយការណ៍អំពីការរំលោភបំពាន និងកសាងការយល់ដឹងអំពីឌីជីថល។
- មនុស្សគ្រប់រូបសុទ្ធតែមានភារកិច្ច៖ មនុស្សគ្រប់រូបហ៊ាននិយាយ តតាំងនឹងការរើសអើងនិងជួយបង្កើតបរិយាកាសឌីជីថលដែលមានសុវត្ថិភាព និងប្រកបដោយបរិយាបន្នជាងមុន។

សទ្ធានុក្រម

- **ការតស៊ូមតិ៖** ការនិយាយឡើងដើម្បីគាំទ្រ ឬការពារអ្នកដទៃ។
- **សម្ព័ន្ធភាព៖** សកម្មភាពដែលក្រុមមនុស្សគាំទ្រគ្នា និងក្រោកឈរឡើងការពារបុគ្គល ឬក្រុមដែលរងការរើសអើងដោយអយុត្តិធម៌ ទោះបីជាពួកគេមិនមែនជាផ្នែកនៃក្រុមនោះក៏ដោយ។

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

- **អំពើហិង្សាខាងយេនឌ័រ៖** ការបង្កគ្រោះថ្នាក់ ឬការរំលោភបំពានដែលតម្រង់ទៅលើនរណាម្នាក់ដោយសារតែភេទរបស់ពួកគេ រួមទាំងអំពើហិង្សាខាងរាងកាយ ផ្លូវចិត្ត ឬតាមអនឡាញ។
- **យុទ្ធសាស្ត្រការពារ៖** វិធីដើម្បីកាត់បន្ថយហានិភ័យ និងបង្កើនសុវត្ថិភាព។
- **ការបៀតបៀនដែលមានគោលដៅ៖** ការវាយប្រហារសំដៅទៅលើបុគ្គល ឬក្រុមជាក់លាក់ណាមួយ។
- **ក្រុមមនុស្សងាយរងគ្រោះ៖** មនុស្សដែលមានហានិភ័យខ្ពស់ពីគ្រោះថ្នាក់តាមអនឡាញ ដូចជាយុវជន ស្ត្រី និងសហគមន៍ភាគតិច។

លំហាត់អនុវត្តន៍

១. ក្រុមមនុស្សងាយរងគ្រោះ៖ ការឆ្លុះបញ្ចាំងពីជីវិតពិត

សូមធ្វើការឆ្លុះបញ្ចាំងអំពីក្រុមមនុស្សងាយរងគ្រោះដែលអ្នកធ្លាប់បានដឹង រួចធ្វើការពិចារណាអំពីបទពិសោធន៍អនឡាញរបស់ពួកគេ។ បន្ទាប់មកសូមឆ្លើយសំណួរខាងក្រោម៖

- **បញ្ហាប្រឈម៖** តើពួកគេកំពុងជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញ?
- **ផលប៉ះពាល់៖** តើបញ្ហាប្រឈមទាំងនោះអាចប៉ះពាល់ដល់ពួកគេយ៉ាងដូចម្តេច?
  ឧទាហរណ៍៖ សុខភាពផ្លូវចិត្ត ការរស់នៅដាច់ឆ្ងាយពីសង្គម?
- **ការគាំទ្រ៖** តើសកម្មភាពអ្វីខ្លះដែលអ្នក ឬអ្នកដទៃអាចធ្វើបានដើម្បីជួយគាំទ្រពួកគេនៅតាមបណ្តាញអនឡាញ?

២. ការការពារក្រុមងាយរងគ្រោះ៖ សំណួរតែមួយ តែផ្តល់ចម្លើយចម្រុះ

សូមបង្កើតសំណួរបើកមួយ អំពីសុវត្ថិភាពអនឡាញសម្រាប់ក្រុមមនុស្សងាយរងគ្រោះ។ ឧទាហរណ៍៖ តើមានវិធីសាស្ត្រអ្វីដែលជួយដល់ក្រុមមនុស្សងាយរងគ្រោះ ឱ្យមានសុវត្ថិភាពនៅលើអនឡាញ? សូមប្រើប្រាស់សំណួរនេះដើម្បីប្រមូលគំនិតផ្សេងៗ ពីមិត្តភក្តិ គ្រួសារ ឬមិត្តរួមការងារ។ បន្ទាប់មកសូមពិចារណាលើចម្លើយនោះ ដោយផ្អែកលើសំណួរខាងក្រោម៖

- តើសកម្មភាពណាខ្លះដែលងាយស្រួលអនុវត្ត និងមានប្រសិទ្ធភាពបំផុត ក្នុងការបង្កើតបរិយាកាសអនឡាញ មួយដែលមានសុវត្ថិភាពជាងមុន?
- តើនរណាខ្លះជាអ្នកទទួលខុសត្រូវ ក្នុងការបង្កើតប្រព័ន្ធអនឡាញប្រកបដោយសុវត្ថិភាព?

៣. ស្ត្រីនិងសុវត្ថិភាពអនឡាញ៖ ការស្វែងយល់ និងការឆ្លុះបញ្ចាំង

សូមប្រើប្រាស់កម្មវិធី MIL Chatbot រួចចូលទៅកាន់ជំពូកទី៥៖ សុវត្ថិភាព និងឯកជនភាពលើអ៊ីនធឺណិត។ ចូរស្វែងយល់ពីខ្លឹមសារស្តីពី ស្ត្រីនិងសុវត្ថិភាពអនឡាញ រួចឆ្លើយសំណួរខាងក្រោម៖

- តើការរំលោភបំពានតាមអនឡាញអ្វីខ្លះដែលស្ត្រីអាចនឹងជួបប្រទះ?
- ហេតុអ្វីបានជាស្ត្រីប្រឈមនឹងការគំរាមកំហែងតាមអនឡាញច្រើនជាងគេ?
- តើចាំបាច់ត្រូវមានការផ្លាស់ប្តូរអ្វីខ្លះ ដើម្បីបង្ការការរំលោភបំពានតាមអនឡាញប្រភេទនេះ?
- ប្រសិនបើអ្នកជាស្ត្រី ឬស្ថិតក្នុងក្រុមមនុស្សងាយរងគ្រោះផ្សេងទៀត តើអ្នកធ្វើអ្វីខ្លះដើម្បីការពារខ្លួន ឬចេញមុខតវ៉ាប្រឆាំងនឹងការរំលោភបំពានតាមអនឡាញ?
- ប្រសិនបើអ្នកជាបុរស ឬមិនស្ថិតក្នុងក្រុមងាយរងគ្រោះណាមួយ តើអ្នកធ្វើអ្វីខ្លះដើម្បីការពារអ្នកដទៃពីការរំលោភបំពានតាមអនឡាញ? ហេតុអ្វីបានជាសកម្មភាពរបស់អ្នកមានសារៈសំខាន់?

សំណួរសំរាប់ពិភាក្សា

១. តើនរណាខ្លះត្រូវបានចាត់ទុកថា ជាក្រុមមនុស្សងាយរងគ្រោះនៅលើអនឡាញ?
២. តើសមាជិកនៃក្រុមទាំងនេះប្រឈមមុខនឹងហានិភ័យអ្វីខ្លះ?
៣. តើការបៀតបៀនតាមអនឡាញប្រភេទណាខ្លះ ដែលដាក់គោលដៅលើក្រុមងាយរងគ្រោះ?
៤. ហេតុអ្វីបានជាក្រុមងាយរងគ្រោះប្រឈមមុខនឹងហានិភ័យខ្ពស់ ពីការរំលោភបំពានតាមអនឡាញ?
៥. តើការបៀតបៀនតាមអនឡាញអាចមានផលប៉ះពាល់អ្វីខ្លះ ដល់ក្រុមងាយរងគ្រោះ និងសហគមន៍របស់ពួកគេ?
៦. តើក្រុមមនុស្សងាយរងគ្រោះត្រូវប្រើប្រាស់យុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីការពារខ្លួនលើអនឡាញ?
៧. តើសម្ព័ន្ធភាពអាចជួយធ្វើឱ្យប្រព័ន្ធអនឡាញកាន់តែមានសុវត្ថិភាព និងប្រកបដោយបរិយាបន្នដោយរបៀបណា?

t.me/moeysnews
sala.moeys.gov.kh
fb.me/krou.moeys.gov.kh

រៀបរៀងដោយ



ឧបត្ថម្ភដោយ

DW Akademie

កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

ឆ្នាំ២០២៦